សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការរំលាយកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ប៉ាង ធីរៈបុត្រ**

**លឹម សុខម៉ារី**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឌុឆ្ឋី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការរំលាយកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ប៉ាង ធីរៈបុត្រ**

**លឹម សុខម៉ារី**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឧដ្ឋី**



ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលរៀន ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ប៉ាង វីរៈបុត្រ** និង **លឹម សុខម៉ារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៧-២០២១។

**សូមលំឱនកាយវាចាចិត្ត ដើម្បីសម្តែងនូវការគោរពដឹងគុណ និងកតញ្ញូតាធម៌ យ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

| | |
|---|---|
| លោកឪពុក **យូ ម៉ុណ្ណា** | លោកឪពុក **លឹម សុខ** |
| អ្នកម្តាយ **ពេញ ផាន្នី** | អ្នកម្តាយ **សៀក សារឿន** |

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតទៅដល់មាតាបិតា ដែលបានផ្តល់កំណើត និងខិតខំប្រឹងប្រែងបីបាច់ថែរក្សាកូនតាំងពីតូចរហូតដល់ធំដឹងក្តីជាមួយការអប់រំល្អៗ ប្រកបដោយព្រហ្មវិហារធម៌ចំពោះកូន។ លោកទាំងទ្វេរបានជួយផ្គត់ផ្គង់គ្រប់បែបគ្រប់យ៉ាង មិនថាកម្លាំងកាយ កម្លាំងចិត្ត ផ្នែកស្មារតី ព្រមទាំងផ្នែកសម្ភារៈ ក្នុងគោលបំណងតែមួយគត់គឺចង់ឃើញកូនៗទទួលបានការអប់រំដែលល្អ។ លោកទាំងពីរជាព្រះព្រហ្ម ជាគ្រូបាអាចារ្យ ជាគ្រូពេទ្យ ជាអ្នកលើកទឹកចិត្តរបស់កូនគ្រប់ពេលវេលា។ លោកបានផ្តល់ឱកាសឲ្យយើងខ្ញុំទាំងពីរនាក់សិក្សារៀនសូត្រតាំងពីថ្នាក់កុមារដ្ឋាន រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឲ្យកូនបានក្លាយជាបុគ្គលមានតម្លៃទាំងចំពោះខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សកលវិទ្យាធិការរង ព្រឹទ្ធិបុរស** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យយើងខ្ញុំទាំងពីរទទួលបាននូវឱកាសក្នុងការចូលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ **លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ** គ្រប់រូបនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលក្នុងអំឡុងពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានទទួលនូវការអប់រំណែនាំ ដែលបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្តក្នុងការបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ព្រមទាំងផ្ទេរនូវចំណេះដឹងដល់ពួកយើងខ្ញុំ និងសិស្សដទៃទៀតតាំងពីថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រពិតជាពុំអាចកាត់ថ្លៃបាន។

ជាពិសេស យើងខ្ញុំទាំងពីរនាក់សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះលោកគ្រូ សាស្ត្រាចារ្យ **ញឹក ឧុធ្ធី** ដែលជាសាស្ត្រាចារ្យដែលបានដឹកនាំក្នុងការសរសេរសារណាមួយនេះ ព្រមទាំងជួយណែនាំ ចង្អុលបង្ហាញ ផ្តល់មតិយោបល់ ដំបូន្មានល្អៗ ទាំងផ្នែកស្មារតី និងឯកសារព្រមទាំងជួយត្រួតពិនិត្យ កែតម្រូវចំណុចខ្វះខាត ជាពិសេសគឺពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតដល់សារណាមួយនេះបានបញ្ចប់ប្រកបដោយជោគជ័យ។

ជាទីចុងបញ្ចប់ យើងខ្ញុំ សូមលើកហត្ថាប្រណម បួងសួងដល់បារមីនៃវត្ថុសក្តិសិទ្ធិ ទេព្តា ក្នុងលោកសូមប្រសិទ្ធិពរជ័យសិរីសួស្តីជូនចំពោះ **អ្នកមានគុណទាំងពីរដែលជាលោកឪពុក និងអ្នកម្តាយ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ លោកពូ អ្នកមីង បងប្អូន និងមិត្តភក្តិទាំងអស់** ជាពិសេសលោកគ្រូសាស្ត្រាចារ្យ **ញឹក ឧុឆ្មី** សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុខភាពល្អ ជោគជ័យគ្រប់ភារកិច្ច និងព្រមទាំងជួបពុទ្ធពរទាំង៤ប្រការគឺ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រអស់រយៈពេល ៤(បួន) ឆ្នាំមកនេះ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយយើងខ្ញុំទាំងពីរនាក់ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានទទួលចំណេះដឹងល្អៗ និងការអប់រំផ្សេងៗទៀតពីលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការខិតខំបង្រៀនយើងខ្ញុំទាំងពីរនាក់ដោយគ្មានការនឿយហត់។ ដើម្បីឆ្លើយតបនឹងការខិតខំប្រឹងប្រែង ការលះបង់របស់សាស្ត្រាចារ្យ យើងខ្ញុំទាំងពីរនាក់ពិតជាថ្លែងអំណរគុណយ៉ាងខ្លាំងដល់សាស្ត្រាចារ្យទាំងអស់ និងសាកលវិទ្យាល័យដោយផ្តល់ឱកាសអោយពួកខ្ញុំបញ្ចេញថ្វីដៃក្នុងការស្រាវជ្រាវចងក្រងសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅក្រោមប្រធានបទ **ការរំលាយកិច្ចសន្យា** ដើម្បីធ្វើជាសារណាសម្រាប់ឆ្នាំនេះ។

សៀវភៅសារណានេះដែលកំពុងតែមានវត្តមាននៅក្នុងដៃរបស់លោកអ្នក គឺត្រូវបានសម្រិតសម្រាំងយ៉ាងខ្លាំងក្នុងការខិតខំស្រាវជ្រាវដោយយកចិត្តទុកដាក់បំផុត ដោយដកស្រង់នូវខ្លឹមសារ នឹងគោលគំនិតប្រកបដោយគុណភាព និងសារៈប្រយោជន៍យ៉ាងចាំបាច់បំផុតដើម្បីយកមកចងក្រងជាសៀវភៅនេះឡើង។ ការលើកយកប្រធានបទស្រាវជ្រាវនេះមកបកស្រាយ ក្នុងគោលបំណងពង្រីកចំណេះដឹងបន្ថែមអោយកាន់តែស៊ីជម្រៅលើការរំលាយកិច្ចសន្យា។ ដោយនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃគឺប្រជាពលរដ្ឋគាត់តែងតែបង្កើតកិច្ចសន្យានៅក្នុងមុខជំនួញរបស់គាត់ ដើម្បីធ្វើជាភស្តុតាងនៅក្នុងករណី ដែលមានវិវាទកិច្ចសន្យា ឬក៏ភាគីនៃកិច្ចសន្យាមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានត្រឹមត្រូវ ដូច្នេះគាត់អាចប្រើប្រាស់វិធីសង្គ្រោះកិច្ចសន្យាដូចជា ការឱ្យអនុវត្តកាតព្វកិច្ចដោយបង្ខំ សំណងនៃការខូចខាត និង ការរំលាយកិច្ចសន្យាជាដើម។ ប៉ុន្តែដោយមានប្រជាពលរដ្ឋយើងខ្លះគាត់ពុំទាន់បានយល់ច្បាស់ និងស៊ីជម្រៅលើនីតិវិធីនៃការរំលាយកិច្ចសន្យា និងអានុភាពនៃសំណងការខូចខាតនៃការរំលាយកិច្ចសន្យានៅឡើយទេ ដែលជាយថាហេតុធ្វើអោយយើងខ្ញុំទាំងពីរនាក់ បានសម្រេចចិត្តចងក្រងសារណាក្រោមប្រធានបទនេះឡើង។ ហើយសារណាមួយក្បាលនេះ ក៏បានតាក់តែងឡើងក្នុងគោលបំណង ដើម្បីចែករំលែកចំណេះដឹង និងធ្វើជាឯកសារពិគ្រោះដល់សិស្សប្អូនផងដែរក្នុងការស្វែងយល់ និងស្រាវជ្រាវប្រធានបទនេះអោយបានស៊ីជម្រៅ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់សូមខន្តីអភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូសិស្សានុសិស្ស និងមិត្តអ្នកអានទាំងអស់នៅរាល់កំហុសខុសឆ្គង ដែលកើតមានឡើងដោយអចេតនា នូវរាល់ចំនុចខ្វះខាតទាំងខ្លឹមសារ និងអក្ខរាវិរុទ្ធដែលមិនត្រឹមត្រូវដោយអចេតនា ព្រមទាំងទទួលយករាល់មតិរិះគន់ក្នុងន័យស្ថាបនាផងដែរ ហើយយើងខ្ញុំទាំងពីរនាក់សូមជូនពរទៅដល់មិត្តអ្នកអានទាំងអស់អោយជួបតែពុទ្ធពរទាំង ៤(បួន) ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ..... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ..... ១

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ..... ២

៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ ..... ២

៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ..... ២

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ២

**ជំពូកទី ១**

**ល័ក្ខខ័ណ្ឌសុពលភាពនៃកិច្ចសន្យា**

**ផ្នែកទី១៖ ការព្រមព្រៀង** ..... ៣

**កថាភាគទី១៖ សំណើ** ..... ៣

១. ល័ក្ខខ័ណ្ឌនៃសំណើ ..... ៣

២. កាលកំណត់នៃសំណើ ..... ៤

២.១ សំណើដែលមានកំណត់អំឡុងពេល ..... ៤

២.២ សំណើដែលគ្មានកំណត់អំឡុងពេល ..... ៤

៣. ការបញ្ចប់សំណើ ..... ៥

**កថាភាគទី២៖ ស្វីការ** ..... ៥

១. ល័ក្ខខ័ណ្ឌនៃស្វីការ ..... ៦

២. ការមកដល់យឺតយ៉ាវនៃស្វីការ ..... ៦

៣. ស្វីការដែលមានបន្ថែមការកែប្រែ ..... ៦

**កថាភាគទី៣៖ វិការៈនៃការព្រមព្រៀង** ..... ៦

១. ការភាន់ច្រឡំ ..... ៧

២. ការឆបោក ..... ៧

៣. ព័ត៌មានមិនពិត ..... ៨

៤. ការរំលោភបំពានលើស្ថានភាព ........ ៩
៥. អំពើកេងចំណេញហួសហេតុ ........ ៩
៦. ការគម្រាមកំហែង ........ ៩
**ផ្នែកទី២៖ កម្មវត្ថុនៃកិច្ចសន្យា ........ ១០**
**កថាភាគទី១៖ ភាពស្របច្បាប់ ឬ ភាពមិនផ្ទុយនឹងការអនុវត្តដោយបង្ខំ ........ ១០**
**កថាភាគទី២៖ ភាពមិនផ្ទុយនឹងសណ្ដាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ........ ១០**
**កថាភាគទី៣៖ ល័ក្ខខ័ណ្ឌទម្រង់កិច្ចសន្យា ........ ១១**
១. កិច្ចសន្យាធ្វើដោយផ្ទាល់មាត់ ........ ១១
២. កិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ ........ ១១
២.១ លិខិតយថាភូត ........ ១២
២.២ លិខិតឯកជន ........ ១២
**ផ្នែកទី៣៖ សមត្ថភាពចុះកិច្ចសន្យា ........ ១២**
**កថាភាគទី១៖ ជនដែលអាចចុះកិច្ចសន្យា ........ ១២**
១. នីតិជន ........ ១២
២. អនីតិជនដែលមានអត្តាធីនភាព ........ ១៣
៣. អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ........ ១៣
**កថាភាគទី២៖ ជនដែលមិនអាចចុះកិច្ចសន្យា ........ ១៣**
១. អនីតិជននៅក្រោមអំណាចមេបា ........ ១៤
២. ជននៅក្រោមហិតូបត្ថម្ភ ........ ១៤
៣. ជននៅក្រោមអាណាព្យាបាលទូទៅ ........ ១៤

**ជំពូកទី ២**

**ការរំលាយកិច្ចសន្យា**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យា ........ ១៦**
**កថាភាគទី១៖ និយមន័យនៃការរំលាយកិច្ចសន្យា ........ ១៦**
**កថាភាគទី២៖ គោលបំណងនៃការរំលាយកិច្ចសន្យា ........ ១៦**
**កថាភាគទី៣៖ ប្រភេទនៃការរំលាយកិច្ចសន្យា ........ ១៧**

១. ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ ..... ១៧
២. ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា ..... ១៧
៣. ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស ..... ១៨
៤. ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង ..... ១៨
**ផ្នែកទី២៖ មូលហេតុនៃការរំលាយកិច្ចសន្យា ..... ១៨**
**កថាភាគទី១៖ កិច្ចសន្យាឯកតោភាគី ..... ១៨**
**កថាភាគទី២៖ កិច្ចសន្យាអញ្ញមញ្ញ ..... ១៩**
**កថាភាគទី៣៖ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរដោយភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ ..... ១៩**
១. ការរំលាយកិច្ចសន្យាដោយការដាស់តឿនភាគីមិនអនុវត្តកាតព្វកិច្ច ..... ១៩
២. ការរំលាយកិច្ចសន្យាដោយមូលហេតុយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ..... ២០
៣. ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកចម្បង ..... ២០
៤. ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់ជំនឿចិត្តរវាងគូភាគី ..... ២០
**កថាភាគទី៤៖ វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា ..... ២១**
១. ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ..... ២២
១.១ ការរំលាយតាមកិច្ចសន្យា ..... ២២
១.២ តាមការព្រមព្រៀងគូភាគី ..... ២៣
១.៣ តាមសន្ទានកម្ម ..... ២៤
១.៣.១ ការជ្រើសរើសសន្ទានការី ..... ២៦
១.៣.២ ការផ្តល់ពត៌មានដល់សន្ទានការី ..... ២៧
១.៣.៣ ការដោះស្រាយវិវាទដោយសន្ទានការី ..... ២៨
១.៣.៤ ការបិទប្រជុំនៃសន្ទានកម្ម ..... ៣១
១.៤ តាមមជ្ឈត្តការ ..... ៣២
១.៤.១ កិច្ចព្រមព្រៀងមជ្ឈត្តការ ..... ៣២
១.៤.២ ដំណើរការមជ្ឈត្តការ ..... ៣៣
១.៤.៣ ការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ..... ៣៦
១.៤.៤ ការប្តឹងឧបាស្រ័យទៅនឹងសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ ..... ៣៧

២. ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការ ................ ៣៨
២.១ ការធ្វើបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា ................ ៣៨
២.២ ការប្រកាសចេញសាលក្រម ................ ៤០
២.៣ ការជួសជុលការខូចខាត ................ ៤២
៣. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកបាន ................ ៤៣
៤. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្អង់ ................ ៤៤
៥. ការរំលាយកិច្ចសន្យាដោយភាគីម្ខាងមានគ្នាច្រើននាក់ ................ ៤៥
**ផ្នែកទី៣៖ ការរំលត់សិទ្ធិនៃការរំលាយកិច្ចសន្យា** ................ ៤៥
**កថាភាគទី១៖ សិទ្ធិរំលាយកិច្ចសន្យានៅពេលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត** ៤៦
**កថាភាគទី២៖ ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារអាជ្ញាយុកាល** ................ ៤៦
**កថាភាគទី៣៖ ការរំលត់ដោយសារការអនុវត្តកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា** .. ៤៧

## ជំពូកទី ៣

## អានុភាពសំណងខូចខាតនៃការរំលាយកិច្ចសន្យា

**ផ្នែកទី១៖ ដំណើរការអានុភាពនៃការរំលាយកិច្ចសន្យា** ................ ៥០
**កថាភាគទី១៖ អានុភាពប្រតិសកម្ម** ................ ៥០
**កថាភាគទី២៖ អានុភាពមិនប្រតិសកម្ម** ................ ៥១
**ផ្នែកទី២៖ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះភាគី និង តតិយជន** ................ ៥២
**កថាភាគទី១៖ ការរំលត់ទំនាក់ទំនងក្នុងកិច្ចសន្យារវាងគូភាគី** ................ ៥២
១. ភាគីនៃកិច្ចសន្យារួចផុតពីកាតព្វកិច្ច និង អញ្ញត្រកម្ម ................ ៥២
២. ការធ្វើបដិទាន ................ ៥៣
២.១ ការធ្វើបដិទានទៅស្ថានភាពដើម ................ ៥៣
២.២ កាតព្វកិច្ចធ្វើបដិទានមិនអាចតាមស្ថានភាពដើម ................ ៥៤
**កថាភាគទី២៖ អានុភាពចំពោះតតិយជន** ................ ៥៥
១. តតិយជននៃគោលការណ៍អានុភាពប្រតិសកម្ម ................ ៥៥
២. តតិយជននៃគោលការណ៍មិនអានុភាពប្រតិសកម្ម ................ ៥៧
**ផ្នែកទី៣៖ ករណីយកិច្ចសងសំណងការខូចខាត** ................ ៥៨

**កថាភាគទី១៖ ការទទួលខុសត្រូវកិច្ចសន្យា**..........................................................................៥៩
**កថាភាគទី២៖ ការរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា** ..............................................៦១
១. ករណីប្រធានសក្តិ..................................................................................................**៦១**
២. កំហុសជនរងគ្រោះ .................................................................................................**៦១**
៣. អំពើតតិយជន .....................................................................................................**៦២**
**សេចក្តីសន្និដ្ឋាន**........................................................................................................ **៦៣**
**អនុសាសន៍**..............................................................................................................**៦៥**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមរស់នៅសព្វថ្ងៃ មនុស្សម្នាក់ៗសុទ្ធតែត្រូវមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីប្រកបកិច្ចការងារផ្សេងៗ។ ទន្ទឹមនឹងនោះ ដើម្បីសំរេចនូវការងារនីមួយៗឲ្យទទួលបានលទ្ធផលល្អសមប្រកបតាមការប្រាថ្នាចង់បាន ជាការចាំបាច់ណាស់ដែលមនុស្សត្រូវប្រើប្រាស់កិច្ចសន្យា ក្នុងការគ្រប់គ្រង និងការពារអត្ថប្រយោជន៍របស់គូភាគីទាំងសងខាង។ ហេតុនេះហើយទើបធ្វើឲ្យ កិច្ចសន្យាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ដែលកិច្ចសន្យាគេតែងអនុវត្តភាគច្រើន ជាប្រភេទកិច្ចសន្យាលក់ទិញ កិច្ចសន្យាជួលដែលគេហៅថា ភតិសន្យា និងកិច្ចសន្យាការងារជាដើម។ លើសពីនេះទៅទៀត ការប្រើប្រាស់កិច្ចសន្យាគឺក្នុងគោលបំណង បង្កើតឲ្យមានភាពច្បាស់រវាងគ្នានឹងគ្នា ភាពស្មោះត្រង់ ក៏ដូចភាពជឿទុកចិត្ត ដែលមិនបណ្តាលឲ្យមានបាត់បង់ ឬខូចខាតនូវផលប្រយោជន៍ចំពោះគ្នាទៅវិញទៅមកផងដែរ។ នៅក្នុងករណីដែលនៅពេលកិច្ចសន្យាត្រូវបានបំពានដោយភាគីម្ខាងនៃកិច្ចសន្យាហើយធ្វើអោយខូចផលប្រយោជន៍ និងបាត់បង់ទំនុកចិត្ត នោះភាគីម្ខាងទៀតអាចសង្គ្រោះកិច្ចសន្យាបាន ដោយផ្អែកទៅលើបញ្ញត្តិនៃការរំលាយកិច្ចសន្យាក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧។ ការរំលាយកិច្ចសន្យានេះគឺត្រូវបានគេយកទៅអនុវត្តជាច្រើនដោយវាជាវិធីសង្គ្រោះមួយ នៅពេលដែលភាគីម្ខាងមិនបានអនុវត្តកាតព្វកិច្ចពេញលេញ ឬក៏បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ដោយត្រូវរំលាយកិច្ចសន្យាចោល ហើយត្រូវសងមកវិញនូវសំណងខូចខាត និងការធ្វើបដិទាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើការរំលាយកិច្ចសន្យាមានលក្ខណៈបែបណា? តើមានមូលហេតុអ្វីខ្លះទើបបណ្តាលឲ្យមានការរំលាយកិច្ចសន្យាកើតឡើង ហើយថាតើត្រូវស្របតាមនីតិវិធីបែបណាខ្លះ ទើបការរំលាយកិច្ចសន្យាអាចអនុវត្តទៅបានដោយមានសុពលភាព? ហើយក្រោយពីការរំលាយកិច្ចសន្យា តើវានឹងមានអានុភាពបែបណាទៅលើភាគីពាក់ព័ន្ធនៃកិច្ចសន្យា? តើមានភស្តុតាងអ្វីខ្លះអាចធ្វើអោយភាគីជាប់បន្ទុករួចផុតពីករណីយកិច្ចបានក្នុងការសងសំណងខូចខាតនៃកិច្ចសន្យា?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងដែលយើងខ្ញុំទាំងពីរនាក់ សំរេចចិត្ត និងចាប់ផ្តើមតាក់តែងនូវសារណានេះឡើង គឺដើម្បីស្វែងយល់ឲ្យបានជាក់លាក់ និងមានភាពស៊ីជម្រៅ ទៅលើប្រធានបទ ក៏ដូចជាបន្ថែមនូវចំណេះដឹងផ្ទាល់ខ្លួននៅក្នុងវិស័យគតិយុត្តិ ទាក់ទងនឹងកិច្ចសន្យា ព្រោះថាកិច្ចសន្យានេះវាមានសារៈសំខាន់ណាស់ នៅក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង។ ពួកខ្ញុំទាំងពីរគិតថា ការធ្វើបែបនេះ គឺជាការចូលរួមចំណែកក្នុងការលើកស្ទួយវិស័យគតិយុត្តនៅក្នុងប្រទេសកម្ពុជា ហើយវាជាអ្វីដែលពួកខ្ញុំទាំងពីរនាក់គិតថាជារឿងដែលគួរធ្វើ ក្នុងនាមពួកខ្ញុំដែលជានិស្សិតផ្នែក នីតិសាស្ត្រនេះផ្ទាល់។ លើសពីនេះទៅទៀត បន្ទាប់ពីការស្រាវជ្រាវនេះបានបញ្ចប់ ឯកសារដែល

ជាសារណាមួយនេះ អាចផ្តល់ជាទុន នឹងជាប្រយោជន៍ដល់អ្នកដែលមានបំណង ចង់ស្វែងយល់ទាក់ទងទៅនឹងមូលដ្ឋានច្បាប់ និងជាពិសេសអំពីប្រធានបទនេះផ្ទាល់ផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះសារណាបញ្ចប់ការសិក្សាមួយនេះ គឺសិក្សាទៅលើលក្ខណៈទូទៅជុំវិញការរំលាយកិច្ចសន្យា ហើយក្នុងនោះផងដែរការស្រាវជ្រាវផ្តោតសំខាន់តែការរំលាយកិច្ចសន្យាទូទៅ ឬកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ គឺមិនបានបកស្រាយលំអិតអំពីការរំលាយកិច្ចសន្យាសំខាន់ៗម្តងមួយនោះទេ។ បន្ថែមពីលើនេះ ការស្រាវជ្រាវ គឺផ្អែកសំខាន់តាម ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា(២០០៧) ដែលជាឯកសារគោល ក៏ដូចជាបានដកស្រង់ពីសៀវភៅដែលមានខ្លឹមសារល្អៗរបស់សាស្ត្រាចារ្យមួយចំនួន មេធាវី ចៅក្រម និងអ្នកអនុវត្តច្បាប់នានាដែលទាក់ទងទៅការរំលាយកិច្ចសន្យា។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវ គឺចង់ឲ្យឯកសារមួយនេះអាចជាទុនសំរាប់អ្នកសិក្សាផ្នែកច្បាប់ មិត្តភក្តិ និងសិស្សប្អូននានា អាចស្វែងយល់និងបង្កើនចំណេះដឹងផ្ទាល់ខ្លួន ដែលវាជាការចូលរួមចំណែកមួយក្នុងការលើកស្ទួយនិងអភិវឌ្ឍន៏វិស័យគតិយុត្តិ ក៏ដូចជាប្រយោជន៍ផ្ទាល់សំរាប់ខ្ញុំទាំងពីរនាក់ ដែលជាអ្នកតាក់តែងសារណានេះឡើង ឲ្យមានភាពច្បាស់លាស់និងស៊ីជម្រៅ អំពីការរំលាយកិច្ចសន្យានេះផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានធ្វើការពន្យល់លើទ្រឹស្តី នៃចំនុចនីមួយៗដោយមានទល្លីករណ៍មកបញ្ជាក់ផងដែរ។ ការសិក្សាស្រាវជ្រាវនេះធ្វើទៅតាមការប្រមូលទិន្នន័យពត៌មានដែលពាក់ព័ន្ធទៅនឹងប្រធានបទដើម្បីធ្វើអោយសារណាមួយនេះមានភាពត្រឹមត្រូវ នឹងទទួលបានប្រសិទ្ធិភាពខ្ពស់ផងដែរ។ នៅក្នុងខ្លឹមសារសារណានេះ គឺយើងខ្ញុំទាំងពីរនាក់បានយកចេញនូវគោលគំនិត ពីក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧, សេចក្តីកំណត់នៃក្រមរដ្ឋប្បវេណី, សេចក្តីពន្យល់ពីក្រមរដ្ឋប្បវេណីជាគោល និងឯកសារផ្សេងទៀត ឬក៏ជាសៀវភៅរបស់អ្នកនិពន្ធល្បីៗរបស់សាស្ត្រាចារ្យជាច្រើនផងដែរ ហើយនៅក្នុងសារណានេះក៏មានភ្ជាប់នូវគំរូកិច្ចសន្យា និងសាលក្រមមួយចំនួននៅក្នុងឧបសម្ព័ន្ធជាច្រើនទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងសារណាមួយនេះ យើងនឹងពិភាក្សាទៅលើបីចំណុចធំៗគឺ៖

- ជំពូកទី១៖ ល័ក្ខខ័ណ្ឌសុពលភាពនៃកិច្ចសន្យា។
- ជំពូកទី២៖ ការរំលាយកិច្ចសន្យា។
- ជំពូកទី៣៖ អានុភាពសំណងខូចខាតនៃការរំលាយកិច្ចសន្យា។

# ជំពូកទី១
# លក្ខខណ្ឌសុពលភាព
# នៃកិច្ចសន្យា

# ជំពូកទី ១
# លក្ខខណ្ឌសុពលភាពនៃកិច្ចសន្យា

តាមន័យអក្សរសាស្ត្រ ពាក្យថា **កិច្ចសន្យា** កើតចេញពីការផ្សំបញ្ចូលគ្នានៃពាក្យ **កិច្ច** បូកនិង **សន្យា** ដែលកិច្ចជាអំពើ ឬ សកម្មភាពអ្វីមួយដើម្បីឲ្យព្រឹត្តិការណ៍អ្វីមួយកើតឡើង។ ចំណែកឯពាក្យសន្យា មានន័យថា ការទទួលធ្វើអ្វីមួយ តាមរយៈការទទួលស្គាល់នូវអ្វីដែលខ្លួននិយាយចំពោះគូភាគី ឬ តតិយជន។ តាមន័យគតិយុត្ត កិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់កាតព្វកិច្ច។[1] កិច្ចសន្យា ជាប្រភពមួយនៃការបង្កើតឲ្យមានកាតព្វកិច្ច រវាងបុគ្គលទាំងសងខាងនៃកិច្ចសន្យា ដែលឲ្យបុគ្គលម្នាក់ដែលបានកំណត់ មានករណីយកិច្ចមួយចំនួនដែលមានចែងក្នុងកិច្ចសន្យា ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ ជាទូទៅកិច្ចសន្យា អាចកើតឡើងបាននៅពេលសំណើ និងស្ទីការត្រូវគ្នា។ ដូចនេះ ដើម្បីបង្កើតកិច្ចសន្យា ត្រូវមានលក្ខខណ្ឌដូចខាងក្រោមៈ

## ផ្នែកទី១ៈ ការព្រមព្រៀង

ការព្រមព្រៀង គឺជាឆន្ទៈរបស់ភាគីចុះកិច្ចសន្យា ដើម្បីបង្កើត និងភ្ជាប់នូវកាតព្វកិច្ចផ្សេងៗរវាង គូភាគី។ ក្នុងនោះផងដែលធាតុផ្សំដើម្បីបង្កើតការព្រមព្រៀងមាន ចំនួន២ធំៗគឺៈ សំណើ និងស្ទីការ។

### កថាភាគទី១ៈ សំណើ

សំណើ គឺជាការសុំបង្កើតកិច្ចសន្យា ដែលធ្វើឡើងដោយមានឆន្ទៈ ភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។[2]

**ឧទាហរណ៍ៈ** លោក ក និយាយថា ខ្លួនលក់រថយន្តរបស់ខ្លួន បើសិនមានអ្នកឲ្យតម្លៃលើ ២០,០០០ ដុល្លារ នេះគឺជាសំណើរដែលជាកិច្ចសន្យាដើម្បីធ្វើអ្វីមួយ (លក់រថយន្ត)។

#### ១. លក្ខខណ្ឌនៃសំណើ

ក្នុងការបង្កើតសំណើមួយឲ្យមានសុពលភាព អ្នកដែលផ្តល់សំណើត្រូវបង្ហាញឆន្ទៈរបស់ខ្លួនឲ្យបានពិតប្រាកដ និងជាក់លាក់ ថាខ្លួនពិតជាចង់បង្កើតសំណើនោះមែន។ លើសពីនេះទៅទៀត ខ្លឹមសារនៃសំណើក៏ត្រូវមានភាពជាក់លាក់ និងច្បាស់លាស់ផងដែរដូចជាៈ ការកំណត់នូវអត្តសញ្ញាណនៃគូភាគី តាវកាលិក និងពេលវេលាកំណត់ជាដើម។ សំណើអាចធ្វើឡើងតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ និងដោយតណ្ហិភាព។

[1] ក្រឹត្យច្បាប់ ៣៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ ៣៨ក្រ.ច, ២៨ តុលា ១៩៨៨, មាត្រា ១។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី ១។

សំណើ ត្រូវមានអានុភាពនៅពេលដែលសំណើនោះ បានដល់ភាគីម្ខាងទៀត។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដកសំណើវិញ បានដល់ភាគីម្ខាងទៀតនៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់នោះអានុភាពសំណើមិនត្រូវកើតឡើងឡើយ។[3]

**ឧទាហរណ៍៖** លោក ក មានបំណងចង់ទិញដីរបស់លោក ខ ដែលបានដាក់លក់ ហើយលោក ក គាត់បានធ្វើសំណើ ដើម្បីស្នើទៅលោក ខ ដើម្បីទិញដីនោះ។ ប៉ុន្តែប៉ុន្មានថ្ងៃក្រោយមកគាត់ក៏បានប្តូរចិត្តថាមិនទិញដីនោះវិញ លោក ក គាត់ក៏បានជូនដំណឹងអំពីការដកសំណើនោះមកវិញ ហើយការជូនដំណឹងនោះបានទៅដល់លោក ខ មុនពេលដែលសំណើទិញដីមួយនោះបានទៅដល់។ នោះសំណើទិញដីរបស់លោក ក ទៅកាន់លោក ខ នោះមិនមានអានុភាពទេ។

## ២. កាលកំណត់នៃសំណើ

សំណើ អាចបង្កើតឡើងជា២ប្រភេទ៖ គឺសំណើដែលមានកំណត់អំឡុងពេល និង សំណើដែលគ្មានកំណត់អំឡុងពេល។

### ២.១ សំណើដែលមានកំណត់អំឡុងពេល

សំណើ អាចធ្វើឡើងបាន ដោយកំណត់អំឡុងពេលសម្រាប់ស្វីការ។ អំឡុងពេលសម្រាប់ស្វីការ ត្រូវគិតចាប់ពីថ្ងៃដែលជូនដំណឹងអំពីសំណើ ប្រសិនបើមិនច្បាស់លាស់ថាអ្នកស្នើកំណត់ពីផ្សេង។

សំណើ ដែលត្រូវបានធ្វើឡើង ដោយមានកំណត់អំឡុងពេលសំរាប់ស្វីការ មិនអាចដកបានវិញទេ។

ប្រសិនបើអ្នកស្នើ មិនបានទទួលដំណឹងអំពីស្វីការ ក្នុងអំឡុងពេលដែលបានកំណត់សម្រាប់ស្វីការនោះទេ សំណើនោះត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ នៅពេលផុតអំឡុងពេលសម្រាប់ស្វីការ។ ក្នុងករណីដែលដំណឹងអំពីការបដិសេធសំណើ បានដល់អ្នកស្នើក្នុងអំឡុងពេលសម្រាប់ស្វីការនោះ សំណើនោះក៏បាត់បង់អានុភាពដែរ។

**ឧទាហរណ៍៖** ក្រុមហ៊ុន លោក ក បានប្រកាសជ្រើសរើសបុគ្គលិកចំនួន ១០ ថ្ងៃ។ ដូចនេះប្រសិនបើមិនទាន់ផុតរយៈពេល ១០ ថ្ងៃនោះទេ ក្រុមហ៊ុនរបស់លោក ក មិនអាចដកសំណើរបស់ខ្លួនបានទេ។

### ២.២ សំណើដែលគ្មានកំណត់អំឡុងពេល

ចំពោះសំណើដែលត្រូវបានធ្វើឡើង ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្វីការ រវាងគូភាគី ដែលកំពុងនិយាយគ្នា នៅក្នុងស្ថានភាពដែលអាចឆ្លើយភ្លាមៗបាន ប្រសិនបើភាគីដែលទទួលសំណើមិនបានយល់ព្រមភ្លាមៗទេ សំណើនោះត្រូវបាត់បង់អានុភាព។[4]

---

[3] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី២។

[4] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៩ កថាខណ្ឌទី ១។

**ឧទាហរណ៍១ ៖** លោក ក បាននិយាយទៅកាន់ លោក ខ ថាចង់លក់រថយន្ត ១ គ្រឿង ក្នុងតម្លៃ ២០០,០០០ ដុល្លារ តែលោក ខ មិនបានឆ្លើយតបទេ។

ចំពោះសំណើដែលធ្វើរវាងគូភាគីដែលមិននិយាយគ្នា ដោយគ្មានកំណត់អំឡុងពេលសម្រាប់ស្ទីការទេ អ្នកស្នើមិនអាចដកសំណើនោះវិញក្នុងអំឡុងពេលសមរម្យបានឡើយ។ ចំពោះអំឡុងពេលសមរម្យដែល កំណត់នៅក្នុងចំណុចនេះ យើងអាចវិនិច្ឆ័យទៅតាមខ្លឹមសារ និងប្រភេទនៃកិច្ចសន្យា។

**ឧទាហរណ៍២ ៖** ប្រសិនបើចំនួនទឹកប្រាក់ក្នុងកិច្ចសន្យាមានចំនួនច្រើន ឬ ប្រសិនបើកម្មវត្ថុនៃកិច្ចសន្យាគឺជាវត្ថុមានតម្លៃ ដូចជាអចលនវត្ថុ អំឡុងពេលសមរម្យនោះប្រហែលជាមានរយៈពេលវែង។ ប្រសិនបើជាកិច្ចសន្យាសាមញ្ញធម្មតា អំឡុងពេលនោះអាចមានរយៈពេលខ្លី។

ការដកសំណើ ត្រូវមានអានុភាព លុះត្រាតែជូនដំណឹងអំពីការដកសំណើនោះ បានមកដល់ភាគីម្ខាងទៀតមុនពេលភាគីម្ខាងទៀតជូនដំណឹងអំពីស្ទីការ។

### ៣. ការបញ្ចប់សំណើ

សំណើអាចនឹងត្រូវបញ្ចប់ ដោយសារមូលហេតុខាងក្រោម៖

- ការដកសំណើ ឬ ការលុបសំណើ។
- ការបដិសេធសំណើដោយអ្នកទទួលសំណើ។
- នៅពេលហួសរយៈពេលកំណត់នៃសំណើ។
- ម្ចាស់ដែលធ្វើសំណើទទួលមរណៈភាព។
- កម្មវត្ថុនៃកិច្ចសន្យាត្រូវបានបំផ្លាញ។
- កម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត។

## កថាភាគទី២៖ ស្ទីការ

ស្ទីការ គឺជាការបង្ហាញឆន្ទៈ ដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ។[5] ការធ្វើស្ទីការនេះមានគោលបំណង ក្នុងការភ្ជាប់ខ្លួនជាមួយអ្នកផ្តល់សំណើ នូវការទទួលយកនូវកាតព្វកិច្ចមួយចំនួន តាមផ្លូវច្បាប់។

**ឧទាហរណ៍៖** លោក ក យល់ព្រមលក់នូវទូរស័ព្ទមួយគ្រឿង ក្នុងតម្លៃ ២០០,០០០៛ ឲ្យទៅលោក ខ ដែលបានស្នើទិញទូរស័ព្ទនោះ។ នៅពេល លោក ក ធ្វើការឆ្លើយតប ដោយបង្កើតនូវស្ទីការនេះឡើង មានន័យថា កិច្ចសន្យា រវាងអ្នកទាំងពីរបានចាប់ផ្តើមនៅពេល លោក ខ បានទទួលនូវស្ទីការនោះ។

[5] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី៣។

**១. ល័ក្ខខ័ណ្ឌនៃស្វីការ**

ស្វីការមួយមានអានុភាព នៅពេលដែលស្វីការនោះបានដល់អ្នកស្នើ។ ប៉ុន្តែប្រសិនបើដំណឹងអំពីការដក ស្វីការនោះវិញដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្វីការដល់ឬមុនពេលស្វីការដល់ នោះអានុភាពនៃស្វីការ មិនត្រូវបានកើតឡើងឡើយ។[6] ជាធម្មតា អ្នកធ្វើស្វីការត្រូវយល់ព្រមទាំងស្រុងនូវរាល់ចំណុចដែលមានកំណត់ នៅក្នុងសំណើ។ ស្វីការត្រូវធ្វើឡើងឲ្យទាន់ពេលមុនសំណើរលត់ស្វីការ ត្រូវតែបញ្ជូនឲ្យដល់អ្នកធ្វើសំណើ ឬឲ្យ បានដល់អ្នកស្នើ។ លើសពីនេះទៅទៀត ដូចទៅនឹងសំណើដែរ ស្វីការអាចធ្វើឡើងតាមរយៈលិខិតជា លាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ និងដោយតណ្ហីភាព។

**២. ការមកដល់យឺតយ៉ាវនៃស្វីការ**

ក្នុងករណី ការជូនដំណឹងអំពីស្វីការ ចំពោះសំណើដែលមានអំឡុងពេលសម្រាប់ស្វីការ មកដល់ភាគី ម្ខាងទៀត ក្រោយពេលអំឡុងពេលសម្រាប់ស្វីការនោះកន្លងផុត ប្រសិនបើអ្នកស្នើស្ថិតក្នុងស្ថានភាពដែលអាច ដឹងថា ភាគីម្ខាងទៀត ជូនដំណឹងអំពីស្វីការនោះ នៅពេលដែលអាចមកដល់ក្នុងអំឡុងពេលសម្រាប់ស្វីការ ក្នុងករណីធម្មតានោះអ្នកស្នើ ត្រូវជូនដំណឹងអំពីការមកដល់ស្វីការដោយមានការយឺតយ៉ាវនោះ ទៅអ្នកធ្វើស្វីការ ដោយគ្មានការយឺតយ៉ាវ។ ក្នុងករណីដែលអ្នកស្នើធ្វេសប្រហែស ក្នុងការជូនដំណឹងអំពីការមកដល់ស្វីការដោយ មានការយឺតយ៉ាវនោះ ស្វីការដែលមកដល់ដោយមានការយឺតយ៉ាវនោះ មានសុពលភាព។ អ្នកស្នើអាចចាត់ទុក ថាស្វីការដែលបានមកដល់អ្នកស្នើ ក្រោយផុតអំឡុងពេលសម្រាប់ស្វីការជាសំណើថ្មី។[7]

**៣. ស្វីការដែលមានបន្ថែមការកែប្រែ**

ស្វីការដោយមានការបន្ថែមការកែប្រែសារធាតុចំពោះសំណើ មិនត្រូវក្លាយជាស្វីការសុពលភាពទេ តែ ស្វីការនោះមានអានុភាពជាសំណើថ្មី។ ប៉ុន្តែប្រសិនបើ ការកែប្រែនោះមិនធ្វើឲ្យមានការកែប្រែសារធាតុទេ ស្វីការ នោះត្រូវមានអនុភាពជាស្វីការ។ ប៉ុន្តែប្រសិនបើអ្នកស្នើ តវ៉ាភ្លាមកិច្ចសន្យាមិនត្រូវបានបង្កើតទេ។ គោលបំណង គឺដើម្បីឲ្យមានការបង្កើតកិច្ចសន្យាតាមលទ្ធភាព ដែលអាចធ្វើបានតាមរយៈ ការសម្របសម្រួល រវាងផល ប្រយោជន៍របស់ភាគីទាំងពីរ ក្នុងការចរចាលើកិច្ចសន្យា។[8]

**កថាភាគទី៣៖ វិការៈនៃការព្រមព្រៀង**

ជាគោលការណ៍ កិច្ចសន្យាមួយអាចមានសុពលភាពតាមផ្លូវច្បាប់ លុះត្រាតែកិច្ចសន្យាមួយនោះ ត្រូវ បានកើតឡើងដោយមានការព្រមព្រៀង និងឆន្ទៈពិតប្រាកដរវាងភាគីទាំងពីរនៃកិច្ចសន្យា ដោយហេតុថា ដំណាក់កាលនៃការបង្កើតកិច្ចសន្យា ភាគីទាំងសងខាងដែលធ្វើសំណើ និងស្វីការ ត្រូវបានបញ្ជាក់ថា ធ្វើដោយ

---

[6] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៧ កថាខណ្ឌទី៤។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៤១។

[8] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៣៤២។

តណ្ហីភាព គឺសំដៅឆន្ទៈច្បាស់លាស់ និងស្មៀមស្ងាត់។ ប្រសិនបើកិច្ចសន្យាមួយមានវិការៈនៃការព្រមព្រៀង ភាគីអាចលុបចោលកិច្ចសន្យានោះបាន។ វិការៈនៃការព្រមព្រៀងមានដូចជា ការភាន់ច្រឡំ ការឆបោក ព័ត៌មានមិនពិត ការរំលោភបំពានលើស្ថានភាព អំពើកេងចំណេះហួសហេតុ និងការគម្រាមកំហែង។

### ១. ការភាន់ច្រឡំ

ការភាន់ច្រឡំនៃការព្រមព្រៀងរបស់កិច្ចសន្យា គឺជាការព្រមព្រៀងមិនពិតប្រាកដ បើមិនមានការភាន់ច្រឡំនោះទេ ភាគីដែលភាន់ច្រឡំប្រាកដជា មិនចុះកិច្ចសន្យាឡើយ។ ចំពោះការភាន់ច្រឡំនេះដែរ បើសិនជាការភាន់ច្រឡំនោះ មិនបានចាត់ទុកថាជាចំណុចសំខាន់ក្នុងកិច្ចសន្យានោះទេ គេមិនអាចបដិសេធ អានុភាពនៃកិច្ចសន្យាឡើយ។

**ឧទាហរណ៍១ ៖** ក្នុងករណីការបញ្ជាទិញទំនិញតាមប្រព័ន្ធអនឡាញ នៅពេលភាគីលក់ទំនិញទទួលបានប្រាក់ ដែលភាគីទិញបានផេរជូន ហើយក៏បានមកភាគីទិញថានឹងផ្ញើរទំនិញតាមក្រុមហ៊ុនដឹកជញ្ជូន ក តែនៅពេលដែលអ្នកដឹកទំនិញពីហាងទៅដាក់ផ្ញើ ក៏បានយកទៅដាក់តាមក្រុមហ៊ុន ខ ទៅវិញ។ ប៉ុន្តែក្នុងរយៈពេលដែលបានបញ្ជាក់ដោយអ្នកលក់ ភាគីអ្នកទិញ ក៏បានទទួលទំនិញដោយគ្មានការខូចខាតទាំងអស់ ដូចនេះ ភាគីទាំងសងខាងមិនអាចបដិសេធអានុភាពនៃកិច្ចសន្យាបានឡើយ ដោយហេតុថា គ្រាន់តែមានការភាន់ច្រឡំបន្តិចប៉ុណ្ណោះ។

ទាល់តែក្នុងករណី ដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗក្នុងកិច្ចសន្យា ដែលអាចមានការប៉ះពាល់ធ្ងន់ធ្ងរ ដល់ផលប្រយោជន៍របស់អ្នកភាន់ច្រឡំ ដូច្នេះ គេអាចទទួលស្គាល់ការលុបចោលកិច្ចសន្យាដោយមូលហេតុភាន់ច្រឡំបាន។

**ឧទាហរណ៍២ ៖** ក្នុងកិច្ចសន្យាលក់ ទិញ នូវរថយន្តមួយគ្រឿងករណីដែលភាគីអ្នកទិញច្រឡំ និយាយថាទិញក្នុងតម្លៃ ១០០,០០០ ដុល្លារ តែឆន្ទៈពិតប្រាកដ គឺគាត់ចង់ទិញត្រឹមតម្លៃ ១០,០០០ ដុល្លារប៉ុណ្ណោះ។ ដូចនេះ បានសេចក្តីថា ការភាន់ច្រឡំទៅចំណុចសំខាន់ៗ ជាសត្យានុម័តនៃកិច្ចសន្យា។[9]

### ២. ការឆបោក

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថា បុគ្គលណាម្នាក់ ឬតតិយជន បានធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ ដោយសារមធ្យោបាយឆបោក។ ការឆបោក មានលក្ខណៈស្រដៀងនឹងការភាន់ច្រឡំ ត្រង់ចំណុចដែលអ្នកបង្ហាញឆន្ទៈ បានបង្ហាញចេញមកក្រៅ ដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។ ប៉ុន្តែ ភាពខុស

[9] គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី. *សេចក្តីអំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៣៤៦។

គ្នានេះកើតឡើងពីសកម្មភាពឆបោករបស់ភាគីម្ខាងទៀត ឬតតិយជន នៅក្នុងករណីឆបោកដែលមានលក្ខណៈខុសពីការភាន់ច្រឡំ។[10] ការឆបោក មានពីរប្រភេទ៖

- **ការឆបោកដោយភាគីម្ខាង៖** បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈ ដោយសារការឆបោករបស់ភាគីម្ខាងទៀត អាចលុបចោលកិច្ចសន្យា ដោយហេតុថាការ បង្ហាញឆន្ទៈនោះមានវិការៈ។[11]
- **ការឆបោកដោយភាគីតតិយជន៖** សំដៅទៅលើជនទាំងឡាយណា ដែលក្រៅពីភាគីម្ខាងទៀត បានប្រើមធ្យោបាយឆបោក ដើម្បីឲ្យអ្នកបង្ហាញឆន្ទៈ មានការភាន់ច្រឡំដោយសារមធ្យោបាយឆបោកនោះ ហើយអ្នកបង្ហាញឆន្ទៈ បានបង្ហាញឆន្ទៈរបស់ខ្លួនដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន។ នៅក្នុងករណីនៃការឆបោករបស់តតិយជន អ្នកបង្ហាញឆន្ទៈ អាចលុបចោលកិច្ចសន្យាបាន តែក្នុងករណីដែលភាគីម្ខាងទៀតបានដឹង ឬអាចនឹងបានដឹងអំពីការឆបោកនេះ។[12]

### ៣. ព័ត៌មានមិនពិត

ព័ត៌មានមិនពិត គឺសំដៅទៅលើករណី ដែលភាគីនៃកិច្ចសន្យាបានលើកឡើងនូវចំណុចដែលជាមូលដ្ឋាគ្រឹះនៃការបង្កើតកិច្ចសន្យា មានលក្ខណៈខុសពីការពិត។ នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញ ដោយភាគីម្ខាងនោះ ខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថាហេតុ ទាំងនោះជាការពិត ប៉ុន្តែប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែនជាការពិតខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[13] នៅក្នុងករណីនៃព័ត៌មានមិនពិត គេតម្រូវឲ្យភាគីម្ខាងទៀត មិនបានដឹងថាហេតុដែលគាត់លើកឡើងនោះមិនមែនជាការពិត។ ប្រសិនបើ គាត់ដឹងថាហេតុនោះខុសពីការពិត គេត្រូវបានចាត់ទុកថាជាការឆបោក។[14]

**ឧទាហរណ៍៖** លោក ក បានលក់រថយន្តមួយគ្រឿង ក្នុងតម្លៃ ៥០,០០០ $ (ប្រាំម៉ឺនដុល្លារ) ទៅឲ្យលោក ខ ដោយបានប្រាប់ថារថយន្តនេះ នាំចូលមកពីសហរដ្ឋអាមេរិក។ ក៏ប៉ុន្តែ ប្រភពនៃរថយន្តនេះពិតប្រាកដ គឺនាំចូលមកពីប្រទេសអូស្រ្តាលី។ បន្ទាប់ពី លោក ខ បានដឹងអំពីព័ត៌មាននេះ គាត់ក៏បានលុបចោលកិច្ច

---

[10] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ៣.* (ភ្នំពេញ, ខែមីនា ឆ្នាំ ២០១៧), ទំព័រទី៥២។

[11] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៤៧ កថាខណ្ឌទី ១។

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៣៤៧។

[13] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៤៨ កថាខណ្ឌទី ១។

[14] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ៣.* (ភ្នំពេញ, ខែមីនា ឆ្នាំ ២០១៧), ទំព័រទី៥២។

សន្យា ដោយផ្អែកទៅលើព័ត៌មានរបស់លោ ក ជាព័ត៌មានមិនពិត។ លោក ក ក៏មិនបានដឹងច្បាស់ពិតប្រាកដ ដែរថា រថយន្តនេះមានប្រភពមកពីប្រទេសអូស្រ្តាលី ដែលមិនមែនមកពីសហរដ្ឋអាមេរិក។ នៅក្នុងករណីនេះគេ អាចនិយាយថា ព័ត៌មានដែលលោកក៏បានប្រាប់នោះគឺជាព័ត៌មានមិនពិត ប៉ុន្តែបើសិនជានៅក្នុងករណីដែល លោក ក បានដឹងពីដំបូងហើយថារថយន្តមួយនោះមានប្រភពមកពីប្រទេសអូស្រ្តាលីទេ តែគាត់នៅតែប្រាប់ លោក ខ ថាមកពីសហរដ្ឋអាមេរិកទៀតនោះ ករណីនេះកែចាត់ទុកថាជាការឆបោកវិញ។

### ៤. ការរំលោភបំពានលើស្ថានភាព

នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើមិនត្រឹមត្រូវនូវឋានៈខ្លួន ដែលមានអាទិភាពជាង ភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើដោយមិនត្រឹមត្រូវនូវស្ថានភាពផ្សេងទៀត ដែលភាគី ម្ខាងទៀតមិនអាចប្រឆាំងតបតបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការ បង្ហាញឆន្ទៈនោះមានវិការៈ។[15]

### ៥. អំពើកេងចំណេញហួសហេតុ

អំពើកេងចំណេញហួសហេតុ សំដៅទៅលើករណីដែលភាគីម្ខាង បានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាស ដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ខ្លៅ ឬ ការខ្វះការពិសោធន៍ ហើយ បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[16]

### ៦. ការគម្រាមកំហែង

បុគ្គលដែលបានបង្ហាញឆន្ទៈដោយសារមានការគំរាមកំហែងពីសំណាក់ភាគីម្ខាងទៀត ឬពីសំណាក់ តតិយជន អាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។[17] ចំពោះការគម្រាម កំហែង គឺអាចជាការគម្រាមកំហែងខាងផ្លូវកាយ ឬ ផ្លូវចិត្តទៅលើភាគីណាមួយ ប្តីឬប្រពន្ធ បុព្វញាតិ ឬ បច្ឆាញាតិ របស់ភាគីណាមួយ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាទិញលក់អចលនទ្រព្យមួយកន្លែង លោក ឃ ដែលជាអ្នកមានបំណង ចង់ទិញដីនោះពីលោក ង គាត់បានប្រើប្រាស់ នូវសកម្មភាពដែលមានលក្ខណៈគម្រាមកំហែងទៅលើលោក ង ដោយសម្លុតឲ្យលោក ង លក់អចលនទ្រព្យមួយនោះឲ្យទៅខ្លួនក្នុងតម្លៃទាបមួយដែលខ្លួនចង់បាន។ នៅក្នុង ករណីនេះលោក ង ដែលជាម្ចាស់អចលនទ្រព្យនោះ បានបង្ហាញឆន្ទៈរបស់ខ្លួន ខុសពីឆន្ទៈពិតប្រាកដ ដោយ

---

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៤៩ កថាខណ្ឌទី ១។

[16] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៥១។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៥០។

ហេតុថាគាត់ត្រូវបានគម្រាមកំហែងពី លោក ឃ ដែលជាអ្នកចង់ទិញ។ ដូច្នេះលោក ង អាចលុបចោលនូវកិច្ចសន្យានោះបាន។

## ផ្នែកទី២៖ កម្មវត្ថុនៃកិច្ចសន្យា

កិច្ចសន្យាមួយ នឹងមានសុពលភាពនៅពេលដែលកាតព្វកិច្ចបានកើតឡើង ពីកិច្ចសន្យានោះ វត្ថុមួយជាក់លាក់អាចធ្វើកើត និងដែលស្របច្បាប់ របៀបរៀបរយសាធារណៈ ឬទំនៀមទម្លាប់ល្អរបស់ប្រពៃណី។ កម្មវត្ថុនៃកិច្ចសន្យាគឺជាកាតព្វកិច្ច ឯកម្មវត្ថុនៃកាតព្វកិច្ចគឺជាតាវកាលិក (អំពើ ឬ វត្ថុ)។ ក្នុងនោះផងដែរ កម្មវត្ថុនៃកិច្ចសន្យាត្រូវតែជាក់លាក់ មានន័យថាភាគីកិច្ចសន្យាត្រូវតែយល់ច្បាស់ពីអ្វីដែលខ្លួនបានសន្យាចំពោះកិច្ចសន្យាដែលមានកម្មវត្ថុជាតាវកាលិក ចេញពីអំពើរបស់មនុស្ស។ កម្មវត្ថុជាក់លាក់ ក៏មានន័យថាជាកម្មវត្ថុត្រូវតែមាននៅពេលបច្ចុប្បន្នដែរ។ ដូច្នេះប្រសិនបើ កម្មវត្ថុមិនមាននៅពេលចុះកិច្ចសន្យា ដោយសារវត្ថុនោះបាត់បង់កិច្ចសន្យា និងពុំមានសុពលភាពឡើយ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាមួយ ដែលកម្មវត្ថុនៃកិច្ចសន្យា គឺតម្រូវឲ្យភាគីនៃកិច្ចសន្យា ធ្វើការដឹកជញ្ជូនទំនិញក្នុងចំងាយដី ១,០០០ គីឡូម៉ែត្រ ដោយប្រើរយៈពេល ១០ នាទី។ ត្រង់ចំណុចនេះនឹងអាចឃើញថាកម្មវត្ថុនៃកិច្ចសន្យាគឺមិនអាចសំរេចទៅបានទេ ដោយវាមានលក្ខណៈហួសឆ្ងាយខ្លាំងធៀបទៅនឹងការពិត ដែលគ្មាននរណាម្នាក់អាចសំរេចបានឡើយ។

### កថាភាគទី១៖ ភាពស្របច្បាប់ ឬ ភាពមិនផ្ទុយនឹងការអនុវត្តដោយបង្ខំ

ប្រសិនបើខ្លឹមសារនៃកិច្ចសន្យា ផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំណាមួយ នោះវាត្រូវបានចាត់ទុកជាមោឃៈ។[18] បញ្ញត្តិដែលអនុវត្តដោយបង្ខំ គឺសំដៅទៅលើបញ្ញត្តិដែលបដិសេធរាល់អានុភាពនៃសកម្មភាពគតិយុត្តដែលផ្ទុយនឹងបញ្ញត្តិនេះ។

**ឧទាហរណ៍៖** នៅក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាថា ភាគីម្ខាងនៃកិច្ចសន្យា មិនអាចលុបចោលកិច្ចសន្យាបានទេ ទោះបីជាគាត់បានបង្ហាញឆន្ទៈដោយសារការភាន់ច្រឡំក៏ដោយ។ ការព្រមព្រៀងបែបនេះ ត្រូវបានចាត់ទុកជាមោឃៈ ព្រោះវាផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ។

### កថាភាគទី២៖ ភាពមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ

ល័ក្ខខ័ណ្ឌនេះ សំដៅទៅលើភាពមិនផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ដែលវាចាំបាច់តម្រូវឲ្យកម្មវត្ថុនោះ ស្របទៅនឹងស្ថានភាពសង្គម។ មានន័យថា ទោះជាការបង្ហាញឆន្ទៈរបស់គូភាគីគ្មានវិការៈក៏ដោយ ក៏កិច្ចសន្យាត្រូវបានចាត់ទុកជាមោឃៈដែរ ប្រសិនបើខ្លឹមសារនៃកិច្ចសន្យាផ្ទុយពីស្ថានភាពសង្គម និងទំនៀមទំលាប់ល្អ។

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៣៥៤ កថាខណ្ឌទី ១ ចំនុច ក។

**ឧទាហរណ៍៖** ប្រសិនបើបុរសម្នាក់ដែលមានប្រពន្ធហើយ ចុះកិច្ចសន្យាជាមួយនារីម្នាក់ទៀត ដើម្បីបានរួមភេទជាមួយនាង និង បង់ប្រាក់កម្រៃឲ្យនាងនោះ កិច្ចសន្យានេះត្រូវបានចាត់ទុកជាមោឃៈ ដោយសារអត្ថន័យនៃកិច្ចសន្យានេះ ផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទំលាប់ល្អ ទោះបីជាគ្មានច្បាប់ហាមឃាត់កិច្ចសន្យាបែបនេះក៏ដោយ។

**កថាភាគទី៣៖ ល័ក្ខខ័ណ្ឌទម្រង់កិច្ចសន្យា**

ជាទូទៅកិច្ចសន្យាទាំងឡាយ អាចត្រូវដាក់ឲ្យប្រតិបត្តិតាមបាន ទោះបីកិច្ចសន្យានោះជាទម្រង់យថាភូត (ការសរសេរ ឬ ជាពាក្យពេចន៍) ឬ ជាវាតរហិត (ចេញពីអំពើ) ក៏ដោយ ក៏កិច្ចសន្យានោះនៅតែអាចដាក់ឲ្យប្រតិបត្តិបានដែរ។ កិច្ចសន្យាយថាភូតអាចជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់។ យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ កិច្ចសន្យាមានអានុភាព ដោយមានការព្រមព្រៀងគ្នាទៅវិញទៅមករបស់ភាគីទាំងពីរតែប៉ុណ្ណោះ ពីព្រោះថាជាគោលការណ៍ ការព្រមព្រៀងគ្នាទៅវិញទៅមកគឺជាកត្តាចាំបាច់សម្រាប់ការបង្កើតកិច្ចសន្យា ហើយក្រៅពីការព្រមព្រៀងនោះ ច្បាប់មិនតម្រូវឲ្យមានល័ក្ខខ័ណ្ឌផ្សេងទៀតទេ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏ច្បាប់ហើយតម្រូវឲ្យមានល័ក្ខខ័ណ្ឌបន្ថែម ចំពោះការបង្កើតកិច្ចសន្យាមួយចំនួន ដូចជាកិច្ចសន្យាប្រគល់វត្ថុ (កិច្ចសន្យាដែលត្រូវបានបង្កើតដោយការប្រគល់វត្ថុ) ឬការរៀបចំលិខិតដែលជាល័ក្ខខ័ណ្ឌចាំបាច់បន្ថែមលើការព្រមព្រៀងគ្នាទៅវិញទៅមក។ ជាពិសេស កិច្ចសន្យា ដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននៃកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុនោះនឹងមានអនុភាព លុះត្រាតែបានធ្វើ លិខិតយថាភូត (ជាលិខិត ធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ ឬ តាមន័យចង្អៀត លិខិតទាំងឡាយដែលរៀបចំឡើងដោយសហការី)។[19]

**១. កិច្ចសន្យាធ្វើដោយផ្ទាល់មាត់**

កិច្ចសន្យាផ្ទាល់មាត់ជាទូទៅ អាចដាក់ឲ្យប្រតិបត្តិបានដូចគ្នានឹងកិច្ចសន្យាលាយលក្ខណ៍អក្សរដែរ ហើយកិច្ចសន្យាទាំងនោះអនុវត្តច្រើនជាងគេសម្រាប់បញ្ហាសាមញ្ញតូចៗក្នុងការរស់នៅប្រចាំថ្ងៃ។

**ឧទាហរណ៍៖** កិច្ចសន្យាទិញទឹកអំពៅមួយកែវក្នុងតម្លៃ ២,០០០ រៀល គឺសុទ្ធតែធ្វើឡើងដោយផ្ទាល់មាត់។

**២. កិច្ចសន្យាធ្វើជាលាយលក្ខណ៍អក្សរ**

ទោះបីជាការបង្កើតកិច្ចសន្យា អាចធ្វើឡើងដោយផ្ទាល់មាត់យ៉ាងណាក៏ដោយ បណ្តាយុត្តាធិការជាច្រើនពិតជាតម្រូវ ប្រភេទកិច្ចសន្យាសំខាន់ៗមួយចំនួន ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ទើបអាចដាក់ឲ្យប្រតិបត្តិបាន។ លើសពីនេះទៅទៀតភាគីទាំងឡាយនៃកិច្ចសន្យា គួរតែធ្វើកិច្ចសន្យាសំខាន់ៗទាំងអស់ ជា

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣៣៦ កថាខណ្ឌទី ២។

លាយលក្ខណ៍អក្សរ ទោះបីមិនមានច្បាប់តម្រូវក៏ដោយ ព្រោះការសរសេរនោះ នាំឲ្យមានការលើកទឹកចិត្តដល់គូភាគីនៃកិច្ចសន្យា ឲ្យមានភាពច្បាស់លាស់ពេញលេញឡើងថែមទៀតក្នុងការធ្វើកិច្ចសន្យារបស់ពួកគេ និងផ្តល់ភ័ស្តុតាងយ៉ាងមុតមាំ ដើម្បីការពារផលប្រយោជន៍របស់ពួកគេនៅក្នុងការបង្កើតកិច្ចសន្យា។ ជាទូទៅ កិច្ចសន្យាអាចធ្វើជាលិខិតយថាភូត និងលិខិតឯកជន ជាល័ក្ខខ័ណ្ឌនៃការបង្កើតកិច្ចសន្យា។[20]

**២.១ លិខិតយថាភូត**

លិខិតយថាភូត ជាលិខិតធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈដែលត្រូវបានអនុញ្ញាតឲ្យប្រតិបត្តិមុខងារនោះ ឬ តាមន័យចង្អៀត លិខិតទាំងឡាយដែលរៀបចំឡើងដោយសហការី។[21]

**២.២ លិខិតឯកជន**

លិខិតឯកជន ជាលិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬ ស្នាមមេដៃ។[22]

## ផ្នែកទី៣៖ សមត្ថភាពចុះកិច្ចសន្យា

សមត្ថភាព គឺជាសម្បទារបស់បុគ្គលម្នាក់ៗ ដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ក្នុងការធ្វើអ្វីមួយដែលច្បាប់តម្រូវឲ្យធ្វើ ឬ ទទួលស្គាល់ថាអាចមានគុណសម្បត្តិនិងធ្វើបាន។ នៅក្រោមប្រព័ន្ធច្បាប់ Common law និងប្រព័ន្ធច្បាប់ Civil law ភាគីនានានៃកិច្ចសន្យាសុពល មួយត្រូវមានសមត្ថភាពតាមផ្លូវច្បាប់ ដើម្បីចុះកិច្ចសន្យា។ គោលបំណងនៃការកំណត់សមត្ថភាពនេះ គឺការពារជនដែលគ្មានសមត្ថភាព កុំឲ្យកេងយកនូវប្រយោជន៍ ដោយសារតែមានស្មារតីមិនពេញលេញ ដោយសារអាយុ ឬដោយសារពិការបញ្ញាស្មារតី។

### កថាភាគទី១៖ ជនដែលអាចចុះកិច្ចសន្យា

ជាទូទៅ បុគ្គលដែលមានសមត្ថភាពគ្រប់គ្រាន់ អាចនឹងធ្វើកិច្ចសន្យាសុពលមួយ បានកាលណាបុគ្គលនោះមានសមត្ថភាព អាចយល់ដឹងអំពីលក្ខណៈនៃការធ្វើកិច្ចសន្យា ហើយអាចគ្រប់គ្រងលើសកម្មភាពនានារបស់ខ្លួនក្នុងការធ្វើកិច្ចសន្យានោះ ហើយអាចដឹងមុនពីលទ្ធផលនៃអំពើ បន្ថែមពីលើនោះទៅទៀតច្បាប់ក៏អនុញ្ញាតឲ្យគេអាចបង្កើតសិទ្ធិ និងកាតព្វកិច្ចផងដែរ។

**១. នីតិជន**

តាមន័យទូទៅ នីតិជន គឺជាបុគ្គលដែលមានអាយុគ្រប់ តាមច្បាប់កំណត់ ហើយមានសមត្ថភាពឯករាជ្យខាងអំពើ។[23] ដោយឡែក បើផ្អែកទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧ នីតិជនមានន័យថា ជនដែលមានអាយុចាប់ពី១៨ ឆ្នាំឡើងទៅ។ ក្នុងការបង្កើតកិច្ចសន្យា នីតិជន ត្រូវបានកំណត់ថាជាជន ដែលមានសម្ថភាពពេញ

[20] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៥១៦។

[21] តាមសទ្ទានុក្រមរដ្ឋប្បវេណី. ឆ្នាំ ២០០៧។

[22] តាមសទ្ទានុក្រមរដ្ឋប្បវេណី. ឆ្នាំ ២០០៧។

[23] តាមសទ្ទានុក្រមរដ្ឋប្បវេណី. ឆ្នាំ ២០០៧។

លេញទាំងស្រុងក្នុងការសំរេចចិត្ត និងធ្វើការបង្ហាញឆន្ទៈចុះកិច្ចសន្យាមួយបាន។ ជាទូទៅ ប្រភេទនៃមនុស្សមួយចំនួន មិនអាចមានសមត្ថភាពពេញលេញ ក្នុងការធ្វើកិច្ចសន្យាបានទេ ប៉ុន្តែមានករណីមួយចំនួនទៀត ដែលច្បាប់អនុញ្ញាតឲ្យ ជនដែលមិនមានសមត្ថភាពទាំងនោះ ដូចជា អនីតិជន ឬ អសមត្ថជន អាចមានសិទ្ធិចុះកិច្ចសន្យាបានដូចជា៖

**២. អនីតិជនដែលមានអត្តាធីនភាព**

អនីតិជន ដែលមានអត្តាធីនភាព មានន័យថាជាអនីតិជនដែលបានដល់ ១៦ឆ្នាំ ទ្រទ្រង់ជីវភាពរបស់ខ្លួនដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន តាមរយៈពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ។ ក្នុងករណីនេះតុលាការ ត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា។[24] ម្យ៉ាងទៀត អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ។ ចំពោះអានុភាពនៃអត្តាធីនភាព គឺ អនីតិជនដែលទទួលនូវអត្តាធីនភាព ត្រូវចាត់ទុកថា បានដល់នីតិភាព។[25] តាមការបកស្រាយខាងលើ អនីតិជនដែលមានអត្តាធីនភាព អាចចុះកិច្ចសន្យាបាន។

**៣. អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម**

អនីតិជនដែលបានទទួលការអនុញ្ញាតឲ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ។[26] ដូចនេះក្នុងករណីដែលកម្មវត្ថុ នៃកិច្ចសន្យាមានលក្ខណៈទាក់ទងទៅនឹងមុខជំនាញរបស់អនីតិជននោះ ហើយអនីតិជនម្នាក់នោះមានសម្ថភាពគ្រប់គ្រាន់ ដើម្បីអនុវត្តកាតព្វកិច្ចតាមការកំណត់ក្នុងកិច្ចសន្យាបាន នោះគេអាចចុះកិច្ចសន្យា ឬ បង្កើតកិច្ចសន្យានោះបាន។ ប្រសិនបើបានដឹងច្បាស់ថាអនីតិជននោះមិនអាចបំពេញភារៈកិច្ច ឬ កិច្ចការអាជីវកម្មនោះបានទេ អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ អាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន។

**កថាភាគទី២៖ ជនដែលមិនអាចចុះកិច្ចសន្យា**

ចំពោះបុគ្គលដែលខ្វះប្រការណាមួយនៃបញ្ញាស្មារតី ឬ អាយុ ជាបុគ្គលដែលអសមត្ថភាពក្នុងការធ្វើកិច្ចសន្យា នោះតាមកំណត់ច្បាប់ បុគ្គលនោះមិនអាចធ្វើការ ចុះកិច្ចសន្យាសុពលមួយបានទេ។ ជនទាំងនោះ ត្រូវបានចាត់ទុកថាជា អសមត្ថជនក្នុងការចុះកិច្ចសន្យា។ អសមត្ថជន គឺជាជនដែលគ្មានសមត្ថភាព ក្នុងការធ្វើអ្វីមួយដែលច្បាប់ហាមឃាត់ បានន័យថា អសមត្ថជននោះ ទោះបីជាមានអាយុលើ ១៨ឆ្នាំ ក៏ដោយ ក៏មិនអាចចុះ

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ២១ កថាខណ្ឌទី១។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ២២។

[26] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ២០ កថាខណ្ឌទី ១។

កិច្ចសន្យា បង្កើតសិទ្ធិ និង ករណីយកិច្ចបានឡើយដោយហេតុថា សិទ្ធិតាមផ្លូវច្បាប់របស់ជននោះត្រូវកំណត់ដូចជា៖

### ១. អនីតិជននៅក្រោមអំណាចមេបា

ជនដែលត្រូវបានកម្រិតសមត្ថភាពទីមួយ គឺអនីតិជន។ អនីតិជនសំដៅទៅលើជនដែលមិនទាន់ដល់នីតិភាព ពោលគឺមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ។ ជាគោលការណ៍ អនីតិជនមិនអាចធ្វើសកម្មភាពគតិយុត្តិដោយឯករាជ្យបានទេ ជារួមសកម្មភាពដែលបានធ្វើឡើងដោយឯករាជ្យ អាចត្រូវបានលុបចោល។ ដើម្បីឲ្យអនីតិជនអាចធ្វើសកម្មភាពបាន ចាំបាច់ត្រូវធ្វើសកម្មភាពតាមរយៈអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអនីតិជនខ្លួនឯងអាចធ្វើសកម្មភាពគតិយុត្តបានក្រោយទទួលការយល់ ពីអ្នកតំណាងដែលច្បាប់បានកំណត់។ ប៉ុន្តែជាករណីលើកលែងអនីតិជនត្រូវបានទទួលស្គាល់ធ្វើសកម្មភាពឯករាជ្យចំពោះសកម្មភាពទាំងឡាយណាដែលមិនសូវសំខាន់។

**ឧទាហរណ៍**៖ ដូចជាការទិញនំចំណីធម្មតា។

### ២. ជននៅក្រោមហិតូបត្ថម្ភ

ជាទូទៅ ជននៅក្រោមហិតូបត្ថម្ភ សំដៅទៅលើជន ដែលមានសមត្ថភាពតិចតួចពេក ក្នុងការយល់ដឹង និង វិនិច្ឆ័យ អំពីលទ្ធផលតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ ក្នុងករណីជនដែលមានល័ក្ខខ័ណ្ឌដូចបានរៀបរាប់ខាងលើ អាចធ្វើការដាក់ពាក្យសុំទៅតុលាការតាមរយៈសាមីខ្លួន សហព័ទ្ធ ឬ ញាតិដែលស្ថិតក្នុងបួនថ្នាក់ អ្នកអាណាព្យាបាលជាដើម ដើម្បីឲ្យចាប់ផ្តើមប្រកាសហិតូបត្ថម្ភនោះបាន។[27] តាមន័យនេះជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ មិនអាចធ្វើកិច្ចសន្យាសុពលបានទេ ដោយមូលហេតុការខ្វះសមត្ថភាពយល់ដឹងអំពីអំពើរបស់ ខ្លួនដូចដែលមានបញ្ជាក់ក្នុងមាត្រា ២៨ នៃក្រមរដ្ឋវេណី ឆ្នាំ ២០០៧។

### ៣. ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្ត៍ ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី។ តុលាការអាចប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅបាន តាមរយៈពេលសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤(បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំឆ្នាំ) នៅពេលដែលមានពាក្យសុំ។[28]

---

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ២៨។

[28] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ២៥។

**ឧទាហរណ៍៖** ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃ ទាក់ទងនឹងចំណុចដូចជា ឈ្មោះ គ្រួសារ ទីកន្លែង ដែលខ្លួននៅជាតិដើម ឫក៏ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ជនដែលមានបញ្ហាស្លាប់ខួរក្បាលជាដើម)។ ជនទាំងនេះ គឺសុទ្ធតែជាជននៅក្រោមអាណាព្យាបាលទូទៅ។

ដោយសារតែជនប្រភេទនេះ មិនមានសមត្ថភាពគ្រប់គ្រាន់ផ្នែកបញ្ញាស្មារតី ទើបច្បាប់កំណត់ឲ្យជននេះ មិនអាចចុះកិច្ចសន្យាសុពលបាននោះទេ។

# ជំពូកទី២

# ការរំលាយកិច្ចសន្យា

# ជំពូកទី ២
# ការរំលាយកិច្ចសន្យា

ជាទូទៅ ការរំលាយកិច្ចសន្យា គឺជាវិធីមួយក្នុងចំណោមវិធីទាំង ៣ (បី) នៃការសង្គ្រោះកិច្ចសន្យាសុពលមួយ។ តាមធម្មតា កិច្ចសន្យាមួយមានសុពលភាព ដោយសារតែ គ្មានវិការៈណាមួយកើតឡើងនៅក្នុងអំឡុងពេលបង្កើតកិច្ចសន្យា។ បើសិនជាមានវិការៈផ្សេងៗនៅអំឡុងពេលដែលចាប់ផ្ដើមបង្កើតកិច្ចសន្យានោះ កិច្ចសន្យានោះមិនមានសុពលភាពទេ ពោលកិច្ចសន្យានោះត្រូវបានមោឃភាពចោល។ ដូចនេះ បន្ទាប់ពីកិច្ចសន្យាមួយមាន សុពលភាពហើយ វាអាចមានបញ្ហាផ្សេងៗកើតឡើង នៅពេលដែលភាគីម្ខាងនៃកិច្ចសន្យាបានរងនូវការបំពានពីភាគីម្ខាងទៀត នៃកិច្ចសន្យាតាមរយៈការមិនអនុវត្តកាតព្វកិច្ច។ នៅពេលដែលមានការមិនអនុវត្តកាតព្វកិច្ច នៃកិច្ចសន្យា ការសង្គ្រោះនៃកិច្ចសន្យាត្រូវបាន បង្កើតឡើងតាមរយៈ ៣(បី)ប្រភេទ៖ ទី១ ការអនុវត្តដោយបង្ខំ ទី២ ការទាមទារសំណងការខូចខាត និង ទី៣ ការរំលាយកិច្ចសន្យា។ ក្នុងករណីខ្លះ ភាគីនៃកិច្ចសន្យាអាចជ្រើសរើស ពហុមធ្យោបាយសង្គ្រោះបាន មានន័យថាភាគីនៃកិច្ចសន្យាអាចជ្រើសរើសមធ្យោបាយសង្គ្រោះបានច្រើនយ៉ាងមកអនុវត្តក្នុងការសង្គ្រោះកិច្ចសន្យា លើកលែងតែមធ្យោបាយទាំងនោះមានភាពផ្ទុយគ្នា។ យើងអាចនិយាយបានថា ការរំលាយកិច្ចសន្យា គឺ ជាមធ្យោបាយចុងក្រោយ សម្រាប់ធ្វើការដោះស្រាយនៅពេលដែលភាគីមិនព្រមអនុវត្តកាតព្វកិច្ច។ នៅក្នុងចំណុចបន្ទាប់យើងនឹងស្វែងយល់លម្អិត ពីទិដ្ឋភាពជុំវិញការរំលាយកិច្ចសន្យា ដែលជាប្រធានបទគោលនៃសារណាមួយនេះ។

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការរំលាយកិច្ចសន្យា

### កថាភាគទី១៖ និយមន័យនៃការរំលាយកិច្ចសន្យា

**ការរំលាយកិច្ចសន្យា** សំដៅទៅលើសកម្មភាព ឯកតោភាគីដែលធ្វើឲ្យភាគីទាំងសងខាង រួចផុតពីករណីយកិច្ចរបស់ខ្លួន នៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត។[29] ការរំលាយកិច្ចសន្យាធ្វើឲ្យមានអានុភាពជាឯកតោភាគី ហើយមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ពីព្រោះ វាគឺជាសកម្មភាពឯកតោភាគី។[30]

### កថាភាគទី២៖ គោលបំណងនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យា ដែលបានបញ្ញត្តិនៅក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៧ ហើយការបញ្ញត្តិនេះ គឺមានគោលបំណងក្នុងការផ្ដល់សិទ្ធិទៅដល់គូភាគីនៃកិច្ចសន្យា ដើម្បីឲ្យភាគីអាចមានសិទ្ធិរំលាយកិច្ចសន្យាមួយចោល ក្នុងការទប់ស្កាត់នូវហានិភ័យ ឬ ក៏បញ្ហាទាំងឡាយណាដែលអាចនឹងកើតមានឡើងនៅពេលអនាគត

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤១១ កថាខណ្ឌទី ១។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣១២។

និង ជាការជួសជុលព្យសនកម្ម ដែលបានកើតឡើងដោយសារការបំពានកិច្ចសន្យាធ្ងន់ធ្ងររបស់ភាគីម្ខាងទៀត។ ក្នុងន័យនេះគេចង់បញ្ជាក់ថា ការដែលផ្តល់ឲ្យភាគីមានសិទ្ធិក្នុងការរំលាយកិច្ចសន្យា មិនមែនជាការដាក់ទណ្ឌកម្ម ទៅលើភាគីណាមួយនៃកិច្ចសន្យានោះទេ ប៉ុន្តែវាជាប្រព័ន្ធដែលផ្តាច់ចំណងកាតព្វកិច្ចនៃកិច្ចសន្យា នៅពេលដែលគោលបំណងនៃកិច្ចសន្យានោះ មិនបានសម្រេចដោយសារតែមានការមិនអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងណាមួយ។

## កថាភាគទី៣៖ ប្រភេទនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យាមាន ៤(បួន)ប្រភេទ ដូចជា៖ (១) ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ (២) ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា (៣) ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស និង (៤) ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង។ សេចក្តីលម្អិតពីប្រភេទនៃការរំលាយកិច្ចសន្យានីមួយៗនឹងត្រូវបានបកស្រាយនៅក្នុងចំណុចតូចៗខាងក្រោម៖

### ១. ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់

ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ គឺជាការរំលាយកិច្ចសន្យា ផ្អែកតាមមូលហេតុណាមួយដែលមានកំណត់ក្នុងច្បាប់ ហេតុនេះក្នុងករណីមូលហេតុណាមួយ ដែលមានបញ្ញត្តិក្នុងច្បាប់ត្រូវបានបំពេញ ភាគីនោះអាចរំលាយកិច្ចសន្យាបាន។ ចំពោះសិទ្ធិរំលាយកិច្ចសន្យាដែលកំណត់ក្នុងច្បាប់ ត្រូវបានបញ្ញត្តិឡើងចាប់ពី **មាត្រា៤០៧ ដល់ ៤១៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧។**

**ឧទាហរណ៍៖** នៅក្នុងករណីដែល ក មិនបានប្រគល់នូវកម្មវត្ថុនៅក្នុងអំឡុងពេលសមរម្យ នៅក្រោយពេលបរិច្ឆេទទេ ទោះបីជាមានការដាស់តឿនរបស់ ខ នោះ ខ អាចលើកឡើងអំពីពីការរំលាយកិច្ចសន្យាបាន។ នៅក្នុងករណីនេះការរំលាយកិច្ចសន្យារបស់ ខ ត្រូវបានអនុវត្តដោយផ្អែកលើមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក នៃក្រមរដ្ឋប្បវេណី ឆ្នា ២០០៧។

### ២. ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា

ការរំលាយកិច្ចសន្យាដែលមានកំណត់ក្នុងកិច្ចសន្យា គឺជាការរំលាយដោយមូលហេតុ ដែលភាគី ***បានកំណត់ជាមុននៅក្នុងកិច្ចសន្យា*** មានន័យថាភាគីម្ខាង ឬ សងខាងអាចរំលាយកិច្ចសន្យាបាន ដោយផ្អែកលើកិច្ចសន្យានោះតែម្តង។

**ឧទាហរណ៍៖** ប្រសិនបើភាគីនៃកិច្ចសន្យា បានធ្វើការព្រមព្រៀងគ្នា នៅក្នុងកិច្ចសន្យាជាមុនថា អ្នកទិញអាចរំលាយកិច្ចសន្យាជាឯកតោភាគី នៅពេលណាក៏បាន ក្នុងរយៈពេលបីសប្តាហ៍ ក្រោយពេលប្រគល់នូវកម្មវត្ថុ ដូច្នេះ អ្នកទិញអាចរំលាយកិច្ចសន្យាបាន តាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

### ៣. ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស

ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេសត្រូវបានកំណត់ ទៅតាមកិច្ចសន្យាសំខាន់នីមួយៗ ដាច់ដោយឡែកពីគ្នា ដូចជា៖ កិច្ចសន្យាលក់ទិញ កិច្ចសន្យាជួល (ភតិសន្យា) និងកិច្ចសន្យាម៉ៅការជាដើម។

**ឧទាហរណ៍៖** នៅក្នុងមាត្រា ៦៦៣ នៃក្រមរដ្ឋប្បវេណីបានបញ្ញត្តថា ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការ បានសម្រេចការងារ។ នេះជាសិទ្ធិរំលាយកិច្ចសន្យារបស់ម្ចាស់ការនៅក្នុងកិច្ចសន្យាម៉ៅការ។[31]

### ៤. ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀង គឺជាការរំលាយកិច្ចសន្យាដោយផ្អែកទៅលើ ឆន្ទៈរបស់គូភាគីទេដែលព្រមព្រៀងគ្នាថ្មី ដែលភាគីទាំងសងខាងមិនបានចែងអំពីការរំលាយនេះ នៅក្នុងកិច្ចសន្យារបស់ខ្លួននៅពេលបង្កើតនោះទេ។

**ឧទាហរណ៍៖** លោក ក បានជួលអគារមួយកន្លែងឲ្យលោក ខ ក្នុងរយៈពេល ៥(ប្រាំ) ឆ្នាំ។ មិនទាន់ដល់រយៈពេល ៥ (ប្រាំ) ឆ្នាំផងលោក ក ក៏ចង់បានអគារនោះមកប្រើប្រាស់វិញ ក្នុងគោលបំណងរបស់ខ្លួនហើយលោក ក បានដាក់សំណើទៅលោក ខ អំពីការរំលាយកិច្ចសន្យាជួលនោះ ដោយយល់ព្រមបង់សំណងខូចខាតទៅកាន់លោក ខ ហើយលោក ខ ក៏បានយល់ព្រម។ ដូចនេះភាគីទាំងពីរបានព្រមព្រៀងគ្នារំលាយកិច្ចសន្យា ដូចនេះការរំលាយកិច្ចសន្យាអាចប្រព្រឹត្តទៅបានដោយមានការព្រមព្រៀងថ្មីរបស់គូភាគីទាំងសងខាង។

ជាទូទៅ ការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀងមានលក្ខណៈខុសគ្នាបន្តិចពី ការរំលាយកិច្ចសន្យាតាមច្បាប់កំណត់ និងរំលាយតាមកិច្ចសន្យា ដោយហេតុថា ការរំលាយកិច្ចសន្យាតាមការព្រមព្រៀងតម្រូវឲ្យមានឆន្ទៈរបស់ភាគីទាំងសងខាង ដោយឡែក ការរំលាយកិច្ចសន្យាតាមច្បាប់កំណត់ និងរំលាយតាមកិច្ចសន្យា អាចធ្វើឡើងដោយឯកតោភាគីបាន។

## ផ្នែកទី២៖ មូលហេតុនៃការរំលាយកិច្ចសន្យា

### កថាភាគទី១៖ កិច្ចសន្យាឯកតោភាគី

កិច្ចសន្យាឯកតោភាគី គឺជាកិច្ចសន្យាដែលបង្កើតកាតព្វកិច្ចចំពោះតែភាគីតែម្ខាងនៃកិច្ចសន្យា។

**ឧទាហរណ៍៖** ដូចជាប្រទានកម្ម ដែលមានចែងនៅក្នុងមាត្រា ៥៦៨ នៃក្រមរដ្ឋប្បវេណី។ ចំពោះកិច្ចសន្យាឯកតោភាគីនេះ គឺមិនចាំបាច់ទទួលស្គាល់ការរំលាយទេ ដោយហេតុថាមានតែភាគីតែម្ខាងទេនៃកិច្ចសន្យាដែលទទួលរ៉ាប់រងកាតព្វកិច្ច។

[31] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៦៦៣។

**កថាភាគទី២៖ កិច្ចសន្យាអញ្ញមញ្ញ**

កិច្ចសន្យាអញ្ញមញ្ញ គឺជាកិច្ចសន្យាដែលភាគីទាំងសងខាងនៃកិច្ចសន្យា មានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជា៖ កិច្ចសន្យាម៉ៅការ កិច្ចសន្យាជួល (ភតិសន្យា) ឬ កិច្ចសន្យាលក់ទំនិញជាដើម។ ជាទូទៅ កិច្ចសន្យាអញ្ញមញ្ញ គឺជាកិច្ចសន្យាដែលបង្កើតឲ្យមានកាតព្វកិច្ចទៅវិញទៅមក (កាតព្វកិច្ចបដិការ) រវាងភាគីទាំងសងខាងនៃកិច្ចសន្យា ពោលគឺភាគីទាំងសងខាងជាម្ចាស់បំណុលផង និងជាកូនបំណុលផង។ នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ការសន្យារបស់ភាគីនៃកិច្ចសន្យាទាំងពីរគឺចំណុះគ្នាទៅវិញទៅមក។ ប្រសិនបើ អ្នកលក់ត្រូវបានសន្យាថានឹងប្រគល់ទំនិញនេះ គឺថាអ្នកលក់ត្រូវទទួលបាននូវតម្លៃ ដែលបានព្រមព្រៀងគ្នា។ ដូចគ្នានេះដែរអ្នកទិញត្រូវតែទូទាត់តម្លៃតែជាថ្លៃថ្នូរនៃការសន្យា នៃការប្រគល់ទំនិញ។ ដូច្នេះ វាកើតមាននូវចំណងគតិយុត្ត រវាងកាតព្វកិច្ច ដែលកើតឡើងពីកិច្ចសន្យាអញ្ញមញ្ញ។ ចំពោះការរំលាយកិច្ចសន្យាអាចធ្វើទៅបាន ចំពោះកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ ដោយសារតែការរំលាយកិច្ចសន្យា គឺជាប្រព័ន្ធដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញអាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួនដោយយកការមិនអនុវត្តកាតព្វកិច្ច របស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុដើម្បីសុំរំលាយកិច្ចសន្យា។

**កថាភាគទី៣៖ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរដោយភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ**

ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។[32] ចំពោះករណី ដែលត្រូវបានចាត់ទុកថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ មានលក្ខណៈដូចខាងក្រោម៖

**១. ការរំលាយកិច្ចសន្យាដោយការដាស់តឿនភាគីមិនអនុវត្តកាតព្វកិច្ច**

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ច តាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឲ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តនៅក្នុងអំឡុងពេលនោះ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាលក់ទិញវត្ថុមួយ ភាគីអ្នកទិញមិនបានបង់ប្រាក់ថ្លៃទិញនៅក្នុងកាលបរិច្ឆេទកំណត់ទេ នោះភាគីអ្នកលក់ត្រូវដាស់តឿនឱ្យភាគីអ្នកទិញអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យមួយ។ នៅក្នុងករណីដែលអ្នកទិញនៅតែមិនអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលសមរម្យ ដែលបានដាស់តឿននោះទេ ភាគីអ្នកលក់អាចរំលាយកិច្ចសន្យានោះបាន។

[32] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៨ ចំណុចទី ១។

### ២. ការរំលាយកិច្ចសន្យាដោយមូលហេតុយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច

ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។[33]

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាលក់ទិញមួយ លោក ក ជាអ្នកទិញ និងលោក ខ ជាអ្នកលក់ហើយ កម្មវត្ថុនៃការលក់ទិញនោះគឺ កុំព្យូទ័រមួយគ្រឿង ក្នុងករណីដែលលោក ក បានបញ្ជាទិញកុំព្យូទ័រនោះពីលោក ខ ក្នុងគោលបំណងយកមកបំពេញការងាររបស់គាត់ ដែលគាត់បានកំណត់ពេលវេលាជាក់លាក់មួយចំពោះលោក ខ។ ដល់ថ្ងៃដែលបានកំណត់ កុំព្យូទ័រនោះ មិនបានប្រគល់ជូនលោក ក ទេ រហូតដល់បីថ្ងៃបន្ទាប់ ទើបបានប្រគល់ជូនលោក ក។ ក្នុងករណីនេះ ហៅថាមានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហើយលោក ក អាចរំលាយកិច្ចសន្យាបានភ្លាមៗ។

### ៣. ការរំលាយកិច្ចសន្យាដោយមូលហេតុអលទ្ធភាពក្នុងការផ្តល់នូវតាវកាលិកចម្បង

ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់នូវតាវកាលិកចម្បងរបស់ខ្លួនបានទេ។[34] ក្នុងករណីនេះ គឺថាខ្លឹមសារនៃតាវកាលិក ដែលកើតចេញពីកិច្ចសន្យានោះមិនបានអនុវត្ត ដោយមានបញ្ហាកើតឡើងនានា។ តាវកាលិកចម្បង គឺជាសកម្មភាពដែលភាគីមិនអាចសម្រេចគោលបំណងនៃកិច្ចសន្យាបាន ប្រសិនបើតាវកាលិកនោះមិនត្រូវបានផ្តល់ឲ្យ។ លើសពីនេះទៅទៀតតាវកាលិកចម្បង ត្រូវសម្រេចដោយផ្អែកលើលក្ខណៈ ឬ ខ្លឹមសារនៃកិច្ចសន្យា និងឆន្ទៈរបស់គូភាគី។

**ឧទាហរណ៍៖** លោក ក ជាអ្នកទិញ និង លោក ខ ជាអ្នកលក់ កម្មវត្ថុនៃការលក់ទិញនោះគឺផ្ទះ ប៉ុន្តែផ្ទះនោះជាប់សិទ្ធិជួលរបស់លោក គ ក្នុងរយៈពេល ១០(ដប់)ឆ្នាំ។ ក្នុងករណីនេះកាតព្វកិច្ចចម្បងរបស់អ្នកលក់គឺផ្ទេរកម្មសិទ្ធិ និងផ្ទេរការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការលក់ទិញនោះ។ ហេតុការណ៍នេះគឺច្បាស់លាស់ហើយថា អ្នកលក់មិនអាចផ្ទេរការកាន់កាប់ទៅឲ្យអ្នកទិញបាន ដូចនេះវាជា ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហើយអ្នកទិញអាចរំលាយកិច្ចសន្យានោះបាន។

### ៤. ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់ជំនឿចិត្តរវាងគូភាគី

ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើឲ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាពេលអនាគតបាន។[35]

[33] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៨ កថាខ័ណ្ឌទី ១ ចំណុច ខ។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៨ កថាខ័ណ្ឌទី ១ ចំណុច គ។

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៨ កថាខ័ណ្ឌទី ១ ចំណុច ឃ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាជួលផ្ទះមួយកន្លែងលោក ក ដែលជាអ្នកជួលផ្ទះ (ភតិកៈ) និងលោក ខ ដែលជាម្ចាស់ផ្ទះ (ភតិបតី)។ លោក ក បានសន្យានឹងលោក ខ ថានឹងបង់ថ្លៃប្រាក់ឈ្នួលផ្ទះនោះក្នុងរយៈពេល ៣(បី)ថ្ងៃ ប៉ុន្តែបីថ្ងៃបានកន្លងផុតទៅលោក ក មិនបានប្រគល់ប្រាក់ឈ្នួលនោះទៅឲ្យលោក ខ ឡើយ គឺទាល់តែ ២០ (ម្ភៃ) ថ្ងៃបន្ទាប់ទៀត ទើបលោក ក បានប្រគល់ ប្រាក់ឈ្នួលនោះទៅឲ្យលោក ខ។ ក្នុងន័យនេះ អាចចាត់ទុកថាជាការបំពានកិច្ចសន្យាដែលមានលក្ខណៈហួសហេតុ ធ្វើឲ្យលោក ខ ដែលជាម្ចាស់ផ្ទះបាត់បង់នូវទំនុកចិត្ត។ ដូចនេះលោក ខ អាចរំលាយកិច្ចសន្យាជួលនោះបាន ដោយមូលហេតុខាងលើ។

**កថាភាគទី៤៖ វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យា**

ការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យានិងត្រូវកើតមានឡើង ប្រសិនបើល័ក្ខខ័ណ្ឌសម្រាប់ការរំលាយកិច្ចសន្យាដែលបានចែងនៅក្នុងមាត្រា ៤០៧ និងមាត្រា ៤០៨ ត្រូវបានបំពេញគ្រប់គ្រាន់ ហើយសិទ្ធិនៃការរំលាយកិច្ចសន្យានេះនិងត្រូវចាប់ផ្តើមដោយទៅលើចំពោះភាគីម្ខាងនៃកិច្ចសន្យា ហើយនឹងត្រូវចាប់ផ្តើមមានអានុភាពនៅពេលដែល ភាគីនេះបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទៅអោយភាគីម្ខាងទៀត។[36] សិទ្ធិរំលាយនៃការរំលាយកិច្ចសន្យាគឺជាសកម្មភាពឯកតោភាគី[37] ដែលត្រូវយកមកអនុវត្តផងដែរ ដោយភាគីម្ខាងនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាដោយខ្លួនឯកឯងបានក្នុងការបង្ហាញឆន្ទៈមួយយ៉ាងពិតប្រាកដ ប៉ុន្តែការបង្ហាញឆន្ទៈក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាត្រូវស្ថិតនៅចាប់ផ្តើមមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈរំលាយបានទៅដល់ភាគីម្ខាងទៀត [38] ហើយភាគីនោះបានទទួលអំពីការជូនដំណឹងនៃការរំលាយកិច្ចសន្យា នោះនាំអោយការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យានឹងត្រូវចាប់ផ្តើមមានអានុភាព។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាពុំបានទទួលអំពីការជូនដំណឹងពីភាគីដែលមានបំណងរំលាយកិច្ចសន្យាទេ នោះកិច្ចសន្យាក៏មិនមានអានុភាពក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាបានដែរ ដូច្នេះគូភាគីនៅតែអនុវត្តកាតព្វកិច្ចរបស់ខ្លួនទៅតាមខល័ក្ខខ័ណ្ឌដែលបានចែងនៅក្នុងកិច្ចសន្យាដូចដើម។

វិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាគឺ ***ភាគីម្ខាង*** ដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យាតាមរយៈការបង្ហាញឆន្ទៈរំលាយចំពោះ***ភាគីម្ខាងទៀត*** បាន ដោយការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅប្រព័ន្ធតុលាការ និង តាមប្រព័ន្ធតុលាការបាន និងមានល័ក្ខខ័ណ្ឌពិសេសមួយចំនួនទៀតដែល ***ភាគីម្ខាង*** មានសិទ្ធអនុវត្តរំលាយកិច្ចសន្យាទៅចំពោះ ***ភាគីម្ខាងទៀត*** ដោយការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកវិញបាន

[36] លោកសាស្ត្រាចារ្យ ហេង បូរ៉ា, "នីតិកាតព្វកិច្ច និង កិច្ចសន្យា," (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៨-២០១៩),ទំព័រ ១២៤។

[37] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៣១២ កថាខណ្ឌទី ១។

[38] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៣១០។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្អង់ និងការរំលាយកិច្ចសន្យាដោយភាគីម្ខាងដែលមានគ្នាច្រើននាក់។[39]

### ១. ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើនៅក្រៅតុលាការបាន ពីព្រោះតែការរំលាយកិច្ចសន្យាគឺជាសកម្មភាពសំខាន់មួយដែលមានប្រទេសខ្លះអនុម័តយកទស្សនៈ ដែលការសំដែងឆន្ទៈរំលាយអាចធ្វើបានតែក្នុងតុលាការដូចជា តាមច្បាប់បារាំង ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា តម្រូវអោយមានសេចក្ដីសម្រេចរបស់តុលាការ។ ដោយឡែក ***ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧*** បានអនុញ្ញាតអោយមានការបង្ហាញឆន្ទៈ រំលាយកិច្ចសន្យានៅក្រៅតុលាការបាន ដោយពិចារណាលើភាពងាយស្រួលនៃការរំលាយដែលជាមធ្យោបាយសង្គ្រោះមួយចំពោះការបំពានកិច្ចសន្យា[40] និងម្យ៉ាងវិញទៀតដោយហេតុថាវាជាការលំបាកក្នុងការសុំអោយតុលាការចេញសេចក្ដីសម្រេចនៅគ្រប់ពេលដែលភាគីម្ខាងមានបំណងរំលាយកិច្ចសន្យា ទោះបីជាភាគីពុំមានវិវាទធ្ងន់ធ្ងរជាមួយភាគីម្ខាងទៀតក៏ដោយ។

ភាគីអាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យានៅក្រៅប្រព័ន្ធតុលាការដោយរួមមាន៖ (១.១) រំលាយតាមកិច្ចសន្យា (១.២) តាមការព្រមព្រៀងគូភាគី (១.៣) តាមសន្ធានកម្ម និង (១.៤) តាមមជ្ឈត្តការ។ គូភាគីនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈ ក្នុងវិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យានៅក្រៅប្រព័ន្ធតុលាការតាមផ្នែកណាមួយ ដោយមិនអោយភាគីណាមួយនៃកិច្ចសន្យាបានរងនូវខូចផលប្រយោជន៍ផ្ទាល់ខ្លួនជាដាច់ខាត។

#### ១.១ ការរំលាយតាមកិច្ចសន្យា

សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយដែលត្រូវបានផ្ដល់អោយទៅភាគីនៃកិច្ចសន្យាក្នុងការរំលាយកិច្ចសន្យាក្នុងករណីដែលបានកំណត់មួយចំនួន ទោះបីជាមិនមានការអនុវត្តកាតព្វកិច្ចក៏ដោយ។ សិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យានេះ ត្រូវបានអនុវត្តតាមការបង្ហាញឆន្ទៈឯកតោភាគីរបស់អ្នកដែលមានសិទ្ធិរំលាយ។ ការរំលាយតាមកិច្ចសន្យានេះ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការរំលាយកិច្ចសន្យាដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចដែលវាជាការរំលាយតាមច្បាប់បានកំណត់។[41]

---

[39] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤០៩។

[40] លោកសាស្ត្រាចារ្យ ហេង បូរ៉ា, ‘‘នីតិកាតព្វកិច្ច និង កិច្ចសន្យា,’’ (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៨-២០១៩),ទំព័រ ១២៤។

[41] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៤១៤។

ដូចនេះសិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាវិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ដែលត្រូវបានផ្ដល់អោយទៅភាគីម្ខាង ឬ ភាគីសងខាងតាមកិច្ចសន្យា ពីព្រោះសិទ្ធិនេះផ្ដល់ដោយកិច្ចសន្យា។[42]

**ឧទាហរណ៍៖** បុរស ក បានចុះកិច្ចសន្យាជួលផ្ទះពីអ្នកស្រី ខ ក្នុងរយៈពេល ២ឆ្នាំ ដោយនៅក្នុងកិច្ចសន្យាជួលផ្ទះនោះ មានខសន្យាដែលចែងថា "ក្នុងស្ថានការណ៍ដែលផ្នែកសេដ្ឋកិច្ចមានការផ្លាស់ប្តូរ ឬក៏ស្ថានការណ៍មួយដែលកើតឡើងមិនអាចទាយទុកមុនបាន នោះភាគីទាំងសងខាងអាចរំលាយកិច្ចសន្យា ដោយធ្វើសេចក្ដីជូនដំណឹងជាមុនរយៈពេល ៣ ខែ"។

ក្នុងករណីនេះ ភាគីដែលពាក់ព័ន្ធទាំងអស់នៅក្នុងកិច្ចសន្យាអាចបង្ហាញឆន្ទៈក្នុងការវិធីអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ដោយតាមរយៈក្នុងការប្រើប្រាស់សិទ្ធិរំលាយតាមកិច្ចសន្យា ហេតុដូច្នេះ មាត្រានេះអាចយកមកអនុវត្តដោយសទិសភាពចំពោះករណីនេះបាន។

### ១.២ តាមការព្រមព្រៀងគូភាគី

សិទ្ធិនៃការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី គឺត្រូវអាស្រ័យទៅតាមខ្លឹមសារនៃការព្រមព្រៀងដែលភាគីមានគោលបំណងរំលាយកិច្ចសន្យា ហេតុដូច្នេះមិនចាំបាច់មានបញ្ញត្តិពិសេស ឬ ក៏ខសន្យានៅក្នុងកិច្ចសន្យាណាមួយឡើយ[43] មានន័យថា ភាគីពាក់ព័ន្ធព្រមព្រៀងគ្នារំលាយកិច្ចសន្យា គឺជាករណីដែលគ្មានការសន្យាជាមុនអំពីសិទ្ធិរំលាយកិច្ចសន្យាទេ ប៉ុន្តែការរំលាយកិច្ចសន្យាត្រូវបានធ្វើឡើងដោយកិច្ចសន្យា និងភាគីអាចព្រមព្រៀងគ្នារំលាយកិច្ចសន្យាបាន។[44]

**ឧទាហរណ៍៖** លោក សំបូរ និង លោក បូរ៉ា បានចុះកិច្ចសន្យាជួលឃ្លាំងមួយ ដោយលោក សំបូរ ជាភតិបតី និងលោក បូរ៉ា ជាភតិកៈ ដោយនៅក្នុងកិច្ចសន្យាជួល គឺមានរយៈពេល ០៤(បួន) ឆ្នាំ ប៉ុន្តែដោយជាអកុសលលោក សំបូរ បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយរងរបួសធ្ងន់មិនអាចដើរ និងធ្វើការបាន ហើយលោកសំបូរបានជួលឃ្លាំងនោះត្រឹមរយៈពេល ០២(ពីរ) ឆ្នាំប៉ុណ្ណោះ បន្ទាប់មកទៀតលោក សំបូរ បានស្នើសុំឈប់ជួលមុនកាលកំណត់ដូចបានចែងនៅក្នុងកិច្ចសន្យា ហើយលោក បូរ៉ា ក៏យល់ព្រម និងបានព្រមព្រៀងគ្នារំលាយកិច្ចសន្យាជួលឃ្លាំងនោះដែលមានរយៈពេល ៤(បួន)ឆ្នាំ។

---

[42] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១៤ កថាខណ្ឌទី ១។

[43] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៤១៤។

[44] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មើលតាមមាត្រា ៤០៩។

ដោយយោងតាមស្ថានភាពនៃអង្គហេតុខាងលើនេះ គឺជាករណីដែលហៅថាការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី។[45]

### ១.៣ តាមសន្ធានកម្ម

វិធីក្នុងការអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ គឺភាគីនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈក្នុងការរំលាយកិច្ចសន្យាតាមសន្ធានកម្មផងដែរ ក្នុងករណីដែលភាគីនៃកិច្ចសន្យាមិនអាចសម្របសម្រួលគ្នាបាន ក្នុងការអនុវត្តសិទ្ធិរំលាយតាមកិច្ចសន្យា និង ការរំលាយកិច្ចសន្យាតាមការព្រមព្រៀងគូភាគី ហេតុដូច្នេះភាគីនៃកិច្ចសន្យាអាចជ្រើសរើសវិធីម្យ៉ាងទៀត ចំពោះភាគីដែលមានបំណងបង្ហាញឆន្ទះក្នុងការរំលាយកិច្ចសន្យាដើម្បីការពារកុំអោយខាតផលប្រយោជន៍រៀងខ្លួន ដែលវិធីការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការនេះគេហៅថា ការរំលាយកិច្ចសន្យាតាមសន្ធានកម្ម។ អ្វីទៅជាសន្ធានកម្ម? តើដំណើរការសន្ធានកម្មមានលក្ខណៈដូចម្តេចខ្លះ? និង តើសន្ធានកម្មអាចដោះស្រាយវិវាទដែលកើតមានឡើងជូនទៅដល់ភាគីនៃជម្លោះបានដែរឬទេ?

សន្ធានកម្មគឺជា ការចរចាដែលមានជំនួយ ឬ ការជួយសម្របសម្រួល នេះសរបញ្ជាក់អោយឃើញថាសន្ធានកម្មត្រូវមានភាគីវិវាទពីរ ឬច្រើន ដែលព្យាយាមចរចាលើដំណោះស្រាយដោយមានជំនួយពីភាគីទីបី ដែលហៅថា សន្ធានការី ដែលត្រូវឈរលើអព្យាក្រឹត្យភាពចំពោះភាគីវិវាទ នឹងរកវិធីដំណោះស្រាយមួយដ៏សមស្របប្រកបដោយភាពយុត្តិធម៌ជូនទៅដល់ភាគីវិវាទ។[46]

ការដោះស្រាយតាមសន្ធានកម្មអាចដោះស្រាយបានគ្រប់វិវាទទាំងអស់ ដែលកើតមានឡើងជូនទៅដល់ភាគីជម្លោះទាំងអស់ដោយរកវិធីដំណោះស្រាយដ៏ល្អមួយ ជូនទៅដល់ភាគីដែលពួកគេមិនអាចព្រមព្រៀងក្នុងប្រការណាមួយបាន។ សន្ធានកម្មនឹងកើតមានឡើង ប្រសិនបើមានកាលៈទេសៈណាមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌទាំងបីដែលកើតមានឡើងដូចជា[47]៖

១) ភាគីមាន ខស្តីពីដំណោះស្រាយវិវាទ នៅក្នុងកិច្ចសន្យាដែលមានស្រាប់របស់ពួកគេ ដែលបានជ្រើសរើសយកមធ្យោបាយសន្ធានកម្មមកប្រើ។

២) ភាគីសម្រេចចិត្តធ្វើសន្ធានកម្ម បន្ទាប់ពីការចរចា ឬក៏ការព្រមព្រៀងមិនត្រូវរ៉ូវគ្នានៅក្នុងវិវាទ។

៣) តុលាការបានបង្គាប់ ឬណែនាំអោយភាគីធ្វើសន្ធានកម្ម។

---

[45] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១៤ កថាខណ្ឌទី ២។

[46] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ៨៣។

[47] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១០៧។

សរុបសេចក្តីមកនៅក្នុងសន្ធានកម្ម ឬ ការសម្រុះសម្រួល ឬក៏ហៅថាសន្ធានការី ដែលជាអ្នកសម្រុះសម្រួល ត្រូវជួយភាគីទាំងឡាយដើម្បីដោះស្រាយវិវាទរបស់ពួកគេផ្ទាល់ ម្យ៉ាងទៀតសន្ធានការីមិនមានអំណាចទៅលើគូភាគីក្នុងការចាប់បង្ខំអោយយកដំណោះស្រាយណាមួយឡើយ។ ផ្ទុយទៅវិញភាគីវិវាទនៅតែមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ ឬមិនចង់ដោះស្រាយក្នុងករណីដែលភាគីវិវាទមិនចង់ដោះស្រាយ ឬ មិនមានការព្រមព្រៀងគ្នា នោះនឹងគ្មានដំណោះស្រាយឡើយទៅភាគីវិវាទ ទោះបីជាមានការខិតខំប្រឹងប្រែងរបស់សន្ធានការីយ៉ាងណាក៏ដោយ។

**ឧទាហរណ៍៖** លោក សំបូរ និង លោក បូរ៉ា បានចុះកិច្ចសន្យាជួលឃ្លាំងមួយដោយលោក សំបូរ ជាភតិបតី និងលោក បូរ៉ា ជាភតិកៈ ដោយនៅក្នុងកិច្ចសន្យាជួលគឺមានរយៈពេល ០៤(បួន) ឆ្នាំ ប៉ុន្តែដោយជាអកុសលលោក សំបូរ បានជួបគ្រោះថ្នាក់ចរាចរណ៍ដោយរងរបួសធ្ងន់មិនអាចដើរ និងធ្វើការបានហើយលោក សំបូរ បានជួលឃ្លាំងនោះត្រឹមរយៈពេល ០២(ពីរ) ឆ្នាំប៉ុណ្ណោះ បន្ទាប់មកទៀតលោក សំបូរ បានស្នើសុំឈប់ជួលមុនកាលកំណត់ដូចបានចែងនៅក្នុងកិច្ចសន្យា ហើយលោក បូរ៉ា មិនយល់ព្រមក្នុងការព្រមព្រៀងគ្នារំលាយកិច្ចសន្យាជួលឃ្លាំងនោះដែលមានរយៈពេល ៤ឆ្នាំទេ ដោយលោក បូរ៉ា បានគិតថាក្នុងករណីដែលរូបលោកព្រមព្រៀងគ្នារំលាយកិច្ចសន្យាជួលរយៈពេល ៤ឆ្នាំ មុនតាមកាលកំណត់រូបលោកនឹងមានការខាតបង់ផលប្រយោជន៍ដ៏ធំ។ ដូច្នេះលោក បូរ៉ា មិនបានព្រមព្រៀងគ្នាក្នុងការរំលាយកិច្ចសន្យា តាមសំណើរបស់លោក សំបូរ បន្ទាប់មកទៀតវិវាទក៏កើតមានឡើងរវាងលោក បូរ៉ា និងលោក សំបូរ ដោយនៅក្នុងកិច្ចសន្យាមិនមានខសន្យាដំណោះស្រាយពីសន្ធានកម្មទេ ប៉ុន្តែភាគីទាំងពីរសម្រេចចិត្តជ្រើសរើសធ្វើតាមសន្ធានកម្ម។

ក្នុងករណីនេះ លោក សំបូរ អាចអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ដោយជ្រើសរើសសិទ្ធិរំលាយកិច្ចសន្យាតាមសន្ធានកម្មមកជំនួសបាន ដោយរូបលោក សំបូរ ត្រូវមានការជ្រើសរើសសន្ធានការីមកជួយជ្រោមជ្រែងនឹងរកវិធីដំណោះស្រាយមួយដែលមានអព្យាក្រឹត្យភាពនៅក្នុងវិវាទដែលកើតមានឡើងនេះ ដោយត្រូវធ្វើការផ្សះផ្សា ចរចា តាមដែលអាចសន្ធានការីធ្វើទៅបាន នឹងគិតថាដំណោះស្រាយមួយនេះគ្មានភាគីណាម្នាក់បានរងនូវការខាតបង់ផលប្រយោជន៍ពីក្នុងកិច្ចសន្យា។

គួរបញ្ជាក់ផងដែរថា នៅក្នុងវិធីដំណោះស្រាយតាមសន្ធានកម្មគឺភាគីវិវាទមានន័យថាលោក សំបូរ និង លោក បូរ៉ា គឺមានសិទ្ធិអំណាចក្នុងការសម្រេចថាតើខ្លួនចង់ទទួលយកដំណោះស្រាយ និងពេញចិត្តដំណោះស្រាយពីសន្ធានការីដែល ឬក៏អត់? ក្នុងករណីដែលលោក សំបូរ និងលោក បូរ៉ា មិនមានការព្រមព្រៀងគ្នា ឬក៏ពេញចិត្តនៅក្នុងដំណោះស្រាយតាមសន្ធានកម្មទេ គឺសន្ធានការីមិនអាចចាប់បង្ខំអោយទទួលយកដំណោះស្រាយរបស់ខ្លួនទេ គឺភាគីនៃវិវាទគឺលោក សំបូរ និង លោក បូរ៉ា អាចមានសិទ្ធិជ្រើសរើសក្នុងការព្រមព្រៀងគ្នាតាមដំណោះស្រាយដែលសន្ធានការីបានលើកឡើងដែរ ឬទេ?

ជាទូទៅសន្ធានកម្ម កើតឡើងបន្ទាប់ពីភាគីវិវាទបានព្យាយាមចរចាគ្នា ប៉ុន្តែមិនអាចរកដំណោះស្រាយមួយបាន។ សម្រាប់សន្ធានកម្មដែលជោគជ័យ ជាទូទៅត្រូវអនុវត្តតាមដំណាក់កាលសំខាន់ៗ មួយចំនួនដូចជា៖ (១.៣.១) ការជ្រើសរើសសន្ធានការី (១.៣.២) ការផ្តល់ពត៌មានដល់សន្ធានការី (១.៣.៣) ការដោះស្រាយវិវាទដោយសន្ធានការី និង (១.៣.៤) ការបិទសន្ធានកម្ម។

### ១.៣.១ ការជ្រើសរើសសន្ធានការី

សន្ធានការីនៅក្នុងសន្ធានកម្ម គឺជាបុគ្គលអព្យាក្រឹត្យម្នាក់ ដែលរងចាំជួយគូភាគីវិវាទនឹងកំណត់អំពីអង្គហេតុដែលកើតមានឡើង ឬ ជួយភាគីអោយចរចាសម្រេចបាននូវដំណោះស្រាយរួមមួយដែលមានមូលហេតុសមស្របដែលអាចទទួលយកបាន ទន្ទឹមនឹងនេះសន្ធានការីមិនមានសិទ្ធិអំណាចក្នុងការបង្ខិតបង្ខំអោយភាគីទទួលយកនូវដំណោះស្រាយរបស់ខ្លួនឡើយ ផ្ទុយទៅវិញសន្ធានការីមានសិទ្ធិក្នុងការស្នើឡើងអោយភាគីនៃវិវាទលើកឡើងនូវមូលហេតុដែលកើតមានឡើង ដើម្បីស្វែងរកនូវដំណោះស្រាយជាប្រយោជន៍សម្រាប់គូភាគីទាំងសងខាង។[48]

សន្ធានការីត្រូវមានអានុភាពចុះសម្រុងជាមួយមនុស្សគ្រប់ប្រភេទទាំងអស់។ លក្ខណៈរបស់សន្ធានការីមានដូចជា៖

- សន្ធានការីត្រូវមានឆន្ទៈក្នុងការស្វែងយល់អំពីចំណុចខ្លាំង និង ចំណុចខ្សោយនៃការទាមទាររបស់ភាគីវិវាទ។
- សន្ធានការីត្រូវតែចេះលើកទឹកចិត្តដល់ភាគីអោយមានជំនឿទុកចិត្តក្នុងការប្រើប្រាស់សន្ធានកម្មដើម្បីដោះស្រាយ ទោះបីជាស្ថានភាពហាក់ដូចជាមិនល្អក៏ដោយ។
- សន្ធានការីត្រូវមានភាពច្នៃប្រឌិតនៅក្នុងការគិតរបស់ខ្លួន ដើម្បីអនុញ្ញាតអោយភាគីពិចារណាអំពីជម្រើសជាច្រើនសម្រាប់ដោះស្រាយ។[49]

នៅមុនពេលការចាប់ផ្តើមដោះស្រាយតាមសន្ធានកម្ម សន្ធានការីត្រូវមានភារកិច្ច ឬ ក៏តួនាទីមួយចំនួនដើម្បីទទួលបានភាពជោគជ័យ។ ភារកិច្ចសន្ធានការីនោះត្រូវមានដូចតទៅ៖

- ត្រូវនៅតែមានភាពអព្យាក្រឹត្យ ទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ។
- ស្តាប់ និងវែកញែកអោយច្បាស់ពីអង្គហេតុដែលកើតមានទៅលើភាគីនីមួយៗ។
- លើកទឹកចិត្តភាគីនីមួយៗអោយស្តាប់ និងពិចារណាអំពីការស្រុះស្រួលគ្នា។

---

[48] ប៉ូលី បញ្ញា. ‘‘នីតិវិនិយោគ,’’ (មេរៀនសម្រាប់ថ្នាក់អនុបណ្ឌិត, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), គ្មានលេខទំព័រ។

[49] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១២៣ ។

- រកដំណោះស្រាយដែលប្រកបដោយគំនិតច្នៃប្រឌិត។
- រកអង្គហេតុ និងអង្គច្បាប់អោយសមស្រប។
- ជួយកាត់បន្ថយនូវភាពតានតឹងរវាងគូភាគីទាំងឡាយ ដោយលើកទឹកចិត្តអោយមានការសហការគ្នា។
- បង្កើតនូវទំនាក់ទំនងរវាងភាគីវិវាទ ប្រសិនបើភាគីទាំងនោះមិននិយាយផ្ទាល់ទៅវិញទៅមក។
- ធ្វើការផ្តល់ពីវិធីប្រាកដនិយម និង សត្យានុម័តសម្រាប់អោយភាគីទាំងឡាយធ្វើការវិភាគទៅលើផលប្រយោជន៍ និងការផ្តល់អោយរបស់ភាគីទាំងនោះ។[50]

សន្ធានការីដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយវិវាទ និងត្រូវបានទទួលស្គាល់ដោយច្បាប់។ សន្ធានការីគឺជា មន្ត្រីមកពីជំនាញខុសគ្នាអាស្រ័យលើបញ្ហានៃជម្លោះដូចជា[51]៖

- ក្រសួងយុត្តិធម៌ គឺមានជំនាញនៅក្នុងជម្លោះគ្រួសារ។
- ក្រសួងការងារ គឺមានជំនាញនៅក្នុងជម្លោះវិវាទការងារ។
- គណៈកម្មាការសុរិយោដី អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី គឺមានជំនាញនៅក្នុងករណីជម្លោះដីធ្លី។
- មជ្ឈមណ្ឌលអាជ្ញាកណ្តាលជាតិ គឺមានជំនាញនៅក្នុងជម្លោះវិវាទពាណិជ្ជកម្ម។
- ក្រុមប្រឹក្សាឃុំសង្កាត់ គឺមានជំនាញនៅក្នុងជំម្លោះស៊ីវិលដូចជាបំណុល និងព្រំដី។

មិនត្រឹមតែប៉ុណ្ណោះ ចៅក្រមក៏ដើរតួនាទីជាសន្ធានការី ប្រសិនបើភាគីណាមួយយកជម្លោះស៊ីវិលទៅដោះស្រាយនៅតុលាការមានន័យថា ចៅក្រមព្យាយាមដោះស្រាយជម្លោះនេះនៅមុនពេលដែលជម្លោះនេះឈានដល់ដំណាក់កាលដោះស្រាយវិវាទតាមផ្លូវច្បាប់។ ក្នុងករណីដែលចៅក្រមមិនអាចសម្រុះសម្រួលបានទេ គឺភាគីជម្លោះអាចដោះស្រាយបន្តទៅតាមមជ្ឈត្តការ និងតាមផ្លូវច្បាប់ ឬក៏ហៅថា តាមផ្លូវតុលាការ។

### ១.៣.២ ការផ្តល់ពត៌មានដល់សន្ធានការី

នៅពេលដែលភាគីបានជ្រើសរើសសន្ធានការីរួចហើយ សន្ធានការីត្រូវត្រៀមរៀបចំខ្លួន និងឯកសារមួយចំនួនដើម្បីសម្រុះសម្រួលបញ្ហានានា ឬក៏ វិវាទដែលកើតមាន។ ដូច្នេះតួនាទីសន្ធានការី ជាដំបូងត្រូវទទួលពត៌មានពីភាគីវិវាទនូវរឿងរ៉ាវទាំងនោះ ហើយត្រូវរក្សាជាការសម្ងាត់ និងមិនប្រាប់ភាគីផ្សេងទៀតទេ។ ចំពោះនៅ

[50] ប៉ូលី បញ្ញា. “នីតិវិនិយោគ,” (មេរៀនសម្រាប់ថ្នាក់អនុបណ្ឌិត, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), គ្មានលេខទំព័រ។

[51] ហេង នីដា, ជា សុគន្ធមិនា, វ៉ាន់ ណារី. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ៖ ប្រទេសកម្ពុជា និង ប្រទេសជប៉ុន.* (ភ្នំពេញ៖ ២០១៦), ទំព័រទី ៥។

ក្នុងករណីដែលភាគីជម្លោះមានវិវាទស្មុគ្រស្មាញ គឺសន្ទានការីអាចស្នើអោយភាគីផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដែលពន្យល់អំពីអង្គហេតុ ដែលនៅក្នុងអង្គហេតុនោះមានការព្រមព្រៀង និងអង្គហេតុដែលមានវិវាទក្នុងការដោះស្រាយតាមផ្លូវច្បាប់ និងភ្ជាប់នូវភស្តុតាង ឬក៏ឯកសារផ្សេងៗដែលគាំទ្រដល់ភាគីនីមួយៗ។

ការផ្តល់ព័ត៌មានដល់សន្ទានការីមុនបែបនេះ គឺសបញ្ជាក់អោយឃើញថាវាមានភាពងាយស្រួលដល់សន្ទានការីក្នុងការដឹកនាំកិច្ចប្រជុំសម្រុះសម្រួលអោយកាន់តែមានប្រសិទ្ធភាពថែមទៀត ដោយសន្ទានការីមិនចាំបាច់មានសំណួរ ឬក៏បញ្ហាពាក់ព័ន្ធជាច្រើនទៅលើនឹងអង្គហេតុ ក្នុងករណីដែលភាគីវិវាទ ឬ ក៏ភាគីជម្លោះបានរៀបចំឯកសារជាលាយលក្ខណ៍អក្សរ នៅបញ្ហាវិវាទដែលកើតមានឡើង ជូនទៅដល់សន្ទានការីអោយពិនិត្យមុនពេលចាប់ផ្តើមធ្វើដោះស្រាយតាមសន្ទានកម្មបានមកដល់។ ជាពិសេស ការធ្វើបែបនេះគឺវាផ្តល់ផលប្រយោជន៍នៅក្នុងសន្ទានកម្ម ដើម្បីមានភាពឆាប់រហ័សក្នុងការដោះស្រាយវិវាទ នឹងរកដំណោះស្រាយអោយមានការព្រមព្រៀងគ្នាឆាប់រហ័សផងដែរដោយមិនមានការចំណាយពេលវេលាយូរ។

នៅមុនពេលដែលសន្ទានការីចាប់ផ្តើមដោះស្រាយតាមសន្ទានកម្ម គឺសន្ទានការីត្រូវជ្រើសរើសកន្លែង ឬក៏ទីតាំងអព្យាក្រឹត្យណាមួយសម្រាប់បើកកិច្ចប្រជុំសម្រុះសម្រួលផងដែរ។ ក្នុងករណីដែលសន្ទានកម្មនោះធ្វើឡើងក្រោមការត្រួតពិនិត្យរបស់មជ្ឈមណ្ឌលសន្ទានកម្មណាមួយ មជ្ឈមណ្ឌលនោះនឹងក្លាយជាទីតាំងសម្រាប់ការដោះស្រាយតាមសន្ទានកម្មតែម្តង ផ្ទុយទៅវិញសន្ទានកម្មក៏អាចធ្វើឡើងនៅ ការិយាល័យច្បាប់របស់សន្ទានការី ការិយាល័យមេធាវី ផ្ទះឯកជន មជ្ឈមណ្ឌលសហគមន៍ ឬក៏កន្លែងរដ្ឋាភិបាលដែលបានគេអនុញ្ញាត ជារួមទៅកន្លែងធ្វើសន្ទានកម្មទីណាក៏បានដែរអោយតែមានជាកសុខភាព និង មិនកន្លែងដែលច្បាប់បានហាមឃាត់ជាដើមហើយផ្តល់ដល់អ្នកចូលរួមនូវភាពជាឯកជន។[52]

### ១.៣.៣ ការដោះស្រាយវិវាទដោយសន្ទានការី

នៅពេលដែលភាគីបានផ្តល់ព័ត៌មានដល់សន្ទានការីអស់ហើយ បូករួមទាំងបានជ្រើសរើសទីតាំងក្នុងការធ្វើសន្ទានកម្មអស់ហើយ និងកំណត់កាលវិភាគនៃការធ្វើសន្ទានកម្មរួចរាល់ផងដែរ នោះការដោះស្រាយវិវាទដោយសន្ទានការីនឹងត្រូវបានចាប់ផ្តើមក្នុង នីតិវិធីនៃសន្ទានកម្មដែលមានដូចជា៖ (ក) ការបើកកិច្ចប្រជុំ (ខ) ការស្តាប់ភាគីជម្លោះទាំងសងខាង (គ) ការបកស្រាយឡើងវិញ និង (ឃ) ការបង្កើតជម្រើស។

#### ក. ការបើកកិច្ចប្រជុំ

នៅពេលដែលដំណើរការបើកកិច្ចប្រជុំ គឺភាគីវិវាទត្រូវជួបជាមួយសន្ទានការីដោយផ្ទាល់។ សន្ទានការីនឹងត្រូវចាប់ផ្តើមដោយអ្នកណែនាំអ្នកចូលរួមអោយស្គាល់គ្នាទៅវិញទៅមកបន្ថែមពីនេះ សន្ទានការីនិងត្រូវរៀបចំ

[52] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១១០។

ឡើងវិញនូវដំណើរការ និងវិធានសម្រាប់កិច្ចប្រជុំ ឆ្លៀតពេលនេះសន្ទានការីក៏ត្រូវពន្យល់អំពីតួនាទីរបស់ខ្លួននៅក្នុងដំណើរការនោះដើម្បីអោយភាគីនីមួយៗ មានការរំពឹងទុកដូចៗគ្នា។

បន្ទាប់ពីនេះគឺសន្ទានការីនឹងត្រូវចាប់ផ្តើមបើកិច្ចប្រជុំជាលើកដំបូង ដោយអោយភាគីនីមួយៗអោយបង្ហាញដំណើររឿងរតាមដែលខ្លួនយល់ឃើញដោយបញ្ជាក់ពី ភស្តុតាង អង្គហេតុ និងអង្គច្បាប់ផងដែរ។ ភាគីនីមួយៗនឹងមានសិទ្ធិក្នុងការបញ្ចេញមតិរៀងខ្លួន និងពន្យល់ផងដែរអំពីផលប្រយោជន៍របស់ខ្លួន ដើម្បីអោយភាគីម្ខាងទៀតដែលកំពុងស្តាប់ និងទទួលបាននូវរឿងរ៉ាវទាំងមូលចេញពីទស្សនៈរបស់ភាគីដែលបានកំពុងថ្លែងនៅក្នុងអំឡុងពេលប្រជុំ។ បន្ទាប់ពីភាគីទីមួយ បានបញ្ចេញមតិចប់រួចហើយនោះភាគីបន្ទាប់ទៀតនឹងថ្លែងមតិនឹងពន្យល់ពីទស្សនៈរបស់ខ្លួនដូចទៅនឹងភាគីទីមួយបានធ្វើដែរ។ ជាមួយគ្នានេះដែរ សន្ទានការីនឹងធ្វើការកត់ត្រាយ៉ាងលម្អិតក្នុងកំឡុងពេលនេះ ដើម្បីធានាថាខ្លួនយល់បានទាំងស្រុងអំពីវិវាទ និងផលប្រយោជន៍ភាគីដែលនៅចំពោះមុខ។ បន្ទាប់ពីភាគីទាំងអស់បានបញ្ចេញមតិថ្លែងរួចហើយអស់ហើយ សន្ទានការីនឹងសុំអោយមានការសម្រាករយៈពេលខ្លី។

បន្ទាប់ពីសំរាកហើយសន្ទានការី និងភាគីវិវាទព្យាយាមស្វែងរកឱកាសដោះស្រាយ ហើយសន្ទានការីនឹងព្យាយាមបំភ្លឺផ្នែកណាដែលមានការព្រមព្រៀងគ្នា និងមិនមានការព្រមព្រៀងគ្នាមានន័យថា សន្ទានការីនឹងជៀសវាងការនិយាយអំពីជំហរ ឬការទាមទារណាដែលពិបាកផ្លាស់ប្តូរ ផ្ទុយទៅវិញសន្ទានការីនឹងសួរអំពីគោលដៅ ការភ័យព្រួយ បំណងប្រាថ្នា និងផលប្រយោជន៍ផ្សេងៗរបស់ភាគី។

### ខ. ការស្តាប់ជម្លោះភាគីទាំងសងខាង

សន្ទានការីត្រូវមានជំនាញក្នុងការស្តាប់ វិភាគ និងវែកញែកអោយបានល្អិតល្អន់ នូវសកម្មភាពចំពោះអ្វីដែលភាគីនិយាយ និងស្វែងរកផលប្រយោជន៍ដ៏សំខាន់ដែលអាចតម្រូវតាមបាននៅក្នុងការព្រមព្រៀងដោះស្រាយ។ ម្យ៉ាងទៀតសន្ទានការីមិនត្រឹមតែធ្វើការស្តាប់នឹងពាក្យសម្តីតែម្យ៉ាងទេ តែសន្ទានការីក៏ត្រូវធ្វើការសង្កេតគ្រប់សកម្មភាពទាំងអស់របស់ភាគីនីមួយៗអោយបានគ្រប់ជ្រុងជ្រោយផងដែរ នឹងមានការវែកញែកវិភាគអោយបានល្អិតល្អន់នូវអ្វីដែលភាគីបានថ្លែង និងបានបញ្ចេញមតិនៅក្នុងកំឡុងពេលប្រជុំ។

### គ. ការបកស្រាយឡើងវិញ

ការបកស្រាយឡើងវិញ គឺជាបច្ចេកទេសមួយដែលបានផ្តល់ទៅអោយសន្ទានការី ដើម្បីនិយាយឡើងវិញនូវពាក្យសម្តីដែលមានភាពខ្វែងគំនិតគ្នា មិនយល់ស្របគ្នាមានន័យថា សន្ទានការីនឹងត្រូវសង្ខេបផលប្រយោជន៍ និងបញ្ហាដើម្បីជំរុញអោយការពិភាក្សាអោយមានទិសដៅកាន់តែមានភាពអព្យាក្រឹត្យ និងវិជ្ជមាន។

ជាគោលការណ៍ការបកស្រាយឡើងវិញនៅក្នុងដំណោះស្រាយវិវាទ មានគោលដៅចម្បងៗចំនួនបីដូចជា[53]៖

១) សម្រាល ឬកាត់បន្ថយភាពប្រទូសរ៉ាយរវាងគ្នា។

២) ផ្លាស់ប្តូរពីការផ្តោតអារម្មណ៍លើជំហរ អោយទៅជាលើផលប្រយោជន៍វិញ។

៣) ផ្លាស់ប្តូរកង្វល់ ឬក៏រអ៊ូរទាំ អោយទៅជាបញ្ហាដែលអាចដោះស្រាយបាន។

ជារួមការបកស្រាយឡើងវិញ គឺដើម្បីស្វែងរកដំណោះស្រាយដែលអាចទទួលយកបាន។ ក្នុងករណីដែលដំណោះស្រាយនោះត្រូវបានរកឃើញថា វាអាចផ្តល់ផលប្រយោជន៍ដល់ភាគីជម្លោះ គឺពេលនោះគេអាចយកដំណោះស្រាយនោះមកធ្វើការដោះស្រាយបាន។ ជាទូទៅដំណោះស្រាយតាមសន្ធានកម្ម គឺគេផ្តល់ឱកាសអោយភាគីនៃជម្លោះជាអ្នកបង្កើត និងស្នើឡើងដំណោះស្រាយខ្លួនឯងតាមដែលអាចធ្វើរួចព្រោះថា ការធ្វើតាមវិធីបែបនេះគឺអាចទទួលបានផលលឿន និងមានភាពស្ថិតស្ថេរជាង។ ក្នុងករណីដែលសន្ធានការីយល់ឃើញថា ភាគីមិនមានលទ្ធភាព ឬមិនមានឆន្ទៈស្នើឡើងនូវដំណោះស្រាយទេនោះ គាត់អាចដើរតួនាទីអោយកាន់តែសកម្មជាងមុនក្នុងការរកដំណោះស្រាយផ្សេងទៀតជូនទៅដល់ភាគី អោយមានភាពអព្យាក្រឹត្យដោយមិនមានភាពលម្អៀងទៅខាងណាមួយ។

### ឃ. ការបង្កើតជម្រើស

ប្រសិនបើភាគីចង់ដោះស្រាយវិវាទដោយជោគជ័យ ពួកគេត្រូវបង្កើតជម្រើសសម្រាប់ផលចំណេញរួម ហើយការបង្កើតជម្រើសនេះ ត្រូវផ្តោតលើផលប្រយោជន៍ដែលប្រហាក់ប្រហែលគ្នាទាំងនោះហើយវាជាចំណុចចាប់ផ្តើមនៃការស្វែងរកដំណោះស្រាយណាមួយហើយសន្ធានការីត្រូវជួយភាគីក្នុងការ បំបែកការបង្កើតជម្រើសអោយដាច់ពីវិនិច្ឆ័យជម្រើស និងព្យាយាមពង្រីកជម្រើសដែលកំពុងពិចារណាជាជាងស្វែងរកចម្លើយតែមួយ មិនត្រឹមតែប៉ុណ្ណោះសន្ធានការីត្រូវស្វែងរកផលចំណេញទៅវិញទៅមក និងគិតអំពីវិធីធ្វើអោយការសម្រេចចិត្តរបស់ភាគីម្ខាងទៀតមានភាពងាយស្រួល។ ក្នុងនាមជាសន្ធានការីត្រូវពង្រីកជម្រើសណាដែល គិតថាវាអាចផ្តល់ផលប្រយោជន៍ដល់ភាគីទាំងសងខាង។

ក្នុងករណីដែលការបង្កើតជម្រើស គឺមានភាគីខាងណាមួយមិនបានសម្រេចចិត្តក្នុងការចូលរួមមិនជ្រើសរើសណាមួយនៃជម្រើសទាំងអស់នោះដោយគិតថាវាអាចមានផលប៉ះពាល់ ឬមិនផ្តល់ផលប្រយោជន៍គឺភាគីនោះអាចស្នើសុំអោយមាន ការជំនួបជាឯកជន ជាមួយសន្ធានការីផ្ទាល់ក្នុងការបរិយាយនូវបញ្ហាទាំងនោះ

[53] ស៊ីវិន អ៊ែម អូស្ទើរមីឡើរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១១៦ និង ១១៧។

ដើម្បីអោយសន្ធានការីអាចរកដំណោះស្រាយផ្សេងទៀត ក្នុងការផ្តល់ផលប្រយោជន៍រួមដោយពុំមានភាគីណាម្នាក់បាត់បង់ ឬក៏ខូចប្រយោជន៍រៀងខ្លួនបានឡើយ។

### ១.៣.៤ ការបិទប្រជុំនៃសន្ធានកម្ម

សន្ធានកម្មនឹងត្រូវបានបញ្ចប់ ដោយមានលទ្ធផលមួយក្នុងចំណោមលទ្ធផលដែលអាចមាន ចំនួន ៣ (បី) ដូចខាងក្រោម[54]៖

១) ភាគីបានឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង។

២) ភាគីមិនឈានដល់ការព្រមព្រៀងគ្នាទាំងស្រុង ប៉ុន្តែនឹងបន្តសន្ធានកម្មនៅពេលក្រោយ។

៣) ភាគីបានឈានទៅដល់ស្ថានភាពជាប់គាំង ហើយសន្ធានកម្មត្រូវបានបញ្ចប់។

ចំពោះក្នុងករណីទី (១) សន្ធានការីនឹងអោយភាគីចុះហត្ថលេខាលើកិច្ចព្រមព្រៀងដោះស្រាយមួយដោយមិនមានការរងចាំទៅថ្ងៃផ្សេង ពីព្រោះភាគីអាចនឹងដូរចិត្តក្នុងប្រការណាមួយបានបើដូរថ្ងៃផ្សេង ឬក៏ទុកពេលយូរជាងនេះក្នុងការចុះហត្ថលេខា ហើយសន្ធានការីនឹងសរសេរនូវចំនុចជាមូលដ្ឋាននៃកិច្ចព្រមព្រៀងនៅចុងបញ្ចប់សម័យប្រជុំដោយរួមជាមួយនឹងហត្ថលេខាភាគី ដែលបានព្រមព្រៀងនៅក្នុងការជ្រើសរើសដំណោះស្រាយនោះ។

ចំពោះក្នុងករណីចំនុចទី (២) សន្ធានការីត្រូវសង្កត់ធ្ងន់លើការរីកចម្រើនដែលបានបង្កើតឡើង និងបង្កើតខសំណើមួយចំនួនសម្រាប់ការពិចារណានានាសម្រាប់កិច្ចប្រជុំលើកក្រោយ។ កិច្ចប្រជុំបន្ទាប់ត្រូវកំណត់កាលបរិច្ឆេទអោយបានឆាប់ ដើម្បីជួយរក្សាភាពជឿនលឿនដែលទទួលបាននៅក្នុងកិច្ចប្រជុំមុន។

ចំពោះក្នុងករណីចំនុចទី (៣) ភាគីណាម្ខាងអាចបញ្ចប់កិច្ចប្រជុំសម្រុះសម្រួលកាន់តែឆាប់ ប្រសិនបើពួកគេមិនមានឆន្ទៈក្នុងការបន្តការពិភាក្សាតទៅទៀត ហើយសន្ធានការីមិនអាចធ្វើអ្វីបានទាំងអស់ក្នុងករណីដែលភាគីណាមួយបដិសេធយ៉ាងដាច់អហង្ការក្នុងការពិភាក្សាតទៅទៀត។ សន្ធានការីក៏អាចអាចជ្រើសរើសយកការបញ្ចប់កិច្ចប្រជុំផងដែរ ប្រសិនបើមិនមានការព្រមព្រៀងណាមួយអាចកើតឡើង។ ទោះបីជាសន្ធានកម្មគឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់ដោះស្រាយ ក៏ទីបំផុតគឺវាអាស្រ័យតែទៅលើភាគីវិវាទខ្លួនឯង ហើយវិវាទនីមួយៗក៏មិនអាចយកមកសម្រុះសម្រួលដោយជោគជ័យដែរ។ ដូចនេះនៅពេលដែលសន្ធានកម្មត្រូវបានបញ្ចប់បែបនេះ ភាគីអាចបន្តវិវាទរបស់ពួកគេនៅក្នុងវេទិកាផ្សេងទៀតដូចជា មជ្ឈត្តការ នឹងក៏អាចបន្តបណ្តឹងទៅតុលាការបានដែរ។[55]

---

[54] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១២១។

[55] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១២២។

### ១.៤ តាមមជ្ឈត្តការ

មុននឹងឈានដល់ការដោះស្រាយតាមរយៈមជ្ឈត្តកម្ម គឺភាគីជម្លោះតែងតែជ្រើសរើសយកការដោះស្រាយតាមកិច្ចសន្យាដែលមានខចែង តាមការព្រមព្រៀង ឬការចរចា និងតាមសន្ធានកម្ម យកមកធ្វើយន្តការដោះស្រាយវិវាទជាមុនសិនព្រោះថា ការព្រមព្រៀង និង សន្ធានកម្ម មានលក្ខណៈងាយស្រួលចំណាយតិច និងចំណេញពេលវេលាព្រមទាំងគោលបំណងរក្សាទំនាក់ទំនងរបស់ភាគីទាំងពីរ។ នៅក្នុងដំណើរការព្រមព្រៀង នឹងសន្ធានកម្មភាគីជម្លោះត្រូវសន្យាធ្វើការចរចា ឬការព្រមព្រៀង និងសន្ធានកម្មជាមុនសិន ហើយប្រសិនបើពួកគេបរាជ័យក្នុងដំណោះស្រាយភាគីនឹងចាប់ផ្តើម ធ្វើមជ្ឈត្តការ ដូចនេះមជ្ឈត្តកម្មនៅតែត្រូវការយកមកធ្វើជាយន្តការក្នុងការដោះស្រាយវិវាទព្រោះការចរចា ឬសន្ធានកម្មមិនមានលក្ខណៈចាប់បង្ខំដល់ភាគីវិវាទទេ ទោះបីជាភាគីទាំងពីរបានព្រមព្រៀងគ្នាហើយក៏ដោយ តែដោយឡែកយន្តការមជ្ឈត្តកម្ម គឺមានលក្ខណៈចាប់បង្ខំទៅដល់ភាគីដែលមិនព្រមគោរព និងអនុវត្តតាមសេចក្តីសម្រេចរបស់មជ្ឈត្តការគឺ មជ្ឈត្តវិនិច្ឆ័យ។ ដូចនេះភាគីវិវាទត្រូវតែធ្វើការចរចា ឬ ការព្រមព្រៀង នឹងសន្ធានកម្មជាមុនសិនមុននឹងឈានដល់មជ្ឈត្តការ។ តើអ្វីទៅជាមជ្ឈត្តការ?

មជ្ឈត្តការ គឺជាការផ្សះផ្សាវិវាទដោយប្រើប្រាស់វេទិកាមជ្ឈត្តកម្មហើយអាចស្ថិតនៅក្នុង ឬនៅក្រៅក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់ស្ថាប័នផ្សះផ្សារអចិន្ត្រៃយ៍[56] មានន័យថាមជ្ឈត្តការ គឺជាស្ថាប័នដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដូចនេះគូភាគីបានព្រមព្រៀងគ្នាដាក់វិវាទរបស់ខ្លួនជូនទៅភាគីទីបី[57] ដែលជាបុគ្គលអព្យាក្រឹត្យមួយដែលហៅថាមជ្ឈត្តករ ឬក្រុមមជ្ឈត្តករ ឬវេទិការមជ្ឈត្តកម្ម ដោយភាគីទីបីនេះត្រូវមានកាតព្វកិច្ច ពិចារណាអំពីភស្តុតាងដែលភាគីវិវាទបានដាក់ជូន និងចេញសេចក្តីសម្រេចហើយត្រូវបានហៅថា មជ្ឈត្តវិនិច្ឆ័យ។ នៅក្នុងដំណើរការមជ្ឈត្តការ ភាគីវិវាទគឺជាអ្នកមានសិទ្ធិក្នុងការជ្រើសរើសនីតិវិធីស្រាប់ដោះស្រាយមជ្ឈត្តករច្បាប់ ដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងពីរ។

#### ១.៤.១ កិច្ចព្រមព្រៀងមជ្ឈត្តការ

ដើម្បីដំណើរការនីតិវិធី នៅក្នុងការដោះស្រាយតាមមជ្ឈត្តការភាគីវិវាទត្រូវមានកិច្ចព្រមព្រៀងផ្សះផ្សារួមមានខចែងស្តីពីមជ្ឈត្តការដែលបានចែងនៅក្នុងកិច្ចសន្យា ឬ ក្នុងកិច្ចព្រមព្រៀងដោយឡែក។[58] នៅពេលដែលបុគ្គលនៃកិច្ចព្រមព្រៀងមជ្ឈត្តការបានព្រមព្រៀងគ្នាធ្វើការដោះស្រាយវិវាទរបស់ខ្លួនដោយមជ្ឈត្តការ នោះមានន័យថា ភាគីទាំងពីរបានព្រមព្រៀងគ្នាជ្រើសយកមជ្ឈត្តការជាយន្តការដោះស្រាយវិវាទរបស់ពួកគេ និងបានបោះសិទ្ធិក្នុងការប្តឹងរបស់ខ្លួនទៅស្ថាប័នតុលាការ។

[56] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ២ ចំនុច ក។
[57] ភាគីទីបីមានន័យថា មជ្ឈត្តករ ឬសាលាក្តីអាជ្ញាកណ្តាល។
[58] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៧។

**ឧទាហរណ៍[59]៖** ខចែងស្តីពីមជ្ឈត្តការរបស់សមាគមមជ្ឈត្តការអាមេរិក

> “រាល់ភាពចម្រូងចម្រាស់ ឬការទាមទារណាមួយដែលកើតចេញពី ឬទាក់ទងនឹងកិច្ចសន្យានេះ ឬការរំលោភនៃកិច្ចសន្យានេះ នឹងត្រូវដោះស្រាយតាមមជ្ឈត្តការ ដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក ស្របតាមវិធានមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (ឬផ្នែកដទៃទៀត) របស់សមាគមនេះហើយសាលក្រមលើមជ្ឈត្តវិនិច្ឆ័យដែលចេញដោយមជ្ឈត្តករ អាចធ្វើឡើងនៅក្នុងតុលាការណាមួយដែលមានយុត្តាធិការក្នុងការងារនេះ” ។

ក្នុងករណីនៃឧទាហរណ៍ខាងលើនេះ គូភាគីបានព្រមព្រៀងគ្នាដោះស្រាយវិវាទរបស់ខ្លួន តាមវិធានមជ្ឈត្តការដែលគ្រប់គ្រងដោយសមាគមមជ្ឈត្តការអាមេរិក។

ចំពោះការដោះស្រាយតាមមជ្ឈត្តការនេះគឺភាគីនៅតែអាចប្តឹងទៅតុលាការបាន ប្រសិនបើភាគីទាំងពីរបានព្រមព្រៀងគ្នាមិនប្តឹងទៅស្ថាប័នមជ្ឈត្តការ ឬកិច្ចព្រមព្រៀងនោះត្រូវបានទុកជាមោឃៈ ឬកម្មវត្ថុនៃវិវាទមិនបានចែងនៅក្នុងកិច្ចព្រមព្រៀងមជ្ឈត្តការ [60] ។ គួរកត់សំគាល់ផងដែរកិច្ចព្រមព្រៀងមជ្ឈត្តការ ត្រូវសរសេរជាលាយលក្ខណ៍អក្សរ ប៉ុន្តែល័ក្ខខ័ណ្ឌតម្រូវនេះអាចបំពេញបានដោយការសរសេរលិខិតឆ្លើយឆ្លងគ្នាទៅវិញទៅមកដែលបង្ហាញអំពីការព្រមព្រៀងទទួលយកការធ្វើមជ្ឈត្តការ។

**ឧទាហរណ៍៖** លោក ប្រាក់ និងអ្នកស្រី មិនា បានផ្ញើរសារគ្នាតាមទូរស័ព្ទដែលបញ្ជាក់ថាពួកគេព្រមព្រៀងគ្នាទទួលយកដំណោះស្រាយវិវាទរបស់ខ្លួនដោយមជ្ឈត្តការក្នុងករណី ដែលកិច្ចសន្យារបស់ពួកគេមានភាគីណាម្ខាងបានបំពាននៅក្នុងកិច្ចសន្យា ប៉ុន្តែពួកគេមិនបានដាក់ខចែងនៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងរបស់ពួកគេទេ ។

ដូចនេះ យោងតាមមាត្រា ៧ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មការផ្ញើរសារបែបនេះក៏អាចចាត់ទុកថា មានភាពគ្រប់គ្រាន់ក្នុងការធ្វើកិច្ចព្រមព្រៀងទទួលយកដំណោះស្រាយដោយមជ្ឈត្តការបាន។ នៅពេលដែលមានកិច្ចព្រមព្រៀងក្នុងការដោះស្រាយតាមយន្តការមជ្ឈត្តការរួចមកហើយគឺ ភាគីនៃវិវាទ និងមជ្ឈត្តករ ឬក៏ភាគីទីបីអាចចាប់ផ្តើមនីតិវិធីនៃមជ្ឈត្តកម្ម ឬក៏ដំណើរការមជ្ឈត្តការបានហើយ។

### ១.៤.២ ដំណើរការមជ្ឈត្តការ

មុននឹងឈានដល់ការដោះស្រាយវិវាទតាមមជ្ឈត្តការគឺភាគី នៃជម្លោះត្រូវអនុវត្តវិធានសំខាន់ៗមានដូចជា៖ (ក) ដាក់ពាក្យបណ្តឹង (ខ) ការជ្រើសរើសមជ្ឈត្តករ (គ) ទីកន្លែងធ្វើមជ្ឈត្តការ និង (ឃ) ភាសា មុននឹងឈានដល់ការដោះស្រាយវិវាទតាមមជ្ឈត្តការ។

---

[59] ស្មីរិន អ៊ែម អូស្មើរមីឡឺរ៍. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១២៥។

[60] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៨។

### ក. ការដាក់ពាក្យបណ្តឹង

នៅពេលមានវិវាទភាគីណាមួយនៃកិច្ចព្រមព្រៀងមជ្ឈត្តការអាចធ្វើការប្តឹងទៅមជ្ឈត្តការបាន ដោយសំអាងទៅលើកិច្ចព្រមព្រៀងមជ្ឈត្តការនោះ។ [61] ភាគីដែលបានដាក់ពាក្យបណ្តឹងទៅមជ្ឈត្តការ គេហៅថាភាគីប្តឹង ហើយភាគីដែលទទួលសំណើគេហៅថា ភាគីឆ្លើយតប។ បន្ទាប់មកទៀតភាគីឆ្លើយតបត្រូវធ្វើពាក្យដោះសាររបស់ខ្លួនដែលឆ្លើយតបទៅនឹងចំនុចដែលបានលើកឡើងនៅក្នុងបណ្តឹងទាមទារ ព្រមទាំងត្រូវភ្ជាប់ឯកសារពាក់ព័ន្ធ និងបណ្តឹងតបដែលខ្លួនមានផងដែរ។[62]

### ខ. ការជ្រើសរើសមជ្ឈត្តករ

ក្រោយពេលដាក់បណ្តឹងទាមទាររបស់ភាគីប្តឹងហើយ ភាគីវិវាទត្រូវជ្រើសរើសវេទិកាមជ្ឈត្តកម្ម។ ភាគីវិវាទមានសេរីភាពក្នុងការកំណត់ចំនួនមជ្ឈត្តករ ប៉ុន្តែចំនួននោះត្រូវតែជាចំនួនដែលសេស។ ក្នុងករណីគ្មានការកំណត់បែបនេះ មជ្ឈត្តករត្រូវតែមានចំនួន ៣(បី)នាក់។ [63] ក្នុងករណីដែលភាគីវិវាទមិនបានកំណត់ចំនួននៃមជ្ឈត្តករទេនោះមជ្ឈត្តករត្រូវបានកំណត់ថាមានចំនួន ៣(បី)នាក់។ [64] គួរបញ្ជាក់ផងដែរថាក្នុងការតែងតាំងមជ្ឈត្តករ ត្រូវពិចារណាលើលក្ខណៈសម្បត្តិរបស់មជ្ឈត្តករដែលមានចែងក្នុងកិច្ចព្រមព្រៀងរបស់ភាគីវិវាទ ដើម្បីធានាដល់ការជ្រើសតាំងមជ្ឈត្តករដែលឯករាជ្យ និងមិនលម្អៀង ហើយត្រូវពិនិត្យលើសញ្ជាតិរបស់មជ្ឈត្តករ និងសញ្ជាតិភាគីវិវាទ។[65]

### គ. ទីកន្លែងធ្វើមជ្ឈត្តការ

ការជ្រើសរើសយកទីកន្លែងណាមួយក្នុងការធ្វើដំណើរការមជ្ឈត្តការ គឺជាការព្រមព្រៀងរបស់ភាគីវិវាទ ប៉ុន្តែក្នុងករណីភាគីវិវាទមិនបានព្រមព្រៀងគ្នាទេនោះ ទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការ គឺធ្វើឡើងនៅភ្នំពេញ។[66] ប៉ុន្តែទីកន្លែងធ្វើមជ្ឈត្តការអាចធ្វើឡើងផ្សេងពីនេះ ប្រសិនបើកាលៈទេសៈនៃសំណុំរឿងតម្រូវដូចជាភាពងាយស្រួលក្នុងការពិនិត្យភស្តុតាង ការស្តាប់សាក្សី ឬអ្នកជំនាញជាដើម។

**ឧទាហរណ៍៖** លោក បូរី មានទីលំនៅឋាននៅកំពង់ចាម និង លោក ដារ៉ូ មានទីលំនៅឋាននៅកំពង់ចាមដូចគ្នា ហើយកម្មវត្ថុដែលជាវិវាទក៏ស្ថិតនៅទីរួមខេត្តនោះដែរ ដូច្នេះទីកន្លែងសម្រាប់ធ្វើមជ្ឈត្តការត្រូវធ្វើឡើងក្នុងខេត្តកំពង់ចាមដូចគ្នាដែរ។

---

[61] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៨។

[62] វិធានមជ្ឈត្តការ UNCITRAL, មាត្រា ១៩។

[63] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ១៨។

[64] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, វិធាន ៩។

[65] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ១៩ កថាខណ្ឌទី ៣ ៤ និង៥។

[66] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, វិធាន ១៦។

### ឃ. ភាសា

ភាគីវិវាទអាចព្រមព្រៀងលើភាសាណាមួយ ឬលើសពីមួយ ដែលត្រូវប្រើប្រាស់ក្នុងដំណើរការធ្វើមជ្ឈត្តការ។ ក្នុងករណីគ្មានការឯកភាពលើភាសាទេ វេទិកាមជ្ឈត្តកម្មត្រូវកំនត់ភាសាណាមួយ ឬលើសពីមួយសម្រាប់ប្រើប្រាស់ក្នុងដំណើរមជ្ឈត្តការ។ វេទិការមជ្ឈត្តកម្មអាចបង្គាប់អោយមានការបកប្រែ ភ្ជាប់ជាមួយនឹងឯកសារភស្តុតាង ដោយប្រើប្រាស់ភាសាណាមួយ ឬ លើសពីមួយដែលបានឯកភាពដោយភាគីវិវាទ ឬដែលបានកំណត់ដោយវេទិកាមជ្ឈត្តកម្ម។[67]

ក្រោយពីបានដឹងពីទីកន្លែងក្នុងការដោះស្រាយវិវាទតាមរយៈមជ្ឈត្តការ និងបានដាក់ពាក្យបណ្ដឹង ព្រមទាំងជ្រើសរើសភាសា និងចំនួនមជ្ឈត្តកររួចហើយ នោះនីតិវិធីនៃការដោះស្រាយនឹងមានការកើតឡើង។ ជាទូទៅដំណើរការមជ្ឈត្តការតម្រូវអោយមានសវនាការមួយ ដែលស្រដៀងគ្នាទៅនឹងការដំណើរការជំនុំជម្រះដូចទៅក្នុងតុលាការដែរ។ នៅក្នុងសវនាការភាគីវិវាទតែងតែធ្វើសេចក្ដីថ្លែងបើក ដែលបញ្ជាក់អំពីអង្គហេតុ និងអង្គច្បាប់។ បន្ទាប់មកភាគីប្ដឹងធ្វើការបង្ហាញសាក្សី និងឯកសារជាភស្តុតាងរបស់ខ្លួន។ សាក្សីត្រូវធ្វើការស្បថស្បែដូចនៅក្នុងដំណើរការកាត់ក្ដីដែរ។ បន្ទាប់មកភាគីប្ដឹង ឬមេធាវីរបស់ខ្លួន នឹងសួរសំនួរដល់សាក្សីដែលមានវត្តមានដោយផ្ទាល់នៅចំពោះមុខវេទិកាមជ្ឈត្តកម្ម។ ពេលខ្លះវេទិកាមជ្ឈត្តកម្មនឹងសួរសំនួរបន្ថែម ដែលស្រដៀងគ្នាទៅនឹងចៅក្រមនៅក្នុងតុលាការនៃរឿងក្ដីរដ្ឋប្បវេណីផងដែរ។ ភាគីឆ្លើយតបក៏មានសិទ្ធិលើកជាសំនួរសួរទៅសាក្សីរបស់ភាគីប្ដឹងដែរ។ ក្រោយពេលភាគីប្ដឹងបានបង្ហាញនូវភស្តុតាងទាំងអស់រួច ភាគីឆ្លើយតបនឹងមានឱកាសបង្ហាញសាក្សីនិងឯកសារជាភស្តុតាងរបស់ខ្លួនវិញម្ដង។ ជាថ្មីម្ដងទៀតវេទិកាមជ្ឈកម្ម និងភាគីប្ដឹងក៏អាចសួរសំណួរទៅសាក្សីទាំងនោះបានដែរ។ បន្ទាប់មកទៀត គូភាគីនឹងផ្លាស់ប្ដូរវេនគ្នាធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ ហើយបន្ទាប់មកទៀត វេទិកាមជ្ឈត្តកម្មនឹងពិភាក្សាដើម្បីសម្រេចរឿងក្ដីនេះ។[68]

សវនការមជ្ឈត្តការមានលក្ខណៈ មិនផ្លូវការជាងដំណើរការកាត់ក្ដីនៅតុលាការដោយសារតែ នីតិវិធី និងភស្តុតាងមានភាពទន់ភ្លន់ជាងនៅក្នុងតុលាការ។ ប៉ុន្តែនៅក្នុងការវេទិកាមជ្ឈត្តការមាន ២ នីតិវិធីសម្រាប់អោយភាគីជម្លោះសម្រេចចិត្តក្នុងការជ្រើសរើស។ ក្នុងករណីគ្មានការព្រមព្រៀងពីនិតិវិធីនេះ វេទិកាមជ្ឈត្តកម្មអាចចាត់ចែងការធ្វើមជ្ឈត្តការទៅតាមបែបណាដែលវេទិកាយល់ឃើញថាសមស្រប ដោយអនុលោមតាមបទប្បញ្ញត្តិ

[67] វិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, មាត្រា ៣០។ និងវិធានស្ដីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, វិធាន ១៨.១ និង១៨.២។

[68] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១៧៦។

នៃច្បាប់នេះ។ នីតិវិធី ក្នុងការដោះស្រាយវិវាទមាន ២(ពីរ)គឺ៖ សវនការដោយផ្ទាល់មាត់ និងដំណើរការមជ្ឈត្តការដោយផ្អែកលើឯកសារផ្សេងៗជាភស្តុតាង។[69]

ដំណើរការមជ្ឈត្តការដោយផ្អែកឯកសារផ្សេងៗជាភស្តុតាង ត្រូវបានជ្រើសរើសជានីតិវិធីក្នុងការដោះស្រាយវិវាទនោះវេទិការមជ្ឈត្តការគឺធ្វើការពិនិត្យ និងសម្រេចតែទៅលើភស្តុតាង ដែលភាគីវិវាទដាក់ជូនអោយពិនិត្យប៉ុណ្ណោះ។ តែបើក្នុងករណីធ្វើឡើងដោយសវនការដោយផ្ទាល់មាត់ត្រូវបានជ្រើសរើសជានីតិវិធីក្នុងការដោះស្រាយវិញនោះ វេទិការមជ្ឈត្តការត្រូវរៀបចំអោយមានសវនការ ដែលនីតិវិធីធម្មតានៃសវនការមជ្ឈត្តការមានភាពដូចគ្នាជាមួយនឹងនីតិវិធីនៅតុលាការដែរ។[70]

នៅក្រោយពេលវិវាទត្រូវបានដោះស្រាយ នីតិវិធីបន្ទាប់គឺការចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។

### ១.៤.៣ ការចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ

បន្ទាប់ពីនីតិវិធីសវនការត្រូវបានបញ្ចប់ នោះមជ្ឈត្តករត្រូវចេញសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ។ ក្នុងការធ្វើមជ្ឈត្តវិនិច្ឆ័យវេទិកាមជ្ឈត្តកម្មត្រូវ សម្រេចពីវិវាទមួយទៅតាមវិធាននៃច្បាប់ ដែលជ្រើសរើសដោយភាគីវិវាទ និងដែលអនុវត្តបានចំពោះកម្មវត្ថុនៃវិវាទនោះ។ ការកំណត់យកច្បាប់ ឬ ប្រព័ន្ធច្បាប់នៃប្រទេសណាមួយដែលត្រូវយកទៅបកស្រាយ គឺមិនត្រូវបកស្រាយដោយសំអាងលើភាពផ្ទុយនៃច្បាប់ ឬវិធាននៃច្បាប់នោះឡើយ វៀរលែងតែមានការបញ្ជាក់ផ្សេងពីនេះ។[71] មជ្ឈត្តករត្រូវប្រើប្រាស់ច្បាប់ណាដែលយល់ថាអាចអនុវត្តបាន ក្នុងករណីដែលភាគីវិវាទមិនបានធ្វើការកំណត់លើប្រព័ន្ធច្បាប់ទេនោះ។ ក្នុងដំណើរការមជ្ឈត្តការដែលមានមជ្ឈត្តករលើសពីមួយនាក់ មជ្ឈត្តវិនិច្ឆ័យរបស់វេទិកាមជ្ឈត្តកម្ម ត្រូវធ្វើឡើងតាមមតិភាគច្រើនដោយរបៀបនៃមជ្ឈត្តករដែលជាសមាជិកនៃវេទិកាមជ្ឈត្តកម្ម។[72] ក្នុងការចេញនូវមជ្ឈត្តវិនិច្ឆ័យនេះវេទិកាមជ្ឈត្តការត្រូវធ្វើ[73]៖

១) ធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយសម្លេងភាគច្រើននៃមជ្ឈត្តករ។

២) បញ្ជាក់អំពីហេតុផលដែលចេញមជ្ឈត្តវិនិច្ឆ័យយោងតាម។

៣)បែងចែកក្នុងចំណោមភាគីវិវាទនូវថ្លៃចំណាយលើមជ្ឈត្តការតាមដែលវេទិកាមជ្ឈត្តកម្មយល់ថាសមស្របលើកលែងតែភាគីវិវាទមានការព្រមព្រៀងគ្នាផ្សេងពីនោះ។

៤) បញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងធ្វើមជ្ឈត្តការ។

---

[69] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, វិធាន ២៤។

[70] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៣២។

[71] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៣៦ កថាខណ្ឌទី ៦ និងទី២។

[72] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៣៧។

[73] ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២ (ប្រទេសកម្ពុជា,២០១០), ទំព័រទី ១៧៨។

៥) ភាគីនីមួយៗ ត្រូវទទួលបានមជ្ឈត្តវិនិច្ឆ័យដែលមានចុះហត្ថលេខាមួយច្បាប់។

ដូចនេះ មជ្ឈត្តករ បានចេញនូវសេចក្តីសម្រេចមជ្ឈត្តវិនិច្ឆ័យ វេទិកាមជ្ឈត្តការកំណត់ចេញតែមជ្ឈត្តវិនិច្ឆ័យដែលជាភាសាខ្មែរ ឬភាសាអង់គ្លេសតែប៉ុណ្ណោះ។[74]

**១.៤.៤ ការប្ដឹងឧបាស្រ័យទៅនឹងសេចក្ដីសម្រេចមជ្ឈត្តវិនិច្ឆ័យ**

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦ មជ្ឈត្តវិនិច្ឆ័យមិនអាចប្តឹងជំទាស់បានឡើយលើកលែងតែនៅក្នុងកាលៈទេសៈដែលរឹតត្បិតបំផុត។ តែទោះជាយ៉ាងនេះក្តីបញ្ញាត្តិនៃច្បាប់បានកំណត់នូវល័ក្ខខ័ណ្ឌមួយចំនួនដែលភាគីអាចធ្វើការប្តឹងតវ៉ានឹងសេចក្តីសម្រេចនោះ។ ភាគីវិវាទអាចប្តឹងជំទាស់ទៅនឹងមជ្ឈត្តវិនិច្ឆ័យតាមទ្រង់ទ្រាយជាបណ្តឹងបដិសេធ និងតាមបែបបដូចខាងក្រោម៖

១) ភាគីវិវាទអាចប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់មជ្ឈត្តការបានតែចំពោះដំណើរការនៃវិវាទមជ្ឈត្តការបានធ្វើខុសនឹងនីតិវិធីដែលភាគីបានកំណត់ក្នុងកិច្ចព្រមព្រៀង ឬ ផ្ទុយនឹងបញ្ញាត្តិនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម។[75]

២) ការប្តឹងជំទាស់នឹងដំណើរការមជ្ឈត្តការអាចត្រូវធ្វើឡើង បើភាគីណាមួយនៃវិវាទបានបាត់បង់សិទ្ធិមួយចំនួនដូចជាការតែងតាំងមជ្ឈត្តករ ឬមិនបានទទួលដំណឹងពីដំណើរការមជ្ឈត្តការ ឬកិច្ចព្រមព្រៀងមជ្ឈត្តការនោះពុំអាចយកជាការបាន ឬ កម្មវត្ថុនៃវិវាទ ពុំអាចដោះស្រាយតាមរយៈមជ្ឈត្តការបាន ឬដំណើរការនៃមជ្ឈត្តការមិនស្របតាមកិច្ចព្រមព្រៀងរបស់ភាគី ឬមជ្ឈត្តវិនិច្ឆ័យផ្ទុយនឹងនយោបាយសាធារណៈជាដើម។[76]

ភាគីវិវាទអាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ជាលាយលក្ខណ៍អក្សរ និងភស្តុតាងដែលបង្ហាញពីកំហុសឆ្គងនៃនីតិវិធីរបស់វេទិកាមជ្ឈត្តការ ដើម្បីអោយសាលាឧទ្ធរណ៍ធ្វើការពិនិត្យនឹងសម្រេចលើបណ្តឹងទាស់នេះក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីនោះបានទទួលមជ្ឈត្តវិនិច្ឆ័យ។ ក្រោយពីសាលាឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើបណ្តឹងទាស់នោះហើយ ក្នុងករណីដែលភាគីមិនពេញចិត្តទៀត គឺភាគីវិវាទអាចធ្វើការប្តឹងបន្តទៅតុលាការកំពូលក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ហើយសេចក្តីសម្រេចរបស់តុលាការកំពូលនេះហើយជាសេចក្តីសម្រេចចុងក្រោយបង្អស់។[77]

---

[74] វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤, វិធាន ១៨.៣។

[75] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៤៤។

[76] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៤៤ កថាខណ្ឌទី២។

[77] ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ០៦ មីនា ២០០៦, មាត្រា ៤៤។

## ២. ការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការ

វិធីអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាគឺជាការបង្ហាញឆន្ទៈរបស់ភាគីម្ខាងទៅម្ខាងទៀត[78] ការរំលាយកិច្ចសន្យា មិនត្រូវការអន្តរាគមន៍របស់តុលាការនោះទេ ហើយប្រសិនបើភាគីបានស្នើសុំអោយតុលាការចេញសាលក្រមរំលាយកិច្ចសន្យាជាអាទ៍ ខ្លឹមសារនៃការទាមទារនេះត្រូវបានចាត់ទុកថា គ្មានផលប្រយោជន៍នៃបណ្តឹង។ បណ្តឹងអាចធ្វើទៅបានក្នុងករណីដែលបណ្តឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្តែង និងដែលវិវាទនោះអាចដោះស្រាយដោយសាលក្រម [79] ហើយកាលណាគ្មានផលប្រយោជន៍នៃបណ្តឹង នឹងនាំអោយការចេញសាលក្រមលើកចោលបណ្តឹងមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។[80]

តែបើក្នុងករណីដែលភាគីបានបង្ហាញឆន្ទៈតាមផ្លូវតុលាការរួចហើយ ដូចជា មានកិច្ចព្រមព្រៀងក្នុងការដោះស្រាយតាមផ្លូវតុលាការ ឬក៏មានខចែងនៅក្នុងកិច្ចសន្យាក្នុងការដោះស្រាយតាមផ្លូវតុលាការនោះ អន្តរាគមន៍របស់តុលាការមានភាពចាំបាច់ដើម្បីសម្រេចគោលបំណងអោយមានលក្ខណៈជាសត្យានុម័ត។ នោះការរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការនឹងមានការកើតឡើងតាម (២.១) ការធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា (២.២) ការប្រកាសចេញសាលក្រម និង (២.៣) និង ការជួសជុលការខូចខាត។

### ២.១ ការធ្វើបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលខុសត្រូវតាមកិច្ចសន្យា

ការសរសេរពាក្យបណ្តឹងអោយបានត្រឹមត្រូវតាមនីតិវិធី គឺមានភាពចាំបាច់ខ្លាំងណាស់សម្រាប់មេធាវី ជាអាទ៍ ក្នុងការអនុវត្តសិទ្ធិរបស់ភាគីនៅចំពោះមុខតុលាការ ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ។ ការប្តឹងគឺជាសកម្មភាពមួយដែលទាមទារអោយមានការបំពេញតាមល័ក្ខខ័ណ្ឌច្បាប់ អោយបានជាក់លាក់មួយជាកំណត់ដែលតម្រូវអោយដើមចោទសរសេរបញ្ជាក់អោយបានច្បាស់លាស់ពីអង្គហេតុ និងមូលហេតុបញ្ជាក់ពីការទាមទារអោយតុលាការចេញសាលក្រម និងត្រូវដាក់ពាក្យបណ្តឹងទៅតុលាការចាំបាច់។ ពាក្យបណ្តឹងត្រូវសរសេរតាមទម្រង់ដូចជា[81]៖

១) ការប្តឹង ត្រូវធ្វើជាលាយលក្ខណ៍អក្សរតាមរយៈការដាក់ពាក្យបណ្តឹងទៅតុលាការ។

២) នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់នូវចំនុចដូចខាងក្រោម[82]៖

ក/ ឈ្មោះ ឬនាមករណ៍ និងអាស័យដ្ឋានភាគី ហើយឈ្មោះ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

---

[78] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៩ កថាខណ្ឌទី ១។

[79] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មើលមាត្រា ៧៤។

[80] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មើលមាត្រា ៨១។

[81] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មើលមាត្រា ៧៥។

[82] សូមមើលគំរូនៃពាក្យបណ្តឹងនៅក្នុង ឧបសម្ព័ន្ធទី៣។

ខ/ ខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារអោយតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ។

៣) នៅក្នុងពាក្យបណ្តឹង ក្រៅពីចំណុចដែលបានកំណត់នៅក្នុងចំនុច ខ នៃកថាខណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរបញ្ជាក់អោយបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងតាមចំនុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុទាមទារ និងភស្តុតាង។

៤) ពាក្យបណ្តឹងដែលសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួនត្រូវចាត់ទុកជាឯកសារត្រៀមផងដែរ។

នៅពេលពាក្យបណ្តឹងបានបំពេញត្រឹមត្រូវតាមល័ក្ខខ័ណ្ឌទម្រង់ហើយ តុលាការនឹងបញ្ជូនពាក្យបណ្តឹងទៅចុងចម្លើយ ហើយចុងចម្លើយត្រូវធ្វើឯកសារចម្លើយដើម្បីឆ្លើយតបជាមួយនឹងពាក្យបណ្តឹងនោះ។[83] ឯកសារចម្លើយ គឺជាប្រភេទមួយនៃឯកសារត្រៀមដែលភាគីចុងចម្លើយត្រូវដាក់មកតុលាការ ដើម្បីឆ្លើយតបនឹងការទាមទាររបស់ដើមចោទ។ ឯកសារចម្លើយ ជាឯកសារដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូងដើម្បីឆ្លើយតបចំពោះពាក្យបណ្តឹង ហេតុនេះនៅក្នុងឯកសារចម្លើយត្រូវឆ្លើយតបនឹងខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារអោយតុលាការចេញ ហើយការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលជាមូលហេតុនៃការទាមទារដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងអង្គហេតុតវ៉ាចំពោះអង្គហេតុ ដែលមានសរសេរនៅក្នុងពាក្យបណ្តឹង និងភស្តុតាង។[84]

នៅពេលដែលចុងចម្លើយបានធ្វើឯកសារចម្លើយ ដើម្បីឆ្លើយតបនឹងពាក្យបណ្តឹងរបស់ដើមចោទ ហើយបានដាក់មកតុលាការ តុលាការនឹងបញ្ជូនឯកសារចម្លើយនោះទៅដើមចោទ ដើម្បីអោយដើមចោទធ្វើការការពារខ្លួន ដែលគេអាចហៅថា មធ្យោបាយការពារខ្លួន[85] ហើយការឆ្លើយតបនោះថា ឯកសារត្រៀមលើកទី១ របស់ដើមចោទ ។

ចំពោះឯកសារត្រៀមលើកទី១ របស់ដើមចោទត្រូវបំពេញនូវចំនុចសារជាតុមួយចំនួនដូចជា ការទទួលស្គាល់ ឬមិនទទួលស្គាល់ចំពោះអង្គហេតុដែលមានកំណត់ក្នុងឯកសារចម្លើយ និងការអះអាងអង្គហេតុតវ៉ាតបក្នុងករណីដែលឯកសារចម្លើយមានអង្គហាតុតវ៉ា។[86] នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់ហើយ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលយ៉ាងរហ័ស និងកោះហៅគូភាគី។ កាលបរិច្ឆេទ

[83] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មើលមាត្រា ១០១។

[84] អ៊ីវ ប៉ូលី. ទេព បូផល. *ការសរសេរពាក្យបណ្តឹង និង សាលក្រម*. (ភ្នំពេញ៖ ២៩ សីហា ២០២០), ទំព័រទី ១១។

[85] មធ្យោបាយការពារខ្លួន គឺជាឯកសារទាំងឡាយដែលចុងចម្លើយបានដាក់ជូនទៅតុលាការ ដើម្បីបញ្ជាក់ថាការទាមទាររបស់ដើមចោទពុំមានមូលហេតុត្រឹមត្រូវ ឬជាឯកសារត្រៀមតបរបស់ចុងចម្លើយ។

[86] សូមមើលគំរូនៃឯកសារចម្លើយនៅក្នុង ឧបសម្ព័ន្ធទី៤។

នេះត្រូវបានកំណត់ក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស។[87]

## ២.២ ការប្រកាសចេញសាលក្រម

នៅក្នុងពាក្យបណ្តឹងដើមចោទត្រូវសរសេរបញ្ជាក់អោយបានច្បាស់លាស់អំពីគោលបំណង នឹងខ្លឹមសារនៃសាលក្រមដែលទាមទារអោយតុលាការសម្រេចសេចក្តីបញ្ចប់ចុងក្រោយ មាននន័យថាការបញ្ជាក់ និងការអះអាងអំពីសិទ្ធិរបស់ដើមចោទដែលកើតមានចំពោះខ្លួនតាមបណ្តឹង ហើយធ្វើអោយតុលាការមានភាពងាយស្រួលអំពីកំណត់ព្រំដែននៃសិទ្ធិ និងមានភាពងាយស្រួលដល់តុលាការក្នុងការសម្រេចសេចក្តីចេញសាលក្រម បើចេញសាលក្រម ហើយមិនមានភាពមិនច្បាស់លាស់អាចមានផលវិបាកកើតឡើងទៅថ្ងៃអនាគត នៅពេលអនុវត្តសាលក្រមស្ថាពរដោយបង្ខំ។

តើខ្លឹមសារនៃសាលក្រម (កម្មវត្ថុនៃបណ្តឹង) ដែលដើមចោទទាមទារអោយតុលាការចេញ និង ដាក់អោយចុងចម្លើយអនុវត្តមានអ្វីខ្លះ? មានដូចជាៈ

១/ ឱ្យចុងចម្លើយប្រគល់ប្រាក់ចំនួន.................ដុល្លារ គិតជាប្រាក់រៀលចំនួន..............និងការប្រាក់.............% ឱ្យដើមចោទគិតតាមកិច្ចសន្យាពីថ្ងៃ.................តទៅ។

២/ ឱ្យចុងចម្លើយសងប្រាក់មេធាវីចំនួន.............ដុល្លារ គិតជាប្រាក់រៀល...............និងការខូចខាតផ្សេងៗចំនួន..............................។

៣/ សុំអោយតុលាការចេញសាលក្រមប្រកាសជាអនុវត្តបណ្តោះអាសន្ន ក្នុងរឿងក្តីនេះដោយភាគីចុងចម្លើយមិនគោរពតាមកិច្ចសន្យា។

៤/ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ និង សោហ៊ុយក្នុងការចំណាយផ្សេងៗ។

ក្នុងករណីនេះ ចង់បញ្ជាក់ថាដើមចោទត្រូវសរសេរបញ្ជាក់អោយបានច្បាស់អំពីចំនួនទឹកប្រាក់ដែលត្រូវទាមទារអោយប្រគល់ ប្រភេទនៃប្រាក់ ទាមទារជាប្រាក់ដើម ឬការប្រាក់ ទាមទារប្រាក់កម្ចី ឬទាមទារការប្រាក់កើតចេញពីអំពើអនីត្យានុកូលផ្សេងៗ ជាដើម។ ការប្តឹងទាមទារបែបនេះជា ប្រភេទនៃបណ្តឹងទាមទារអោយចុងចម្លើយផ្តល់តាវកាលិក។ ការទាមទារតាមផ្លូវបណ្តឹងមាន ៣(បី)ប្រភេទៈ

១) បណ្តឹងទាមទារអោយផ្តល់តាវកាលិក (ប្រគល់ជាវត្ថុ)ៈ ជាប្រភេទនៃបណ្តឹងដែលដើមចោទទាមទារទៅតុលាការចេញសាលក្រមបង្គាប់អោយចុងចម្លើយផ្តល់ ឬប្រគល់តាវកាលិក ដោយផ្អែកតាមការអះអាងអំពីអត្ថិភាពនៃសិទ្ធិទាមទាររបស់ ដើមចោទដែលមានលើកម្មវត្ថុនៃបណ្តឹងនោះ។

---

[87] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មាត្រា ៨០។

**ឧទាហរណ៍៖** លោក មាស ប្ដឹងទាមទារអោយតុលាការចេញសាលក្រមបង្គាប់អោយចុងចម្លើយអ្នកស្រី ធីតា ផ្ដល់ ឬ ប្រគល់ប្រាក់កម្ចីចំនួន ១០លានរៀល មកខ្លួនតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី ០១/១២/២០២០ ជាកំហិត។

២) បណ្ដឹងទាមទារអោយបញ្ជាក់អំពីអត្ថិភាព ឬអនត្ថិភាពនៃសិទ្ធិ៖ ជាប្រភេទបណ្ដឹងទាមទារអោយចេញសាលក្រមបញ្ជាក់អំពីអត្ថិភាព ឬអនត្ថិភាពនៃសិទ្ធិទំនាក់ទំនងគតិយុត្តិដែលបានអះអាងដោយដើមចោទតាមផ្លូវបណ្ដឹង ។

**ឧទាហរណ៍៖** លោក ក បានកម្ចីប្រាក់បរិភោគពីលោក ខ ចំនួន២០០០ដុល្លារអាមេរិក និងអោយការប្រាក់ ១% ក្នុងមួយខែ ដោយកំណត់សងប្រាក់ទៅលោក ខ ទាំងប្រាក់ដើម និងការប្រាក់នៅថ្ងៃ ១០/១០/២០១៤ ដោយគិតពីថ្ងៃចុះកិច្ចសន្យានៅថ្ងៃ ១០/១០/២០១០ តទៅ។ តែមកដល់ថ្ងៃកំណត់លោក ក មិនបានអនុវត្តកាតព្វកិច្ចសងប្រាក់កម្ចីទៅលោក ខ តាមកិច្ចសន្យាទេ ដោយគិតមកដល់ឆ្នាំ២០២០ នេះមានរយៈពេល ១០(ដប់)ឆ្នាំហើយ។

ក្រោយមកនៅឆ្នាំ២០១៩ នេះលោក ខ ប្ដឹងទាមទារប្រាក់កម្ចីពីលោក ក ដូច្នេះ លោក ខ ត្រូវបញ្ជាក់និងអះអាងអំពីអត្ថិភាពនៃសិទ្ធិ លើបំណុលដែលខ្លួនមានចំពោះលោក ក ដោយផ្អែកតាមកិច្ចសន្យាកម្ចីប្រាក់ ចំណែកលោក ក ទទួលស្គាល់អង្គហេតុពិតបានខ្ចី និងទទួលប្រាក់ពីលោក ខ ប្រាកដមែន កាលពីថ្ងៃទី ១០/១០/២០១៥ នោះប៉ុន្តែមិនទទួលស្គាល់ការទាមទារដោយលោក ក ត្រូវអះអាងនិងបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ ទាមទារលើបំណុលរបស់លោក ខ ដោយមូលហេតុផុតអាជ្ញាយុកាល។

គួរកត់សម្គាល់ផងដែរ បើជឿថាអង្គហេតុនិងការទាមទាររបស់ដើមចោទនោះត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមទទួលស្គាល់ការទាមទារនោះ។ ហើយ បើចុងចម្លើយទទួលស្គាល់អង្គហេតុ និងការទទួលការទាមទាររបស់ដើមចោទ តុលាការចេញសាលក្រមទទួលស្គាល់ការទាមទារ។ តែបើក្នុងករណីដែលភាគីចុងចម្លើយមិនជឿថា អង្គហេតុនិងការទាមទាររបស់ដើមចោទនោះត្រឹមត្រូវ តុលាការត្រូវចេញសាលក្រមច្រានចោលការទាមទារនោះ ហើយបើចុងចម្លើយទទួលអង្គហេតុ តែច្រានចោលការទាមទាររបស់ដើមចោទ នោះចុងចម្លើយត្រូវមានភស្តុតាងមកបញ្ជាក់ តែបើចុងចម្លើយទទួលស្គាល់ការទាមទារនោះ ពុំចាំបាច់យកភស្តុតាងមកបញ្ជាក់ទេ។

៣) បណ្ដឹងទាមទារអោយអោយបង្កើត ប្ដូរ ឬ រំលត់ចំណងគតិយុត្តិ៖ នៅក្នុងបណ្ដឹងនេះគឺទាមទារអោយតុលាការចេញសាលក្រមប្រកាសបង្កើតជាថ្មីនៅទំនាក់ទំនងគតិយុត្តិ (ការកើត

មានឡើងនូវការប្តូរ ឬរលត់) ដោយផ្អែកលើការអះអាងអំពី អត្ថិភាពនៃសិទ្ធិបង្កើត ឬអំពីមូល-ហេតុនៃការបង្កើតទំនាក់ទំនងគតិយុត្តិកំណត់មួយ ដែលជាការទាមទារតាមផ្លូវបណ្តឹង។

**ឧទាហរណ៍៖** បណ្តឹងលែងលះ (បណ្តឹងសុំរំលត់ចំណងអាពាហ៍ពិពាហ៍) ដែលធ្វើឡើង រវាងដើមចោទ និងចុងចម្លើយ។ ចំពោះបណ្តឹងប្រភេទនេះ ទោះបីគូភាគីបានបង្ហាញឆន្ទៈស្របគ្នាថា យល់ព្រមលែងលះតាមការព្រមព្រៀងក៏ដោយ ក៏ពួកគេមិនអាចរំលត់ចំណងអាពាហ៍ពិពាហ៍បានទេ ហើយចំណងអាពាហ៍ពិពាហ៍ថ្មីមិនអាចកើតឡើងបានទេ និងមិនមានអានុភាពទេ។ បើចង់អោយបណ្តឹងនេះមានសុពលភាព ភាគីត្រូវដាក់ពាក្យបណ្តឹង ដោយតុលាការចេញសាលក្រមលែងលះទើបចំណងអាពាហ៍ពិពាហ៍ត្រូវរំលត់។

ដូចនេះនៅពេលដែលតុលាការបានទទួលនូវប្រភេទបណ្តឹងណាមួយហើយ បន្ទាប់មកទៀតតុលាការក៏បានដំណើរការនីតិវិធីចប់នៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការត្រូវប្រកាសបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងថយទៅបន្ទប់ពិភាក្សារយៈពេលខ្លី រួចតុលាការចុចកណ្តឹងប្រាប់សញ្ញាថាតុលាការចូលសវនាការវិញ បើតុលាការយល់ឃើញថាសំណុំរឿងក្តីមិនមានភាពស្មុគស្មាញ ត្រូវប្រកាសសាលក្រមចុងក្រោយភ្លាមនៅពេលឱកាសនោះតែម្តងគឺជាសាលក្រមអង្គសេចក្តី។ [88] ក្នុងករណីយល់ឃើញថា មិនមានពេលវេលាគ្រប់គ្រាន់ ឬសំណុំរឿងក្តីមានភាពស្មុគ្រស្មាញ ឬមានកាលៈទេសៈពិសេសផ្សេងទៀត នោះតុលាការត្រូវប្រកាសលើការប្រកាសសាលក្រមទៅពេលក្រោយដោយទុកក្នុងអំឡុងពេល ១(មួយ) ខែគិតពីកាលបរិច្ឆេទបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ ប៉ុន្តែការកំណត់អំឡុងពេល ១(មួយ) ខែនេះមិនត្រូវយកមកអនុវត្តឡើយចំពោះរឿងក្តីដែលមានភាពស្មុគ្រស្មាញខ្លាំង ឬ មានកាលៈទេសៈពិសេសផ្សេងទៀត។ [89] បន្ទាប់មកទៀតតុលាការអាចប្រាប់ពីកាលបរិច្ឆេទប្រកាសសាលក្រមនៅសាលសវនការតែម្តង ឬប្រាប់នៅពេលក្រោយតាមដីកាកោះហៅ ឬគ្រប់មធ្យោបាយតាមការដែលអាចធ្វើបាន។ ដូចនេះសាលក្រមនិងចូលជាស្ថាពរ នៅពេលដែលអំឡុងពេលនៃការប្តឹងឧបាស្រ័យបានផុតនឹងអំឡុងពេល [90] ១(មួយ) ខែគិតចាប់ពីទាំងកាលបរិច្ឆេទទទួលបានការបញ្ជូនលិខិត ឬក៏ជូនដំណឹងសាលក្រម។

### ២.៣ ការជួសជុលការខូចខាត

សាលក្រមដែលសំរេចសេចក្តីលើការទទួលខុសត្រូវ និងមានខចែងកំណត់អំពីបែបបទ ហើយនិងចំនួនទឹកប្រាក់នៃការជួសជុលលើទំហំការខូចខាត។ ការទាមទារជួសជុលសំណងការខូចខាតជាសិទ្ធិរបស់ជនរងគ្រោះ ដោយសិទ្ធិទាមទារការជួសជុលនេះកើតឡើងនៅពេលមានការខូចខាត។ ប៉ុន្តែឥណទេយ្យ នៃប្រាក់ជំងឺ

[88] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មាត្រា ១៨០ កថាខណ្ឌទី ១។

[89] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មាត្រា ១៨៧។

[90] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១ មិថុនា ២០០៦, មាត្រា ១៩៣ កថាខណ្ឌទី ១។

ចិត្ត ដែលសំរេចលើការទទួលខុសត្រូវគឺមាននៅថ្ងៃចេញសាលក្រម ដោយការចេញសាលក្រមត្រូវបានកំណត់វាយតំលៃនៃការខូចខាត ដោយគិតទៅដល់ព្រឹត្តិការណ៍មានទៅមុខចាប់តាំងពីការកើតមានការខូចខាតជាអាទ៍។ ជាទូទៅការជួសជុលព្យសនកម្មគឺធ្វើឡើងតាមវិធី ២(ពីរ)យ៉ាង[91] គឺ (ក) ការជួសជុលតាមសមាសភាពវត្ថុ និងការជួសជុលតាមសមមូល និង (ខ) ការជួសជុលចំនួនទឹកប្រាក់។

**ក. ការជួសជុលតាមសមាសភាពវត្ថុ និងការជួសជុលតាមសមមូល**

ការជួសជុលតាមសមាសភាពវត្ថុ គឺអាចទទួលបានក្នុងការខូចខាតជាសម្ភារៈ នៅពេលដែលកម្មវត្ថុបានបែកបាក់ដោយអំពើអនីត្យានុកូល អ្នករងគ្រោះអាចទាមទារសំណង ដូចជាតម្លៃនៃវត្ថុដែលបែកបាក់ ឬ សោហ៊ុយជួសជុលវត្ថុនោះជាអាទ៍[92] និងការជួសជុលតាមសមមូល គឺជាការបង់ប្រាក់ជំងឺចិត្តសំរាប់ទូទាត់ព្យសនកម្មដែលជនរងគ្រោះទទួលរង។[93]

**ឧទាហរណ៍៖** បុរស ក បានព្រមព្រៀងគ្នាធ្វើកិច្ចសន្យាជួលផ្ទះពីបុរស ខ ក្នុងរយៈពេលជួល ២ឆ្នាំដោយនៅក្នុងអំឡុងពេលជួល បុរស ក បានធ្វើអោយបង្ខូច និងទ្វារងការបែកបាក់ជាច្រើនដោយគ្មានការថែទាំដ៏ល្អពីបុរស ក ដែលជាអ្នកជួលផ្ទះពីបុរស ខ។ ដូចនេះបុរស ខ អាចទាមទារសំណងពីបុរស ក ដែលជាតម្លៃនៃវត្ថុដែលបែកបាក់ ឬ ក៏សោហ៊ុយជួសជុលវត្ថុនោះជាអាទ៍។

**ខ. ការជួសជុលចំនួនទឹកប្រាក់**

ទំហំនៃការជួសជុល គឺត្រូវសមស្របគ្នាជាមួយទំហំនៃការខូចខាត។ ការជួសជុលសោហ៊ុយលើការខូចខាតត្រូវតែជួសជុលលើគ្រប់ផលវិបាកផ្ទាល់នៃអំពើនាំអោយមានការខូចខាតទាំងអស់។ ចៅក្រមមានសិទ្ធិពេញលេញក្នុងការធ្វើមូលវិចារណ៍លើសាលក្រម។ [94] ក្នុងការគណនាចំនួនទឹកប្រាក់នៃការខូចខាតសតិអារម្មណ៍ដោយសារអំពើអនីត្យានុកូលចំនួនទឹកប្រាក់នៃជម្ងឺចិត្តត្រូវបានវាយតម្លៃ ដោយគិតពិចារណានូវស្ថានភាពផ្សេងៗដូចជាកម្រិតនៃកំហុសចេតនា ឬ អចេតនារបស់អ្នកប្រព្រឹត្តអំពើបំពានប្រភេទនិង កម្រិតនៃការរងគ្រោះ អំពើរបស់អ្នកប្រព្រឹត្ត អំពើបំពាននៅក្រោយអំពើបង្កអោយមានការរងគ្រោះនោះ។[95]

**៣. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនអាចដកបាន**

ការដកនូវការរំលាយសំដៅទៅលើការដកការរំលាយកិច្ចសន្យា ជាឯកតោភាគីដោយភាគីដែលមានសិទ្ធិរំលាយក្រោយពេលការរំលាយមានអានុភាព។ ការដកការរំលាយកិច្ចសន្យាបែបនេះ មិនត្រូវបានទទួល

[91] ញឹក វុធ្ធី. ‘‘នីតិកាតព្វកិច្ច៖ ភាគទី២,’’ (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ទំព័រទី ២៥ និង ២៦។

[92] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៧៥៩។

[93] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៧៦០, ៧៦១, និង ៧៦២។

[94] ញឹក វុធ្ធី. ‘‘នីតិកាតព្វកិច្ច៖ ភាគទី២,’’ (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ, ទំព័រទី ២៥។

[95] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៧៥៨ កថាខណ្ឌទី ២។

ស្គាល់ឡើយ។ [96] ក្នុងករណីដែលភាគីមានសិទ្ធិរំលាយកិច្ចសន្យាអាចដកឆន្ទៈនៃការរំលាយកិច្ចសន្យា នោះអានុភាពនៃកិច្ចសន្យានឹងត្រូវផ្លាស់ប្ដូរ ហើយជាលទ្ធផលឋានៈរបស់ភាគីម្ខាងទៀត ឬ ភាគីដែលមានផលប្រយោជន៍ពាក់ព័ន្ធ នឹងក្លាយជាអស្ថិរភាព។ ប៉ុន្តែគេអាចចាត់ទុកថាជាជនដែលមានសិទ្ធិរំលាយ អាចដកនូវឆន្ទៈរំលាយកិច្ចសន្យាបាន ក្នុងករណីដែលការជូនដំណឹងពីការដកឆន្ទៈបានដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នា ឬ មុនពេលឆន្ទៈរំលាយ ព្រោះការរំលាយមានអានុភាពនៅពេលដែលវាបានដល់។

ជាងនេះទៅទៀតបញ្ញត្តិទូទៅនៃការបង្ហាញឆន្ទៈ ត្រូវយកមកអនុវត្តចំពោះឆន្ទៈរំលាយផងដែរ ដូច្នេះគេអាចលុបចោលឆន្ទៈបាន ក្នុងករណីនៃការភាន់ច្រឡំ ឆបោក ឬគំរាមកំហែង ជាអាទិ៍ [97] ហើយម្យ៉ាងទៀតប្រសិនបើមានតតិយជនដែលមានផលប្រយោជន៍ ក្នុងការរំលាយសុពលភាពនៃការដកការរំលាយជាធម្មតាមិនអាចអះអាង (មិនកើតមាន) បានទេផ្អែកលើកិច្ចព្រមព្រៀងរវាងភាគីនៃកិច្ចសន្យានោះ។

**ឧទាហរណ៍៖** លោក ក បានព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាជួលអាគារមួយពីអ្នកស្រី ខ តែត្រូវបានរំលាយកិច្ចសន្យាវិញ ដោយមូលហេតុមិនអនុវត្តកាតព្វកិច្ចរបស់ ក ដោយលោក ក បានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ហេតុនេះហើយអ្នកស្រី ខ បានបង្ហាញឆន្ទៈរំលាយកិច្ចសន្យាពី លោក ក។ បន្ទាប់មកទៀត អ្នកស្រី ខ បានព្រមព្រៀងជួលអាគារនោះទៅអោយលោក គ ហើយបន្ទាប់មកទៀតភាគីទាំងពីរបានស្រុះស្រួលគ្នាក្នុងការដកនូវការរំលាយកិច្ចសន្យានោះវិញដោយផ្អែកតាមការព្រមព្រៀងរវាងលោក ក និងអ្នកស្រី ខ តែវាត្រូវបានធ្វើអោយប៉ះពាល់ផលប្រយោជន៍ពីលោក គ ដោយត្រូវបានខូចខាត។ ដូច្នេះ ក្នុងករណីនេះ ការដកនេះមិនត្រូវបានទទួលស្គាល់ទេលុះត្រាតែមានស្វីការពីលោក គ។

## ៤. ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្គង់

ការបង្ហាញឆន្ទរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្គង់បាន គឺសំដៅទៅលើព្រឹត្តិការណ៍ដែលកើតឡើងនៅពេលអនាគត ហើយដែលមិនទៀងទាត់។ ទន្ទឹមនឹងនេះល័ក្ខខ័ណ្ឌបង្អង់មានន័យថា កាតព្វកិច្ច ឬសិទ្ធិនឹងមានអានុភាពនៅពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញ។[98]

**ឧទាហរណ៍៖** លោក ក បានបង្កើតកិច្ចសន្យាទិញដីឡូត៍មួយពីលោក ខ ហើយលោក ក មិនបានបង់ប្រាក់គ្រប់គ្រាន់នៅកាលបរិច្ឆេទប្រគល់នោះទេ បន្ទាប់មកលោក ខ បានប្រាប់លោក ក ថាគាត់នឹងរំលាយកិច្ចសន្យានៅពេលដែលលោក ក មិនបានបង់ប្រាក់គ្រប់គ្រាន់ក្នុងរយៈពេល ១(មួយ) ខែ។ ដូច្នេះ ឆន្ទៈនៃការរំលាយនេះត្រូវបានដាក់ល័ក្ខខ័ណ្ឌបង្អង់មួយសប្ដាហ៍។

---

[96] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤០៩ កថាខណ្ឌទី ២។

[97] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៤០៩។

[98] គណៈកម្មការទទួលបន្ទុកការពារសេចក្ដីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី. *សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤.* ( ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០), មាត្រា ៤០៩។

### ៥. ការរំលាយកិច្ចសន្យាដោយភាគីម្ខាងមានគ្នាច្រើននាក់

ក្នុងករណីដែលភាគីម្ខាងទៀតមានច្រើននាក់ ការរំលាយកិច្ចសន្យា ត្រូវធ្វើឡើងដោយបុគ្គលទាំងអស់នោះចំពោះភាគីម្ខាងទៀត ឬ ដោយភាគីម្ខាងទៀតចំពោះបុគ្គលទាំងអស់នោះ។ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានរលត់ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមបុគ្គលនៃភាគីដែលមានច្រើននាក់ សិទ្ធិរំលាយនោះក៏ត្រូវរលត់ចំពោះបុគ្គលផ្សេងទៀតនៃភាគីនោះដែរ។[99]

**ឧទាហរណ៍៖** ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ២០១៨ ក បានលក់ដី ខ អោយទៅ គ, ឃ, ង និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិអោយទៅអ្នកទាំង ៣។ អ្នកទាំង ៣ មិនបានប្រគល់ប្រាក់គ្រប់ចំនួនទេទោះបីជា ក បានដាស់តឿនយ៉ាងណាក៏ដោយ។ នៅថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៨ ក បានផ្ញើរអ៊ីម៉ែលថារំលាយកិច្ចសន្យាទៅ គ។ ហើយថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៨ ក បានទូរស័ព្ទទៅ ឃ បន្ទាប់ពីជូនដំណឹងទៅ គ និង ឃ ដូចនេះ ក បានសំរេចចិត្តធ្វើលិខិតជូនដំណឹងចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០១៨ ទៅអោយ ង ម្នាក់ទៀតអំពីការរំលាយកិច្ចសន្យាក្នុងប្រអប់សំបុត្រផ្ទះរបស់ ង។

ដូចនេះចំពោះអានុភាពនៃការរំលាយ ត្រូវកំណត់យកកាលបរិច្ឆេទនៃការជូនដំណឹងចំពោះអ្នកចុងក្រោយ ដោយសារកំណត់យកគោលការណ៍បានទៅដល់។ ក្នុងឧទាហរណ៍ខាងលើ ការបង្ហាញឆន្ទៈរំលាយមានអានុភាពនៅថ្ងៃទី ១៦ កញ្ញា ឆ្នាំ ២០១៨ ជាពេលចុងក្រោយដែលការបង្ហាញឆន្ទៈរំលាយបានដល់ចំពោះភាគីទាំងអស់។

## ផ្នែកទី៣៖ ការរំលត់សិទ្ធិនៃការរំលាយកិច្ចសន្យា

ភាគីនៅក្នុងកិច្ចសន្យា គឺមានសិទ្ធិក្នុងការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា នៅពេលណាដែលភាគីណាមួយនៃកិច្ចសន្យាបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ គឺភាគីនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដោយតាមប្រព័ន្ធតុលាការ ឬ ក៏ក្រៅប្រព័ន្ធតុលាការ ដើម្បីរកសេចក្តីសម្រេចមួយជូនទៅភាគីណាម្ខាងនៃកិច្ចសន្យាបានទទួលនូវផលប្រយោជន៍មកវិញ។ ប៉ុន្តែការអនុវត្តវិធីសិទ្ធិរំលាយកិច្ចសន្យាក៏អាចរំលត់បានដែល ដោយភាគីណាមួយនៃកិច្ចសន្យាមិនអាចប្រើប្រាស់បន្តវិធីអនុវត្តសិទ្ធិរំលាយកិច្ចសន្យាបានទៀតទេ ហើយភាគីនៃកិច្ចសន្យាមិនអាចអះអាងនូវសិទ្ធិរំលាយកិច្ចសន្យាណាមួយទេទោះបីជានៅក្នុងស្ថានភាពដែលមិនត្រឹមត្រូវ ឬក៏មិនសមស្របតាមប្រការណាមួយបានឡើយ ពីព្រោះថា សិទ្ធិរំលាយកិច្ចសន្យានោះត្រូវបានផុតរលត់ ដោយគ្មានភាពជានិរន្តន៍។ ជាគោលការណ៍ សិទ្ធិរំលាយកិច្ចសន្យាត្រូវផុតរលត់ផ្អែកលើមូលហេតុទូទៅនៃការរំលត់សិទ្ធិ ដែលភាគីនៃកិច្ចសន្យាត្រូវបានអស់សិទ្ធិក្នុងប្រការណាមួយ។ ក្រមរដ្ឋប្បវេណីមានបញ្ញត្តិយ៉ាងច្បាស់លាស់ ស្តីពីមូលហេតុពិសេសនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា។[100]

[99] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១០។

[100] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១២ និង ៤១៣។

**កថាភាគទី១៖ សិទ្ធិរំលាយកិច្ចសន្យានៅពេលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត**

សិទ្ធិរំលាយត្រូវរំលត់ ក្នុងករណីដែលភាគីមានសិទ្ធិរំលាយធ្វើអោយមានការខូចខាត ឬ ការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះបានដោយចេតនា[101] ឬធ្វើអោយវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃ ឬ ការផ្លាស់ប្តូរទម្រង់ដោយចេតនា។

**ឧទាហរណ៍១ ៖** ក្នុងករណីដែលអ្នកទិញរថយន្តរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុរថយន្តនោះមានវិការៈ ប្រសិនបើអ្នកទិញនោះធ្វើអោយខូចខាតដោយចេតនាដល់រថយន្តដែលខ្លួនត្រូវប្រគល់វិញ ហើយខ្លួនចង់រំលាយកិច្ចសន្យានោះ មានន័យថាអ្នកទិញត្រូវបាត់បង់សិទ្ធិរំលាយដោយសិទ្ធិរំលាយនោះត្រូវផុតរលត់។ បើភាគីបានអនុវត្តសិទ្ធិរំលាយ ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃវត្ថុ ដែលជាកម្មវត្ថុនោះត្រឹមកម្រិតដែលបានកំណត់នៅក្នុងកិច្ចសន្យា។[102]

មូលហេតុដែលសិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់នៅក្នុងករណីខាងលើ គឺដោយសារតែវាផ្ទុយនឹងគោលការណ៍នៃភាពសុចរិត និង ស្មោះត្រង់ ក្នុងករណីភាគីដែលបានធ្វើអោយខូចខាត ឬ មិនអាចសងវត្ថុនោះវិញដោយចេតនាអាចរំលាយកិច្ចសន្យាបាន។ ដោយឡែកនៅក្នុងករណីភាគីម្ខាងទៀត មានកំហុស ឬមានមូលហេតុក្នុងការខូចខាត ឬការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះភាគីដែលមានសិទ្ធិរំលាយគ្មានករណីយកិច្ចក្នុងការសងប្រាក់នូវតម្លៃនៃវត្ថុនោះ ដូចបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ៤១២ កថាខណ្ឌទី ២ ឡើយ។

**ឧទាហរណ៍២ ៖** ក្នុងករណីអ្នកទិញរំលាយកិច្ចសន្យា លក់ទិញរថយន្តដោយមូលហេតុដែលរថយន្តនោះមានវិការៈ ដោយរថយន្តនោះខូចខាតបណ្តាលមកពីវិការៈនោះដូចជា រថយន្តបានបុកបង្គោលខ្សែភ្លើងមួយដោយមកពីហ្វ្រាំងមិនជាប់ល្អ។ ដូចនេះអ្នកទិញគ្មានការទទួលខុសត្រូវលើការខូចខាតនៃរថយន្តនោះទេ ហើយអ្នកលក់មានការទទួលខុសត្រូវ ឬ បង្កើតមូលហេតុនៃការខូចខាតនោះ ហេតុដូច្នេះអ្នកទិញមិនចាំបាច់សងជាប្រាក់ចំពោះផ្នែកដែលបាក់បែករបស់រថយន្តនោះទេ។

**កថាភាគទី២៖ ការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយសារអាជ្ញាយុកាល**

អាជ្ញាយុកាល នៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទានមានអំឡុងពេល ៥(ប្រាំ)ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច។ គួរបញ្ជាក់ផងដែរថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា និង សិទ្ធិទាមទារអោយធ្វើបដិទានបន្ទាប់ពីការរំលាយកិច្ចសន្យាវាមិនដូចនឹងការទាមទារអោយសងសំណងការខូចខាតទេ។[103] អាជ្ញាយុកាល នៃសិទ្ធិរំលាយកិច្ចសន្យាគិត

---

[101] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ៣.* (ភ្នំពេញ, ខែមីនា ឆ្នាំ ២០១៧), ទំព័រទី ១៩១។

[102] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤១២ កថាខណ្ឌទី ២។

[103] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤០៦។

ចាប់ពីពេលដែលការមិនអនុវត្តកាតព្វកិច្ច។ ក្នុងករណីនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច សិទ្ធិរំលាយកិច្ចសន្យាមិនត្រូវកើតឡើង ប្រសិនបើម្ចាស់បំណុលមិនបានដាស់តឿន។ ប៉ុន្តែ ប្រសិនបើការអនុវត្តកាតព្វកិច្ចនេះមានភាពយឺតយ៉ាវ នោះម្ចាស់បំណុលអាចបង្កើតសិទ្ធិរំលាយដោយធ្វើការដាស់តឿនពេលណាក៏បាន។ ហេតុដូច្នេះ គ្មានបញ្ហាទេចំពោះការចែងថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ចាប់គិតពីពេលនៃការយឺតយ៉ាវក្នុងការអនុវត្តកាតព្វកិច្ច ។

**ឧទាហរណ៍៖** នៅក្នុងករណីដែល ក និង ខ បានចុះកិច្ចសន្យាលក់ទិញ ប៉ុន្តែ ខ មិនបានបង់ប្រាក់ថ្លៃលក់ទិញទេ ទោះបីជាមានការប្រគល់វត្ថុរបស់ ក ក៏ដោយ។ ខ ត្រូវស្ថិតនៅក្នុងភាពយឺតយ៉ាវចាប់ពីពេលដែល ក បានធ្វើការប្រគល់កម្មវត្ថុ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃការរំលត់ ត្រូវគិតចាប់ពីពេលដែល ខ ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ ក ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារបដិទានក្នុងអំឡុងពេល ៥ឆ្នាំ ចាប់ពីពេលប្រគល់វត្ថុរបស់ ក។

ចំពោះសិទ្ធិនៃការទាមទារអោយធ្វើបដិទានដែលកើតឡើងដោយអនុវត្តសិទ្ធិរំលាយកិច្ចសន្យា គ្មានអាជ្ញាយុកាលដោយឡែកពិសេសទេ ហេតុដូច្នេះសិទ្ធិទាមទារអោយធ្វើបដិទាននេះនឹងត្រូវរលត់ ប្រសិនបើមិនទាមទារអោយធ្វើបដិទានមុនអាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាត្រូវបានសម្រេច។

**កថាភាគទី៣៖ ការរំលត់ដោយសារការអនុវត្តកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យា**

ដើម្បីបង្កើតអានុភាពនៃការរំលាយ ដោយផ្អែកលើមូលហេតុថាការយឺតយ៉ាវនៅក្នុងអនុវត្តកាតព្វកិច្ច គឺភាគីម្ខាងទៀត មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយភាគីដែលចង់រំលាយកិច្ចសន្យាបានដាស់តឿនអោយអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យ ប៉ុន្តែកូនបំណុលមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនក្នុងអំឡុងពេលនោះ។ ប៉ុន្តែប្រសិនបើកូនបំណុលបានអនុវត្តកាតព្វកិច្ចនៅក្នុងអំឡុងពេលនោះ នោះកាតព្វកិច្ចត្រូវរលត់ដោយសារការអនុវត្តកាតព្វកិច្ចពីកូនបំណុល ដូចនេះសិទ្ធិរំលាយក៏ត្រូវរលត់ដែរ។

**ឧទាហរណ៍៖** ក បានទិញម៉ូតូពី ខ មួយគ្រឿងក្នុងតម្លៃ ២០០០ដុល្លារ (ពីរពាន់ដុល្លារអាមេរិក)។ ក ក៏បានបង្កើតកិច្ចសន្យាទិញលក់ ដែលចុះនៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១២។ បន្ទាប់មក ខ បានប្រគល់ម៉ូតូនោះអោយ ក តាមកិច្ចសន្យាតែ ក មិនបានបង់ប្រាក់គ្រប់នោះទេដោយនៅខ្វះទឹកប្រាក់ចំនួន ៥០០ ដុល្លារ (ប្រាំរយដុល្លារ) ទៀតដោយធ្វើការសន្យាថា នឹងប្រគល់អោយនៅ ថ្ងៃទី ៣១ មករា ឆ្នាំ ២០១៣។ លុះមកដល់ថ្ងៃកំណត់ពេល ក នៅតែមិនទាន់បង់ប្រាក់ដែលខ្វះនៅឡើយទេទៅ ខ បន្ទាប់មកទៀត ខ ក៏បានចេញលិខិតដាស់តឿន[104] ទៅដល់ ក ក្នុងការសងប្រាក់ដែលមានអំឡុងពេល ១ខែ សំរាប់ការសងបើ ក មិនសងទេនោះ ខ និងធ្វើការអនុ-វត្តសិទ្ធិរំលាយកិច្ចសន្យា។ លុះដល់ពេលវេលាជិត ១ខែ ក ក៏បានប្រគល់ប្រាក់ ៥០០ដុល្លារ (ប្រាំរយដុល្លារ

[104] សូមមើលគំរូលិខិតដាស់តឿននៅក្នុង ឧបសម្ព័ន្ធទី៦។

អាមេរិក)ទៅ ខ។ ដូចនេះសិទ្ធិរំលាយកិច្ចសន្យា របស់ ខ គឺត្រូវបានរលត់ដោយសារការអនុវត្តកាតព្វកិច្ចនៃភាគីកិច្ចសន្យា គឺ ក។

ចំពោះករណីដែលម្ចាស់បំណុលប្រកែកមិនព្រមទទួលយកកម្មវត្ថុ ទោះបីជាកូនបំណុលបានស្នើផ្តល់ការអនុវត្តកាតព្វកិច្ច ដោយយោងទៅតាមការដាស់តឿនរបស់ម្ចាស់បំណុល តើវានឹងទៅជាយ៉ាងណា? នៅក្នុងករណីនេះប្រសិនបើម្ចាស់បំណុល បានទទួលនូវកម្មវត្ថុនោះកាតព្វកិច្ចនឹងត្រូវរលត់ ។ ដូច្នេះ នៅក្នុងករណីនេះគេអាចទទួលស្គាល់ថា សិទ្ធិរំលាយរបស់ម្ចាស់បំណុលត្រូវរលត់ដោយសារការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល។

# ជំពូកទី៣

# អានុភាពសំណងខូចខាត

# នៃការរំលាយកិច្ចសន្យា

# ជំពូកទី ៣

# អានុភាពសំណងការខូចខាតនៃការរំលាយកិច្ចសន្យា

ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ នឹងធ្វើអោយកិច្ចសន្យានោះត្រូវបានរំលាយ នោះភាគីម្ខាងនៃកិច្ចសន្យាអាចបង្ហាញឆន្ទៈទៅភាគីម្ខាងទៀតនៃកិច្ចសន្យា ដោយធ្វើលិខិតដាស់តឿនក្នុងការអនុវត្តកាតព្វកិច្ច តែបើកូនបំណុលមិនបានអនុវត្តកាតព្វកិច្ចទៀត នោះសិទ្ធិនៃការរំលាយកិច្ចសន្យានឹងត្រូវបានរលត់ ដោយភាគីនៃកិច្ចសន្យាមិនចាំបាច់អនុវត្តកាតព្វកិច្ចទៀតទេ មានន័យថា ការរំលាយកិច្ចសន្យានាំអោយគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត។ ថ្វីត្បិតតែ ការរំលាយកិច្ចសន្យាបានផុតទៅមែន តែការសងសំណងការខូចខាតនៅតែកើតមានដើម្បីសងនូវផលប្រយោជន៍ដែលភាគីបានបាត់បង់នៅក្នុងកិច្ចសន្យា និងរងនូវការខូចខាត។

ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារអោយសងការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ចមានអំឡុងពេល ៥(ប្រាំ)ឆ្នាំ ក្រោយពីពេលដែលការខូចខាតនោះបានកើតឡើង។[105] អំឡុងពេលនៃអាជ្ញាយុកាល អាចត្រូវបានគិតចាប់ពីពេលដែលមិនអនុវត្តកាតព្វកិច្ចរបស់ភាគីណាមួយនៃកិច្ចសន្យា ប៉ុន្តែវាគួរតែគិតបន្ទាប់ពីការចាប់ផ្តើមកើតមានការខូចខាត ដោយហេតុថាភាគីណាម្នាក់អាចទាមទារសំណងបានលុះត្រាតែការខូចខាតណាមួយកើតឡើង។ ដូច្នេះហើយអំឡុងពេលនៃអាជ្ញាយុកាលត្រូវបានគណនាចាប់ពីពេលដែលការខូចខាតកើតឡើង។

**ឧទាហរណ៍៖** ក្នុងករណីដែលអ្នកទទួលបញ្ញើដែលថែរក្សាថូដែលជាកម្មសិទ្ធិរបស់អ្នកផ្ញើរ ដោយផ្អែកលើកិច្ចសន្យាបញ្ញើ បានធ្វើអោយបែកថូនោះ ដោយកំហុសក្នុងការគ្រប់គ្រងនោះអ្នកទទួលបញ្ញើត្រូវសងសំណងការខូចខាតជាទឹកប្រាក់ស្មើនឹងតម្លៃនៃថូ ដូច្នេះកម្មសិទ្ធិលើថូនឹងត្រូវផ្ទេរទៅអ្នកទទួលបញ្ញើដែលសងសំណងការខូចខាត។ ហើយអាជ្ញាយុកាល នៃការរំលត់សិទ្ធិទាមទារសំណងត្រូវគិតចាប់ពីពេលដែលថូនោះបានបែក។

ដូច្នេះនៅពេលដែលមានអានុភាពនៃការរំលាយកិច្ចសន្យាកើតឡើង តើការសងសំណងខូចខាតត្រូវបានកើតឡើងតាមវិធីគតិយុត្តិបែបណាខ្លះ ដើម្បីអោយមានភាពសមស្របក្នុងការផ្តល់យុត្តិធម៌ទៅដល់ភាគីដែលបានខាតបង់ប្រយោជន៍ខ្លាំងនៅពេលរំលាយកិច្ចសន្យា?

ដើម្បីបកស្រាយនូវការមានចម្ងល់នៅក្នុងបញ្ហានេះ ដូច្នេះនៅក្នុងជំពូកនេះយើងនឹងសិក្សាលម្អិតទៅលើចំណុចអានុភាពសំណងខូចខាតនៃការរំលាយកិច្ចសន្យាដែលត្រូវបានបែងចែកចេញជា ៣(បី)ផ្នែក៖ ផ្នែកទី ១ ដំណើរការអានុភាពនៃការរំលាយកិច្ចសន្យា, ផ្នែកទី ២ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះភាគី និងតតិយជន និង ផ្នែកទី ៣ ករណីយកិច្ចសងសំណងការខូចខាត។

---

[105] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤០៦។

## ផ្នែកទី១៖ ដំណើរការអានុភាពនៃការរំលាយកិច្ចសន្យា

កិច្ចសន្យាមួយត្រូវបានរំលាយ ចំណងកិច្ចសន្យានេះនឹងត្រូវរលត់។ ការរំលាយកិច្ចសន្យានឹងរំលត់រាល់កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និង នាំអោយភាគីនៃកិច្ចសន្យារួចផុតពីកិច្ចសន្យានោះ។ ប៉ុន្តែ ក្នុងករណីរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តកាតព្វកិច្ច នោះករណីយកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចនៅតែមានអានុភាព។

នៅពេលដែលអានុភាពកើតចេញពីការរំលាយកិច្ចសន្យា នោះនឹងអោយមានលក្ខណវិនិច្ឆ័យថ្មីមួយទៀតនៃអានុភាពនោះគឺ (១) អានុភាពប្រតិសកម្ម ដែលទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា និង (២) អានុភាពមិនប្រតិសកម្ម ដែលមិនទទួលស្គាល់អានុភាពនៃការរំលាយកិច្ចសន្យា។

### កថាភាគទី១៖ អានុភាពប្រតិសកម្ម

គំនិតដែលទទួលស្គាល់អានុភាពប្រតិសកម្ម គឺនៅក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយ វាត្រូវចាត់ទុកថា គ្មានកិច្ចសន្យាតាំងពីដំបូង។ ដូច្នេះ ប្រសិនបើភាគីបានទទួលតាវកាលិក នៅមុនពេលរំលាយគាត់ត្រូវធ្វើបដិទានឡើងវិញ នូវស្ថានភាពដើមរបស់ភាគីម្ខាងទៀត ដោយផ្អែកលើសេចក្តីសម្រើនឥតហេតុ។[106] នៅក្នុងសេចក្តីចម្រើនឥតហេតុកាតព្វកិច្ចត្រូវសង ជាទូទៅត្រូវបានកម្រិតត្រឹមផលប្រយោជន៍ដែលមាន។[107]

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យា ក បានទិញអំបិលពី ខ ១០ គីឡូក្រាម ដែលមួយគីឡូមានតំលៃ ៤ពាន់រៀលដោយ ក បានទទួលអំបិលហើយបានអោយលុយទៅ ខ ពីរម៉ឺនរៀល។ ប៉ុន្តែ ក មិនបានបង់ប្រាក់ ពីរម៉ឺនរៀលទៀតទេ ទោះបីជា ខ បានដាស់តឿនហើយបានកំណត់ពេលសមរម្យដើម្បីអោយ ក បង់ប្រាក់ក៏ដោយហើយ ក បានប្រើប្រាស់អំបិលអស់ ៤ គីឡូទៅហើយ។ ក្នុងករណីនេះ ខ អាចរំលាយកិច្ចសន្យា ដូច្នេះភាគីទាំងសងខាងត្រូវធ្វើបដិទានឡើងវិញនូវស្ថានភាពដើម ដោយផ្អែកលើសេចក្តីចម្រើនឥតហេតុ។ ខ ត្រូវប្រគល់ប្រាក់ ពីរម៉ឺនរៀលអោយទៅ ក ដូចគ្នាដែរ ហើយ ក ត្រូវប្រគល់អំបិល ១០គីឡូក្រាមអោយ ខ វិញ ក៏ប៉ុន្តែ ក ប្រើប្រាស់អំបិលអស់ ៤ គីឡូក្រាម ដូច្នេះ ក ត្រូវសងមកវិញនូវអំបិល ៤ គីឡូក្រាមដែលបានប្រើអស់ ឬត្រូវសងជាប្រាក់ មួយម៉ឺនប្រាំមួយពាន់រៀលដែលមានតម្លៃស្មើនឹងអំបិលនោះ។

- **ទំនាក់ទំនងជាមួយការផ្ទេរកម្មសិទ្ធិ**

ដោយផ្អែកតាមគំនិត ក ការផ្ទេរកម្មសិទ្ធិត្រូវបានរលត់ដោយប្រតិសកម្ម ព្រោះការរំលាយមានអានុភាពប្រតិសកម្ម។

[106] សេចក្តីចម្រើនឥតហេតុ គឺជាការទទួលផលប្រយោជន៍ ដោយសារទ្រព្យសម្បត្តិ ឬ ពលកម្មរបស់អ្នកដទៃ ដោយគ្មានមូលហេតុតាមផ្លូវច្បាប់ ហើយធ្វើអោយមានការបាត់បង់ផលប្រយោជន៍ដល់អ្នកដទៃ ដោយសារការទទួលផលនោះ។

[107] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៧៣៦ កថាខណ្ឌទី ១។

**ឧទាហរណ៍៖** លោក ពៅ បានបង្កើតកិច្ចសន្យាទិញ លក់ម៉ូតូ អោយទៅលោក វិជ្ជា ដោយប្រគល់ម៉ូតូរួចរាល់ហើយតែលោក វិជ្ជា មិនបានប្រគល់ប្រាក់អោយលោក ពៅ ទេ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ បន្ទាប់មកទៀតលោក ពៅ បានបង្ហាញឆន្ទៈក្នុងការរំលាយកិច្ចសន្យា។ ដូច្នេះ អ្នកទិញដែលជាលោក វិជ្ជា ត្រូវបានបង្ហាញឆន្ទៈក្នុងការរំលាយកិច្ចសន្យាពីលោក ពៅ។ ដូច្នេះមានន័យថាលោក ពៅ ត្រូវចាត់ទុកថាជាកម្មសិទ្ធិករតាំងពីដំបូង ហើយលោក ពៅ អាចទាមទារអោយប្រគល់ម៉ូតូមកវិញដោយផ្អែកលើកម្មសិទ្ធិ ប្រសិនបើលោក វិជ្ជា បានកាន់កាប់ម៉ូតូនោះ។

**កថាភាគទី២៖ អានុភាពមិនប្រតិសកម្ម**

គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្ម គឺក្នុងករណីដែលកិច្ចសន្យាត្រូវបានរំលាយ ត្រូវចាត់ទុកថាគ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុល និងកាតព្វកិច្ចដើម ត្រូវផ្លាស់ប្តូរទៅជា សិទ្ធិទាមទារ និងកាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគី។[108] នៅក្នុងគំនិតនេះ បញ្ញត្តិនៃការរំលាយកិច្ចសន្យា ត្រូវយកមកអនុវត្តចំពោះពេលអនាគត ហើយទាក់ទងនឹងការអនុវត្តកាតព្វកិច្ច ដែលមិនទាន់ត្រូវបានអនុវត្ត គឺមិនមានអត្ថិភាពទៀតទេនៅពេលអនាគត។ ផ្ទុយទៅវិញ ចំពោះកាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាពហើយមិនអាចក្លាយជាសេចក្តីចម្រើនឥតហេតុទេ។

**ឧទាហរណ៍៖** នៅក្នុងកិច្ចសន្យាលក់ទិញ ក បានលក់រថយន្តអោយទៅ ខ ដោយប្រគល់រថយន្តរួចរាល់ហើយ ក៏ប៉ុន្តែ ខ មិនបានប្រគល់ប្រាក់អោយ ក ទេ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ ហើយ ក បានសម្រេចចិត្តរំលាយកិច្ចសន្យា។ ក បានរំលាយកិច្ចសន្យានោះមិនត្រូវចាត់ទុកថា ខ គ្មានកម្មសិទ្ធិតាំងពីដំបូងឡើយ ប៉ុន្តែនៅពេលដែល ក បានរំលាយកិច្ចសន្យា ខ ត្រូវប្រគល់រថយន្តទៅអោយ ក វិញដែលជាកាតព្វកិច្ចថ្មីដោយផ្អែកលើការរំលាយកិច្ចសន្យា។ ការផ្ទេររថយន្តទៅវិញនេះគឺខុសពីចំណុចនៃអានុភាពប្រតិសកម្ម ព្រោះការសងតាវកាលិកត្រឡប់ទៅវិញនេះគឺជាកាតព្វកិច្ចថ្មី មិនមែនផ្អែកលើសេចក្តីចម្រើនឥតហេតុដូចករណីដែលផ្អែកលើទ្រឹស្តីអានុភាពប្រតិសកម្មទេ។

ដូច្នេះ ចំពោះចំណុចទាំងពីរខាងលើគឺ អានុភាពប្រតិសកម្ម និង អានុភាពមិនប្រតិសកម្មគឺនឹងចាប់ផ្តើមមានអានុភាពនៅពេលដែលការរំលាយកិច្ចសន្យាត្រូវបានកើតឡើង ដែលភាគីនៃកិច្ចសន្យានោះមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចដែលបានចែងនៅក្នុងកិច្ចសន្យា ជាលទ្ធផលនៅពេលដែលមានការរំលាយកិច្ចសន្យាបានកើតឡើងនោះនឹងនាំអោយភាគីនៃកិច្ចសន្យាបានបង្កើតកាតព្វកិច្ចជាថ្មីមួយទៀតក្នុងការសង និងការប្រគល់នូវតាវកាលិកទៅម្ចាស់ដើមវិញ។

[108] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១១ កថាខណ្ឌទី ២។

បន្ទាប់ពីអានុភាពនៃការរំលាយកិច្ចសន្យាបានកើតឡើង តើទំនាក់ទំនងក្នុងកិច្ចសន្យារវាងគូភាគីនឹងត្រូវចងភ្ជាប់កាតព្វកិច្ចអ្វីខ្លះ? ហើយអានុភាព នៃការរំលាយកិច្ចសន្យាវានឹងធ្វើអោយខូចផលប្រយោជន៍ដល់តតិយជនដែរ ឬទេ?

## ផ្នែកទី២៖ អានុភាពនៃការរំលាយកិច្ចសន្យាចំពោះភាគី និង តតិយជន

អានុភាពនៃការរំលាយកិច្ចសន្យា គឺមានអានុភាពទៅលើភាគីក្នុងការរំលត់ករណីយកិច្ចនៅក្នុងកិច្ចសន្យា ដោយបង្កើតកាតព្វកិច្ចថ្មីក្នុងការសងតាវការលិក និងសំណងការខូចខាតដែលកើតឡើងទៅម្ចាស់ដើមវិញក្នុងពេលអនាគតណាមួយ ហើយអានុភាពនៃការរំលាយកិច្ចសន្យា ក៏មានអានុភាពទៅលើតតិយជនដែរក្នុងការការពារផលប្រយោជន៍មិនអោយរងនូវការខូចខាតពីការរំលាយកិច្ចសន្យាពីភាគីកិច្ចសន្យាមុន។ ការការពារផលប្រយោជន៍ទៅលើតតិយជន លុះត្រាតែកិច្ចសន្យានោះត្រូវបានបង្កើតអោយមានលក្ខណៈគតិយុត្តតាមផ្លូវច្បាប់ និងមិនមានវិការៈនៅក្នុងកិច្ចសន្យាហើយតតិយជនមានគោលការណ៍នៃភាពសុចរិត និងភាពស្មោះត្រង់ ។

### កថាភាគទី១៖ ការរំលត់ទំនាក់ទំនងក្នុងកិច្ចសន្យារវាងគូភាគី

អានុភាពនៃការរំលាយកិច្ចសន្យានាំអោយគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត[109] មានន័យថាទំនាក់ទំនងភាគីនៅក្នុងកិច្ចសន្យា និងមានការកែប្រែប្រួលនូវកាតព្វកិច្ច។ ដូច្នេះនៅក្នុងចំនុចនេះយើងនិងសិក្សាស៊ីជម្រៅទៅលើចំនុច ២(ពីរ)យ៉ាង៖ (១) ភាគីនៃកិច្ចសន្យារួចផុតពីកាតព្វកិច្ច និង អញ្ញត្រកម្ម និង (២) ការធ្វើបដិទាន ។

#### ១. ភាគីនៃកិច្ចសន្យារួចផុតពីកាតព្វកិច្ច និង អញ្ញត្រកម្ម

អានុភាពនៃការរំលាយកិច្ចសន្យាធ្វើអោយចំណង និងទំនាក់ទំនងនៃកិច្ចសន្យានឹងត្រូវរលត់។ ការរំលាយកិច្ចសន្យានឹងរលត់រាល់កាតព្វកិច្ចទាំងឡាយ របស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និងនាំអោយគូភាគីនៃកិច្ចសន្យារួចផុតកាតព្វកិច្ចពីកិច្ចសន្យានោះ។ ប៉ុន្តែក្នុងករណីដែលកិច្ចសន្យា ត្រូវបានរំលាយដោយមូលហេតុ មិនអនុវត្តកាតព្វកិច្ចនោះករណីយកិច្ចសងសំណងការខូចខាត របស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ច នៅតែមានអានុភាពដែលវាជាអញ្ញត្រកម្មនៅក្នុងកិច្ចសន្យាសំរាប់ភាគីដែលបានបាត់បង់ផលប្រយោជន៍ ដោយភាគីម្ខាងទៀតដែលទួលបានតាវកាលិកតាមកិច្ចសន្យា ត្រូវមានកាតព្វកិច្ចផ្ទេរតាវកាលិកនោះមកអោយវិញ។ ចំពោះកាតព្វកិច្ចដែលភាគីនៅមិនទាន់បានបំពេញរវាងគ្នានៅក្នុងកិច្ចសន្យានឹងគ្នា ត្រូវរលត់ឆ្ពោះទៅអនាគត ដោយសារការរំលាយកិច្ចសន្យា ដូចនេះនាំអោយកាតព្វកិច្ចភាគីត្រូវបញ្ចប់ លើកលែងតែសំណងខូចខាតដែលវាជាការទទួលខុសត្រូវក្រៅកិច្ចសន្យា។

[109] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១១ កថាខណ្ឌទី ១ និង ២។

## ២. ការធ្វើបដិទាន

បដិទាន គឺជាការស្តារឡើងវិញនូវស្ថានភាពដើម ឬការប្រគល់ត្រឡប់វិញ។[110] អានុភាពនៃការរំលាយកិច្ចសន្យា នឹងនាំអោយមានការកើតឡើងនូវអានុភាពប្រតិសកម្ម និង មិនប្រតិសកម្មដោយភាគីនៃកិច្ចសន្យាត្រូវធ្វើបដិទានគ្នាទៅវិញទៅមកនូវរាល់កម្មវត្ថុ ឬក៏តាវកាលិកទាំងឡាយដែលបានចុះកិច្ចសន្យា ដោយត្រូវផ្ទេរកម្មសិទ្ធិទៅម្ចាស់ដើមវិញ។ ការផ្ទេរកម្មសិទ្ធិ ត្រូវបានចាត់ទុកថាភាគីនៃកិច្ចសន្យានោះមិនមែនជាកម្មសិទ្ធិករតាំងពីដំបូង ដូច្នេះកម្មសិទ្ធិករ ដែលជាម្ចាស់នៃកម្មវត្ថុនោះ អាចទាមទារនូវសិទ្ធិក្នុងការគ្រប់គ្រងលើវត្ថុរបស់ខ្លួនវិញបាន ។

### ២.១ ការធ្វើបដិទានទៅស្ថានភាពដើម

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីអោយភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយកិច្ចសន្យា។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។[111]

**ឧទាហរណ៍១៖** នៅក្នុងកិច្ចសន្យាលក់ទិញ ក បានទិញម៉ូតូរបស់ ខ ដោយបានទទួលម៉ូតូនោះហើយ តែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ លុះដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀតអោយ ខ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះ ខ មានសិទ្ធិរំលាយកិច្ចសន្យា ហើយទាមទារម៉ូតូរបស់ខ្លួនមកវិញ តែត្រូវប្រគល់ប្រាក់ពាក់កណ្តាលដែលខ្លួនបានទទួលអោយទៅ ក វិញផងដែរ។ ដូចនេះ កាតព្វកិច្ចក្នុងការធ្វើបដិទានឡើងវិញ ត្រូវអនុវត្តនៅពេលជាមួយគ្នា។ ជាទូទៅកាតព្វកិច្ចធ្វើបដិទានមានលក្ខណៈស្របនិងគោលគំនិតអានុភាពប្រតិសកម្ម និង គោលគំនិតអានុភាពមិនប្រតិសកម្ម ក្នុងការសងតាវកាលិកនោះទៅអោយភាគីម្ខាងទៀត។

- **ទំហំនៃករណីយកិច្ចធ្វើបដិទាន**

ក្រៅពីតាវកាលិកជាប្រាក់ ដែលខ្លួនបានទទួល ភាគីត្រូវសងទៅវិញទៅមកផងដែរ នូវការប្រាក់នៃប្រាក់ដែលបានទទួល និង ផលប្រយោជន៍ទាំងឡាយបានមកពីការប្រើប្រាស់តាវកាលិកដែលទទួលបាន។[112] ក្នុងន័យនេះកាតព្វកិច្ចធ្វើបដិទានមានន័យថា មិនត្រឹមតែជាការធ្វើបដិទានទៅស្ថានភាពពេលបង្កើតកិច្ចសន្យាទេ ប៉ុន្តែទៅដល់ស្ថានភាពដែលអាចមាន។

[110] តាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី, ឆ្នាំ២០០៧។

[111] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មាត្រា ៤១១ កថាខណ្ឌទី ២។

[112] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១១ កថាខណ្ឌទី ៣។

**ឧទាហរណ៍២៖** នៅក្នុងការបង្កើតកិច្ចសន្យាទិញលក់ ក បានទិញម៉ូតូរបស់ ខ ដោយបានទទួលម៉ូតូនោះ ហើយតែ ខ បានទទួលប្រាក់តែពាក់កណ្តាល។ ដល់ថ្ងៃប្រគល់ប្រាក់ ក នៅតែមិនបានប្រគល់ប្រាក់ពាក់កណ្តាលទៀតអោយ ខ ទោះបីជាមានការដាស់តឿនយ៉ាងណាក៏ដោយ។ ក្នុងករណីនេះចំពោះអ្នកលក់ ខ មានសិទ្ធិរំលាយកិច្ចសន្យា ហើយទាមទារម៉ូតូរបស់ខ្លួនមកវិញរួមជាមួយនឹងទឹកប្រាក់ដែលមានតម្លៃស្មើនឹងថ្លៃជួលម៉ូតូក្នុងរយៈពេលដែល ក បានប្រើប្រាស់ម៉ូតូនេះដែលជាផលប្រយោជន៍បានមកពីវត្ថុនោះ។ ចំពោះអ្នកទិញ ក វិញមានសិទ្ធិទាមទារប្រាក់ពាក់កណ្តាល រួមជាមួយការប្រាក់គិតចាប់ពីពេលដែលអ្នកលក់ ខ បានទទួលប្រាក់នោះ។

## ២.២ ភាតព្វកិច្ចធ្វើបដិទានមិនអាចតាមស្ថានភាពដើម

ក្នុងករណីដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវវត្ថុ មានន័យថាការធ្វើបដិទានមិនអាចតាមស្ថានភាពដើមនូវកម្មវត្ថុដែលបានចែងនៅក្នុងកិច្ចសន្យា ដូចនេះនៅពេលវត្ថុក្នុងកិច្ចសន្យារងការខូចខាត ឬមានការផ្លាស់ប្តូរតាមទម្រង់ដើម នោះសិទ្ធិរំលាយត្រូវរលត់ចំពោះភាគីមានសិទ្ធិរំលាយ។ សិទ្ធិរំលាយត្រូវរលត់ក្នុងករណីដែលភាគីមានសិទ្ធិរំលាយ[113]៖

- បានធ្វើអោយមានការខូចខាត ឬ បាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា។

  **ឧទាហរណ៍១៖** កម្មវត្ថុនៃកិច្ចសន្យាបានលក់បន្ត ឬ បានបាក់បែកអស់ដោយចេតនា។
- ធ្វើអោយវត្ថុនោះក្លាយជាវត្ថុផ្សេង ដោយការកែច្នៃ ឬ ការផ្លាស់ទម្រង់ ដោយចេតនា។

  **ឧទាហរណ៍២៖** ការទិញអង្ករ ដោយអ្នកទិញបានយកអង្ករនោះធ្វើជានំបញ្ចុកអស់ទៅហើយ។

នៅក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើអោយខូចខាត ឬបាត់បង់ ឬមិនអាចសងមកវិញដោយមិនមានចេតនា នោះសិទ្ធិរំលាយមិនត្រូវរលត់ទេ។ គាត់អាចរំលាយកិច្ចសន្យាបានប៉ុន្តែ គាត់ត្រូវសងជាទឹកប្រាក់ចំពោះតម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតនូវតម្លៃដែលជាកម្មវត្ថុនោះ។

**ឧទាហរណ៍៣៖** នៅក្នុងកិច្ចសន្យាទិញលក់លោក ណេត បានទិញពិរថយន្តពីលោក ហេង ដែលជារថយន្តថ្មី ហើយភាគីទាំងពីរនាក់បានអនុវត្តកាតព្វកិច្ចរួចរាល់ហើយ ដោយលោក ណេត បានទទួលរថយន្ត និងលោក ហេង បានទទួលប្រាក់ទាំងអស់នោះផងដែរ។ ប៉ុន្តែក្រោយមកលោក ណេត បានដឹងថារថយន្តនោះមិនមែនជារថយន្តថ្មីទេ ហើយបានទាមទារអោយលោក ហេង ប្រគល់រថយន្តថ្មីដោយកំណត់អំឡុងពេលសមរម្យ តែលោក ហេង នៅតែមិនព្រមប្រគល់ហេតុនេះហើយបានជា លោក ណេត រំលាយកិច្ចសន្យា តែមុនពេលប្រគល់រថយន្តនោះលោក ណេត បានធ្វើអោយខូចខាតរថយន្តដោយអចេតនាក្នុងគ្រោះថ្នាក់ចរាចរណ៍មួយ។

[113] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤១២។

ដូចនេះ លោក ណោត អាចរំលាយកិច្ចសន្យាបាន តែត្រូវចេញថ្លៃជួសជុលរថយន្តនោះ ដែលខ្លួនបានធ្វើអោយខូចខាត ហើយលោក ហេង ត្រូវប្រគល់ប្រាក់អោយគ្រប់ចំនួនដែលទទួលបានពីលោក ណោត ជាមួយនឹងការប្រាក់។ ជាទូទៅ នៅក្នុងករណីបែបនេះលោក ណោត អាចរំលត់កាតព្វកិច្ចរបស់ខ្លួន ត្រឹមកម្រិតនៃចំនួនដែលស្មើគ្នាដោយបង្ហាញឆន្ទៈទូទាត់។[114]

**កថាភាគទី២៖ អានុភាពចំពោះតតិយជន**

ការបង្ហាញឆន្ទៈដោយការរំលាយកិច្ចសន្យា[115] យើងចាត់ទុកថាកម្មសិទ្ធិត្រូវបានផ្ទេរត្រឡប់មកវិញ បញ្ហាកើតមាននៅពេលដែលភាគីម្ខាងបានលក់ ឬក៏ផ្ទេរទៅអោយភាគីមួយទៀត **(តតិយជន)** មុនពេលភាគីម្ខាងទៀតបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា។ ការរំលាយកិច្ចសន្យា មិនអាចធ្វើអោយខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនទេ។[116] ដូចនេះយើងត្រូវចោទសួរថា តើផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនជាអ្វី និងកើតមាននៅពេលណា? នៅមុនការរំលាយកិច្ចសន្យា ឬ ក្រោយការរំលាយកិច្ចសន្យា?

**ឧទាហរណ៍៖** ***(ករណីសិក្សាទី ១)*** លោក ក បានលក់ផ្ទះមួយកន្លែងអោយទៅ លោក ខ ហើយការផ្ទេរកម្មសិទ្ធិត្រូវបានចុះបញ្ជី។ បន្ទាប់មកលោក ខ បានលក់ផ្ទះនោះអោយទៅលោក គ ហើយ គ បានធ្វើការផ្ទេរកម្មសិទ្ធិដោយចុះបញ្ជី។ ក្រោយមកលោក ក បានរំលាយកិច្ចសន្យាដោយមូលហេតុថាមានការបំពានកិច្ចសន្យាដោយការមិនបានបង់ប្រាក់ថ្លៃលក់ផ្ទះ។

***(ករណីសិក្សាទី ២)*** លោក ក បានលក់ផ្ទះមួយកន្លែងអោយទៅលោក ខ ហើយការផ្ទេរកម្មសិទ្ធិត្រូវបានចុះបញ្ជី។ ក្រោយមកលោក ក បានរំលាយកិច្ចសន្យាដោយហេតុថាមិនទាន់បង់ប្រាក់ថ្លៃឈ្នួល។ ប៉ុន្តែការចុះបញ្ជីមិនទាន់បានលុបចោលនៅឡើយហើយ លោក ខ បានលក់ដីនេះអោយទៅលោក គ។

ក្នុងករណីនេះ វាមានសារៈសំខាន់ណាស់ក្នុងការគិតថា តើត្រូវការពារផលប្រយោជន៍តតិយជនយ៉ាងដូចម្តេច ដើម្បីកុំអោយមានការខូចខាតដល់តតិយជនបើតតិយជននោះជាជនសុចរិត និងគ្មានកំហុស?

ដូចនេះ នៅក្នុងចំនុចនេះយើងនឹងសិក្សាអោយស៊ីជម្រៅលើការការពារផលប្រយោជន៍តតិយជន ដោយមានការបកស្រាយពីរផ្សេងគ្នា៖ (១) តតិយជននៃគោលការណ៍អានុភាពប្រតិសកម្ម និង (២) តតិយជននៃគោលការណ៍មិនអានុភាពប្រតិសកម្ម។

**១. តតិយជននៃគោលការណ៍អានុភាពប្រតិសកម្ម**

តាមរយៈការរំលាយកិច្ចសន្យា គឺត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូងរវាងគូភាគី។ នៅក្នុងករណីដែលអ្នកលក់បានប្រគល់វត្ថុហើយ បន្ទាប់មកកិច្ចសន្យាត្រូវបានរំលាយ នោះអ្នកលក់អាចទាមទារអោយ

---

[114] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧ មើលមាត្រា ៤៦៤ កថាខណ្ឌទី ១។

[115] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧ មើលមាត្រា ៤១១ កថាខណ្ឌទី ២។

[116] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧ មាត្រា ៤១១ កថាខណ្ឌទី ៤។

អ្នកទិញប្រគល់វត្ថុមកវិញបាន ដោយផ្អែកលើកម្មសិទ្ធិដោយសារអានុភាពប្រតិសកម្ម គឺនាំអោយសិទ្ធិលើកម្មសិទ្ធិមិនត្រូវបានផ្ទេរតាំងពីរដំបូង។ ប៉ុន្តែដោយមាត្រា ៤១១ កថាខណ្ឌទី៤ បានបញ្ជាក់ថា ការរំលាយកិច្ចសន្យាមិនអាចធ្វើអោយខូចខាតផលប្រយោជន៍ត្រឹមត្រូវ របស់តតិយជនឡើយ តែមាត្រានេះ ក៏មិនបានកំណត់អំពីតតិយជនដែលមានមុន ឬ ក្រោយការរំលាយកិច្ចសន្យានោះទេ។

- **តតិយជនមានវត្តមានមុនការរំលាយកិច្ចសន្យា**

នៅក្នុង**ករណីសិក្សាទី១** គឺជាគោលបំណងនៃមាត្រា ៤១១ កថាខណ្ឌទី ៤ គឺការពារផលប្រយោជន៍ត្រឹមត្រូវ តាមច្បាប់របស់តតិយជនបើតតិយជនជាជនសុចរិត និងគ្មានកំហុស ហើយលើសពីនេះតតិយជនត្រូវមានទំនាក់ទំនងនៅក្នុងកិច្ចសន្យាមុនពេលរំលាយកិច្ចសន្យា ទើបអាចអះអាងអំពីផលប្រយោជន៍របស់ខ្លួនបាន។ ដូចនេះ ចំពោះករណីសិក្សាទី ១ លោក គ បានចុះបញ្ជីផ្ទេរកម្មសិទ្ធិរួចរាល់ ហើយលោក គ មានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់។ ជារួមលោក គ ត្រូវបានការការពារ មានន័យថាក្រោយការរំលាយកិច្ចសន្យា បើលោក គ បានចុះបញ្ជីផ្ទេរកម្មសិទ្ធិហើយលោក ក មិនអាចទទួលកម្មសិទ្ធិត្រឡប់មកវិញទេ។

- **តតិយជនមានវត្តមានក្រោយការរំលាយកិច្ចសន្យា**

តតិយជន ដែលបានចុះកិច្ចសន្យានៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានទេ ព្រោះអានុភាពប្រតិសកម្មបានកើតឡើងរួចហើយ។ តតិយជននៅក្រោយការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថា បានទទួលកម្មសិទ្ធិពីជនដែលមិនមានកម្មសិទ្ធិ។ ដូច្នេះ តតិយជនមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិទេ។ ជាការពិត នៅក្នុងករណីដែលកម្មសិទ្ធិ គឺជាចលនវត្ថុ តតិយជនអាចធ្វើលទ្ធកម្មកម្មសិទ្ធិ ប្រសិនបើ តតិយជនបានបំពេញលទ្ធកម្ម ដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ។ [117] ដោយឡែកនៅក្នុងករណីកម្មវត្ថុ គឺជាអចលនវត្ថុ តតិយជនមិនអាចទទួលបានកម្មសិទ្ធិតាមរយៈលទ្ធកម្មដោយសុចរិតនោះទេ។ ក៏ប៉ុន្តែមានគំនិតមួយដែលអាចសង្គ្រោះ និង ការពារតតិយជនប្រភេទនេះតាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងគោលគំនិតនៃការបង្ហាញឆន្ទៈមិនពិត។[118]

**នៅក្នុងករណីសិក្សាទី២** ដើម្បីការពារតតិយជនគឺលោក គ ក្នុងករណីនេះលោក គ ជាជនសុច្ចរិត និងគ្មានកំហុស។ ដូច្នេះប្រសិនបើលោក គ ជាជនសុច្ចរិត និងគ្មានកំហុស ហើយត្រូវបានចុះបញ្ជីផ្ទេរកម្មសិទ្ធិដែលជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពរួចរាល់ហើយលោក ក មិនអាចតតាំងជាមួយ លោក គ បានទេ ព្រោះថាលោក ក បានបន្សល់ទុកនូវការចុះបញ្ជី ហើយបានបង្កើតទិដ្ឋភាពមួយដែលបង្ហាញថាលោក ខ គឺជាកម្មសិទ្ធិករលើអចលនវត្ថុនោះ ហើយលោក គ បានជឿជាក់ថាលោក ខ គឺជាម្ចាស់សិទ្ធិពិតប្រាកដមែន។ នៅក្នុងករណីនេះប្រសិនបើលោក គ ជឿជាក់ថាលោក ខ គឺជាម្ចាស់កម្មសិទ្ធិដោយពិតប្រាកដដោយសុចរិត និងគ្មានកំហុស នោះ

117 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧ មើលមាត្រា ១៩៣។

118 ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧ មើលមាត្រា ៣៥៣ កថាខណ្ឌទី ២។

គឺមានលទ្ធភាពក្នុងការការពារជនដូចជាលោក គ តាមរយៈការអនុវត្តដែលមានលក្ខណៈស្រដៀងទៅនឹងទៅមាត្រា ៣៥៣ កថាខណ្ឌទី ២។ ដូច្នេះលោក ក មិនអាចលើកឡើងពីកម្មសិទ្ធិរបស់ខ្លួនចំពោះលោក គ ដែលជាជនសុចរិត និងគ្មាកំហុសធ្ងន់ធ្ងរបានទេ។

### ២. តតិយជននៃគោលការណ៍មិនអានុភាពប្រតិសកម្ម

ទោះបីជាការរំលាយកិច្ចសន្យាមិនមានអានុភាពប្រតិសកម្ម តែពេលមានការរំលាយកិច្ចសន្យា ម្ចាស់កម្មសិទ្ធិអាចទាមទារអោយធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបាន ទោះបីជាវត្ថុនោះត្រូវបានផ្ទេរអោយទៅតតិយជនហើយក៏ដោយ។

**នៅក្នុងករណីសិក្សាទី១** ប្រសិនបើអានុភាពប្រតិសកម្មមិនត្រូវបានទទួលស្គាល់ទេ ជាទូទៅកម្មសិទ្ធិត្រូវបានគេចាត់ទុកថាបានផ្ទេរពីលោក ខ ទៅលោក គ នៅពេលបង្កើតកិច្ចសន្យារវាងលោក ខ និង លោក គ ដោយហេតុថាលោក ខ ត្រូវបានគេចាត់ទុកថាជាកម្មសិទ្ធិករតាំងពីមុនពេលរំលាយកិច្ចសន្យា។ ហេតុដូច្នេះក្នុងករណីលោក ខ បានលក់ផ្ទះអោយលោក គ មុនការរំលាយកិច្ចសន្យានោះគេចាត់ទុកថា ផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់របស់លោក គ ត្រូវបានការការពារ។

ដោយឡែកចំពោះ**ករណីសិក្សាទី២** ក្រោយការរំលាយកិច្ចសន្យាទើបលោក ខ បានលក់ផ្ទះអោយលោក គ នេះគឺមានន័យថាកម្មសិទ្ធិត្រូវបានផ្ទេរត្រឡប់មកអោយលោក ក វិញ ហើយបន្ទាប់មកទើបលោក ខ បានលក់ផ្ទះនោះទៅអោយលោក គ ដែលនេះមានលក្ខណៈស្រដៀងគ្នានិងការផ្ទេរកម្មសិទ្ធិពីរដងជាន់គ្នា ដោយមិនគិតថាលោក គ បានទិញផ្ទះនោះនៅមុន ឬ នៅក្រោយការរំលាយកិច្ចសន្យា ដូច្នេះបុគ្គលណាដែលបានទទួលនូវល័ក្ខខ័ណ្ឌតតាំងមុនបុគ្គលផ្សេងទៀតអាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន។ នៅក្នុងបញ្ហានេះអាចត្រូវបានចាត់ទុកថាវាស្របនឹងបញ្ហានៃ ល័ក្ខខ័ណ្ឌតតាំង និង តតិយជន នៅក្នុងករណីនៃការផ្ទេរពីរដងជាន់គ្នា។[119]

- **ល័ក្ខខ័ណ្ឌតតាំង**

ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌតតាំងចំពោះអចលនវត្ថុ។ ដូច្នេះទោះបីជាអ្នកលក់បានទទួលកម្មសិទ្ធិពីអ្នកទិញ ហើយអ្នកទិញបានលក់កម្មវត្ថុនោះទៅអោយតតិយជនក៏ដោយ តែបើតតិយជនបានចុះបញ្ជីអំពីការផ្ទេរមុនអ្នកលក់ នោះតតិយជននឹងមានអានុភាពជាងអ្នកលក់ ហើយអ្នកលក់មិនអាចទាមទារអោយតតិយជនប្រគល់វត្ថុនោះមកវិញ និងលុបចោលការចុះបញ្ជីរបស់តតិយជនបានទេ។

- **ករណីពិសេស**

នៅក្នុងតតិយជននៅមុនការរំលាយកិច្ចសន្យាមានន័យថា**នៅក្នុងករណីសិក្សាទី១** លោក ក នឹងមិនចាំបាច់ត្រូវរំលាយកិច្ចសន្យា ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់លោក ខ នោះទេ ហើយលោក ក អាចទាមទារសំណងនៃការខូចខាតពីលោក ខ ដោយមិនចាំបាច់រំលាយកិច្ចសន្យា។ ផ្ទុយទៅវិញចំពោះ**ករណីសិក្សា**

[119] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ១៣៤ កថាខណ្ឌទី ២។

**ទី២** នៅក្នុងករណីនៃតតិយជននៅក្រោយការរំលាយកិច្ចសន្យា កម្មវត្ថុនៃភាពសុចរិត ឬទុច្ចរិតគឺមិនមែនជាអង្គហេតុថាលោក ខ ស្ថិតនៅក្នុងស្ថានភាពមិនអនុវត្តកាតព្វកិច្ចនោះទេ ប៉ុន្តែគឺជាអង្គហេតុដែលថាកិច្ចសន្យានោះត្រូវបានគេរំលាយ។ ប្រសិនបើលោក គ បានដឹងថា កិច្ចសន្យារវាងលោក ក និង លោក ខ ត្រូវបានគេរំលាយ នោះមានន័យថាលោក គ បានដឹងថាលោក ខ មិនមានសិទ្ធិទេ។ នៅក្នុងករណីនេះ ភាពចាំបាច់ដើម្បីការពារលោក គ គឺមិនមានខ្ពស់ទេ។ ដូច្នេះ ប្រសិនបើលោក គ បានធ្វើសកម្មភាពដោយទុច្ចរិត គេអាចចាត់ទុកថាលោក គ ត្រូវបានដកចេញពីតតិយជនព្រោះលោក គ មិនមានផលប្រយោជន៍ត្រឹមត្រូវ។[120]

## ផ្នែកទី៣៖ ករណីយកិច្ចសងសំណងការខូចខាត

ទោះបីជាកិច្ចសន្យាត្រូវបានរលត់តាំងពីដំបូង ដោយអានុភាពប្រតិសកម្មក៏ដោយ ក៏ការខូចខាតដោយសារការមិនអនុវត្តកាតព្វកិច្ចនៅតែមាននៅក្រោយការរំលាយកិច្ចសន្យា ដូចនេះភាគីដែលមានសិទ្ធិរំលាយអាចទាមទារសំណងនៃការខូចខាតបានជាធម្មតា ព្រោះការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចនៅតែមាននៅក្រោយការរំលាយកិច្ចសន្យា ។

សំណងការខូចខាត គឺជាការសងនូវសំណងពីសំណាក់កូនបំណុល ចំពោះការខូចខាតដែលកើតមានចំពោះម្ចាស់បំណុល។ តើសំណងខូចខាត កើតមាននៅពេលណា?

សំណងការខូចខាត កើតឡើងដោយសារ[121]៖

- ការមិនអនុវត្តកាតព្វកិច្ច។
- សកម្មភាពអំពើអនីត្យានុកូល។

សំណងការខូចខាត នឹងផ្តល់អោយម្ចាស់បំណុល ប៉ុន្តែការទទួលសំណងនេះគឺលុះត្រាតែគោរពនូវល័ក្ខខ័ណ្ឌដើម្បីទទួលបានសំណង។[122] ការមិនអនុវត្តកាតព្វកិច្ច និង សកម្មភាពអំពើអនីត្យានុកូលគឺតម្រូវអោយកូនបំណុលមានការទទួលខុសត្រូវក្នុងការសងសំណងខូចខាតដែលកើតមានឡើងតាមកិច្ចសន្យា។ ប៉ុន្តែមានករណីពិសេសមួយចំនួនដែលកូនបំណុលអាចជៀសផុតក្នុងការទទួលខុសត្រូវកិច្ចសន្យាបានផងដែរ ក្នុងករណីដែលកូនបំណុលមានសំអាងបញ្ជាក់ថា ខ្លួនគ្មានកំហុស ចំពោះការមិនអនុវត្តកាតព្វកិច្ចនោះទេ កូនបំណុលនោះត្រូវរួចផុតពីការទទួលខុសត្រូវក្នុងការសងសំណងខូចខាត។

---

[120] ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ. *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ ១ ដល់ ៣.* (ភ្នំពេញ, ខែមីនា ឆ្នាំ ២០១៧), ទំព័រទី ១៩៧។

[121] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៣៩៨ និង មាត្រា៧៤២។

[122] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៣៩៨។

### កថាភាគទី១៖ ការទទួលខុសត្រូវកិច្ចសន្យា

អំពើនៃការទទួលខុសត្រូវដែលកើតចេញពីការមិនប្រត្តិបត្តិកិច្ចសន្យាដែលការមិនប្រត្តិបត្តិ ឬក៏ អនុវត្ត តាមកិច្ចសន្យានោះបណ្តាលអោយមានការខូចខាតដល់ជនរងគ្រោះភាគីនៃកិច្ចសន្យា។ [123] ដូច្នេះប្រសិនបើភាគី នៃកិច្ចសន្យាមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនទៅតាមកិច្ចសន្យាទេ នោះភាគីនៃកិច្ចសន្យាត្រូវមានការទទួល ខុសត្រូវលើកិច្ចសន្យាទៅតាមទំហំនៃសំណងការខូចខាត[124] ដែលពិចារណា និងគណនាទៅលើការខូចខាតជា ធម្មតា ឬជាការខូចខាតដោយកាលៈទេសៈពិសេស ឬជាឆន្ទៈព្យាបាទ និងអំពើមិនស្មោះត្រង់។

**ក) ការខូចខាតជាធម្មតា៖** ដោយសារការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល អនុញ្ញាត អោយម្ចាស់បំណុលទទួលបាននូវសំណងការខូចខាតត្រឹមតែតម្លៃនៃកម្មវត្ថុដែលខូចខាតនោះ។

**ឧទាហរណ៍១ ៖** ក្រុមហ៊ុនលក់អង្ករ បានលក់អង្ករចំនួន ១(មួយ)តោន ដែលមានតម្លៃ ៥០០$ (ប្រាំរយដុល្លារអាមេរិក) អោយលោក សំណាង ប៉ុន្តែអង្ករនោះដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូច ខាតមុនពេលប្រគល់។ តើ លោកសំណាងត្រូវទទួលបានសំណងការខូចខាតប៉ុន្មាន? ដូច្នេះនៅក្នុង ករណីនេះ ក្រុមហ៊ុនលក់អង្ករត្រូវបានចាត់ទុកថាអលទ្ធភាពនៅក្នុងការអនុវត្ត ដែលតម្លៃថ្លូវនោះគឺជាការ ខូចខាតធម្មតា មានន័យថាក្រុមហ៊ុនលក់អង្ករ ត្រូវសងការខូចខាត ដែលបានកើតឡើងទៅតាមតម្លៃ កម្មវត្ថុនៃកិច្ចសន្យាជូនដល់លោក សំណាង។

**ខ) ការខូចខាតដោយកាលៈទេសៈពិសេស៖** កើតឡើងចំពោះម្ចាស់បំណុលដោយសារកាលៈ-ទេសៈពិសេសត្រូវបានសង ប្រសិនបើការកើតឡើងនៃការខូចខាតពិសេសនេះ ត្រូវបានគូភាគីអាច ព្យាករណ៍បាន។

**ឧទាហរណ៍២ ៖** នៅក្នុងករណីដែលលោក ខ បានទិញរថយន្តមួយពីលោក ក នៅក្នុងតម្លៃ ១.០០០(មួយពាន់ដុល្លារអាមេរិក) ប៉ុន្តែលោក ក មិនបានប្រគល់រថយន្តទេ នៅកាលបរិច្ឆេទកំណត់។ ទន្ទឹមនឹងនេះលោក ខ បានបង្កើតកិច្ចសន្យាលក់ទិញរថយន្តនេះជាមួយនឹងលោក គ នៅក្នុងតម្លៃ ១.៥០០ដុល្លារ។ បន្ទាប់មកលោក គ បានរំលាយកិច្ចសន្យាជាមួយនឹងលោក ខ ដោយសារការយឺត យ៉ាវនៅក្នុងការអនុវត្តកាតព្វកិច្ចរបស់ ខ។ នៅក្នុងករណីនេះ ការខូចខាតពិសេសគឺ ៥០០ដុល្លារ ដែល ជាផលប្រយោជន៍ពីការលក់បន្តទៀត។ នៅក្នុងករណីការខូចខាតពិសេស ម្ចាស់បំណុលត្រូវបង្ហាញថា ការកើតឡើងនៃការខូចខាតពិសេសត្រូវបានព្យាករណ៍ជាមុនដោយគូភាគីនៅពេលបង្កើតកិច្ចសន្យា។

---

[123] ញឹក វុទ្ធី. “នីតិកាតព្វកិច្ច៖ ភាគទី២,” (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ទំព័រទី ២០។

[124] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤០១។

នៅក្នុងករណីខាងលើ ការខូចខាតពិសេស គឺផលប្រយោជន៍នៃការលក់ឡានបន្តទៀតចំនួន ៥០០ដុល្លារ ហើយកាលៈទេសៈពិសេសគឺជាអង្គហេតុដែលលោក ខ បានធ្វើកិច្ចសន្យាលក់បន្តជាមួយនឹងបុគ្គលដទៃទៀត។ នៅក្នុងករណីនេះប្រសិនបើលោក ក បានដឹងថាលោក ខ បានចុះកិច្ចសន្យាលក់ទិញជាមួយនឹងលោក គ នៅក្នុងតម្លៃ ១.៥០០ដុល្លារ នោះគាត់ត្រូវសង ៥០០ដុល្លារ ដែលជាការខូចខាតពិសេស។ ប៉ុន្តែប្រសិនបើលោក ក បានដឹងថាលោក ខ បានចុះកិច្ចសន្យាលក់ទិញជាមួយនឹងលោក គ ប៉ុន្តែលោក ក មិនបានដឹងពីតម្លៃទេ នោះការខូចខាតដែលលោក ក ត្រូវសង គឺជាភាពខុសគ្នារវាង ១.០០០ដុល្លារ និងតម្លៃថយន្តនៅលើទីផ្សារ។

ករណីលើកលែង ប្រសិនបើគូភាគីមិនបានគិតពិចារណាអំពីការខូចខាតពិសេសនោះ នៅពេលបង្កើតកិច្ចសន្យា នោះកូនបំណុលមិនចាំបាច់សងសំណងនៃការខូចខាតពិសេសឡើយ។[125]

**គ) ការមិនអនុវត្តកាតព្វកិច្ចដោយឆន្ទៈព្យាបាទ ឬអំពើមិនស្មោះត្រង់៖** នៅក្នុងចំណោមការមិនអនុវត្តកាតព្វកិច្ច គឺមានករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ច ដោយមានគោលបំណងបង្កនូវការខូចខាតទៅដល់ម្ចាស់បំណុល។ នៅក្នុងករណីនេះ អាចអោយតុលាការបង្គាប់អោយកូនបំណុលសងផលប្រយោជន៍ទៅអោយម្ចាស់បំណុលដូចជា ការខូចខាតផលប្រយោជន៍ ឬ ផលប្រយោជន៍ដែលកូនបំណុលទទួលបាន ប្រសិនបើមានការខូចខាតកើតឡើង។

**ឧទាហរណ៍៣៖** អ្នកស្រី ធីតា គឺជាម្ចាស់កសិដ្ឋានចិញ្ចឹមមាន់ បានលក់នូវមាន់មួយចំនួនអោយទៅអ្នកស្រី បូផា ដែលជាម្ចាស់កសិដ្ឋានចិញ្ចឹមមាន់ដែរ។ ប៉ុន្តែ មាន់ដែលអ្នកស្រី ធីតា បានលក់អោយទៅអ្នកស្រី បូផា នោះមានជម្ងឺ ហើយអ្នកស្រី ធីតា បានដឹងពីហេតុនេះ នៅមុនពេលប្រគល់ ប៉ុន្តែមិនបានប្រាប់ទៅអ្នកស្រី បូផា ទេ។ បន្ទាប់មកមាន់របស់អ្នកស្រី បូផា ទាំងអស់បានឆ្លងជម្ងឺ និងស្លាប់ទាំងអស់។ ការខូចខាតប្រភេទនេះត្រូវបានចាត់ទុកថាជាឆន្ទៈព្យាបាទ និង ត្រូវសងសំណងនៃការខូចខាតទោះបីជាការខូចខាតនោះមិនអាចព្យាករបានមុនក៏ដោយ។ ឆន្ទៈព្យាបាទ មិនចាំបាច់តែទាក់ទងទៅនឹង ***អំពើមិនស្មោះត្រង់ហួសហេតុ*** ទេ ប៉ុន្តែគោលគំនិតនៃ ***អំពើមិនស្មោះត្រង់ហួសហេតុ*** គឺត្រូវបានរាប់បញ្ចូលទាំងគូភាគីដែលមានឆន្ទៈព្យាបាទ នៅពេលធ្វើការកំណត់ពីទំហំនៃការខូចខាត។

- **អាជ្ញាយុកាលនៃការទាមទារសំណងការខូចខាត**

ការទាមទារចំពោះសំណងការខូចខាត ត្រូវធ្វើក្នុងរយៈពេល ៥(ប្រាំ)ឆ្នាំ ក្រោយពេលការខូចខាតកើតឡើងមិនមែនក្រោយការមិនអនុវត្តទេ។ ដូចនេះសំណងការខូចខាត គឺជាផ្នែកនៃការទទួលខុសត្រូវនៅពេលដែលបុគ្គលណាម្នាក់មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

[125] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០ ធ្នូ ២០០៧, មើលមាត្រា ៤០១ ចំនុច ខ។

## កថាភាគទី២៖ ការរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា

កូនបំណុលដែលធ្វើអោយមានការខូចខាត ត្រូវរួចផុតពីកាតព្វកិច្ចដាក់បន្ទុកលើខ្លួនអោយជួសជុលការខូចខាតដែលជនរងគ្រោះបានទទួលទាំងស្រុង ឬ មិនទាំងស្រុង ទោះជាមានហេតុចំណងហេតុផលច្បាស់លាស់យ៉ាងណាក៏ដោយ។ កូនបំណុល ឬ ជនទទួលខុសត្រូវ ត្រូវបង្ហាញភស្តុតាងថាការខូចខាតនោះបណ្តាលមកពីការករណីពុំជួនកាល (១) ប្រធានសក្តិ (២) កំហុសជនរងគ្រោះ និង (៣) អំពើរបស់តតិយជន។[126]

### ១. ករណីប្រធានសក្តិ

ប្រធានសក្តិគឺជាព្រឹត្តិការណ៍ទាំងឡាយ ដែលមិនអាចប៉ាន់ស្មានបានជាមុន និងមិនអាចជំនះបាន ហើយដែលវារារាំងមិនអោយកូនបំណុលបំពេញកាតព្វកិច្ចរបស់ខ្លួនបាន។ ប្រធានសក្តិជាព្រឹត្តិការណ៍ដែលមានប្រភពពីក្រៅពីបុគ្គលជាបំណុល ដូចជា៖ គ្រោះធម្មជាតិ រាជសក្តិ ។ល។

**ឧទាហរណ៍៖** អ្នកស្រី ក បានចុះកិច្ចសន្យាទិញលក់រូបអាពាហ៍ពិពាហ៍ពីអ្នកស្រី ខ នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៧ ហើយអ្នកស្រី ក បានសន្យាថានឹងប្រគល់ប្រាក់អោយគ្រប់ចំនួននៅថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៨។ លុះដល់ថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៨ ផ្ទះរបស់អ្នកស្រី ខ ត្រូវបានឆ្លងចរន្តអគ្គិសនីនឹងត្រូវបានឆាបឆេះយ៉ាងសន្ធោសន្ធៅដែលធ្វើអោយផ្ទះរបស់អ្នកស្រី ខ ខូចខាតយ៉ាងដំណំ រួមជាមួយនឹងក្រណាត់ដែលផ្ទុកសំរាប់កាត់រូបអាពាហ៍ពិពាហ៍ នឹងសំលៀកបំពាក់ផងដែរ។ ដូចនេះ អ្នកស្រី ក អាចរួចផុតពីការទទួលខុសត្រូវលើកិច្ចសន្យាព្រោះថានេះជាករណីប្រធានសក្តិមួយដែលយើងមិនអាចជំនះបាន និងប៉ាន់ស្មានជាមុន។

### ២. កំហុសជនរងគ្រោះ

បើសិនកំហុសជនរងគ្រោះជាមូលហេតុតែមួយ នៃការខូចខាតនោះវាគ្មានចំណងហេតុផលរវាងការខូចខាត ហើយនិងអំពើរបស់ចុងចំលើយ នោះចុងចំលើយត្រូវរួចផុតពីការទទួលខុសត្រូវទាំងស្រុង។ ប៉ុន្តែបើនៅក្នុងករណីដែល បើសិនជនរងគ្រោះមានកំហុស ហើយចុងចំលើយក៏មានកំហុសដែរ នោះការទទួលខុសត្រូវត្រូវចែកគ្នាទទួលខុសត្រូវ។ ការបែងចែកទទួលខុសត្រូវ ត្រូវធ្វើទៅតាមភាពធ្ងន់ស្រាលនៃកំហុសរបស់ម្នាក់ៗ។

**ឧទាហរណ៍៖** បុរស ក បានផ្ញើរថូរផ្កាបុរាណដែលមានតម្លៃមួយ ទៅតាមបុរស ខ ដែលជាអ្នកបើកបរនៅក្រុមហ៊ុនដឹកជញ្ជូនមួយយកទៅអោយមិត្តភក្តិរបស់គាត់។ បន្ទាប់មកទៀត បុរស ខ បានរៀបចំដឹកជញ្ជូនថូរផ្កាបុរាណ ដែលមានតម្លៃអោយមានសុវត្ថិភាព ជូនទៅមិត្តភក្តិរបស់បុរស ក។ នៅក្នុងកំឡុងពេលធ្វើដំណើរ មានរថយន្តមួយដែលបានបើកបរនៅក្នុងល្បឿនលឿនហើយបានមកប៉ះជាមួយ នឹងឡានបុរស ខ ដែលកំពុងដឹកជញ្ជូនឥវ៉ាន់ជូនទៅអតិថិជន ហើយធ្វើអោយឡានរបស់បុរស ខ ត្រូវធ្លាក់ផ្លូវទៅម្ខាងទៀតហើយឥវ៉ាន់នៅក្នុងឡានរបស់បុរស ខ ក៏បានរប៉ះទង្គិចជាមួយនឹងឥវ៉ាន់ផ្សេងទៀត ហើយក៏បានធ្វើអោយប៉ះថូរផ្កាបុរាណដែលមាន

[126] ញឹក វុធ្ធី. "នីតិកាតព្វកិច្ច៖ ភាគទី២," (មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ), ទំព័រទី ២២ និង ២៣។

តម្លៃរបស់បុរស ក ផងដែរ។ ចំណែកឯបុរសដែលបើករថយន្តនៅក្នុងល្បឿនលឿននោះក៏រងរបួស និងមានសភាពធ្ងន់ផងដែរ។

ដូចនេះ នៅក្នុងករណីនេះបុរស ខ អាចរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា ដែលវាជាកំហុសជនរងគ្រោះដែលបុរសនោះបានបើករថយន្តនៅក្នុងល្បឿនលឿន ដូចនេះរាល់ការខូចខាតគឺកំហុសជនរងគ្រោះជាអ្នកទទួលខុសត្រូវ។ ក៏ប៉ុន្តែប្រសិនបើក្នុងករណីវាជាកំហុសជនរងគ្រោះផង និងបុរស ខ ផង នោះរាល់ការខូចខាតត្រូវបែងចែកទៅតាមភាពធ្ងន់ស្រាលនៃកំហុសរបស់ម្នាក់ៗ។

**៣. អំពើតតិយជន**

អំពើតតិយជនជាអំពើរបស់មនុស្សម្នាក់ក្រៅពីជនរងគ្រោះ ហើយនិងចុងចំលើយ ហើយបង្កើតបានជាព្រឹត្តិការណ៍មិនអាចទប់ទល់បានឈ្នះ ហើយមិនអាចប៉ាន់ស្មានមុនបានដែលជាហេតុធ្វើអោយចុងចម្លើយរួចផុតពីការទទួលខុសត្រូវ។

**ឧទាហរណ៍៖** លោក ក បានចុះកិច្ចសន្យាទិញរថយន្តពីហាងលក់រថយន្តរបស់លោក ខ នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០២០។ ដោយលោក ខ បានសន្យានឹងប្រគល់រថយន្តទៅអោយលោក ក នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០២០ នៅពេលរថយន្តនោះបានដឹកមកដល់ហាងរបស់គាត់។ នៅពេលដែលរថយន្តនោះបានដឹកមកដល់ហាងរបស់គាត់ហើយ ក៏មានបុគ្គលិកនៅក្នុងហាងរបស់លោក ខ ដែលជាបុគ្គលិកផ្នែកសំអាតបានធ្វើអោយធ្លាក់ចង្កៀងមួយយ៉ាងធំដែលបានដាក់តាំងនៅក្នុងហាងនោះ ក្នុងអំឡុងពេលបុគ្គលិកនោះបានសំអាតហាងរថយន្តនៅបរិវេនជាន់ខាងលើនៃហាង ដែលបណ្តាលអោយចង្កៀងនោះ បានធ្លាក់មកចំរថយន្តរបស់លោក ក ដែលត្រូវបានខូចខាតក្នុងការបែកកញ្ចក់ និងកំពិតផ្នែកខាងលើគម្របរថយន្តរបស់បុរស ក។

ដូចនេះ នៅក្នុងករណីនេះវាជាអំពើតតិយជនដែលជាបុគ្គលិកសំអាតនៅក្នុងហាងរបស់លោក ខ ដែលជាព្រឹត្តិការណ៍មិនអាចប៉ាន់ស្មានជាមុន ហើយលោក ខ អាចរួចផុតពីការទទួលខុសត្រូវកិច្ចសន្យា។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយខាងលើរួចមក ល័ក្ខខ័ណ្ឌសុពលភាពនៃកិច្ចសន្យានឹងអាចកើតមានក្នុងការចងកាតព្វកិច្ចភាគីនៃកិច្ចសន្យាលុះត្រាតែគោរពទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ជាគោលនៅក្នុងការបង្កើតកិច្ចសន្យាគ្រប់ប្រភេទ។ ជាទូទៅ សុពលភាពនៃកិច្ចសន្យា នឹងចាប់ផ្តើមមានអានុភាពដោយភាគីនៃកិច្ចសន្យាមានការព្រមព្រៀង កម្មវត្ថុនិងទម្រង់នៃកិច្ចសន្យាមិនផ្ទុយនឹងច្បាប់ ហើយភាគីនៃកិច្ចសន្យាអាចមានសមត្ថភាពក្នុងការចុះកិច្ចសន្យា ដូចនេះកិច្ចសន្យានឹងមានអានុភាពហើយស្របទៅតាមល័ក្ខខ័ណ្ឌគតិយុត្តិនៃច្បាប់ ហើយកាតព្វកិច្ចគូភាគីនៃកិច្ចសន្យានឹងចាប់ផ្តើមក្នុងការអនុវត្តរវាងម្ចាស់បំណុល និង កូនបំណុល។ ជាទូទៅភាគច្រើននៅពេលដែលកិច្ចសន្យាចាប់ផ្តើមមានការអនុវត្តកាតព្វកិច្ចហើយ គឺកិច្ចសន្យាតែងតែមានបញ្ហាក្នុងកំឡុងពេលអនុវត្តកាតព្វកិច្ចដោយភាគីម្ខាងនៃកិច្ចសន្យាខកខានក្នុងការអនុវត្តកាតព្វកិច្ចអោយបានល្អ ឬក៏ភាគីនៃកិច្ចសន្យាគ្មានលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច ដែលជាយថាហេតុធ្វើអោយកិច្ចសន្យានោះត្រូវបានរំលាយកិច្ចសន្យា។

ប្រភេទនៃការរំលាយកិច្ចសន្យាអាចរំលាយទៅបានដោយកំណត់នៃច្បាប់ ការរំលាយកិច្ចសន្យាដែលកំណត់នៅក្នុងកិច្ចសន្យា ការរំលាយកិច្ចសន្យាដោយផ្អែកលើបញ្ញត្តិពិសេស និងការរំលាយកិច្ចសន្យាដោយមានការព្រមព្រៀងគ្នាជាដើម។ ការរំលាយកិច្ចសន្យានេះអាចធ្វើទៅបានតែលើប្រភេទកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញបានបំពានកិច្ចសន្យាធ្ងន់ធ្ងរមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន។ នៅពេលដែលកិច្ចសន្យាត្រូវបានបំពានយ៉ាងធ្ងន់ធ្ងរហើយ នោះភាគីម្ខាងនៃកិច្ចសន្យាអាចអនុវត្តសិទ្ធិនៃការរំលាយកិច្ចសន្យាបានដោយតាមប្រព័ន្ធតុលាការ និង ក្រៅប្រព័ន្ធតុលាការ។ ជាការពិតណាស់ការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការគឺជាជម្រើសភាគីក្នុងកិច្ចសន្យាដែលបានជ្រើសរើស ដោយភាគីយល់ឃើញថាវាមានល្បឿនលឿនជាងនៅក្នុងដំណើរការនីតិវិធីប្រព័ន្ធតុលាការ ហើយមិនសូវមានលក្ខណៈស្មុគ្រស្មាញច្រើន។ ជាទូទៅការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការអាចធ្វើទៅបានតាមរយៈ ការរំលាយតាមកិច្ចសន្យា ការរំលាយតាមការព្រមព្រៀងរបស់គូភាគី តាមសន្ធានកម្ម និង តាមមជ្ឈត្តការ។ ដោយឡែកប្រសិនបើភាគីនៃកិច្ចសន្យាមិនចង់រំលាយក្រៅប្រព័ន្ធតុលាការទេ គឺភាគីនៃកិច្ចសន្យាអាចធ្វើខសន្យាចែងក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការបាន បន្ទាប់មកទៀតភាគីនៃកិច្ចសន្យាអាចរៀបចំដាក់ពាក្យបណ្តឹងតាមនីតិវិធីតុលាការដោយអនុលោមតាមក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦នៃព្រះរាជណាចក្រកម្ពុជា។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះគឺមិនអាចដកវិញបានទេ ប្រសិនបើលិខិតនោះត្រូវបានដល់ភាគីម្ខាងទៀតនៃកិច្ចសន្យាហើយភាគីនោះបានទទួលផងដែរ ម្យ៉ាងទៀតប្រសិនបើការរំលាយកិច្ចសន្យានេះមានភាគីច្រើននាក់ នោះភាគីដែលបង្ហាញឆន្ទៈរំលាយកិច្ចសន្យាត្រូវជូនដំណឹងអំពីការរំលាយកិច្ចសន្យានេះអោយបានគ្រប់គ្នា។ នៅពេលដែលភាគីនៃកិច្ច

សន្យាបានដឹង និង ទទួលបានការបង្ហាញឆន្ទៈរំលាយកិច្ចសន្យានេះហើយមិនមែនមានន័យថាកិច្ចសន្យានោះត្រូវបានបញ្ចប់ការអនុវត្តកាតព្វកិច្ចទាំងស្រុងនោះទេ មានន័យថាភាគីនៃកិច្ចសន្យានឹងត្រូវបង្កើតកាតព្វកិច្ចថ្មីមួយទៀត គឺត្រូវសងសំណងការខូចខាត និងបង្វែរវត្ថុដែលជាកម្មវត្ថុកិច្ចសន្យាគឺការធ្វើបដិទានទៅភាគីនៃកិច្ចសន្យាដែលបានបាត់បង់ផលប្រយោជន៍។

បន្ទាប់ពីកិច្ចសន្យាត្រូវបានរំលាយហើយ នោះដំណើរការអានុភាពនៃការរំលាយកិច្ចសន្យានិងត្រូវបានចាប់ផ្តើមដោយ អានុភាពប្រតិសកម្ម និង អានុភាពមិនប្រតិសកម្ម។ អានុភាពប្រតិសកម្ម គឺជាការទទួលស្គាល់នូវការសងតាវកាលិកមកដល់ភាគីម្ចាស់ដើមវិញ ដែលគេត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ហើយភាគីដែលទទួលបានតាវកាលិកនៃកិច្ចសន្យានោះត្រូវបានចាត់ទុកថាជាសេចក្តីចម្រើនឥតហេតុ នោះភាគីនៃកិច្ចសន្យាត្រូវមានកាតព្វកិច្ចសងនូវតាវកាលិកនោះមកម្ចាស់ដើមវិញ គឺសងត្រឹមផលប្រយោជន៍ដែលកើតមាន។ ចំណែកឯអានុភាពមិនប្រតិសកម្មវិញ គឺផ្អែកទៅលើសិទ្ធិលើបំណុល និងកាតព្វកិច្ចដើម ត្រូវផ្លាស់ប្តូរទៅជា សិទ្ធិទាមទារ និង កាតព្វកិច្ចធ្វើបដិទានទៅស្ថានភាពដើមរបស់ភាគីវិញ។ ដូចនេះ ភាគីនៃកិច្ចសន្យាត្រូវធ្វើបដិទានស្ថានភាពដើមទៅអោយភាគីដែលបានខាតបង់ផលប្រយោជន៍ ប៉ុន្តែក៏មាននៅក្នុងករណីខ្លះដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវវត្ថុ មានន័យថាការធ្វើបដិទានមិនអាចតាមស្ថានភាពដើមនូវកម្មវត្ថុដែលបានចែងនៅក្នុងកិច្ចសន្យា ដូចនេះនៅពេលវត្ថុក្នុងកិច្ចសន្យារងការខូចខាត ឬ មានការផ្លាស់ប្តូរតាមទម្រង់ដើមនោះសិទ្ធិរំលាយត្រូវរលត់ចំពោះភាគីមានសិទ្ធិរំលាយកិច្ចសន្យា ហើយត្រូវសងជាទឹកប្រាក់សមមូលចំពោះតម្លៃដែលត្រូវបានបន្ថយដោយសារការខូចខាតនូវតម្លៃដែលជាកម្មវត្ថុនោះ។ ការសងសំណងការខូចខាតនេះពេលខ្លះភាគីដែលជាប់បន្ទុកក៏អាចរួចផុតពីការទទួលខុសត្រូវផងដែរ ដោយគ្រាន់តែបង្ហាញភស្តុតាងថាខ្លួនគ្មានកំហុសក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាដើមដូចជា ករណីប្រធានសក្តិ កំហុសជនរងគ្រោះ និង អំពើតតិយជនជាដើម ដែលជាដើមហេតុធ្វើអោយមានការរាំងស្ទះក្នុងការអនុវត្តកាតព្វកិច្ចរបស់ភាគីម្ខាងនៃកិច្ចសន្យា ។ គួរបញ្ជាក់ផងដែរថា អានុភាពនៃការរំលាយកិច្ចសន្យានេះមិនអាចធ្វើអោយប៉ះពាល់ផលប្រយោជន៍ដល់តតិយជនបានទេជាពិសេសតតិយជនមានវត្តមាននៅមុនពេលរំលាយកិច្ចសន្យា គឺតតិយជនត្រូវបានការពារផលប្រយោជន៍ស្របច្បាប់ ប៉ុន្តែប្រសិនបើនៅក្នុងករណីដែលតតិយជនមានវត្តមាននៅក្រោយការរំលាយកិច្ចសន្យាវិញ គឺតតិយជនក៏ត្រូវបានការការពារដែលតែក្នុងល័ក្ខខ័ណ្ឌដែលតតិយជននោះត្រូវមានការចុះបញ្ជីផ្ទេរកម្មសិទ្ធិត្រឹមត្រូវពិតប្រាកដ ដោយសុចរិត ស្មោះត្រង់ និងគ្មានកំហុសទើបតតិយជននោះអាចមានកម្មសិទ្ធិពិតប្រាកដក្នុងល័ក្ខខ័ណ្ឌតតាំងជាមួយម្ចាស់ដើមដែលមានគោលបំណងរំលាយកិច្ចសន្យា។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និង ការតាក់តែងអត្ថបទសារណាមួយនេះក្រោមប្រធានបទមួយដែលមានចំណងជើងថា “**ការរំលាយកិច្ចសន្យា**” រួចមកយើងខ្ញុំយល់ឃើញថា ការរំលាយកិច្ចសន្យានេះនៅតែមិនមែនជាវិធីដោះស្រាយ និង ជាជម្រើសដ៏ល្អសំរាប់ភាគីដែលទទួលរងគ្រោះពីភាគីម្ខាងដែលបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនោះទេ ដោយហេតុថាភាគីដែលរងគ្រោះនៅតែអាចមានឱកាសខ្ពស់នៅក្នុងការខាតបង់ផលប្រយោជន៍ដែលទោះបីជាមានការរំលាយកិច្ចសន្យាដើម្បីសង្គ្រោះការខាតបង់ក៏ដោយ។ យើងដឹងហើយថា ការរំលាយកិច្ចសន្យាគឺត្រូវបានកើតឡើងដោយសារភាគីម្ខាងនៃកិច្ចសន្យាមានការបំពានយ៉ាងធ្ងន់ធ្ងរ ដោយមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន រួមទាំងអលទ្ធភាពនៅអំឡុងពេលការអនុវត្តកិច្ចសន្យាផងដែរ ដោយយើងមិនអាចប៉ាន់ស្មានទុកជាមុននៅពេលបង្កើតកិច្ចសន្យា ដូច្នេះហើយទោះបីជាភាគីម្ខាងទៀតដែលមានសិទ្ធិអនុវត្តរំលាយកិច្ចសន្យាក៏ពិបាកនៅក្នុងការទាមទារសំណងខូចខាតផងដែរ ព្រោះថាកូនបំណុលមិនមានលទ្ធភាពក្នុងការអនុវត្តកិច្ចសន្យារបស់ខ្លួនស្រាប់បាត់ទៅហើយ ទោះបីជាកូនបំណុលព្រមទទួលខុសត្រូវលើសំណងការខូចខាតទៅលើជនរងគ្រោះក៏ដោយ ក៏ការសងនោះអាចមានថេរវេលាយូរដែរសំរាប់ភាគីដែលជាប់បន្ទុកក្នុងការអនុវត្តកាតព្វកិច្ចថ្មីរបស់ខ្លួនទៀត លើសពីនេះទៅទៀតការសងសំណងខូចខាតពេលខ្លះវាអាចនឹងលើសលប់ ដូចទៅនឹងការអនុវត្តកិច្ចសន្យាតាំងពីដំបូងដែល ដែលវាអាចធ្វើអោយកូនបំណុលពេលខ្លះពិបាកទទួលយក ក្នុងការសងសំណងកាខូចខាតនេះ។ ជាលទ្ធផលដើម្បីអោយ ការរំលាយកិច្ចសន្យានេះមានប្រសិទ្ធិភាព តម្លាភាព និងប្រកបដោយយុត្តិធម៌ ជាពិសេសកាត់បន្ថយដល់ការខាតបង់ខ្ពស់យើងខ្ញុំសូមផ្តល់ជាអនុសាសន៍មតិយោបល់អោយស៊ីជម្រៅនិងសំខាន់ៗ នៅពេលដែលបង្កើតកិច្ចសន្យាគ្រប់ប្រភេទដើម្បីជៀសវាងការមានបន្ទុកហានិភ័យទៅថ្ងៃអនាគតៈ

**ការបង្កើតកិច្ចសន្យា**

- មុនពេលបង្កើតកិច្ចសន្យា ភាគីនៃកិច្ចសន្យាត្រូវមើលលើស្ថានភាពជាក់ស្តែងថា តើភាគីនៃកិច្ចសន្យាមានសមត្ថភាព និងលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចតាមខសន្យាបានដែរឬទេ។
- គ្រប់ប្រភេទកិច្ចសន្យាទាំងអស់ត្រូវមានលក្ខណៈស្តង់ដារ និងស្របតាមផ្លូវច្បាប់មានសាក្សី និងស្នាមមេដៃយ៉ាងពិតប្រាកដ។
- ភាគីនៃកិច្ចសន្យាត្រូវមានការព្រមព្រៀងគ្នាជាមុនសិន និងយល់អោយច្បាស់ពី ពាក្យកិច្ចសន្យា។
- យល់អោយច្បាស់លាស់ទៅលើល័ក្ខខ័ណ្ឌ និងកាតព្វកិច្ចដែលកិច្ចសន្យាអោយត្រូវអនុវត្ត។

- មានខសន្យាចែងនៅក្នុងកិច្ចសន្យាអោយបានគ្រប់ប្រការ តាមតែអាចទៅរួចដើម្បីងាយស្រួលនៅពេលមានបញ្ហាទៅថ្ងៃក្រោយ។
- ភាគីនៃកិច្ចសន្យាត្រូវយល់អោយច្បាស់ពីកម្មវត្ថុនៅក្នុងកិច្ចសន្យា និងលទ្ធផលមួយចំនួននៅពេលដែលមិនអនុវត្តកាតព្វកិច្ចពីកិច្ចសន្យានោះ។
- គ្រប់ខចែងដែលនៅក្នុងកិច្ចសន្យាត្រូវធ្វើដោយស្ម័គ្រចិត្ត នៃភាគីនៃកិច្ចសន្យាដែលខ្លួនគិតថាមានសមត្ថភាពក្នុងការអនុវត្តកាតព្វកិច្ចនោះដោយគ្មានការបង្ខិតបង្ខំ ឬគ្មានការយល់ស្របពីភាគីម្ខាងនៃកិច្ចសន្យា។
- ប្រសិនបើភាគីនៃកិច្ចសន្យាចង់បង្ហាញឆន្ទះរំលាយកិច្ចសន្យា ឬក៏ធ្វើលិខិតដាស់តឿនអោយអនុវត្តកាតព្វកិច្ចនោះត្រូវធ្វើលិខិតជូនដំណឹងទៅដល់ភាគីម្ខាងទៀតដែលគិតថាភាគីម្ខាងទៀតប្រាកដជាបានទទួលលិខិតនោះយ៉ាងពិតប្រាកដ។

**ការសងសំណងការខូចខាត**

- ត្រូវមានខសន្យាចែងអោយច្បាស់នៅក្នុងកិច្ចសន្យា ពីសំណងការខូចខាតនៅពេលដែលភាគីណាម្ខាងមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ព្រោះថាធ្វើបែបនេះភាគីនៃកិច្ចសន្យាអាចដឹងពីសំណងការខូចខាតមុន ដើម្បីចាប់បង្ខំភាគីនៃកិច្ចសន្យាអោយអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានផងដែរ។ ក្នុងករណីដែលភាគីនៃកិច្ចសន្យាបញ្ជាក់ពីការខូចខាតនៅក្រោយពេលកិច្ចសន្យាមិនត្រូវបានអនុវត្តកាតព្វកិច្ចពីភាគីម្ខាងហើយ វានឹងអាចធ្វើភាគីនៃកិច្ចសន្យាពិបាកទទួលយក និងមិនត្រូវរ៉ូវគ្នាក្នុងការសងសំណងការខូចខាត។
- ប្រសិនបើភាគីម្ខាងនៃកិច្ចសន្យាមិនអាចសងសំណងការខូចខាតបានទេ ភាគីដែលមានសិទ្ធិទារសំណងការខូចខាតត្រូវមានការយោគយល់ ដោយអោយភាគីជាប់បន្ទុកគាត់អាចប្រាប់ពីលទ្ធភាពត្រឹមកម្រិតមួយដែលគាត់អាចសងបាន ឬក៏ម្ចាស់បំណុលអាចរឹបអុសយកកម្មវត្ថុពីកូនបំណុលដែលមានតម្លៃសមមូលនឹងសំណងការខូចខាតនោះ។

ជាទីចុងបញ្ចប់ ការរំលាយកិច្ចសន្យា នឹងអាចជាវិធីសង្គ្រោះដ៏ល្អមួយដល់ជនរងគ្រោះនៅពេលដែលភាគីនៃកិច្ចសន្យាបានបង្កើតកិច្ចសន្យាមួយដែលមិនមានភាពច្បាស់លាស់ និងមិនមានខសន្យាមួយចំនួនពីការព្យាករណ៍ទុកជាមុននៅពេលភាគីម្ខាង នៃកិច្ចសន្យាអញ្ញមញ្ញបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួននោះភាគីដែលរងការខូចខាតនៅផលប្រយោជន៍ អាចនឹងមិនមានឱកាសការសងត្រឡប់មកវិញនូវសំណងការខូចខាត។

# ឯកសារយោង

# ឯកសារយោង

## រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣។

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ចុះថ្ងៃទី០៨ ធ្នូ ២០០៧។
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៦/០២១, ចុះថ្ងៃទី០៦ កក្កដា ២០០៦។
- ច្បាប់ស្តីពីមជ្ឈត្តកាផ្នែកពាណិជ្ជកម្ម, លេខ នស/រកម/០៥០៦/០១០, ចុះថ្ងៃទី០៦ មីនា ២០០៦។
- ក្រឹត្យ-ច្បាប់ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា, លេខ ៣៨ក្រ.ច, ចុះថ្ងៃទី២៨ តុលា ១៩៨៨។
- វិធានស្តីពីមជ្ឈត្តការរបស់មជ្ឈមណ្ឌលជាតិ នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា, រាជធានីភ្នំពេញ ១១ កក្កដា ២០១៤ ។

## សៀវភៅតែងនិពន្ធ

- ក្រុមការងារនៃគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ភ្នំពេញ៖ ខែមីនា ឆ្នាំ ២០១៧, *សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ភាគ១ ដល់ ភាគ៣*។
- គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី និង ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី, ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០០៩-២០១០, *សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ១ ដល់ ភាគ៦*។
- គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់. ២០០៧. *សន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី*, ភ្នំពេញ៖ ទីស្តីការគណៈរដ្ឋមន្ត្រី។
- ចាត សូរិៈ. ២០១២. *នីតិកិច្ចសន្យា.* ភ្នំពេញ។
- ជ្រា ឈុនឡេង. ស៊ុយ វុឌ្ឍី, កែសម្រួល. ២០១៨. *ច្បាប់កិច្ចសន្យា,* បោះពុម្ពលើកទី២។
- ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ. ២០១៤. *សេចក្តីផ្តើមនីតិរដ្ឋប្បវេណី.* ភ្នំពេញ។
- ស្ទីវិន អ៊ែម អូស្ទើរមីឡឺរ៍. ២០១០. *ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា.* បោះពុម្ពលើកទី២. ប្រទេសកម្ពុជា។
- វចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត។

– អៀង សំណាង. ២០២១. *ច្បាប់កិច្ចសន្យា*។

**ឯកសារពិភាក្សា**

– គី ប៊ុនទ្រាន. នីតិវិធីរដ្ឋប្បវេណី. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ។
– ជួប បិតបេរបូទ្ធិ. គ្មានកាលបរិច្ឆេទ. *អត្ថបទស្តីពីល័ក្ខខ័ណ្ឌសុពលភាព និងការរំលាយកិច្ចសន្យា។*
– ញឹក វុធ្វី. នីតិកាតព្វកិច្ច, ភាគទី២. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ។
– តុប ដាវី. សូ សុវណ្ណារិទ្ធិ, ផ្តល់ប្រឹក្សា. ១១ កញ្ញា ២០១៩. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា*។
– នីតិកោសល, កែសម្រួល. ២០២០. *ការរំលាយកិច្ចសន្យា សំណងខូចខាត និងការទទួលបន្ទុកហានិភ័យ.* ភ្នំពេញ។
– ប៉ូលី បញ្ញា. នីតិវិនិយោគ. មេរៀនសម្រាប់ថ្នាក់អនុបណ្ឌិត, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ។
– មេធាវីតម្រាច្បាប់, ចែករំលែក. គ្មានកាលបរិច្ឆេទ. *កិច្ចការពារតតិយជនពាក់ព័ន្ធនឹងការលុបចោល និងការរំលាយកិច្ចសន្យា.* ភ្នំពេញ។
– រស់ ស៊ីសុវណ្ណា. នីតិកាតព្វកិច្ច, ភាគ១ ដល់ ភាគ៣. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, គ្មានកាលបរិច្ឆេទ។
– ហេង បូរ៉ា. នីតិកាតព្វកិច្ច និង នីតិកិច្ចសន្យា. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៣, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩។
– ហេង បូរ៉ា. នីតិកិច្ចសន្យាពិសេស. មេរៀនសម្រាប់ថ្នាក់បរិញ្ញាបត្រឆ្នាំទី៤, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៩។
– ហេង នីដា, ជា សុគន្ធមិនា, វ៉ាន់ ណារី. ២០១៦. *ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការៈ ប្រទេសកម្ពុជា និង ប្រទេសជប៉ុន.* ភ្នំពេញ។
– អ៊ីវ ប៉ូលី. ២០១៧. *ការរំលាយកិច្ចសន្យា.* វិភាគទានច្បាប់។
– អ៊ីវ ប៉ូលី. ទេព បូផល. គ្មានកាលបរិច្ឆេទ. *ការសរសេរពាក្យបណ្តឹង និង សាលក្រម*។

**និក្ខេបបទ**

– ធីម ហ៊ិន. ២០១៨. យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ. និក្ខេបបទអនុបណ្ឌិត, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

# ឧបសម្ព័ន្ធ

# តារាងបញ្ជីឧបសម្ព័ន្ធ

| លេខរៀងឧបសម្ព័ន្ធ | បរិយាយ |
|---|---|
| ឧបសម្ព័ន្ធទី ១ | គំរូកិច្ចសន្យាលក់ទិញ ដីផ្ទះ |
| ឧបសម្ព័ន្ធទី ២ | គំរូកិច្ចសន្យាជួលផ្ទះ |
| ឧបសម្ព័ន្ធទី ៣ | គំរូពាក្យបណ្តឹង |
| ឧបសម្ព័ន្ធទី ៤ | គំរូឯកសារចម្លើយ |
| ឧបសម្ព័ន្ធទី ៥ | គំរូសាលក្រមការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា |
| ឧបសម្ព័ន្ធទី ៦ | គំរូលិខិតរំលឹកដាស់តឿន |
| ឧបសម្ព័ន្ធទី ៧ | គំរូលិខិតសងប្រាក់ |
| ឧបសម្ព័ន្ធទី ៨ | គំរូលិខិតប្រគល់ ឬទទួលប្រាក់ |
| ឧបសម្ព័ន្ធទី ៩ | លិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យា |
| ឧបសម្ព័ន្ធទី ១០ | លិខិតប្រកាសរំលាយកិច្ចសន្យា |
| ឧបសម្ព័ន្ធទី ១១ | សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ៨៧៧ "ង១" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩ |
| ឧបសម្ព័ន្ធទី ១២ | សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ១០២៤ "ក១" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ |
| ឧបសម្ព័ន្ធទី ១៣ | សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ ១៣៨៣ "ញ" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ |

**ឧបសម្ព័ន្ធទី ១**

# គំរូកិច្ចសន្យាលក់ទិញ ដីផ្ទះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាលក់_ទិញដី_ផ្ទះ</u>

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.......... ក្រុមទី...........ភូមិ................. ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង..................... ហៅកាត់ថា **ភាគី "ក" ជាអ្នកទិញ** ........................................... ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ............ ចុះថ្ងៃទី..........ខែ.........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ...........ផ្លូវលេខ.......... ក្រុមទី...........ភូមិ................. ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ....................ខេត្ត/ក្រុង..................... ហៅកាត់ថា **ភាគី "ខ" ជាអ្នកលក់** ........................................... ។

***ភាគី "ក" និងភាគី "ខ" បានព្រមព្រៀងចុះកិច្ចសន្យាលក់-ទិញ តាមប្រការដូចខាងក្រោម:***

**<u>ប្រការ១:</u> អចលនទ្រព្យ ដី ឬផ្ទះ**

ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនទ្រព្យលេខ................................ចុះថ្ងៃទី.........ខែ.........ឆ្នាំ........... ចេញ ដោយស្ថាប័នមានសមត្ថកិច្ច....................................................................................... ។

**<u>ប្រការ២:</u> អំពីតម្លៃអចលនទ្រព្យ និងការទូទាត់**

ភាគីទាំងពីរបានឯកភាពលើតម្លៃអចលនទ្រព្យ គឺ....................ដុល្លារ (.......................................) ដែលត្រូវទូទាត់តាមរយ: តាមសាច់ប្រាក់សុទ្ធ នៅពេលដែល ភាគី "ខ" រៀបចំឯកសាររួចរាល់ផ្តល់ឱ្យភាគី "ក" ចុះថ្ងៃទី.........ខែ............ឆ្នាំ............. ។

**<u>ប្រការ៣:</u> ការទទួលខុសត្រូវរបស់ភាគី "ខ"**

ត្រូវបំពេញបែបបទលើឯកសារ (កាត់ឈ្មោះ) នៃអចលនទ្រព្យនេះប្រគល់ឱ្យភាគី "ក" ដោយថ្លៃចំណាយ នៃសេវា ក្នុងកាត់ឈ្មោះនេះជាការទទួលខុសត្រូវរបស់ភាគី "ខ" ។

**<u>ប្រការ៤:</u> ការទទួលខុសត្រូវរបស់ភាគី "ក"**

ភាគី "ក" មានសិទ្ធិកាន់កាប់ឯកសារទៅដំរះបញ្ជីលក់-ទិញ នៅគ្រប់ស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ៥:** កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរចំនួន ០៤ច្បាប់ សម្រាប់ភាគី"ក" និងភាគី"ខ" រក្សាទុកចំនួន ០១ច្បាប់ម្នាក់ មេធាវី ០១ច្បាប់ និងតំកល់ទុកនៅឃុំ/សង្កាត់ចំនួន ០១ច្បាប់ ។

**ប្រការ៦:** កិច្ចសន្យានេះធ្វើឡើងរវាងភាគី"ក" និងភាគី"ខ" ដោយគ្មានការបង្ខិតបង្ខំពីភាគីណាមួយឡើយ ហើយកិច្ចសន្យានេះមានសុពលភាពនៅពេលដែលចុះហត្ថលេខា និងផ្តិតស្នាមមេដៃស្តាំ ជាភស្តុតាង ។

ធ្វើនៅ................ ថ្ងៃទី..........ខែ...........ឆ្នាំ............

| **ភាគី"ខ"** | **សាក្សីភាគី"ខ"** | **សាក្សីភាគី"ក"** | **ភាគី"ក"** |
|---|---|---|---|
| ឈ្មោះ......................... | ឈ្មោះ......................... | ឈ្មោះ......................... | ឈ្មោះ......................... |

លេខ:..................

បានឃើញ និង បញ្ជាក់ថា ស្នាមមេដៃស្តាំទាំងអស់

តាមឈ្មោះរៀងគ្នាខាងលើ ពិតជាបានផ្តិតនៅចំពោះ

មុខយើងជាមេឃុំ/ចៅសង្កាត់ តាមខ្លឹមសារនៃ

កិច្ចសន្យាប្រាកដមែន ។

ធ្វើនៅ..............ថ្ងៃទី...........ខែ...........ឆ្នាំ.........

**មេឃុំ/ចៅសង្កាត់** ..................

បានឃើញ និង បញ្ជាក់ថា

ភាគីទាំងពីរបានផ្តិតមេដៃស្តាំ ចំពោះមុខមេធាវី

ប្រាកដមែន ។

ធ្វើនៅ............ថ្ងៃទី.........ខែ..........ឆ្នាំ.........

**មេធាវី**

**ឧបសម្ព័ន្ធទី ២**

**គំរូកិច្ចសន្យាជួលផ្ទះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

***

**<u>កិច្ចសន្យាជួលផ្ទះ</u>**

**<u>ភាគីម្ចាស់ផ្ទះ:</u>** យោងទៅលើកិច្ចសន្យានេះលោក......................ភេទ...........អាយុ..........ជនជាតិ...............

កាន់អត្តសញ្ញាប័ណ្ណលេខ.................... ជាម្ចាស់ ផ្ទះលេខ........... ផ្លូវលេខ

...................................សង្កាត់...........................................

ខណ្ឌ.............................រាជធានីភ្នំពេញ (ដែលហៅថាភាគី "ក") បានព្រមព្រៀងជួលផ្ទះលេខ

........... ផ្លូវលេខ ........................................ សង្កាត់ ...............................

ខណ្ឌ...........................................រាជធានីភ្នំពេញ ដែលហៅថា "ផ្ទះជួល" ទៅអោយ :

**<u>ភាគីអ្នកជួល:</u>** ................................... ភេទ .........សញ្ជាតិ ....... មុខរបរ ......................

កាន់អត្តសញ្ញាប័ណ្ណលេខ.................... ......................ដែលហៅថាភាគី "ខ" ។

**ភាគីទាំងពីរព្រមព្រៀងគ្នាក្នុងការជួលផ្ទះខាងលើដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម:**

<u>ប្រការ១:</u> **រយៈពេលនៃកិច្ចសន្យាជួល**

រយៈពេលនៃកិច្ចសន្យាជួលផ្ទះនេះមានចំនួន...................ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ......... ខែ .........

ឆ្នាំ២០១៣ ដល់ ថ្ងៃទី .................. ខែ .............. ឆ្នាំ២០១៣ ក្នុងតំលៃឈ្នួលមួយខែចំនួន

.........................ដុល្លារ (.................................................ដុល្លារសហរដ្ឋអាមេរិក)

ដោយមិនបញ្ចូលថ្លៃ ប្រើប្រាស់ទឹក ភ្លើង ទូរស័ព្ទ ខ្សែកាប អ៊ិនធឺណែតរបស់ភាគី "ខ" ឡើយ ។

<u>ប្រការ២:</u> **ការបង់ប្រាក់**

-ភាគី “ខ” នឹងបង់ប្រាក់កក់ទៅអោយភាគី “ក” សំរាប់រយៈពេល០........ខែទុកគិតលើចុងក្រោយនៃកិច្ចសន្យា នេះចំនួន.................ដុល្លារ (.........................................ដុល្លារសហរដ្ឋអាមេរិក) ប្រាក់ដំកល់នេះភាគី “ក” និងប្រគល់ជូនវិញនៅចុងបញ្ចប់នៃកិច្ចសន្យា ។

-ប្រាក់បង់មុនចំនួន០......ខែសំរាប់ការស្នាក់នៅដំបូងដែលមានចំនួន...............ដុល្លារ(.......................................................................ដុល្លារសហរដ្ឋអាមេរិក) គឺគិតចាប់ពី ថ្ងៃទី ........ ខែ ........ ឆ្នាំ ២០១៣ ដល់ ថ្ងៃទី ...........ខែ ........ ឆ្នាំ ២០១៣ គឺនៅពេលចុះហត្ថលេខាលើកិច្ចសន្យាជួលផ្ទះនេះ ។

-ការបង់ប្រាក់ឈ្នួលផ្ទះបន្ទាប់គឺនៅថ្ងៃទី ........... ខែ .........ឆ្នាំ ២០១៣ នឹង រៀងរាល់ ថ្ងៃទី .................នៃខែនិមួយៗ មិនអោយហួសពីមួយសប្តាហ៍ឡើយ ។

<u>ប្រការ៣ៈ</u> **ការបញ្ចប់កិច្ចសន្យាជួល**

ក) កិច្ចសន្យានេះនឹងបញ្ចប់ដោយស្វ័យប្រវត្តិនៅថ្ងៃ ទី ........ ខែ ..........ឆ្នាំ ២០១៣ ។

ខ) កិច្ចសន្យានេះនឹងពិភាក្សាឡើងវិញដោយភាគីទាំងពីរគឺភាគី “ក” និង ភាគី “ខ” ជាត្រូវជួលបន្តឬក៏បញ្ឈប់កិច្ចសន្យា ។

គ) ក្នុងរយៈពេលនៃកិច្ចសន្យានេះភាគីទាំងពីរមិនមានសិទ្ធិបញ្ឈប់កិច្ចសន្យានេះមុនពេលកំណត់បានទេ ក្នុងករណីភាគី “ខ” បញ្ឈប់កិច្ចសន្យានេះមុនពេលកំណត់នោះប្រាក់កក់ដំកល់មួយខែនឹងមិនប្រគល់ជូនភាគី “ខ” វិញឡើយប៉ុន្តែប្រសិនបើភាគី “ក” មានបំណងចង់បញ្ឈប់កិច្ចសន្យានេះមុនពេលកំណតវិញ ភាគី “ក” ត្រូវប្រគល់ប្រាក់កក់ដំកល់.........................ខែទៅអោយភាគី “ខ” វិញហើយត្រូវបង់ថ្លៃសងជំងឺចិត្តចំនួន០...................ខែបន្ថែមទៀតទៅអោយភាគី “ខ” ។

ខ) ភាគី "ខ" ធានាក្នុងការជួសជុលដោយខ្លួនឯងក្នុងរយៈពេលជួលនេះ និងត្រូវធ្វើការត្រួតពិនិត្យ ថែរក្សា និងជួសជុលសំភារៈបរិក្ខារផ្សេងៗដែលបានផ្តល់ជូន ។

គ) នៅថ្ងៃចប់កិច្ចសន្យាភាគី "ខ" ត្រូវប្រគល់ជូនវិញនូវសំភារៈដែលបានផ្តល់ទៅតាមបញ្ជីសំភារៈក្នុងលក្ខណៈល្អ ។

ឃ) ភាគី "ខ" ត្រូវធ្វើការជួសជុលឡើងវិញ នូវរាល់ការខូចខាតចំពោះបរិក្ខារទាំងឡាយណាដែលបានផ្តល់ជូនដោយភាគី "ក" ដោយការខូចខាតបាក់បែកនោះមិនបណ្តាលមកពីការសឹករិចរឹល, ខូចខាតដោយគ្រោះ ធម្មជាតិ ។

ប្រការ៩: ភាគី "ក" ត្រូវទទួលខុសត្រូវលើការបង់ពន្ធទាំងឡាយដែលទាក់ទងទៅការជួលផ្ទះនេះចំណែកពន្ធលើអាជីវកម្មផ្សេងៗវិញ ជាបន្ទុករបស់ភាគី "ខ" ។

<u>ប្រការ១០:</u> ភាគី "ខ" មិនត្រូវបង្កអោយមានភាពរំខានដល់អ្នកជិតខាង ។

<u>ប្រការ១១:</u> ភាគីទាំងពីរត្រូវគោរពទៅតាមលក្ខខ័ណ្ឌនិងរាល់ប្រការនៃកិច្ចសន្យាខាងលើ ។

ប្រសិនបើភាគីណាមួយអនុវត្តខុសពីកិច្ចសន្យាខាងលើនេះត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។ កិច្ចសន្យានេះធ្វើឡើងជាបួនច្បាប់ ពីរច្បាប់ជាភាសាខ្មែរ និង ពីរច្បាប់ទៀតជាភាសា អង់គ្លេស ដែលមានតំលៃស្មើគ្នាចំពោះមុខច្បាប់ ។

ភ្នំពេញ, ថ្ងៃទី......ខែ......ឆ្នាំ ២០១៣

ហត្ថលេខា (ឬស្នាមមេដៃ) ភាគី "ក" | ហត្ថលេខា (ឬស្នាមមេដៃ) ភាគី "ខ"

សាក្សី | សាក្សី

ឧបសម្ព័ន្ធទី ៣

គំរូពាក្យបណ្ដឹង

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្ដឹង

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី[1]។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ..................................................

លេខទូរស័ព្ទ ៖ ..................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................. [2]

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

---

[1] ឈ្មោះ និងអាសយដ្ឋាន មានបញ្ញត្តិនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ប៉ុន្តែចំពោះចំណុចផ្សេងទៀត ដូចជា ថ្ងៃខែឆ្នាំកំណើតជាអាទិ៍ ជាចំណុចដែលពុំមានបញ្ញត្តិក្នុងច្បាប់ទេ។ ប៉ុន្តែ ក៏មានករណីដែលពុំអាចកំណត់អំពីភាគី តាមរយៈឈ្មោះ និង អាសយដ្ឋានបានផងដែរ ដូច្នេះ ត្រូវសរសេរចំណុចទាំងនោះក្នុងកម្រិតមួយដែលចាំបាច់ ដើម្បីអាចកំណត់អំពីភាគី។

[2] មាត្រា ២៤៩ និងមាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការដាក់ពីទីកន្លែងដែលត្រូវបញ្ជូន មិនមែនជាកាតព្វកិច្ចនោះទេ។ ប្រសិនបើពុំមានការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូនទេ ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅឋានរបស់ដើមចោទ ជាអាទិ៍។ ហេតុនេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ដើមចោទមានបំណងធ្វើការបញ្ជូនទៅកាន់ទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ដើមចោទជាអាទិ៍ គឺមានភាពចំបាច់ក្នុងការសរសេរអំពីទីកន្លែងដែលត្រូវបញ្ជូននៅក្នុងលិខិតពាក្យបណ្ដឹងជាអាទិ៍។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងខេត្តរតនគិរី**[3]

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**[4] **៖**

(១) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។[5]

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។[6]

---

[3] ដើមចោទត្រូវតែដាក់ពាក្យបណ្ដឹងទៅតុលាការដែលមានសមត្ថកិច្ច (មាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ សមត្ថកិច្ចសាលាជម្រះក្ដីត្រូវកំណត់តាមពេលដាក់ពាក្យបណ្ដឹង (មាត្រា ១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

នៅក្នុងរឿងក្ដីនេះ លំនៅឋានរបស់ចុងចម្លើយ នៅរាជធានីភ្នំពេញ ដូច្នេះ សាលាដំបូងរាជធានីភ្នំពេញមានសមត្ថកិច្ចជម្រះក្ដី (ចំណុច ក មាត្រា ៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត ដោយសារតែរឿងក្ដីនេះ គឺជារឿងក្ដីដែលទាមទារឲ្យធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ (បណ្ដឹងទាក់ទងនឹងការចុះបញ្ជី) ដូច្នេះ តុលាការដែលមានសមត្ថកិច្ចទៅលើ "ទីកន្លែងដែលត្រូវចុះបញ្ជី" មានសមត្ថកិច្ចជម្រះក្ដី (ចំណុច ជ មាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ "ទីកន្លែងដែលត្រូវចុះបញ្ជី" គឺជា "រដ្ឋបាលសុរិយោដី រាជធានី ខេត្តដែលអចលនវត្ថុស្ថិតនៅ (ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្ដីនេះ ដោយសារតែអចលនវត្ថុស្ថិតនៅខេត្តរតនគិរី ដូច្នេះហើយ រដ្ឋបាលសុរិយោដីខេត្តរតនគិរី គឺជា "ទីកន្លែងដែលត្រូវចុះបញ្ជី" ហើយសាលាដំបូងខេត្តរតនគិរីដែលមានសមត្ថកិច្ចនៅទីនោះ ក៏មានសមត្ថកិច្ចជម្រះក្ដីដែរ។

ដើមចោទ អាចដាក់ពាក្យបណ្ដឹងទៅតុលាការណាមួយក៏បានដូចជាសាលាដំបូងរាជធានីភ្នំពេញ ឬ សាលាដំបូងខេត្តរតនគិរី ប៉ុន្តែ នៅក្នុងរឿងក្ដីនេះ ដោយសារតែដើមចោទកំពុងរស់នៅខេត្តរតនគិរី ហេតុនេះក៏បានដាក់ពាក្យបណ្ដឹងទៅសាលាដំបូងខេត្តរតនគិរី។

[4] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[5] អ្នកចុះបញ្ជី គឺជាមន្ត្រីសុរិយោដី (ប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមរដ្ឋប្បវេណី (តទៅនៅពេលដែលហៅដោយសង្ខេបថា "ប្រកាសអន្តរក្រសួង" ដែលសំដៅទៅលើប្រកាសអន្តរក្រសួងនេះ ) មាត្រា ៩០) មិនមែនជាចុងចម្លើយទេ។ ចុងចម្លើយមានកាតព្វកិច្ចធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី (មាត្រា ១០ កថាខណ្ឌទី ១ នៃប្រកាសអន្តរក្រសួង) ពោលគឺ ចុងចម្លើយមានកាតព្វកិច្ចមិនលើសពីការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជីឡើយ។ នៅពេលដែលសាលក្រមបង្គាប់ទៅចុងចម្លើយអំពីការត្រូវធ្វើការបង្ហាញឆន្ទៈក្នុងការដាក់ពាក្យសុំចុះបញ្ជី (ធ្វើនីតិវិធីដាក់ពាក្យសុំចុះបញ្ជី) បាន ចូលជាស្ថាពរ នឹងត្រូវបានចាត់ទុកថា ចុងចម្លើយបានធ្វើការបង្ហាញឆន្ទៈនៅពេលចូលជាស្ថាពរនោះ (មាត្រា ៥២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ជាងនេះទៅទៀត ដើមចោទដែលជាអ្នកមានសិទ្ធិចុះបញ្ជីនៅពេលដែលទទួលបានសាលក្រមស្ថាពរដែលបង្គាប់អំពីនីតិវិធីចុះបញ្ជីមកធ្វើជាលិខិតអនុវត្ត គឺអាចដាក់ពាក្យសុំចុះបញ្ជីតែម្នាក់ឯងបាន (មាត្រា ១០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ មន្ត្រីសុរិយោដីនឹងមានកាតព្វកិច្ចចុះបញ្ជីនៅពេលដែលចាប់ផ្ដើមមានពាក្យសុំ (ប្រកាសដដែល មាត្រា ៦ កថាខណ្ឌទី ២)។ វានឹងមិនអាចទៅរួចឡើយដែលមន្ត្រីសុរិយោដីមានកាតព្វកិច្ចចុះបញ្ជី ទាំងពុំមានពាក្យសុំពីភាគី។

[6] តុលាការត្រូវសម្រេចសេចក្ដីអំពីករណីយកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ (កថាខណ្ឌទី ៣ មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ហើយ ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់ភាគីចាញ់ក្ដី (មាត្រា ៦៤ កថាខណ្ឌទី ១)។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និង អង្គហេតុដែលជាមូលហេតុនៃការទាមទារ [7]

### ខ.១. ការបង្កើតកិច្ចសន្យាលក់ទិញ [8]

**ខ.១.១.** នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទបានលក់អចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដី L") ក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិកទៅឲ្យចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ") ។ **(ភស្តុតាង $X_1$)**

**ខ.១.២.** ដើមចោទ និង ចុងចម្លើយបានធ្វើលិខិតយថាភូត (លិខិតលក់ផ្តាច់) ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។ **( ភស្តុតាង $X_1$)**

**ខ.១.៣.** ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាដូចខាងក្រោមអំពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់៖

**ក.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃថ្លៃលក់ នឹងបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

**ខ.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ នឹងត្រូវបង់នៅក្នុងអំឡុងពេល ១ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

---

[7] អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរនៅក្នុងពាក្យបណ្តឹង (ចំណុច ខ កថាខណ្ឌទី ២ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងទៀត នៅក្នុងពាក្យបណ្តឹង ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង តាមចំណុចដែលត្រូវការបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[8] កិច្ចសន្យាលក់ទិញ អាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ (មាត្រា ៥១៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះ "បញ្ញត្តិពិសេសក្នុងច្បាប់" មានដូចជា កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី។ ពោលគឺ ក្នុងករណីកិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែល "ភាគីម្ខាងមានករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ" កិច្ចសន្យានេះ នឹងមានអានុភាពលុះត្រាតែបានធ្វើលិខិតយថាភូត (កថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី)។ ចំពោះអត្ថន័យនៃ "លិខិតយថាភូត" ក្នុងកថាខណ្ឌទី ២ មាត្រា ៣៣៦ នៃក្រមរដ្ឋប្បវេណី ត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

### ខ.២. ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុចុងចម្លើយមិនអនុវត្តកាតព្វកិច្ច[9]

**ខ.២.១.** នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទ និង ចុងចម្លើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលទៅរដ្ឋបាលសុរិយោដីខេត្តរតនគិរីដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។ **(ភស្តុតាង $X_2$)**

**ខ.២.២.** ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត។

**ខ.២.៣.** នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ ដើមចោទបានដាស់តឿន[10]ទៅចុងចម្លើយឲ្យបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ

---

[9] ភាគីម្ខាងនៃកិច្ចន្យាអញ្ញមញ្ញអាចរំលាយកិច្ចសន្យាបានភ្លាមៗ ក្នុងករណីដែលភាគីម្ខាងទៀត "បំពានកិច្ចសន្យាធ្ងន់ធ្ងរ" (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី)។

ជាដំបូង កិច្ចសន្យាលក់ទិញ គឺជាកិច្ចសន្យាដែលភាគីម្ខាងហៅថា អ្នកលក់មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឲ្យទៅភាគីម្ខាងទៀតហៅថា អ្នកទិញ ហើយអ្នកទិញមានករណីយកិច្ចត្រូវចេញថ្លៃជាប្រាក់ឲ្យអ្នកលក់ (មាត្រា ៥១៥ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ កិច្ចសន្យានេះ គឺជាកិច្ចសន្យាអញ្ញមញ្ញ។

បន្ទាប់មកទៀត ចំពោះខ្លឹមសារនៃ "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" គឺត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី។ ភាគីម្ខាងនៃកិច្ចសន្យាដែលចង់រំលាយកិច្ចសន្យាអញ្ញមញ្ញ ចាំបាច់ត្រូវអះអាងអំពីមូលហេតុដែលត្រូវបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រាដដែលនេះ។

ហើយ ភាគីម្ខាងនៃកិច្ចសន្យាដែលមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយកិច្ចសន្យាដោយការបង្ហាញឆន្ទៈអំពីការរំលាយទៅភាគីម្ខាងទៀតបាន។ **ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចធ្វើឡើងនៅក្រៅតុលាការបាន (កថាខណ្ឌទី ១ មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី) ដើម្បីអះអាងអំពីការរំលាយកិច្ចសន្យា ពុំចាំបាច់ធ្វើការដាក់ពាក្យបណ្តឹងទេ។**

**ការរំលាយកិច្ចសន្យានាំឲ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសងការខូចខាត (កថាខណ្ឌទី ១ មាត្រា ៤១១ នៃក្រមរដ្ឋប្បវេណី)។ ម្យ៉ាងវិញទៀត ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ (កថាខណ្ឌទី ២ មាត្រា ៤១១នៃក្រមរដ្ឋប្បវេណី)។ ក្នុងករណីដែលដើមចោទពុំមានតាវកាលិកដែលចង់ទាមទារឲ្យចុងចម្លើយដែលជាភាគីម្ខាងទៀតសងមកវិញទេនោះ គ្រាន់តែបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាទៅកាន់ចុងចម្លើយនៅក្រៅតុលាការ គឺជាការគ្រាប់គ្រាន់ ហើយពុំចាំបាច់ដាក់ពាក្យបណ្តឹងមកកាន់តុលាការទេ។**

[10] នៅក្នុងរឿងក្តីនេះ ដោយហេតុថា ដើមចោទកំពុងតែអះអាងអំពី "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ផ្អែកតាមចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ដូច្នេះហើយ ចាំបាច់ត្រូវតែអះអាងអំពី ① កាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ (ថ្ងៃទី ៣១ ខែ វិច្ឆិកា ឆ្នាំ ២០១៨) បានកន្លងផុត ("ខ.២.១." និង "ខ.២.២.") និង ② ការបានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ ("ខ.២.៣.")។

នៅក្នុងអំឡុងពេល២សប្តាហ៍ ជាមួយគ្នានេះ ក៏បានធ្វើការបង្ហាញឆន្ទៈ[11] អំពីការរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" នៅពេលដែលមិនបានបង់ប្រាក់ថ្លៃលក់នៅក្នុងអំឡុងពេល ២សប្តាហ៍។ **(ភស្តុតាង $X_3$)**

**ខ.២.៤.** ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះទេ គិតមកដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ។[12]

**ខ.២.៥.** នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ បានផ្តល់នូវការប្រគល់ "ដីL" ទៅចុងចម្លើយ ផ្អែកតាម "កិច្ចសន្យានៃរឿងក្តីនេះ" ។[13] **(ភស្តុតាង $X_4$)**

**ដូច្នេះ ដើមចោទទាមទារឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ដោយផ្អែកលើកការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។**[14]

## គ. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តីនៃរឿងក្តីនេះ គប្បីជាបន្ទុករបស់ចុងចម្លើយ (កថាខណ្ឌទី ១ មាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

---

[11] ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា អាចដាក់លក្ខខណ្ឌបង្អង់បាន (កថាខណ្ឌទី ៣ មាត្រា ៤០៩ និង វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ នៅពេលដែលបង្ហាញឆន្ទៈរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទបានដាក់លក្ខខណ្ឌបង្អង់ថា "បើមិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន (អំឡុងពេល ២សប្តាហ៍) ។

[12] ដើមចោទអះអាងអំពីលក្ខខណ្ឌបង្អង់ ( លក្ខខណ្ឌដែលលើកឡើងថា "មិនបង់ប្រាក់នៅក្នុងអំឡុងពេលដាស់តឿន") ដែលបានដាក់នៅពេលបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យា គឺត្រូវបានបំពេញ (កថាខណ្ឌទី ៣ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី)។

[13] អ្នកទិញអាចមិនព្រមបង់ប្រាក់ថ្លៃទិញបាន រហូតដល់ពេលដែលអ្នកលក់បានផ្តល់នូវការសងចំពោះកាតព្វកិច្ចរបស់ខ្លួន (កថាខណ្ឌទី ១ មាត្រា ៥៥៨ នៃក្រមរដ្ឋប្បវេណី)។ ដូច្នេះហើយ ទោះបីជាអ្នកទិញមិនបានអនុវត្តកាតព្វកិច្ចបង់ថ្លៃទិញក៏ដោយ ដរាបណានៅក្នុងអំឡុងពេលដែលត្រូវទទួលនូវការផ្តល់ការសងកាតព្វកិច្ចរបស់អ្នកលក់ គឺមិនអាចនិយាយថា "បំពានកិច្ចសន្យាធ្ងន់ធ្ងរ"បានទេ។

នៅក្នុងរឿងក្តីនេះ ដើមចោទដែលជាអ្នកលក់ ក្រៅពីមានករណីយកិច្ចធ្វើការចុះបញ្ជីផ្ទេរកម្មសិទ្ធិ នៅមានករណីយកិច្ចប្រគល់ដី L (មាត្រា ៥៣០ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ បើសិនជាមិនអះអាងអំពីការបានធ្វើនីតិវិធីផ្ទេរកម្មសិទ្ធិ ("ខ.២.១.") ហើយបន្ថែមនូវការអះអាងអំពីការបានផ្តល់នូវការប្រគល់ដី L ("ខ.២.៥.") ទេនោះ មិនអាចនិយាយបានថា ការមិនអនុវត្តករណីយកិច្ចបង់ថ្លៃទិញរបស់ចុងចម្លើយ គឺជា "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" បានទេ។

[14] បញ្ជាក់ឲ្យបានច្បាស់អំពីសារធាតុគតិយុត្តនៃសិទ្ធិទាមទារ។

**ខ. ភស្តុតាង**

១. លិខិតលក់ផ្តាច់ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ **(ភស្តុតាង $X_1$)**

២. ច្បាប់ចម្លងនៃពាក្យសុំចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ **(ភស្តុតាង $X_2$)**

៣. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩) **(ភស្តុតាង $X_3$)**

៤. រូបថត (សារនៅក្នុងTelegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) **(ភស្តុតាង $X_4$)**

សេចក្តីដូចមានកំណត់ សូម **លោកប្រធាន** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។ សូម **លោកប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

ខេត្តរតនគិរី, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

ឧបសម្ព័ន្ធទី ៤

គំរូឯកសារចម្លើយ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ឯកសារចម្លើយ[1]

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រីមេធាវី ៖ B

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..............................

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖..................................................

លេខទូរស័ព្ទ ៖....................................................

**ទីកន្លែងបញ្ជូន** ៖ ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី.................[2]

---

[1] ឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការជាលើកដំបូង ហៅថា "ឯកសារចម្លើយ"។ នៅក្នុងឯកសារនេះនឹងត្រូវសរសេរអំពី ① ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទបានសរសេរនៅក្នុងពាក្យបណ្ដឹង ② ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង និង ③ អង្គហេតុដើម្បីតវ៉ាចំពោះអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង (កថាខណ្ឌទី៣ មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] មាត្រា ២៤៩ និង មាត្រា ២៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ការសរសេរអំពីកន្លែងបញ្ជូន មិនមែនជាកាតព្វកិច្ចទេ។ ប្រសិនបើមិនបានសរសេរអំពីទីកន្លែងបញ្ជូន ការបញ្ជូននឹងត្រូវធ្វើឡើងនៅលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍។ ដូច្នេះ ក្នុងករណីដែលអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយចង់ធ្វើការបញ្ជូនទៅទីកន្លែងណាផ្សេងក្រៅពីលំនៅដ្ឋានរបស់ចុងចម្លើយជាអាទិ៍ ចាំបាច់ត្រូវសរសេរអំពីកន្លែងបញ្ជូនចូលទៅក្នុងលិខិតលាយលក្ខណ៍អក្សរ ដូចជា ឯកសារចម្លើយជាអាទិ៍។

**សូមគោរពជូន**

**លោក ៸ ចៅក្រមនៃសាលាដំបូងខេត្តរតនគិរី**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់**ឯកសារចម្លើយដើម្បីឆ្លើយ**តបនឹងពាក្យបណ្តឹងចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ របស់ឈ្មោះ X

**<u>យោង</u>**៖-មាត្រា **១០១ កថាខណ្ឌទី ៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ .........ចុះថ្ងៃទី០១ ខែ មីនា ឆ្នាំ ២០១៩

## ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ

(១) ច្រានចោលការទាមទាររបស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## ខ. ការទទួលស្គាល់ ឬ មិនទទួលស្គាល់នូវអង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្តឹង

### ខ.១. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការបង្កើតកិច្ចសន្យាលក់ទិញនៃចំណុច ខ.១." នៅក្នុងពាក្យបណ្តឹង

**ខ.១.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.១."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.២."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.១.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.១.៣."** នៃពាក្យបណ្តឹង ៖ ចុងចម្លើយទទួលស្គាល់ ។

### ខ.២. ការទទួលស្គាល់ ឬ មិនទទួលស្គាល់អំពី "ការរំលាយកិច្ចសន្យាលក់ទិញដោយមូលហេតុចុងចម្លើយមិនអនុវត្តកាតព្វកិច្ចនៃចំណុច "ខ.២." នៅក្នុងពាក្យបណ្តឹង[3]

[3] អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច "ខ.២.២." នៃពាក្យបណ្តឹង (ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត) គឺជា "អង្គហេតុដែលអត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែងចំពោះតុលាការ" (កថាខណ្ឌទី ២ មាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ តុលាការពុំចាំបាច់ទទួលស្គាល់ដោយផ្អែកលើភស្តុតាងទេ។ ហេតុនេះ ភាគីក៏ពុំចាំបាច់ធ្វើការទទួលស្គាល់ ឬ មិនទទួលស្គាល់ដែរ។

**ខ.២.១.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.១."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.២.២.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៣."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.២.៣.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៤."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

**ខ.២.៤.** អង្គហេតុដែលត្រូវបានសរសេរនៅក្នុងចំណុច **"ខ.២.៥."** នៃពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ ។

## គ. អង្គហេតុតវ៉ា

### គ.១. ការព្រមព្រៀងអំពីការផ្លាស់ប្ដូរកាលបរិច្ឆេទអនុវត្ត[4]

**គ.១.១.** នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងអំពីការផ្លាស់ប្ដូរកាលបរិច្ឆេទបង់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលមិនទាន់បានបង់នៃប្រាក់ថ្លៃលក់ទិញក្នុង "កិច្ចសន្យាលក់ទិញនៃរឿងក្ដីនេះ" ពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ ទៅជាថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៩។[5]

---

[4] លក្ខខណ្ឌមួយនៃ "ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ" ដែលមាននៅក្នុងចំណុច ក កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី គឺ "ភាគីម្ខាង "មិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់" ។ ប្រសិនបើ "ពេលកំណត់" នេះត្រូវបានផ្លាស់ប្ដូរ ហើយភាគីម្ខាងបានអនុវត្តសិទ្ធិរំលាយនៅពេលដែលអំឡុងពេលអនុវត្តកាតព្វកិច្ចមិនទាន់បានមកដល់ គឺមានន័យថាមិនទាន់បានបំពេញលក្ខខណ្ឌដែលលើកឡើងថា "មិនបានអនុវត្តតាមពេលកំណត់" នៅឡើយទេ ហេតុនេះ ភាគីម្ខាងមិនអាចរំលាយកិច្ចសន្យាបានទេ។ ដូច្នេះ កាលបរិច្ឆេទអនុវត្តដែលត្រូវបានផ្លាស់ប្ដូរ នឹងមានតួនាទីសម្រាប់ធ្វើជាការតវ៉ាអំពី ការរំលាយកិច្ចសន្យាដោយមូលហេតុការមិនអនុវត្តកាតព្វកិច្ច។

[5] អង្គហេតុដែលសរសេរនៅក្នុងចំណុច "គ.១.១." ពុំមានឯកសារបញ្ជាក់ដោយផ្ទាល់ទៅលើចំណុចនេះទេ (ឧទាហរណ៍៖ សារដែលដើមចោទបានយល់ព្រមទៅលើចំណុចនោះ)។

ប៉ុន្តែ ដើមចោទកំពុងតែអះអាងអំពីការកន្លងផុតនៃថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលជាកាលបរិច្ឆេទអនុវត្តកាតព្វកិច្ចនៅពេលដំបូងដោយគិតជាមុនថាកាលបរិច្ឆេទអនុវត្តកាតព្វកិច្ចមិនត្រូវបានផ្លាស់ប្ដូរទេ ដូច្នេះហើយ តុលាការព្យាករថា ការព្រមព្រៀងអំពីការផ្លាស់ប្ដូរកាលបរិច្ឆេទអនុវត្ត ប្រាកដជាមានវិវាទ។

ដូច្នេះហើយ ក្នុងនាមជាចុងចម្លើយ គប្បីអះអាងទុកជាមុនអំពី អង្គហេតុសំខាន់ (គ.១.២.) ដែលជាអង្គហេតុដែលពាក់ព័ន្ធនឹងការព្រមព្រៀងអំពីការផ្លាស់ប្ដូរកាលបរិច្ឆេទ ទើបជាការប្រសើរ។ ចំណុចនេះគឺមានគោលបំណងដូចគ្នាទៅនឹងការកំណត់ដែលលើកឡើងថា "នៅក្នុងពាក្យបណ្ដឹង តាមចំណុចដែលត្រូវបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុដែលជាមូលហេតុនៃការទាមទារ និង ភស្តុតាង (កថាខណ្ឌទី ៣ មាត្រា ៧៥ នៃក្រមរដ្ឋប្បវេណី)។

**គ.១.២.** ការព្រមព្រៀងនៅក្នុងចំណុច "**គ.១.១.**" ខាងលើ ដោយចុងចម្លើយធ្វើសំណើអំពីការផ្លាស់ប្តូរទៅកាន់ដើមចោទ ហើយដើមចោទបានធ្វើស្វីការយល់ព្រមលើសំណើនោះ។ នៅខណៈពេលដែលចុងចម្លើយកំពុងរៀបចំរើចាកចេញពីភ្នំពេញទៅខេត្តរតនគិរី ត្រូវបានគេបបួលពិភាក្សារឿងដែលធ្វើឲ្យចំណេញលុយ ដោយសារតែចិត្តនឹកឃើញចង់បាន ក៏ចូលរួមនិយាយរឿងនោះ ដូច្នេះហើយក៏ត្រូវបានគេបោកយកលុយបានសម្រេច។ ហើយចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលចុងចម្លើយមានគម្រោងបង់ទៅឲ្យដើមចោទឲ្យបានត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១៨ ដែលជាគម្រោងកាលពីដើមនោះក៏ពិបាកនឹងបង់បានដែរ។ ដូច្នេះហើយ នៅពេលដែលបានទទួលការទាក់ទងពីដើមចោទអំពីការប្រគល់ "ដី L" ចុងចម្លើយក៏បានផ្ញើសារទៅវិញថា "សូមឲ្យរង់ចាំ ៣ ខែតទៀត" ។ បន្ទាប់មក ដើមចោទក៏បានទូរស័ព្ទមកចុងចម្លើយភ្លាមៗ និងក្រោយពីបានស្តាប់អំពីខ្លឹមសារដែលចុងចម្លើយត្រូវបានគេបោក ដើមចោទក៏បាននិយាយមកកាន់ចុងចម្លើយថា "ខ្ញុំដឹងហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញហើយ"។ **(ភស្តុតាង $Y_1$ និង $Y_2$)**

**គ.១.៣.** យោងតាមការព្រមព្រៀងចំណុច "**គ.១.១.**" ខាងលើនេះ ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលខ្វះត្រូវបានផ្លាស់ប្តូរកាលបរិច្ឆេទអនុវត្តបង់ប្រាក់នោះមកនៅត្រឹមថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩ វិញ។

**ដូច្នេះហើយ គិតត្រឹមថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដែលដើមចោទបានបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាគឺ ចុងចម្លើយមិនទាន់បានបំពានកិច្ចសន្យធ្ងន់ធ្ងរនៅឡើយទេ (កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះ ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទគឺ ត្រូវមោឃៈ។ ចុងចម្លើយមិនមានករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ទេ។**

**បើទោះបីជាការរំលោយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទ មានសុពលភាពក៏ដោយ ក៏ចុងចម្លើយនឹងអះអាងអំពីការតវ៉ាដូចមានខាងក្រោម ៖[6]**

**គ.២. ការអនុវត្តព្រមគ្នា**

**គ.២.១.** នៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ២០១៨ ចុងចម្លើយបានបង់ប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលជាមួយភាគនៃថ្លៃលក់ទិញដោយផ្អែកលើ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ឲ្យទៅដើមចោទ។[7] **(ភស្តុតាង$Y_3$)**

**គ.២.២.** ចុងចម្លើយបដិសេធអំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ដែរ រហូតទាល់តែដើមចោទសងប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការប្រាក់ ៥ % ក្នុងមួយឆ្នាំ ដែលគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច (កថាខណ្ឌទី ២ និង ទី ៣ មាត្រា ៥១១) ។[8]

---

[6] ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬ ទាំងអស់ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឲ្យភាគីនោះទទួលបដិទានឡើងវិញ ដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាង មានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។ (កថាខណ្ឌទី ២ មាត្រា ៥១១ នៃក្រមរដ្ឋប្បវេណី)

បើទោះបីជាការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទមានសុពលភាពក៏ដោយ ក៏ចុងចម្លើយអះអាងថា ការទាមទាររបស់ដើមចោទ (ការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" ) និង ការអនុវត្តនូវករណីយកិច្ចធ្វើបដិទានស្ថានភាពដើមដែលដើមចោទមានចំពោះចុងចម្លើយត្រូវធ្វើឡើងនៅក្នុងពេលតែមួយ ដូច្នេះហើយ ចុងចម្លើយអាចរាំងតុលាការពីការទទួលស្គាល់ទាំងមូលទៅលើការទាមទាររបស់ដើមចោទបាន។ ក្នុងករណីដែលតុលាការបានទទួលស្គាល់នូវការតវ៉ានេះ នាំឲ្យតុលាការត្រូវទទួលស្គាល់នូវការទាមទារដែលដើមចោទបានទាមទារនូវតាវកាលិកធម្មតាដោយកម្រិតនូវការផ្តល់តាវកាលិកតបវិញ (ទទួលស្គាល់មួយផ្នែក ហើយច្រានចោលមួយផ្នែក)។

ហើយ ខ្លឹមសារនៃករណីយកិច្ចធ្វើបដិទានស្ថានភាពដើមដែលដើមចោទមានចំពោះចុងចម្លើយ គឺជាការសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក និង ការប្រាក់ ៥% ក្នុងមួយឆ្នាំនៃប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច (កថាខណ្ឌទី ៣ មាត្រា ៥១១នៃក្រមរដ្ឋប្បវេណី)។

[7] ដើម្បីអះអាងអំពីការតវ៉ាឲ្យអនុវត្តព្រមគ្នា ក៏ចាំបាច់ត្រូវអះអាងអំពីភាគីម្ខាងដែល " កំពុងទទួលតាវកាលិកនៃកិច្ចសន្យាមួយភាគ ឬ ទាំងអស់" ផងដែរ (កថាខណ្ឌទី ២ មាត្រា ៥១១ នៃក្រមរដ្ឋប្បវេណី)។ នៅក្នុងរឿងក្តីនេះ ចុងចម្លើយចាំបាច់ត្រូវអះអាងថា បានបង់ថ្លៃលក់ទិញមួយភាគឲ្យទៅដើមចោទផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ"។

[8] ការប្រើនូវការតវ៉ាឲ្យអនុវត្តព្រមគ្នា ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើឆន្ទៈរបស់ម្ចាស់សិទ្ធិដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា។ បើទោះបីជានៅពេលដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នាក៏ដោយ ហើយមិនបានអះអាងអំពីសិទ្ធិតវ៉ានោះ ហើយអនុវត្តកាតព្វកិច្ចរបស់ខ្លួនវិញ ក៏ពុំមានបញ្ហាណាមួយតាមផ្លូវច្បាប់ដែរ។ ដូច្នេះហើយ ក្នុងករណីដែលម្ចាស់សិទ្ធិប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ចាំបាច់ត្រូវអះអាងអំពីឆន្ទៈថានឹងប្រើសិទ្ធិនោះ។

ដូច្នេះហើយ បើទោះបីជា ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលធ្វើឡើងដោយដើមចោទ មានសុពលភាពក៏ដោយ ក៏ចុងចម្លើយបដិសេធអំពីការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី ៤" ដែរ រហូតទាល់តែដើមចោទសងប្រាក់ ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក ដោយភ្ជាប់ជាមួយនឹងការប្រាក់ ៥ ភាគរយក្នុងមួយឆ្នាំ ដែលគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច។

**ឃ. ភស្តុតាង**

១. រូបថត (សារនៅក្នុង Telegram ដែលត្រូវបានផ្ញើទៅមករវាងដើមចោទ និងចុងចម្លើយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨) **(ភស្តុតាង$Y_1$)**

២. កំណត់ត្រាដែលចុងចម្លើយបានសរសេរអំពីខ្លឹមសារដែលបាននិយាយគ្នាតាមទូរស័ព្ទជាមួយដើមចោទ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៨ **(ភស្តុតាង$Y_2$)**

៣. លិខិតទទួលប្រាក់ **(ភស្តុតាង$Y_3$)**

៤. ការសាកសួរសាមីចុងចម្លើយ

សូម **លោកចៅក្រម** សម្រេចតាមការស្នើសុំ ដោយក្តីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

B

<u>**ឯកសារភ្ជាប់**</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០២ ច្បាប់"

៣-ឯកសារចម្លងនៃឯកសារចម្លើយ "ចំនួន ០២ ច្បាប់"

| ឧបសម្ព័ន្ធទី ៥ | គំរូសាលក្រមការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិដោយផ្អែកលើការរំលាយកិច្ចសន្យា |
| --- | --- |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តរតនគិរី

**តុលាការរដ្ឋប្បវេណី**

សំណុំរឿងលេខ .......

ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩

សាលក្រមលេខ .........

ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៩

**សាលក្រម**[1]

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តរតនគិរី**[2]

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ

ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៩[3][4]

**ចៅក្រមជំនុំជម្រះ**

លោក J ជាចៅក្រមនៃសាលាដំបូងខេត្តរតនគិរី

**ក្រឡាបញ្ជី**

លោកស្រី C ជាក្រឡាបញ្ជីនៃសាលាខេត្តរតនគិរី

---

[1] ការសម្រេចសេចក្តី គឺចែកចេញជា សាលក្រម និង ដីកាសម្រេច (មាត្រា ១៧៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ដូច្នេះ មានភាពចាំបាច់នៅក្នុងការបញ្ជាក់ឲ្យបានច្បាស់លាស់ថា អំពីប្រភេទនៃការសម្រេចសេចក្តីដាក់នៅត្រង់ចំណុចចាប់ផ្តើម។ ដោយសារតែ សាលក្រម និង ដីកាសម្រេចមានភាពខុសគ្នាចំពោះវិធីក្នុងការធ្វើឧបាស្រ័យជាអាទិ៍ ។ ជាគោលការណ៍បណ្តឹងឧបាស្រ័យចំពោះសាលក្រម គឺ បណ្តឹងឧទ្ធរណ៍ ហើយ បណ្តឹងឧបាស្រ័យចំពោះដីកាសម្រេច គឺ បណ្តឹងជំទាស់ (កថាខណ្ឌទី ១ មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] សាលក្រមរដ្ឋប្បវេណីត្រូវតែសរសេរអំពីចំណុចដែលចែងនៅក្នុងមាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៨៩ កថាខណ្ឌទី ១ ចំណុច ខ ។ សាលក្រមនឹងត្រូវកំណត់ជាស្ថាពរនូវទំនាក់ទំនងសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តិនាពេលបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១៩៤ កថាខណ្ឌទី ២) ហេតុនេះ ចាំបាច់ត្រូវសរសេរឲ្យបានច្បាស់លាស់អំពី ពេលដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។ សាលក្រមគឺជាការសម្រេចសេចក្តីរបស់តុលាការដែលត្រូវបានធ្វើឡើងដោយកំណត់ជាមុននូវទំនាក់ទំនងអង្គហេតុគិតមកដល់ត្រឹមថ្ងៃបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់។

[4] ការប្រកាសសាលក្រមត្រូវធ្វើឡើងក្នុងអំឡុងពេល ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ (មាត្រា ១៨៧ នៃក្រមរដ្ឋប្បវេណី)។ ហើយការប្រកាសសាលក្រមចាំបាច់ត្រូវធ្វើឡើងដោយផ្អែកលើច្បាប់ដើមនៃមូលសាលក្រម (កថាខណ្ឌទី ១ មាត្រា ១៨៨ នៃក្រមរដ្ឋប្បវេណី) ដូច្នេះហើយ ចាំបាច់ត្រូវតែបញ្ចប់នូវការតាក់តែងច្បាប់ដើមនៃមូលសាលក្រមឲ្យបាន គិតត្រឹមពេលប្រកាសសាលក្រម។

**ដើមចោទ**

ឈ្មោះ ៖ X

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ ភូមិ...... ឃុំ.......ស្រុក......... ខេត្តរតនគិរី។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ P

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ .................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ...................................................

លេខទូរស័ព្ទ ៖ ....................................................

**ចុងចម្លើយ**

ឈ្មោះ ៖ Y

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់មនោរម្យ ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ**

លោក/លោកស្រី ៖ B

អាសយដ្ឋានការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ .................................

ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី ៖ ...................................................

លេខទូរស័ព្ទ ៖ ....................................................

## អង្គហេតុ និង ចំណុចវិវាទ

### ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

(១) បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ។

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ. ដំណើររឿងក្តី និង ចំណុចវិវាទ

### ខ.១. ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ចំពោះអចលនវត្ថុដែលបានកត់ត្រានៅក្នុងបញ្ជីឧបសម្ព័ន្ធ (តទៅហៅថា "ដីL" ) ដើមចោទបានទាមទារនូវការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដដែល ដោយផ្អែកលើការរំលាយកិច្ចសន្យាលក់ទិញចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ។

### ខ.២. អង្គហេតុដែលគ្មានវិវាទ[5]

**ខ.២.១.** នៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ដើមចោទបានទិញ "ដី L" ក្នុងតម្លៃ ១០០.០០០ (មួយសែន) ដុល្លារអាមេរិកពីចុងចម្លើយ (តទៅហៅថា "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" )។

**ខ.២.២.** ដើមចោទ និង ចុងចម្លើយបាន "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ជាលិខិតយថាភូត (លិខិតលក់ផ្តាច់)។[6]

**ខ.២.៣.** ចំពោះ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទ និង ចុងចម្លើយបានព្រមព្រៀងគ្នាដូចខាងក្រោមអំពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់៖

- **ក.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃថ្លៃលក់ នឹងបង់នៅពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។
- **ខ.** ចំពោះប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលខ្វះ នឹងត្រូវបង់នៅក្នុងអំឡុងពេល ១ខែ គិតចាប់ពីពេលដែលបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូល។

**ខ.២.៤.** ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ចុងចម្លើយបានបង់ប្រាក់[7]ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកនៃ "កិច្ចសន្យាលក់ទិញនៃ

---

[5] មាត្រា ១២៣ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំណុចនេះនឹងត្រូវសរសេរអំពីអង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការ និង អង្គហេតុដែលតុលាការយល់ឃើញថា អត្ថិភាពនៃអង្គហេតុនោះមានភាពជាក់ស្តែង។

[6] ក្រមរដ្ឋប្បវេណី មាត្រា ៣៣៦ កថាខណ្ឌទី ២។ អង្គហេតុដែលមានភាពចាំបាច់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់នូវ "កិច្ចសន្យានៃរឿងក្តីនេះ" ដែលបានបង្កើតឡើងដោយមានសុពលភាព។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[7] ចំណុចនេះគឺជាអង្គហេតុដែលមានភាពចាំបាច់ដើម្បីធ្វើជាមូលហេតុ អំពីការតវ៉ាឲ្យអនុវត្តព្រមគ្នាដែលចុងចម្លើយអះអាង។(ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

រឿងក្តីនេះឲ្យទៅដើមចោទ ហើយ ដើមចោទ និង ចុងចម្លើយបានដាក់ពាក្យសុំចុះបញ្ជីផ្ទេរកម្មសិទ្ធិទាំងមូលដោយផ្អែកលើ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។

**ខ.២.៥.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ បានកន្លងផុត។

**ខ.២.៦.** នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដើមចោទបានដាស់តឿនឲ្យចុងចម្លើយបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យបានក្នុងអំឡុងពេល ២ សប្តាហ៍ ហើយព្រមគ្នានោះ ក៏បានធ្វើការបង្ហាញឆន្ទៈ[8] អំពីការរំលាយ "កិច្ចសន្យានៃរឿងក្តីនេះ" នៅពេលដែលមិនមានការបង់ប្រាក់ថ្លៃលក់ទិញនៅក្នុងអំឡុងពេល ២សប្តាហ៍។

**ខ.២.៧.** ចុងចម្លើយមិនបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកឲ្យបានត្រឹមថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ទេ។[9]

**ខ.២.៨.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានផ្តល់នូវការប្រគល់ដី L ទៅឲ្យចុងចម្លើយ ដោយផ្អែកតាម "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ។[10]

**ខ.២.៩.** នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនៃរឿងក្តីនេះ នាថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៩ ចុងចម្លើយបានប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ក្នុងករណីដែលតុលាការវិនិច្ឆ័យថា "ការរំលាយកិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" មានសុពលភាព ចុងចម្លើយនឹងបដិសេធនូវការធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដី L" លុះត្រាតែបានទទួលនូវការសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំនៃប្រាក់នេះ គិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា

[8] ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាដោយដាក់ល័ក្ខខ័ណ្ឌបង្អង់ (កថាខណ្ឌទី៣ មាត្រា ៤០៩ និង កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណី) ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[9] ចំណុចនេះគឺជាអង្គហេតុដែលចាំបាច់ដើម្បីបង្ហាញថា លក្ខខណ្ឌបង្អង់ត្រូវបានបំពេញ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

[10] ចំណុចនេះគឺជាអង្គហេតុដែលចាំបាច់ដើម្បីធ្វើជាមូលហេតុអំពី "ការបំពានកិច្ចសន្យា" របស់ចុងចម្លើយ (មាត្រា ៤០៧ នៃក្រមរដ្ឋប្បវេណី)។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃពាក្យបណ្តឹង។)

ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងរួច ។ [11]

**ខ.៣. ចំណុចវិវាទ**

**នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ តើដើមចោទ និង ចុងចម្លើយបានធ្វើការព្រមព្រៀងអំពីការផ្លាស់ប្តូរកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះមកជាថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៩វិញដែរ ឬ ទេ? (តទៅ ការព្រមព្រៀងនេះ ហៅថា "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ")។**

**ខ.៤. ការអះអាងរបស់ភាគីចំពោះចំណុចវិវាទ**

ខ.៤.១. ការអះអាងរបស់ចុងចម្លើយ

នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានបង្កើត "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ជាមួយចុងចម្លើយ។

ពោល នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ នៅពេលដែលមានការទាក់ទងពីដើមចោទ អំពីការប្រគល់ "ដីL" ចុងម្លើយបានផ្ញើសារថា "សុំឲ្យរង់ចាំ ៣ខែតទៀត" ចំពោះការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះ។ ចំពោះសារនេះ ដើមចោទបានទូរស័ព្ទទៅចុងចម្លើយ ភ្លាមៗ ដោយបានបញ្ជាក់អំពីមូលហេតុនោះ ហើយបានឆ្លើយតបថា " ខ្ញុំយល់ហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើងវិញ" ។ តាមរយៈការឆ្លើយតបនេះ នាំឲ្យ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" បានបង្កើតឡើង។

ខ.៤.២. ការអះអាងរបស់ដើមចោទ

"ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ពុំបានបង្កើតឡើងទេ។

---

[11] ចំពោះការប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា ឬ យ៉ាងណានោះ គឺអាស្រ័យទៅលើឆន្ទៈរបស់ម្ចាស់សិទ្ធិដែលមានសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (មាត្រា ៥០៧ នៃក្រមរដ្ឋប្បវេណី) ។ (ការពន្យល់លម្អិត សូមយោងតាម Footnote នៃឯកសារចម្លើយ។)

ចុងចម្លើយបង្ហាញឆន្ទៈយ៉ាងច្បាស់អំពីការអនុវត្តសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នានៅក្នុងឯកសារចម្លើយចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៩ (ចំណុច "គ.២.២." នៃឯកសារចម្លើយ) ប៉ុន្តែការបង្ហាញឆន្ទៈរបស់ចុងចម្លើយនេះមានភាពច្បាស់លាស់ចំពោះតុលាការ គឺនៅពេលដែលខ្លឹមសារដែលបានសរសេរនៅក្នុងឯកសារចម្លើយនេះត្រូវបានអះអាងនៅក្នុងកាលវិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ដូច្នេះហើយ ចាំបាច់ត្រូវតែសរសេរអំពីពេលវេលាឲ្យច្បាស់លាស់ចំពោះតុលាការអំពី ការបង្ហាញឆន្ទៈរបស់ចុងចម្លើយក្នុងការប្រើសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (នៅក្នុងរឿងក្តីនេះ កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលត្រូវបានធ្វើឡើងនៅថ្ងៃទី ៥ ខែមេសា ឆ្នាំ ២០១៩) ។

ដើមចោទបានទូរស័ព្ទទៅចុងចម្លើយវិញភ្លាមៗ ក្រោយពីបានទទួលសារពីចុងចម្លើយថា "សូមឲ្យរង់ចាំ ៣ ខែតទៀត" ចំពោះការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះ ប៉ុន្តែ ការទូរស័ព្ទនោះ គឺគ្រាន់តែបញ្ជាក់ពីមូលហេតុដែលចុងចម្លើយមិនអាចបង់ប្រាក់ថ្លៃលក់ទិញឲ្យបានត្រឹមកាលបរិច្ឆេទតែប៉ុណ្ណោះ។ ដើមចោទមិនទាន់បានធ្វើស្ទីការទទួលសំណើពីចុងចម្លើយទេ។

## សំអាងហេតុ

## ក. ការវិនិច្ឆ័យចំពោះចំណុចវិវាទ

### ក.១. ការទទួលស្គាល់អង្គហេតុ

អង្គហេតុដែលគូភាគីគ្មានវិវាទ និង អង្គហេតុដែលត្រូវបានទទួលស្គាល់តាមរយៈភស្តុតាងដែលបានកត់ត្រានៅតាមចំណុចចុងក្រោយនីមួយៗ មានដូចខាងក្រោម៖

**ក.១.១.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដើមចោទបានជូនដំណឹងអំពីការបានប្រែក្លាយសភាព "ដី L" សម្រាប់ធ្វើការប្រគល់ និងដាស់តឿនអំពីការទទួលយកការប្រគល់នោះ ជាមួយគ្នានេះ ក៏បានផ្ញើសារបញ្ជាក់អំពីការបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទៅចុងចម្លើយ ។ **(ភស្តុតាង$X_4$ និង $Y_1$)**

**ក.១.២.** នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ចំពោះសារដែលបានសរសេរនៅក្នុងចំណុច "**ក.១.១.**" ខាងលើនេះ ចុងចម្លើយបានផ្ញើសារថា " សុំឲ្យរង់ចាំ ៣ ខែតទៀត" ទៅកាន់ដើមចោទ ។ **(គ្មានវិវាទ)**

**ក.១.៣.** ដើមចោទបានទូរស័ព្ទទៅចុងចម្លើយវិញភ្លាម នៅក្រោយពេលដែលទទួលបានសារដូចបានសរសេរនៅក្នុងចំណុច "**ក.១.២.**" ។ នៅក្នុងការសន្ទនាតាមទូរស័ព្ទនោះ ចុងចម្លើយបានពន្យល់ទៅដើមចោទថា ចុងចម្លើយត្រូវបានគេបោកយកប្រាក់ ហើយមិនអាចបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះឲ្យបានភ្លាមៗទេ ។ **(គ្មានវិវាទ)**

**ក.១.៤.** ក្រោយពីការទូរស័ព្ទនៅក្នុងចំណុចដែលសរសេរនៅ **"ក.១.៣."** រហូតដល់ថ្ងៃទី១១ ខែមករា ឆ្នាំ ២០១៩ ដែលដើមចោទធ្វើការបង្ហាញឆន្ទៈទៅចុងចម្លើយ ដូចនៅក្នុងចំណុចស្ដីពី "អង្គហេតុនិង ចំណុចវិវាទ" ដែលបានសរសេរខាងលើ ត្រង់ចំណុច **"ខ.២.៦."** ដើមចោទ និង ចុងចម្លើយពុំបានទាក់ទងគ្នាទេ ។ **(ភស្តុតាង $X_3$ ភស្តុតាង $X_4$ លទ្ធផលនៃការសាកសួរសាមីដើមចោទ និង ចុងចម្លើយនីមួយៗ ទំនាក់ទំនង និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់[12])**

## ក.២. សេចក្ដីសន្និដ្ឋានចំពោះចំណុចវិវាទ

ប្រសិនបើប្រៀបផ្ទឹមអង្គហេតុដែលបានទទួលស្គាល់នៅក្នុងចំណុច **"ក.១."** ខាងលើ និង "អង្គហេតុដែលគ្មានវិវាទ ចំណុច **ខ.២.**" នៃចំណុចស្ដីពី "អង្គហេតុ និង ចំណុចវិវាទ" ខាងលើ តុលាការទទួលស្គាល់ថា អង្គហេតុដែលដើមចោទបានទូរស័ព្ទទៅចុងចម្លើយ និង បានសន្ទនាគ្នាជាមួយចុងចម្លើយ នៅក្រោយពេលដែលបានទទួលសំណើពីចុងចម្លើយអំពី "ការព្រមព្រៀងផ្លាស់ប្តូរនៃរឿងក្ដីនេះ" ភ្លាមៗ។

ប៉ុន្តែ នៅក្នុងការសន្ទនាគ្នាខាងលើនេះ ពុំមានភស្តុតាងដែលជាក់លាក់គ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ដើមចោទបានធ្វើស្និការទៅចុងចម្លើយចំពោះសំណើអំពី "ការព្រមព្រៀងផ្លាស់ប្តូរនៃរឿងក្ដីនេះ" ទេ ។ ពោលគឺ ចុងចម្លើយអះអាងថា ដើមចោទបានឆ្លើយតបនៅក្នុងការសន្ទនាគ្នាខាងលើនេះថា " ខ្ញុំយល់ហើយ។ ឆ្នាំក្រោយនឹងមានភាពប្រសើរឡើង" ហើយបានថ្លែងការដូចគ្នាទៅបែបនេះដែរ[13] ប៉ុន្តែបើទោះបីជា ដើមចោទបាននិយាយបែបនោះក៏ដោយ ក៏ឃ្លាភ្ជាប់ដែលនៅខាងមុខការនិយាយបែបនោះ មិនមានភាពច្បាស់លាស់ឡើយ ក្រៅពីនេះទៀត ដោយសារ

---

[12] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ដោយគិតពិចារណាអំពី "ដំណើរការ និង ខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់" ផងដែរ មិនមែនពិចារណាតែទៅលើលទ្ធផលនៃការស្រាវជ្រាវភស្តុតាងនោះទេ។

[13] "ការអះអាង" និង "ការថ្លែងការ" ផ្អែកតាមន័យច្បាប់ គឺមានភាពខុសគ្នា។ "ការអះអាង" គឺជាពាក្យដែលត្រូវបានបញ្ញត្តនៅក្នុងមាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី រីឯ "ការថ្លែងការ" គឺជាលទ្ធផលនៃការសាកសួរសាមីភាគី ហើយគឺជាវិធីមួយនៃការបញ្ជាក់ ។ យ៉ាងណាមិញ នៅពេលដែលជាសាក្សី ហើយមិនមែនភាគី គេហៅថា "កស្សិណសាក្សី"។

ភាគីចាំបាច់ត្រូវ "អះអាង" អំពីអង្គហេតុណាមួយ ហើយ "បញ្ជាក់" អង្គហេតុនោះ។ ហេតុនេះហើយ នៅក្នុងរឿងក្ដីនេះ បានសរសេរថា ចុងចម្លើយបាន "អះអាង" ហើយ បាន "ថ្លែងការ" ដែលជាវិធីមួយនៃការបញ្ជាក់។

តែពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីទទួលស្គាល់ថា ការនិយាយរបស់ដើមចោទនេះ គឺជាស្ទីការចំពោះសំណើនៃ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" ឡើយ។

ហេតុនេះ ដោយសារតែ អង្គហេតុដែលលើកឡើងថាដើមចោទបានធ្វើស្ទីការ ចំពោះសំណើនៃ "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" មិនត្រូវបានទទួលស្គាល់ទេ ដូច្នេះ តុលាការមិនអាចទទួលស្គាល់ថា "ការព្រមព្រៀងអំពីការផ្លាស់ប្តូរនៃរឿងក្តីនេះ" បានបង្កើតឡើងទេ។

## ខ. ការវិនិច្ឆ័យចំពោះការទាមទារ

### ខ.១. ស្តីអំពី ការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដោយផ្អែកលើមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ (ការមិនបង់ថ្លៃលក់ទិញ)

ផ្អែកតាមការលើកឡើងខាងលើ ដោយសារតែតុលាការទទួលស្គាល់ថា ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ទិញឲ្យបានត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ដែលជាកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ទិញចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកដែលនៅខ្វះនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ទេ ហើយទោះបីជាដើមចោទបានដាស់តឿនឲ្យអនុវត្តកាតព្វកិច្ចនោះដោយបានកំណត់អំឡុងពេល ២ សប្តាហ៍គិតចាប់ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ ក៏ដោយ ក៏ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចដែរ ដូច្នេះ តុលាការទទួលស្គាល់ថា ចុងចម្លើយបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ (ចំណុច ក. កថាខណ្ឌទី ១ មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី)។

ហើយ នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៩ ដើមចោទបានបង្ហាញឆន្ទៈ ទៅចុងចម្លើយ ដោយបានដាក់លក្ខខណ្ឌបង្អង់ថា "បើមិនបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះឲ្យបានក្នុងអំឡុងពេល ២សប្តាហ៍" នឹងរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ហើយដោយសារតែ ចុងចម្លើយមិនបានបង់ប្រាក់ថ្លៃលក់ទិញដែលនៅខ្វះឲ្យបានត្រឹមថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ទេ ដូច្នេះហើយតុលាការទទួលស្គាល់ថា ការបង្ហាញឆន្ទៈអំពីការរំលាយកិច្ចសន្យាមានអានុភាព ( កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ មាត្រា ៤០៩ និង កថាខណ្ឌទី ៣ មាត្រា ៣២៥ )

ហេតុដូច្នេះហើយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ត្រូវបានរំលាយ។

### ខ.២. ស្តីអំពី ការតទ៉ាឲ្យអនុវត្តព្រមគ្នា

ផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ចុងចម្លើយមានករណីយកិច្ចធ្វើនីតិវិធីចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិលើ "ដីL" ឲ្យទៅដើមចោទ (កថាខណ្ឌទី ២ មាត្រា ៩១១ នៃក្រមរដ្ឋប្បវេណី)។

ប៉ុន្តែ ផ្អែកតាមការរំលាយ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដើមចោទក៏មានករណីយកិច្ចសងប្រាក់ចំនួន ៥០.០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិកជាថ្លៃលក់ទិញមួយភាគនៃ "កិច្ចសន្យាលក់ទិញនៃរឿងក្តីនេះ" ដែលបានទទួលរួចរាល់ និង ការប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំ នៃប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មាត្រា ៩១១ និង មាត្រា ៣១៨ នៃក្រមរដ្ឋប្បវេណី)។

ម្យ៉ាងវិញទៀត តុលាការទទួលស្គាល់ថា ចុងចម្លើយបានអនុវត្តសិទ្ធិតវ៉ាឲ្យអនុវត្តព្រមគ្នា (កថាខណ្ឌទី ២ មាត្រា ៩១១ នៃក្រមរដ្ឋប្បវេណី) នៅក្នុងនីតិវិធីនៃបណ្តឹងនេះ។

ហេតុនេះ ការទាមទាររបស់ដើមចោទទៅចុងចម្លើយ មានមូលហេតុដែលត្រូវកម្រិតឲ្យផ្តល់តាវកាលិកតប។

### គ. ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី

ដោយសារតែការទាមទារនូវតាវកាលិកធម្មតារបស់ដើមចោទមានមូលហេតុដែលត្រូវកម្រិតឲ្យផ្តល់តាវកាលិកតប ដូច្នេះ ដើមចោទក៏សក្តិសមចំពោះការទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីផងដែរ។ ហើយដើមចោទដាក់ពាក្យបណ្តឹងនៃរឿងក្តីនេះ ក៏ដោយសារតែចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច ប៉ុន្តែ ប្រសិនបើពិចារណាអំពីតាវកាលិកតបរបស់ដើមចោទវិញ គឺលើសពី ១ ភាគ ២ នៃចំនួនទឹកប្រាក់ថ្លៃលក់ទិញ ដូច្នេះ គប្បីឲ្យដើមចោទទទួលបន្ទុក ១ ភាគ ៣ ហើយចុងចម្លើយទទួលបន្ទុក ២ ភាគ ៣ ចំពោះភាគលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ។ (កថាខណ្ឌទី ១ នៃមាត្រា ៦៤ ក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. បង្គាប់ឲ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអចលនវត្ថុដែលបានកត់ត្រាក្នុងបញ្ជីឧបសម្ព័ន្ធឲ្យទៅដើមចោទ ជាថ្នូរនឹងការទទួលនូវការបង់ប្រាក់ពីដើមចោទចំនួន ៥០.០០០

(ប្រាំម៉ឺន) ដុល្លារអាមេរិក និង ប្រាក់ចំនួន ៥ % ក្នុង ១ឆ្នាំនៃទឹកប្រាក់នេះ ដោយគិតចាប់ពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៨ រហូតដល់ថ្ងៃសងរួច។

**២.** ច្រានចោលការទាមទារផ្សេងពីនោះរបស់ដើមចោទ។[14]

**៣.** ប្រាក់ប្រដាប់ក្តីចែកជា ៣ភាគ ដោយ ១ភាគ គឺជាបន្ទុករបស់ដើមចោទ ក្រៅពីនេះជាបន្ទុករបស់ចុងចម្លើយ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនការជាសាធារណៈ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៩ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃសុក្រ ទី១១ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ខេត្តរតនគិរី, ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០១៩

**ចៅក្រម**

[14] តុលាការមិនមែនទទួលស្គាល់នូវការទាមទារដែលដើមចោទបានទាមទារនូវការកាលិកធម្មតាទាំងបែបនោះតែម្តងទេ ដូច្នេះ ត្រូវតែបញ្ជាក់អំពីចំណុចការទទួលស្គាល់នោះឲ្យបានច្បាស់លាស់។ (ខ្លឹមសារលំអិត សូមយោងតាម Footnoteនៃឯកសារចម្លើយ)

**ឧបសម្ព័ន្ធ**

## បញ្ជី[15]

| | |
|---|---|
| "គោលបំណងនៃពាក្យសុំចុះបញ្ជី" | ការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ |
| "មូលហេតុនៃពាក្យសុំចុះបញ្ជី និង កាលបរិច្ឆេទ" | ការរំលាយកិច្ចសន្យាចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៩ |
| "បុគ្គលមានសិទ្ធិចុះបញ្ជី" | ដើមចោទ (X)<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ .......................................<br>ឈ្មោះរបស់ឪពុកម្ដាយ៖ ...................(ឪពុក)<br>.....................(ម្ដាយ) |
| "បុគ្គលមានកាតព្វកិច្ចចុះបញ្ជី" | ចុងចម្លើយ (Y)<br>ថ្ងៃខែឆ្នាំកំណើត ៖ ថ្ងៃ......ខែ..........ឆ្នាំ.........<br>ទីកន្លែងកំណើត ៖ .......................................<br>ឈ្មោះរបស់ឪពុកម្ដាយ៖ ...................(ឪពុក)<br>.....................(ម្ដាយ) |
| "អត្តសញ្ញាណនៃអចលនវត្ថុ" | ទីតាំងដី ៖ ផ្លូវលេខ....... ភូមិ....... ឃុំ........ ស្រុក ....... ខេត្ត រតនគិរី<br>លេខក្បាលដី ៖ ........ |

[15] នៅក្នុងសាលក្រម សាលដីកាដែលជំនួសឲ្យការបង្ហាញឆន្ទៈរបស់បុគ្គលមានកាតព្វកិច្ចចុះបញ្ជី ចាំបាច់ត្រូវតែមានការសរសេរទាំងអស់នូវចំណុចដែលចាំបាច់នៅពេលធ្វើពាក្យសុំចុះបញ្ជី (ឧទាហរណ៍ ៖ ចំពោះពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ គឺត្រូវសរសេរអំពីចំណុចដែលបានកំណត់នៅក្នុងប្រការ ២៦ និង ប្រការ ៣១ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី)។ ហើយត្រូវធ្វើការបញ្ជាក់ថា គ្មានភាពខ្វះចន្លោះឡើយ។

## ឧបសម្ព័ន្ធទី ៦

## គំរូលិខិតរំលឹកដាស់តឿន

 រៀបរៀងដោយ លោក ស៊ុនហៀង ម៉េងលើម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

### <u>លិខិតរំលឹកដាស់តឿន</u>

ខ្ញុំ............................ ជាប្រធានក្រុមហ៊ុន............................ មានទីតាំងអាគារលេខ:..........ផ្លូវលេខ:...........សង្កាត់......................ខណ្ឌ......................រាជធានីភ្នំពេញ ។ លេខទូរស័ព្ទ......................

**<u>គោរពជូន</u>**

**លោក** .................... **និងភរិយា** .........................

*<u>មេត្តាជ្រាប</u> ។*

**<u>កម្មវត្ថុ</u>**: សុំរំលឹកអំពីការបង់ការប្រាក់ ។

**<u>យោង</u>**: - កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី...... ខែ......... ឆ្នាំ............ ។

- កិច្ចសន្យាបង្កើតសិទ្ធិលើការបញ្ចាំ ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ។
- លិខិតប្រគល់-ទទួលប្រាក់ ចុះថ្ងៃទី......... ខែ......... ឆ្នាំ............ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនលោក .............. និងភរិយា .............. ជ្រាបថា: កាលពីថ្ងៃទី...... ខែ...... ឆ្នាំ......... **លោក និងភរិយា**បានចុះកិច្ចសន្យាខ្ចីបរិភោគ ជាមួយនឹងខ្ញុំនូវចំនួនទឹកប្រាក់សរុប.................USD(...........**ដុល្លារអាមេរិក**) ដោយសន្យាបង់ការប្រាក់ក្នុង១(មួយ)ខែ............USD(.................**ដុល្លារអាមេរិក**) អោយបានទៀងទាត់ជូនខ្ញុំ គឺនៅចន្លោះថ្ងៃទី០១ ដល់ថ្ងៃទី០៣នៃខែនីមួយៗ ។ នៅថ្ងៃទី...... ខែ... ឆ្នាំ២០១៦ **លោក និងភរិយា**បានបំពេញកាតព្វកិច្ចតាមការកំណត់នៅក្នុងកិច្ចសន្យា ប៉ុន្តែខែបន្តបន្ទាប់រហូតមកដល់ថ្ងៃទី......ខែ......... ឆ្នាំ២០១៦នេះ **លោក និងភរិយា**មិនទាន់បានបំពេញកាតព្វកិច្ចដូចមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគនូវឡើយទេ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក និងភរិយា មេត្តាជ្រាបជាពត៌មាន និងមកទូទាត់ប្រាក់តាមកាតព្វកិច្ចដូចមានចែងនៅក្នុងកិច្ចសន្យាតាមការកំណត់ នៅក្រុមហ៊ុន...........ដែលមានអាស័យដ្ឋានអាគារលេខ:...... ផ្លូវ...... សង្កាត់.............. ខណ្ឌ........... រាជធានីភ្នំពេញ ក្នុងរយៈពេល........... ចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងនេះ ។

ខ្ញុំសង្ឃឹមថា ក្រោយពីបានទទួលនូវលិខិតនេះហើយ លោក និងភរិយា ពិតជាចូលរួមសហការបំពេញកាតព្វកិច្ចយ៉ាងល្អប្រសើរជាមួយយើងខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ......ខែ ...... ឆ្នាំ ២០១៦

**ហត្ថលេខា និងត្រា**

**ឧបសម្ព័ន្ធទី ៧**

**គំរូលិខិតសងប្រាក់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតសងប្រាក់

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ............................អាយុ..........ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ.................... ចុះថ្ងៃទី.........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

**បានសងប្រាក់ចំនួន**.......................ដុល្លារ (....................................................) នៅថ្ងៃទី............ ខែ............ឆ្នាំ............. ។

ទៅឱ្យឈ្មោះ...............................អាយុ............ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ....................... ចុះថ្ងៃទី..........ខែ..........ឆ្នាំ.......... មានទីលំនៅផ្ទះលេខ............ផ្លូវលេខ........... ក្រុមទី............ភូមិ.................. ឃុំ/សង្កាត់.....................ស្រុក/ខណ្ឌ.....................ខេត្ត/ក្រុង...................... ។

សងប្រាក់គ្រប់ចំនួន ហើយសូមបញ្ចប់នូវកិច្ចសន្យាទិញ-លក់ដីនិងផ្ទះ ចុះថ្ងៃទី.........ខែ..........ឆ្នាំ............ ចាប់ពីពេលនេះតទៅ។

**ធ្វើនៅ...............ថ្ងៃទី.........ខែ...........ឆ្នាំ២០.......**

| **ស្នាមមេដៃស្ដាំសងប្រាក់** | **សាក្សីអ្នកសងប្រាក់** | **សាក្សីអ្នកទទួលប្រាក់** | **ស្នាមមេដៃស្ដាំអ្នកទទួលប្រាក់** |
| --- | --- | --- | --- |
| ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... | ឈ្មោះ........................... |

ឧបសម្ព័ន្ធទី ៨ | គំរូលិខិតប្រគល់ ឬទទួលប្រាក់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់/ ទទួលប្រាក់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ................................... ភេទ........... ថ្ងៃខែឆ្នាំកំណើត................................ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ............ក្រុមទី..........ភូមិ................ឃុំ/សង្កាត់.................................ស្រុក/ខណ្ឌ................ ខេត្ត/រាជធានី.................កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ៖ ..........................លេខទូរស័ព្ទ: ................................................ ពិតជាបាន៖ **ប្រគល់** ប្រាក់ចំនួន................................ អក្សរ ................................................ **នៅ**ឲ្យឈ្មោះ ................................................. ភេទ........... ថ្ងៃខែឆ្នាំកំណើត.................................... អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ................ក្រុមទី...................... ភូមិ ..................................ឃុំ/សង្កាត់......................................ស្រុក/ខ័ណ្ឌ................................ខេត្ត/ក្រុង ................................................កាន់អត្តសញ្ញាណប័ណ្ណខ្មែរលេខ៖ ..................................លេខទូរស័ព្ទ: ................................................... ពិតប្រាកកដមែននៅថ្ងៃទី............ខែ...........ឆ្នាំ................ដែលជាប្រាក់ ........................................................................................................................................................................................................................................ ។

**ស្នាមមេដៃស្តាំអ្នកប្រគល់** | **សាក្សីដឹងឮ** | **ស្នាមមេដៃអ្នកទទួល**

........................................ ..................... ....................... ........................................

| ឧបសម្ព័ន្ធទី ៩ | លិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យា |
|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតជូនដំណឹងស្តីពីការរំលាយកិច្ចសន្យាលក់-ទិញដី

លោក [redacted] កើតឆ្នាំ១៩៤៧ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: [redacted] ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ១០ ផ្លូវបេតុង ភូមិពោធិ៍រលំ សង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាអ្នកលក់ដី និងជា **ភាគី "ក"**។

**សូមជម្រាបមក**

លោក [redacted] កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: [redacted] ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៥ និងលោក [redacted] កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ: [redacted] ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៥ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្ទះលេខ ៥៩ ភូមិទួលពង្រ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ជាអ្នកទិញដី និងជា **ភាគី "ខ"** ។

**កម្មវត្ថុ៖** ជូនដំណឹងស្តីពីការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០ ,កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០,កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដោយមូលហេតុ **ភាគី "ខ"** បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

**យោង៖**
- កិច្ចសន្យាទិញ-លក់អចលនវត្ថុ(ដី) ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០។
- កិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក [redacted] និងលោក [redacted] ជ្រាបថា៖ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ខ្ញុំ ហើយនិងលោក បានព្រមព្រៀងគ្នាជាលើកចុងក្រោយនៅចំពោះមុខមេធាវីទាំងសងខាង ដោយកំណត់យកថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ ជាលើកចុងក្រោយនៃការប្រគល់-ទទួលប្រាក់ដំណាក់កាលទី៤ ដែលមានទឹកប្រាក់ចំនួន ១៥០.០០០ (ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក។ ប៉ុន្តែរហូតមកដល់ពេលនេះ នៅតែពុំឃើញលោកមកអនុវត្តកាតព្វកិច្ចបង់ប្រាក់មកឱ្យខ្ញុំឡើយ យោងតាមកិច្ចសន្យាទិញ-លក់ដីខាងលើ ត្រង់ប្រការ៥ ចំណុច៥.១ ចំណុច៥.៣ និងយោងតាមកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ត្រង់ចំណុចទី៣ គឺលោកបាន**បំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ** និងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្ញុំយ៉ាងខ្លាំងទៀតផង។ ហេតុដូច្នេះខ្ញុំសម្រេចចិត្តបង្ហាញឆន្ទៈរំលាយកិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០, កិច្ចសន្យា ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងកិច្ចសន្យាបន្ថែម ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលធ្វើឡើងរវាងលោក និងខ្ញុំ ចាប់ពីពេលនេះតទៅ។ ចំណែកប្រាក់ដែលលោកបានទូទាត់ឱ្យខ្ញុំទាំងអស់កន្លងមក ត្រូវក្លាយជាកម្មសិទ្ធិរបស់ខ្ញុំ ដោយលោកគ្មានសិទ្ធិទាមទារមកវិញឡើយ ហើយខ្ញុំនឹងធ្វើការចូលគ្រប់គ្រង ចាត់ចែងអចលនវត្ថុខាងលើជាម្ចាស់កម្មសិទ្ធិវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកជា**ភាគី "ខ"** ជ្រាបជាព័ត៌មាន។

សូមលោកជា **ភាគី "ខ"** ទទួលនូវការរាប់អានអំពីខ្ញុំ។

ថ្ងៃ[illegible]ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០
ស្នាមមេដៃស្តាំ

[redacted]

បានឃើញ
ថ្ងៃ[illegible]ខែមិគសិរ ឆ្នាំជូត ទោស័ក ពស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០
ហត្ថលេខា និងត្រា

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

[redacted]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

<u>លិខិតជូនដំណឹង</u>

ខ្ញុំបាទឈ្មោះ [redacted] ភេទប្រុស ឆ្នាំកំណើត ១៩៧១ ជនជាតិខ្មែរ ដែលមានអាសយដ្ឋាន នៅផ្ទះលេខ ១៨១ ផ្លូវលេខ ២BT ក្រុម ទី ១២ ភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

<u>ជម្រាបមក</u>

លោកស្រី [redacted]

<u>កម្មវត្ថុ:</u> ស្តីអំពីការរំលាយកិច្ចសន្យាចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

<u>យោង:</u> -កិច្ចសន្យា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤។

-ដីកាបញ្ជាឱ្យចូលខ្លួន[redacted]ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោកស្រី ជ្រាបថាផ្អែកតាមកិច្ចសន្យា ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ និងលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ខ្ញុំបាទអស់ការទុកចិត្ត និងប្រគល់សិទ្ធិទៀតហើយ ដោយហេតុថា ចាប់តាំងពីខ្ញុំប្រគល់សិទ្ធិ និងចុះកិច្ចសន្យាមក មានរយៈពេល ៥ឆ្នាំ មកហើយតែគ្មានលទ្ធផលការងារ ហើយថែមទាំងលួចផ្ទើឯកសារដីរបស់ខ្ញុំទៀតផង លើសពីនេះ លោកស្រី មានជាប់ពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀត ជាក់ស្តែងដូចមានក្នុងដីកាបញ្ជាឱ្យចូលខ្លួន[redacted] ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ទៀតផង។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកស្រី មេត្តាជ្រាបតាមការជូនដំណឹងនេះតទៅ និងប្រគល់ឯកសារច្បាប់ដើមដូចជាឯកសារ ដី ផ្ទះ សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងឯកសារផ្សេងទៀត ។

ថ្ងៃចន្ទ ២កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ត្រូវនឹងថ្ងៃទី២២ខែមិថុនា ឆ្នាំ ២០២០

ស្នាមេដៃសាមី

មេធាវី

AVOCAT

ATTORNEY AT LAW

KINGDOM OF CAMBODIA

[redacted]

[redacted]

ឧបសម្ព័ន្ធទី ១០

# លិខិតប្រកាសរំលាយកិច្ចសន្យា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លិខិតប្រកាសរំលាយកិច្ចសន្យា

យោង : - ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ [redacted] ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨

- កិច្ចសន្យាលក់-ទិញដី ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ ។

នាងខ្ញុំ [redacted] អាយុ ៥២ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី ១៤-០២-២០០៨ ចេញដោយសាលារាជធានីភ្នំពេញ ទីលំនៅផ្ទះលេខ ៨៥អឺ០ ផ្លូវ ២៤០ សង្កាត់អូឡាំពិក ខណ្ឌចំការមន រាជធានីភ្នំពេញ ជាអ្នកទិញដីទំហំ ៣០.៦១២ម² ទីតាំងស្ថិតនៅភូមិបាលិលេយ្យ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ [redacted] ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ម្ចាស់កម្មសិទ្ធិឈ្មោះ [redacted] និងប្រពន្ធ [redacted] ។

ដោយគ្មានលទ្ធភាពចូវទាត់ប្រាក់ឲ្យអ្នកលក់ដីតទៅទៀត នាងខ្ញុំ [redacted] ជាអ្នកទិញដី សូមប្រកាសដូចខាងក្រោម :

១- ស្ម័គ្រចិត្តរំលាយកិច្ចសន្យាទិញ-លក់ដី ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១០ តទៅ ។

២- អនុញ្ញាតឲ្យឈ្មោះ [redacted] និងប្រពន្ធ [redacted] មានសិទ្ធិចាត់ចែងលើអចលនវត្ថុ ដូចមានក្នុងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ [redacted] ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨ ដោយគ្មានសញ្ញាអ្វីឡើយ ។

ដើម្បីជាសក្ខីភាព នាងខ្ញុំ សូមផ្តិតមេដៃនៅចំពោះមុខចៅសង្កាត់អូឡាំពិក ដើម្បីទុកជាចំណាំតាមផ្លូវច្បាប់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ៩ ឆ្នាំ ២០១៤

ស្នាមមេដៃស្តាំ

[redacted]

លេខ....២៤១/១៤.....

បានឃើញ និងបញ្ជាក់ថា : ឈ្មោះ [redacted]

ពិតជាបានផ្តិតមេដៃ នៅចំពោះមុខយើងខ្ញុំប្រាកដមែន។

អូឡាំពិក ថ្ងៃទី ១៥ ខែ ៩ ឆ្នាំ ២០១៤

ចៅសង្កាត់

[redacted]

**ឧបសម្ព័ន្ធទី ១១**

**សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ៨៧៧ “ង១” ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩**

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**តុលាការរដ្ឋប្បវេណី**
សំណុំរឿងរដ្ឋប្បវេណីលេខ ៧៤៥
ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨
សាលក្រមលេខ **៨៧៧ “ង១”**
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩

**សាលក្រម**
**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់នៅ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៨

**ចៅក្រមជំនុំជម្រះ**

លោក **ហាន សុខេមរិន** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **ឯក ពុធស្រីរ័ត្ន** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទ៖**

ឈ្មោះ **ជ** ភេទប្រុស អាយុ ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ

។ អាសយដ្ឋាន រាជធានី ភ្នំពេញ ។

**ចុងចម្លើយ៖**

ឈ្មោះ **ច១** ភេទស្រី អាយុ៤៣ឆ្នាំ និងកូន ឈ្មោះ **ច២** ភេទប្រុស អាយុ ២៦ឆ្នាំ មានអាសយដ្ឋាន
រាជធានីភ្នំពេញ ។

**អង្គហេតុ និង ចំណុចវិវាទ**

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

១-រំលាយកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។

២-ឲ្យចុងចម្លើយសងប្រាក់ដើមជំពាក់សរុបចំនួន $២១.៧៩១,៦៣ (ម្ភៃមួយពាន់ប្រាំពីររយកៅសិបមួយដុល្លារនិងហុកសិបបីសេន) និងសងនូវអត្រាការប្រាក់ ១,៨% ក្នុងមួយខែ លើប្រាក់ដើមចំនួន $៧,៥០០(ប្រាំពីរពាន់ប្រាំរយ) ដុល្លារ ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសងនូវអត្រាការប្រាក់ ១,៤% ក្នុងមួយខែ លើប្រាក់ដើមចំនួន $១៤.២៩១,៦៣ (ដប់បួនពាន់ពីររយកៅសិបមួយដុល្លារ និងហុកសិបបីសេន) ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣-បង់ប្រាក់ពិន័យស្មើនឹងចំនួនពីរ(២)ដងនៃការប្រាក់ជំពាក់។

៤-សងនូវប្រាក់ជម្ងឺចិត្តនៃការខាតបង់ពេលវេលា ចំនួន ៦.០០០.០០០រៀល (ប្រាំមួយលានរៀលគត់)។

៥-សុំប្រកាសឲ្យសាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នបាន លើចំណុចទី២ ខាងលើ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ.ដំណើររឿងក្តី និង ចំណុចវិវាទ**

**ខ.១ ការសង្ខេបអំពីរឿងក្តី**

កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ ច១ និងកូនប្រុសឈ្មោះ ច២ បានមកទំនាក់ទំនងសុំខ្ចីចងការប្រាក់បន្ថែមពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាខាខណ្ឌសែនសុខ ខ្ចីប្រាក់ចំនួន $១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដើម្បីពង្រីកមុខរបរហើយសហចុងចម្លើយបានសងអស់នៅសល់ប្រាក់ដើមចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក។ លុះដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ សហចុងចម្លើយបានមកខ្ចីប្រាក់បន្ថែមទៀត ចំនួន ១៧.៥០០ (មួយម៉ឺនប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក សហចុងចម្លើយបានបង់ប្រាក់ដើម និងការប្រាក់រយៈពេល ១១ខែ តែនៅកំឡុងខែកុម្ភៈ ឆ្នាំ២០១៨ សហចុងចម្លើយមកបង់ប្រាក់ចំនួន ៤៥០ (បួនរយហាសិប) ដុល្លារអាមេរិក បន្ទាប់មកសហចុងចម្លើយខកខានមកបង់ប្រាក់ដើម និងការប្រាក់មកឱ្យខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ដើមចោទរហូតដល់សព្វថ្ងៃនេះ។ សរុបមកសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ២១.៧៩១,៦៣ (ពីរម៉ឺនមួយពាន់ប្រាំពីររយកៅសិបមួយ និងហុកសិបបីសេន) ដុល្លារអាមេរិក ដោយការខកខានមិនបានសងបំណុលរបស់សហចុងចម្លើយ តាមកាលកំណត់ក្នុងតារាងកាលវិភាគសងប្រាក់នៃកិច្ចសន្យា។

**ខ.២ អង្គហេតុដែលគ្មានវិវាទ**

គ្មាន

**ខ.៣ អង្គហេតុដែលជាចំណុចវិវាទ**

១-រំលាយកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។

២-ឱ្យចុងចម្លើយសងប្រាក់ដើមជំពាក់សរុបចំនួន $២១.៧៩១,៦៣ (ម្ភៃមួយពាន់ប្រាំពីររយកៅសិបមួយដុល្លារនិងហុកសិបបីសេន) និងសងនូវអត្រាការប្រាក់ ១,៨% ក្នុងមួយខែ លើប្រាក់ដើមចំនួន $៧,៥០០(ប្រាំពីរពាន់ប្រាំរយ) ដុល្លារ ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសងនូវអត្រាការប្រាក់ ១,៤% ក្នុងមួយខែ លើប្រាក់ដើមចំនួន $១៤.២៩១,៦៣ (ដប់បួនពាន់ពីររយកៅសិបមួយដុល្លារ និងហុកសិបបីសេន) ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

៣-បង់ប្រាក់ពិន័យស្មើនឹងចំនួនពីរ(២)ដងនៃការប្រាក់ជំពាក់។

៤-សងនូវប្រាក់ជម្ងឺចិត្តនៃការខាតបង់ពេលវេលា ចំនួន ៦.០០០.០០០រៀល (ប្រាំមួយលានរៀលគត់)។

៥-សុំប្រកាសឱ្យសាលក្រមនេះមានអានុភាពអនុវត្តបណ្តោះអាសន្នបាន លើចំណុចទី២ ខាងលើ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

**ខ.៤ ការអះអាងរបស់គាគីស្តីពីចំណុចវិវាទ**

**-ការអះអាងរបស់ដើមចោទ**

ខ្ញុំនៅតែសុំរក្សាសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០១៨ ដដែល ពុំមានអ្វីបន្ថែមទៀតទេ ។ កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ ឈ្មោះ ច១ និងកូនប្រុសឈ្មោះ ច២ បានមកទំនាក់ទំនងសុំខ្ចីចងការប្រាក់បន្ថែមពី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាខាខណ្ឌសែនសុខ ខ្ចីប្រាក់ចំនួន $១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដើម្បីពង្រីកមុខរបរហើយសហចុងចម្លើយបានសងអស់នៅសល់ប្រាក់ដើមចំនួន ៧.៥០០ (ប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ។ លុះដល់ថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ សហចុងចម្លើយ

បានមកខ្ចីប្រាក់បន្ថែមទៀត ចំនួន ១៧.៥០០ (មួយម៉ឺនប្រាំពីរពាន់ប្រាំរយ) ដុល្លារអាមេរិក សហចុងចម្លើយបានបង់ប្រាក់ដើម និងការប្រាក់ រយៈពេល ១១ខែ តែនៅកំឡុងខែកុម្ភៈ ឆ្នាំ២០១៨ សហចុងចម្លើយមកបង់ប្រាក់ចំនួន ៤៥០ (បួនរយហាសិប) ដុល្លារអាមេរិក បន្ទាប់មកសហចុងចម្លើយខកខានមកបង់ប្រាក់ដើម និងការប្រាក់មកឱ្យខាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ខ្ញុំរហូតដល់សព្វថ្ងៃនេះ។ សរុបមកសហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ២១.៧៩១,៦៣ (ពីរម៉ឺនមួយពាន់ប្រាំពីររយកៅសិបមួយ និងហុកសិបបីសេន) ដុល្លារអាមេរិក ដោយការខកខានមិនបានសងបំណុលរបស់សហចុងចម្លើយ តាមកាលកំណត់ក្នុងតារាងកាលវិភាគសងប្រាក់នៃកិច្ចសន្យា គឺបានបំពានកាតព្វកិច្ចក្នុងកិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ត្រង់ប្រការ៥ នៃកិច្ចសន្យាចងការប្រាក់នេះ។ ដោយសហចុងចម្លើយមិនបានបំពេញកាតព្វក្នុងកិច្ចសន្យាធ្វើឱ្យខាតប្រយោជន៍យ៉ាងធ្ងន់ធ្ងរទាំងពេលវេលា និងប្រាក់កាក់របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សាខាខណ្ឌសែនសុខ ដូច្នេះខ្ញុំស្នើសុំដល់តុលាការសម្រេចការទាមទាររបស់ខ្ញុំបាទផង ។ ខ្ញុំសុំសំណូមពរឱ្យតុលាការសម្រេច តាមពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ ។

**-ការអះអាងរបស់ចុងចម្លើយ** ៖ ក្រឡាបញ្ជីបានបញ្ជូនដីកាកោះទៅឱ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ៤៣ឆ្នាំ និងកូនឈ្មោះ ច២ ភេទប្រុស អាយុ ២៦ឆ្នាំ ត្រឹមត្រូវ ប៉ុន្តែតាំងពីដំណាក់កាលនៃនីតិវិធីសម្រាប់ការទាញហេតុផល និងរហូតដល់ដំណាក់កាលទាញហេតុដោយផ្ទាល់មាត់ សហចុងចម្លើយ អវត្តមានដោយគ្មានមូលហេតុ។

**ខ.៥.ចំណុចគ្មានវិវាទ** ៖

គ្មាន។

**ខ.៦.ចំណុចវិវាទ** ៖

ការទាមទាររបស់ដើមចោទ

**សំអាងហេតុ**

ក.ក្រឡាបញ្ជីបានបញ្ជូនដីកាកោះទៅឱ្យចុងចម្លើយឈ្មោះ ច១ ភេទស្រី អាយុ ៤៣ឆ្នាំ និងកូនឈ្មោះ ច២ ភេទប្រុស អាយុ ២៦ឆ្នាំ ដើម្បីចូលរួមក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តាមនីតិវិធីច្បាប់រួចរាល់ហើយ ប៉ុន្តែចុងចម្លើយមិនបានចូលបង្ហាញខ្លួនទៅតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដូច្នេះតុលាការចាត់ទុក ថាចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដោយគប្បីតុលាការចេញសាលក្រមកំបាំងមុខចុងចម្លើយ តាមបញ្ញត្តិមាត្រា២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ខ.ស្តីពីចំណុចវិវាទទី១**

ផ្អែកតាមភស្តុតាងដែលភ្ជាប់ជាមួយពាក្យបណ្តឹង តុលាការទទួលស្គាល់ថា ដើមចោទ និងចុងចម្លើយ ពិតជាបានបង្កើតកិច្ចសន្យាខ្ចីចងការប្រាក់ជាមួយគ្នាប្រាកដមែន តាមរយៈកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និង កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ហើយចុងចម្លើយអាក់ខានមិនបានអនុវត្តកាតព្វកិច្ចសងរបស់ខ្លួនតាមតារាងកាលវិភាគសងប្រាក់ដែលបានបង្ហាញក្នុងភស្តុតាងកាលវិភាគសងប្រាក់ឥណទាន ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ និង ចុះថ្ងៃ១៧ ខែមករា ឆ្នាំ២០១៧ ការទាមទារអោយតុលាការរំលាយកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ អាចឱ្យតុលាការពិចារណា និងសម្រេចតាមបាន ស្របតាមការព្រមព្រៀងរបស់ភាគីតាមប្រការ៥ នៃកិច្ចសន្យាខ្ចីចងការប្រាក់ និងតាមមាត្រា៤០៧,៤០៨ នៃក្រមរដ្ឋប្បវេណី។

ហេតុនេះ តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ-។

**ខ. ស្តីពីចំណុចទិទានទី២**

ដើមចោទបានអះអាងអំពីអង្គហេតុថា សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចំនួន ២១.៧៩១,៦៣ (ពីរម៉ឺនមួយពាន់ប្រាំពីររយកៅសិបមួយ និងហុកសិបបីសេន) ដុល្លារអាមេរិក ដោយការខកខានមិនបានសងបំណុលរបស់សហចុងចម្លើយ តាមកាលកំណត់ក្នុងតារាកាលវិភាគសងប្រាក់នៃកិច្ចសន្យា គឺបានបំពានកាតព្វកិច្ចក្នុងកិច្ចសន្យាចងការប្រាក់ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧ ត្រង់ប្រការ៥ នៃកិច្ចសន្យាចងការប្រាក់នេះដោយទារទារឱ្យសងនូវអត្រាការប្រាក់ ១,៨% ក្នុងមួយខែ លើប្រាក់ដើមចំនួន $៧,៥០០(ប្រាំពីរពាន់ប្រាំរយ) ដុល្លារ ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន និងសងនូវអត្រាការប្រាក់ ១,៤% ក្នុងមួយខែ លើប្រាក់ដើមចំនួន $១៤.២៩១,៦៣ (ដប់បួនពាន់ពីររយកៅសិបមួយដុល្លារ និងហុកសិបបីសេន) ដោយគិតចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។ តាមមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាក់ស្តែង តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើមូលដ្ឋានភស្តុតាង និង អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការតែប៉ុណ្ណោះ។

ហេតុនេះ តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ ត្រង់ចំណុចការប្រាក់ ។ ប៉ុន្តែផ្អែកតាមមាត្រា ៥៨៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីដែលមានខ្លឹមសារថា នៅពេលគូភាគីកំណត់នូវអត្រាការប្រាក់លើសពីអត្រាការប្រាក់ដែលត្រូវបានកម្រិត នោះអត្រាការប្រាក់ដែលលើសក្នុងកិច្ចសន្យា នឹងត្រូវមោឃៈភាព ។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចបន្ថយកម្រិតនៃអត្រាការប្រាក់ មកត្រឹមអត្រាការប្រាក់ដែលត្រូវបានកម្រិត ត្រឹម ១៨% ក្នុងមួយឆ្នាំ ដើម្បីឱ្យស្របតាមប្រការ១ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ទាក់ទងនឹងអត្រាការប្រាក់ដែលត្រូវបានកម្រិតឆ្នាំ២០១១ និងអត្រា១៧ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

**គ. ស្តីពីចំណុចទិទានទី៣**

ដើមចោទទាមទារឱ្យចុងចម្លើយបង់ប្រាក់ពិន័យស្មើនឹងចំនួនពីរ(២)ដងនៃការប្រាក់ជំពាក់ ដោយដើមចោទអះអាងផ្អែកតាមកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។ តាមមាត្រា ១២៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាក់ស្តែង តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើមូលដ្ឋានភស្តុតាង និង អង្គហេតុដែលភាគីបានសារភាពនៅចំពោះមុខតុលាការតែប៉ុណ្ណោះ។

ហេតុនេះ តុលាការទទួលស្គាល់អំពីការទាមទាររបស់ដើមចោទ ត្រង់ចំណុចប្រាក់ពិន័យនេះ ដែលអាចត្រូវបានរាប់បញ្ចូលទៅក្នុងការប្រាក់យឺតយ៉ាវ ។ ប៉ុន្តែប្រាក់សំណងនៃការខូចខាតដោយសារការយឺតយ៉ាវនេះត្រូវបានកំណត់ត្រឹម២៧% ក្នុងមួយឆ្នាំ ដោយយោងតាមប្រការ២ នៃប្រកាសរបស់ក្រសួងយុត្តិធម៌ឆ្នាំ២០១១ ខាងលើដដែល។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចបន្ថយ។

**ឃ. ស្តីពីចំណុចទិទានទី៤**

ដើមចោទទាមទារសងនូវប្រាក់ជម្ងឺចិត្តនៃការខាតបង់ពេលវេលា ចំនួន ៦.០០០.០០០រៀល (ប្រាំមួយលានរៀលគត់)។តាមទាមទាររបស់ដើមចោទត្រង់ចំណុចនេះ ពុំមានហេតុផលត្រឹមត្រូវទេ ដោយហេតុថា គូភាគីបានកំណត់ជាមុននូវទំហំនៃការខូចខាត ឬប្រាក់ពិន័យ ដែលត្រូវបានរាប់បញ្ចូលទៅក្នុងការប្រាក់យឺតយ៉ាវនៅក្នុងកិច្ចសន្យារួចរាល់ហើយ។ ម្យ៉ាងទៀត បើបានកំណត់ទំហំនៃការខូចខាតជាមុននៅក្នុងកិច្ចសន្យារួចរាល់ហើយ ហើយទទួលស្គាល់នូវការទាមទារជម្ងឺចិត្តនៃការខាតបង់ពេលវេលានេះទៀត នោះនាំឱ្យការសងមានចំនួនពីរដង លើចំណុចតែមួយ។

ហេតុនេះតុលាការពិចារណា និងសម្រេចច្រានចោលការទាមទារចំណុចនេះ។

កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជា សាលក្រមគម្រូទេ

**ខ. ស្ដីពីការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន**

ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ (ការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ) ហើយតុលាការយល់ឃើញថា មានភាពចាំបាច់ ដូច្នេះ ប្រកាសថា ចំណុចទី២ នៃចំណុចខាងក្រោមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។

**គ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

នៅក្នុង "រឿងក្ដីស្ដីពីការទាមទារឱ្យសងប្រាក់កម្ចីនៃរឿងក្ដីនេះ" ចុងចម្លើយបានចាញ់ក្ដីទាំងស្រុង។

ហេតុនេះ ចំពោះប្រាក់ប្រដាប់ក្ដីគឺឱ្យចុងចម្លើយទទួលបន្ទុកទាំងស្រុង។

**សេចក្ដីសម្រេចបញ្ចប់**

**១.**រំលាយកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៦ និងកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៧។

**២.**បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ចំនួន $២១.៧៩១,៦៣ (ម្ភៃមួយពាន់ប្រាំពីររយកៅសិបមួយដុល្លារនិងហុកសិបបីសេន) ឱ្យទៅដើមចោទ។

**៣.**បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ក្នុងអត្រាចំនួន ១៨% ក្នុងមួយឆ្នាំ នៃប្រាក់ចំនួន $២១.៧៩១,៦៣ (ម្ភៃមួយពាន់ប្រាំពីររយកៅសិបមួយដុល្លារ និងហុកសិបបីសេន) ខាងលើ គិតចាប់ពីថ្ងៃខែចុងចម្លើយខកខានបង់ប្រាក់រហូតដល់ថ្ងៃសងចប់សព្វគ្រប់។

**៤.**បង្គាប់ឱ្យសហចុងចម្លើយ បង់ប្រាក់ពិន័យស្មើនឹងចំនួន ២៧% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃខកខានបង់ប្រាក់រហូតដល់ថ្ងៃសងចប់សព្វគ្រប់។

**៥.**ក្រៅពីចំណុចទី ២,៣ & ៤ ខាងលើនេះ ច្រានចោលការទាមទាររបស់ដើមចោទលើសពីនេះ។

**៦.**សាលក្រមនេះអាចអនុវត្តបណ្ដោះអាសន្នបាន ចំពោះចំណុចទី ២ តែប៉ុណ្ណោះ។

**៧.**ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលក្រមនេះបានត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩។

ក្នុងករណីដែលប្ដឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងនៅក្នុងរយៈពេល០១(មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រម**

**ហត្ថលេខា និងត្រា ហាន សុខេមរិន**

---

**បានឃើញ**

**ចៅក្រម**

ហាន_សុខេមរិន

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

ឯក_ពុធស្រីរ័ត្ន

**ឧបសម្ព័ន្ធទី ១២**

**សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ១០២៤ “ ក១” ចុះថ្ងៃទី២៦ខែសីហា ឆ្នាំ២០១៩**

*កំណត់សំគាល់ : សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ **១០២៤ “ក១”**

-ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

-សំណុំរឿងរដ្ឋប្បវេណីលេខ ១០៣៣

ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី**២៦** ខែសីហា ឆ្នាំ **២០១៩** វេលាម៉ោង០៩ និង ០០ នាទីព្រឹក នៅសាលសវនាការទី៥ លើសំណុំរឿងរដ្ឋប្បវេណីលេខ ១០៣៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក **ថាន់ ឡេង** ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

-កញ្ញា **ប្រច់ ពេជ្រមាលា** ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទ៖ឈ្មោះ **ធនាគារ** ជ អាសយដ្ឋានលេខ រាជធានីភ្នំពេញ តំណាងដោយលោក

តជ ។

-អ្នកតំណាងដោយអាណត្តិ “ដើមចោទ” ៖ លោកស្រីមេធាវី **ឡាំ សុគន្ធាវ៉ា** និងកញ្ញាមេធាវី **ហួត សុខកនិកា** អាសយដ្ឋានលេខ៣១៥ វិថីព្រះអង្គឌួង កែងនឹងមហាវិថីព្រះមុន្នីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងកញ្ញាមេធាវី **ហួត សុខកនិកា** អាសយដ្ឋានលេខ១៣៦ ផ្លូវលេខ៦ សង្កាត់ទួលសង្កែ ខណ្ឌឬស្សី រាជធានីភ្នំពេញ ។

-សហចុងចម្លើយឈ្មោះ ច១ ភេទប្រុស កើតឆ្នាំ១៩៦៧ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០២ និងឈ្មោះ ច២ ភេទស្រី កើតឆ្នាំ១៩៦៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៦ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ រាជធានីភ្នំពេញ។

និងឈ្មោះ ច៣ ភេទស្រី កើតឆ្នាំ១៩៨៨ កាន់អត្តសញ្ញណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១២ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ រាជធានីភ្នំពេញ ។

-អ្នកតំណាងដោយអាណត្តិ “ចុងចម្លើយ” ៖ គ្មាន ។

## I. អង្គហេតុ និងចំណុចវិវាទ

**១.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

**១.១.**រំលាយកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ។

**១.២.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់មកដើមចោទដែលមានប្រាក់ដើមចំនួន ១៩,៩៥២.៤៥ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក កៀសសែសិបប្រាំសេន)។

ក.ការប្រាក់គិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់មានការទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាការប្រាក់ ១.២០% (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៩៥២.៤៥ $ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លារអាមេរិក ក្បៀសសែសិបប្រាំសេន)។

ខ.ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រហូតដល់មានការទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ស្មើនឹង ២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាចងការប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។

**១.៣.**ថ្លៃសេវាកម្មច្បាប់ចំនួន ៥,០០០$ (ប្រាំពាន់ដុល្លារអាមេរិក)។

**១.៤.**ប្រាក់ប្រដាប់ក្ដី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ។

**១.៥.**សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបានត្រង់ចំណុច **១.២ (ក.ខ)** ខាងលើ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្ដី**

កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ ច១ ឈ្មោះ ច២ ឈ្មោះ ច៣ បានចុះកិច្ចសន្យាខ្ចីប្រាក់ពី **ធនាគារ** ជ ដែលមានទឹកសរុបចំនួន ២៥,០០០$ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) តាមអត្រាការប្រាក់ ១.២០% (មួយចុចម្ភៃភាគរយ) ក្នុងមួយខែ រយៈពេលខ្ចីប្រាក់ ៦០ ខែ (ដោយធ្វើការបង់ការប្រាក់ និងប្រាក់ដើម) គិតចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១។ របៀបសងប្រាក់ក្នុងកិច្ចសន្យាត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ដោយការសងប្រាក់ដើម ឬការប្រាក់មួយលើកៗ ត្រូវបង់ដោយផ្ទាល់ ឬកាត់យកជាស្វ័យប្រវត្តិពី គណនីរបស់សហចុងចម្លើយដូចដែលមានចែកក្នុងប្រការ១.២ ចំណុច៥ នៃកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។ ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន សហចុងចម្លើយមិនបានគោរពកាតព្វកិច្ចនៃការបង់ប្រាក់ប្រចាំខែតាមកិច្ចសន្យាឡើយ ដោយបានខកខានបង់ប្រាក់ដើម និងការប្រាក់ឱ្យធនាគារ និងហួសកាលកំណត់។

**៣.អង្គហេតុដែលអះអាងដោយដើមចោទ**

**ដើមចោទ ធនាគារ** ជ តំណាងដោយលោក តជ

មានលោកស្រី **ឡាំ** សុគន្ធាភ៌ ជាមេធាវីតំណាងដោយអាណត្តិ បានថ្លែងការណ៍នៅដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផលថា៖ ខ្លួននៅតែប្តឹងទាមទារ និងអះអាងដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨ ដដែល មិនមានការកែប្រែទេ និងសូមបញ្ជាក់ជូនលោកចៅក្រមថា៖ ចំណុចដែលកូនក្ដីខ្លួនទាមទារពីសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ ឈ្មោះ ច៣ នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ បានចុះកិច្ចសន្យាខ្ចីប្រាក់ពីកូនក្ដីខ្លួន **ធនាគារ** ជ ចំនួន ២៥,០០០$ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) រយៈពេល៦០ខែ (គិតចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១) ដោយព្រមព្រៀងគិត អត្រាការប្រាក់ចំនួន ១.២០% (មួយចុចម្ភៃភាគរយ) ក្នុងមួយខែលើប្រាក់ដើម។

-របៀបសងប្រាក់បានអនុវត្តតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារដោយសងទាំងប្រាក់ដើម និងការប្រាក់គិតពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១ ដូចមានចែងក្នុងកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ត្រង់ប្រការ ១.២ ចំណុច៥។

-ការអនុវត្តកាតព្វកិច្ចរបស់ខ្លួនសហចុងចម្លើយមិនបានបំពេញ និងគោរពកាតព្វកិច្ចក្នុងការបង់ប្រាក់ប្រចាំខែតាមការកំណត់ក្នុងតារាងកាលវិភាគសងប្រាក់ក្នុងកិច្ចសន្យាឡើយ។

-ប្រាក់ដើមដែលសហចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ មិនបានបង់មានចំនួន ១៩,៩៥២.៤៥ $ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក ក្បៀសសែសិបប្រាំសេន)។

-ដោយខកខានបង់ប្រាក់ដើម និងការប្រាក់ជូនធនាគារចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧។

-ការប្រាក់ពិន័យចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។

ដោយពិនិត្យឃើញថាកូនក្តីខ្លួន និងត្រូវបាត់បង់ផលប្រយោជន៍ ឬជួបបញ្ហាធ្ងន់ធ្ងរទៅថ្ងៃមុខ ទើបកូនក្តីខ្លួនប្តឹងសុំ៖

**១.**រំលាយកិច្ចសន្យាខ្ចីប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ។

**២.**បង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសងប្រាក់មកដើមចោទដែលមានប្រាក់ដើមចំនួន ១៩,៩៥២.៤៥ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក ក្បៀសសែសិបប្រាំសេន)។

ក.ការប្រាក់គិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់មានការទូទាត់ចប់សព្វគ្រប់ ក្នុងអត្រាការប្រាក់ ១.២០% (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៩៥២.៤៥ $ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក ក្បៀសសែសិបប្រាំសេន)។

ខ.ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ រហូតដល់មានការទូទាត់ចប់សព្វគ្រប់ក្នុងអត្រាការប្រាក់ស្មើនឹង ២(ពីរ)ដង នៃអត្រាការប្រាក់ដែលមានចែងក្នុងកិច្ចសន្យាចងការប្រាក់លេខ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦។

**៣.**ថ្លៃសេវាកម្មច្បាប់ចំនួន ៥,០០០$ (ប្រាំពាន់ដុល្លារអាមេរិក)។

**៤.**ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ។

**៥.**សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុច ១.២ (ក.ខ) ខាងលើ។

សហចុងម្លើយកម្ចីប្រាក់នៅសាខា ដាក់ប្លង់ដីទទ់ ដោយមានភ្ជាប់ក្នុងពាក្យបណ្តឹង។

**៤.អង្គហេតុដែលអះអាងដោយចុងចម្លើយ**

ចុងចម្លើយឈ្មោះ ច២ បានថ្លែងការណ៍នៅដំណាក់កាលត្រៀមសម្រាប់ការទាញហេតុផលថា៖ ឈ្មោះ ច១ ជាប្តីរបស់ខ្លួន។ ខ្លួនបានខ្ចីលុយពីធនាគារដើម្បីបង្កើតមុខរបរចិញ្ចឹមជ្រូក តែត្រូវខ្សោយធន ហើយក្រោយមកបានខ្ចីបន្ថែមបីធនាគារ ដើម្បីរត់ការក្បួយទៅក្រៅប្រទេស ហើយម្តាយឈឺ ក៏អាក់ខានបង់លុយ សងទៅធនាគាររហូតមក ខាងធនាគារបានចុះទៅទារបំណុល ក៏បានឃើញស្ថានភាពលំបាកក្នុងគ្រួសារខ្លួនផងដែរ។

នៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ប្តីឈ្មោះ ច១ និងខ្លួនឈ្មោះ ច២ និងឈ្មោះ ច៣ បានចុះកិច្ចសន្យាខ្ចីប្រាក់ពីធនាគារ ដ ចំនួន ២៥,០០០$ (ម្ភៃប្រាំពាន់ដុល្លាអាមេរិក) រយៈពេល ៦០ ខែ (គិតចាប់ពីថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៦ ដល់ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២១) ដោយព្រមព្រៀងគិតអត្រាការប្រាក់ចំនួន ១.២០% (មួយចុចម្ភៃភាគរយ) ក្នុងមួយខែលើប្រាក់ដើម។ ប្រាក់ដើមចំនួន ១៩,៩៥២.៤៥$ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក និងសែសិបប្រាំសេន) ខ្លួនទទួលស្គាល់ និងបានដាក់ប្លង់ទន់នៅធនាគារ តែដីនេះត្រូវលក់

ឲ្យគេហើយ។ សព្វថ្ងៃខ្លួនជួលផ្ទះគេនៅ។ ចំពោះការប្រាក់ខ្លួនទទួលស្គាល់ តែប្រាក់ពិន័យខ្លួនមិនទទួលស្គាល់ទេ។ ខ្លួនសុំសងប្រាក់ជូនធនាគារតាមលទ្ធភាព។

**៥.ចំណុចគ្មានវិវាទ**

-ចុងចម្លើយទទួលស្គាល់ប្រាក់ដើមចំនួន ១៩,៩៥២.៤៥$ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក និងសែសិបប្រាំសេន) ។

-ចុងចម្លើយទទួលស្គាល់ការប្រាក់ លើអត្រាការប្រាក់ ១.២០% (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៩៥២.៤៥ $(ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក ក្បៀសសែសិបប្រាំសេន) ។

**៦.ចំណុចវិវាទ**

-ចុងចម្លើយបដិសេធចោលប្រាក់ពិន័យ ស្មើនឹង ២(ពីរ)ដង នៃអត្រាការប្រាក់។

-ដើមចោទទាមទារថ្លៃសេវាកម្មច្បាប់ចំនួន ៥,០០០$ (ប្រាំពាន់ដុល្លារអាមេរិក)។

-ដើមចោទទាមទារប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ។

-ដើមចោទទាមទារសាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានត្រង់ចំណុច ១.២ (ក.ខ) ខាងលើ។

## II.ការពិនិត្យភស្តុតាង

**១. ភស្តុតាងជាឯកសារដែលភាគីដើមចោទដាក់ជូនតុលាការ**

១.១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ រវាង ធនាគារ ជ និង ឈ្មោះ ច១ ឈ្មោះ ច២ ឈ្មោះ ច៣ ។

១.២.កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ រវាង ធនាគារ ជ និង ឈ្មោះ ច១ ឈ្មោះ ច២ ។

១.៣.តារាងរំលស់ប្រាក់ដើម និងការប្រាក់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ របស់ធនាគារ ជ និងឯកសារស្តីអំពីតារាងបង់ប្រាក់មួយចំនួនទៀត។

**២. ភស្តុតាងជាឯកសារដែលភាគីចុងចម្លើយដាក់ជូនតុលាការ**

- គ្មាន ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

១.តាមកិច្ចកិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៤ និងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ រវាងដើមចោទ **ធនាគារ** ជ តំណាងដោយលោក តជ និង ចុងចម្លើយឈ្មោះ ច១ ឈ្មោះ ច២ និងឈ្មោះ ច៣ ពិតជាបានព្រមព្រៀងចុះកិច្ចសន្យាខ្ចីបរិភោគ មានប្រាក់ដើមចំនួន $២៥,០០០ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) និងព្រមព្រៀងបញ្ចាំអចលនវត្ថុ ដីចំនួន០២កន្លែង ដើម្បីធានាកាតព្វកិច្ចដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១០ និងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៤ ស្ថិតនៅភូមិ

ខេត្តកំពង់ស្ពឺ ជាមួយគ្នាពិតប្រាកដមែន។

២.សហចុងចម្លើយបានទទួលស្គាល់ប្រាក់ដើមដែលនៅសល់ចំនួន ១៩,៩៥២.៤៥$ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក និងសែសិបប្រាំសេន) និងការប្រាក់លើអត្រា ១.២០% (មួយក្បៀសម្ភៃភាគរយ) ក្នុងមួយខែ លើប្រាក់ដើមចំនួន ១៩,៩៥២.៤៥ $(ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លាអាមេរិក ក្បៀសសែសិបប្រាំសេន) ។

៣.ដើមចោទឈ្មោះ **ធនាគារ** ជ តំណាងដោយលោក តជ បានប្តឹងទាមទារប្រាក់ពិន័យស្មើនឹងពីរដងនៃអត្រាការប្រាក់ ឃើញថាការទាមទារនេះ មិនត្រឹមត្រូវតាមច្បាប់ឡើយ។ ទោះបីជាសហដើមចោទបានព្រមព្រៀងជាមួយចុងចម្លើយតាំងពីពេលចុះកិច្ចសន្យាក៏ដោយ។ ដោយហេតុថាចុងចម្លើយមិនមែនជាគ្រឹះស្ថានធនាគារ ឬគ្រឹះស្ថានហិរញ្ញវត្ថុ ដែលគ្រប់គ្រងដោយច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឡើយ។ ដូចនេះការកំណត់ប្រាក់ពិន័យត្រូវស្ថិតនៅក្រោម ក្រមរដ្ឋប្បវេណី និងប្រកាសលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ។

៤.ដើមចោទទាមទារថ្លៃសេវាកម្មច្បាប់ចំនួន ៥,០០០$ (ប្រាំពាន់ដុល្លារអាមេរិក) ពីសហចុងចម្លើយ គប្បីតុលាការពិនិត្យ និងសម្រេចតាមជាក់ស្តែង។

៥.ដើមចោទសុំឱ្យតុលាការប្រកាសអនុវត្តជាបណ្តោះអាសន្នសាលក្រមត្រង់ប្រាក់ដើម, ការប្រាក់ និងប្រាក់ពិន័យ ឃើញថាមានលក្ខណៈត្រឹមត្រូវត្រង់ចំណុចប្រាក់ដើម គប្បីតុលាការសម្រេចតាមការស្នើសុំ តាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឯចំណុចទាមទារផ្សេងក្រៅពីនេះ គប្បីតុលាការច្រានចោលការស្នើសុំនេះ។

៦.ប្រាក់ប្រដាប់ក្តីគប្បីជាបន្ទុករបស់សហចុងចម្លើយ។

## សេចក្តីសម្រេចបញ្ចប់

**១. ទទួលស្គាល់ការទាមទាររបស់ដើមចោទ ធនាគារ** ជ តំណាងដោយលោក តជ ដែលមានលោកស្រី **ឡាំ សុគន្ធាវ៉ា** និងកញ្ញាមេធាវី **ហួត សុខកនិកា** ជាមេធាវីតំណាងដោយអាណត្តិដូចខាងក្រោម៖

**១.១ បង្គាប់ឱ្យ**សហចុងចម្លើយឈ្មោះ ច១ , ឈ្មោះ ច២ និងឈ្មោះ ច៣ សងប្រាក់ទៅដើមចោទ **ធនាគារ** ជ តំណាងដោយលោក តជ ដែលមានលោកស្រី **ឡាំ សុគន្ធាវ៉ា** និងកញ្ញាមេធាវី **ហួត សុខកនិកា** ជាមេធាវីតំណាងដោយអាណត្តិដូចខាងក្រោម៖

១.១.១ ប្រាក់ដើមចំនួន ១៩,៩៥២.៤៥$ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លារអាមេរិក ក្បៀសសែសិបប្រាំសេន) ។

១.១.២ ការប្រាក់១.២០%/១ខែ (មួយក្បៀសម្ភៃភាគរយក្នុងមួយខែ) លើប្រាក់ដើមចំនួន ១៩,៩៥២.៤៥$ (ដប់ប្រាំបួនពាន់ប្រាំបួនរយហាសិបពីរដុល្លារអាមេរិក ក្បៀសសែសិបប្រាំសេន) គិតចាប់ពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧ រហូតដល់ពេលសងប្រាក់គ្រប់ចំនួន ។

១.១.៣ ការប្រាក់ពិន័យស្មើនឹងពីរដងនៃអត្រាការប្រាក់គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៧ រហូតដល់ពេលសងប្រាក់គ្រប់ចំនួន។

១.១.៤ សេវាកម្មផ្នែកច្បាប់ចំនួន ១០.០០០.០០០៛ (ដប់លានរៀល)។

ការទាមទារលើសពីនេះច្រានចោល។

**២**. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុច ១.១.១ នៃសេចក្តីសម្រេចបញ្ចប់នេះ។

៣.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនៅថ្ងៃទី**២៦** ខែសីហា **ឆ្នាំ២០១៩** ចំពោះមុខមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ កំបាំងមុខសហចុងចម្លើយ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ ៕

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា ថាន់ ឡេង

---

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ថ្ងៃចន្ទ ១១រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

ថាន់_ឡេង

**ក្រឡាបញ្ជី**

ស្រង់ ពេជ្រចាណា

ឧបសម្ព័ន្ធទី ១៣

**សាលក្រមសាលាដំបូងរាជធានីភ្នំពេញ, លេខ ១៣៨៣ "ញ" ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩**

*កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមរដ្ឋប្បវេណី**

លេខ ១៣៨៣ "ញ"

ថ្ងៃព្រហស្បត្តិ៍ ៤កើត ខែកត្តិក

ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណីលេខ ៥៧៥

ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ ២០១៩ នៅសាលសវនាកាទី៣ នៃសាលាដំបូងរាជធានីភ្នំពេញ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៥៧៥ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក **លី សុខលេខ** ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី **សាគល ករុណា** ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

-ដើមចោទឈ្មោះ ជ ភេទស្រី អាយុ ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរ មានទីលំនៅ ខេត្តព្រះសីហនុ ឪពុកឈ្មោះ ឪពុក ជ ម្តាយឈ្មោះ មាយ ជ នៅលីវ ។ (អវត្តមាន)

លោក **សុខ គ្រុយ** ជាមេធាវីតំណាងដោយអាណត្តិ (អវត្តមាន)

-ចុងចម្លើយឈ្មោះ ច ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ មានទីលំនៅ រាជធានីភ្នំពេញ ។ (អវត្តមាន)

លោក **អឿង រិទ្ធា** ជាមេធាវីតំណាងដោយអាណត្តិ (អវត្តមាន)

I.**អង្គហេតុ និងចំណុចវិវាទ**

**១-ខ្លឹមសារសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ៖**

**-ដើមចោទទាមទារឱ្យសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមសម្រេចដូចតទៅ ៖**

**ក**-ទាមទារប្រាក់ដើមចំនួន **១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក** ពីចុងចម្លើយឈ្មោះ ច ។

**ខ**-ទាមទារថ្លៃជំងឺចិត្ត ចំនួន ៨ ០០០ ០០០ (ប្រាំបី)លានរៀល ។

**គ**-ទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**២-ខ្លឹមសារសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ ៖**

**-ចុងចម្លើយទាមទារឱ្យសាលាដំបូងរាជធានីភ្នំពេញចេញសាលក្រមសម្រេចដូចតទៅ ៖**

**ក**-ទាមទារសុំរំលាយកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៥ និងរំលាយកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ចោល ។

ខ-ទាមទារប្រាទនចោលការទាមទារប្រាក់ដើមចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក របស់ដើមចោទ ។

គ-ទាមទារប្រាលចោលការទាមទារថ្លៃជំងឺចិត្តចំនួន ៨ ០០០ ០០០ (ប្រាំបី)លានរៀល របស់ដើមចោទ ។

ឃ-ទាមទារឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**២-ការពន្យល់ត្រួសៗអំពីរឿងក្តី**

ចុងចម្លើយឈ្មោះ ច បានខ្ចីប្រាក់ពីដើមចោទឈ្មោះ ជ ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ ដោយដើមចោទ និងចុងចម្លើយ បានព្រមព្រៀងគ្នាមិនគិតការប្រាក់ទេ ដោយបានសន្យាសងប្រាក់ទាំងអស់ឱ្យដើមចោទវិញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ប៉ុន្តែនៅពេលដល់កំណត់នៃការសងប្រាក់ ចុងចម្លើយពុំបានសងប្រាក់ឱ្យមកដើមចោទវិញ រហូតមកដល់ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ចុងចម្លើយបានមកសម្របសម្រួលជាមួយនឹងដើមចោទ សុំសងប្រាក់មកដើមចោទ ដោយបង់រំលោះក្នុងមួយខែ ចំនួន ២០០ (ពីររយ)ដុល្លារអាមេរិក ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ តទៅ ប៉ុន្តែមកដល់ពេលបច្ចុប្បន្នចុងចម្លើយ នៅតែពុំបានសងប្រាក់ឱ្យដើមចោទដដែល ។

**៣-អង្គហេតុដែលអះអាងដោយដើមចោទ ៖**

-ដើមចោទឈ្មោះ ជ ដោយមានលោក **សុខ គ្រុយ** ជាមេធាវីតំណាងដោយអាណត្តិ បានអះអាងថា ៖ ខ្លួនសុំរក្សាតាមខ្លឹមសារនៃពាក្យបណ្តឹង ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៣ របស់កូនក្តីខ្លួនដដែល ដោយទាមទារឱ្យចុងចម្លើយឈ្មោះ ច សងប្រាក់ដែលបានខ្ចីពីកូនក្តីខ្លួន ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក តាមកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ ដោយដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា មិនរយកការប្រាក់លើប្រាក់កម្ចីខាងលើនេះទេ ដោយនៅក្នុងកិច្ចសន្យា គឺបញ្ជាក់ថា ចុងចម្លើយត្រូវសងប្រាក់ទាំងអស់មកឱ្យខ្លួនវិញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ។ ចុងចម្លើយពិតជាបានទទួលប្រាក់ពីកូនក្តីខ្លួនពិតប្រាកដមែន នៅចំពោះមុខសាក្សីឈ្មោះ ស ជ ។ ក្រោយមកចុងចម្លើយបានមកសុំសងប្រាក់រំលោះមកឱ្យកូនក្តីខ្លួន តាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ដោយសន្យាបង់រំលោះ ២០០(ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ តទៅ ប៉ុន្តែចាប់តាំងពីបានធ្វើកិច្ចសន្យាសងប្រាក់ខាងលើរួចមក ចុងចម្លើយពុំទាន់បានសងប្រាក់រំលោះមកឱ្យកូនក្តីខ្លួនម្តងណាឡើយ ។

ខ្លួនសំណូមពរសុំទាមទារប្រាក់ដើមពីចុងចម្លើយឈ្មោះ ច ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក ,ទាមទារជំងឺចិត្តចំនួន ៨ ០០០ ០០០ (ប្រាំបី)លានរៀល ,និងទាមទារឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

**៤-អង្គហេតុដែលអះអាងដោយសហចុងចម្លើយ ៖**

ចុងចម្លើយឈ្មោះ ច ដោយមានលោក **អៀង វិទ្ធា** ជាមេធាវីតំណាងដោយអាណត្តិ បានអះអាងថា ៖ ខ្លួនសុំឱ្យតុលាការប្រាទនចោលការទាមទារទាំងអស់របស់ដើមចោទ និងទាមទារសុំឱ្យ

តុលាការរំលាយកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ និងទាមទារសុំរំលាយកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ចោល ដោយមូលហេតុថា កូនក្តីខ្លួនពុំបានទទួលបានប្រាក់កម្ចីខាងលើ ពីដើមចោទនោះទេ ដោយគ្រាន់តែបានធ្វើកិច្ចសន្យាខ្ចីលុយតែប៉ុណ្ណោះ ។

**៥-ចំណុចវិវាទ ៖**

តើកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ មានសុពលភាពត្រឹមត្រូវ តាមផ្លូវច្បាប់ដែរឬទេ ?

តើនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ មានការប្រគល់ទទួលប្រាក់ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក រវាងដើមចោទ និងចុងចម្លើយដែរឬទេ ?

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ ៖**

-កិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ ។

-កិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ។

## សំអាងហេតុ

ផ្អែកតាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាង តុលាការយល់ឃើញថា ៖

-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលបានប្តឹងទាមទារប្រាក់ពីចុងចម្លើយឈ្មោះ ច ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក ដោយផ្អែកកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ និងតាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ដោយបានកំណត់ថា មិនគិតអត្រាការប្រាក់ និងបានកំណត់ថា ចុងចម្លើយត្រូវសងប្រាក់ឱ្យដើមចោទវិញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ប៉ុន្តែនៅពេលដល់កំណត់សងចុងចម្លើយ ពុំបានសងប្រាក់មកដើមចោទនោះទេ ក្រោយមកបានមកសុំសងប្រាក់មកឱ្យដើមចោទ ដោយសុំសងរំលោះចំនួន ២០០(ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ តាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ដោយចាប់គិតពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ ប៉ុន្តែចាប់តាំងពីធ្វើកិច្ចសន្យាសងប្រាក់ខាងលើរួចមក ចុងចម្លើយពុំដែលបានសងប្រាក់រំលោះ តាមការសន្យាខាងលើមកឱ្យដើមចោទនោះទេ ។

-តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ ដែលទទួលស្គាល់ថាបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ និងកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ដោយចាប់គិតពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ សុំសងរំលោះចំនួន ២០០ (ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ ជាមួយនឹងដើមចោទពិតប្រាកដមែន ប៉ុន្តែចុងចម្លើយអះអាងថា ពុំបានទទួលប្រាក់ចំនួន ១០ ០០០(មួយម៉ឺន)ដុល្លារអាមេរិក ពីដើមចោទនោះទេ ដោយគ្រាន់តែបានធ្វើកិច្ចសន្យាខ្ចីប្រាក់តែប៉ុណ្ណោះ ។

-យោងតាមការសេចក្តីថ្លែងការណ៍ខាងលើ និងផ្អែកតាមកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ រវាងដើមចោទ និងចុងចម្លើយ ដែលបានព្រមព្រៀងគ្នាឱ្យប្រាក់ចំនួន ១០ ០០០(មួយម៉ឺន) មិនគិតអត្រាការប្រាក់ និងបានកំណត់ថា ចុងចម្លើយត្រូវសងប្រាក់ឱ្យដើមចោទវិញ នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១២ ប៉ុន្តែនៅពេលដល់កំណត់សងចុងចម្លើយ ពុំបានសងប្រាក់មកដើមចោទនោះទេ ក្រោយមកបានមកសុំសងប្រាក់មកឱ្យដើមចោទ ដោយសុំសងរំលោះចំនួន ២០០(ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ តាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ដោយចាប់គិតពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ ប៉ុន្តែចាប់តាំងពីធ្វើកិច្ចសន្យាសងប្រាក់ខាងលើរួចមក ចុងចម្លើយពុំដែលបានសងប្រាក់រំលោះ តាមការសន្យាខាងលើមកឱ្យដើមចោទនោះទេ ប៉ុន្តែចុងចម្លើយបានបដិសេធពុំបានទទួលប្រាក់ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក ដោយគ្រាន់តែបានធ្វើកិច្ចសន្យាខ្ចីលុយតែប៉ុណ្ណោះ ទោះបីជាចុងចម្លើយបដិសេធថា ពុំបានទទួលប្រាក់កម្ចីខាងលើ គឺពុំមានមូលដ្ឋាន គប្បីតុលាការក្នុងការលើកយកមកពិចារណាបានឡើយ ដោយមូលហេតុថា ចុងចម្លើយពុំមានសាក្សី ឬភស្តុតាងបញ្ជាក់ថា ពុំបានទទួលប្រាក់ពីដើមចោទនោះទេ ប៉ុន្តែបើផ្អែកតាមកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ បង្ហាញឱ្យឃើញថា ចុងចម្លើយទទួលស្គាល់ថាបានខ្ចីប្រាក់ និងបានទទួលប្រាក់ពីដើមចោទ ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក ដោយសុំសងរំលោះទៅដើមចោទវិញ ក្នុងមួយខែចំនួន ២០០ (ពីររយ)ដុល្លារអាមេរិក ក្នុងមួយខែ គិតចាប់ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៣ បញ្ជាក់បានថា ដើមចោទ និងចុងចម្លើយបានបង្កើតនូវកិច្ចសន្យាព្រមព្រៀងខ្ចីប្រាក់ចំនួន ១០ ០០០ (មួយម៉ឺន)ដុល្លារអាមេរិក ហើយដើមចោទក៏បានប្រគល់ប្រាក់ឱ្យទៅចុងចម្លើយរួចហើយ ដល់ការកំណត់នោះទេ ជាមានការដាស់តឿនរបស់ដើមចោទ ក៏ចុងចម្លើយមិនគោរពនូវកាតព្វកិច្ចនៃកិច្ចសន្យា ។

-ចុងចម្លើយបានទាមទារសុំរំលាយកិច្ចសន្យាខ្ចីលុយ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ និងសុំរំលាយកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ គឺពុំមានមូលហេតុនៃការរំលាយកិច្ចសន្យា តាមបញ្ញត្តិមាត្រា ៤០៧ និងមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការពុំលើកយកមកពិចារណា ។

-ដើមចោទបានប្តឹងទាមទារជំងឺចិត្តចំនួន ៨ ០០០ ០០០ (ប្រាំបី) លានរៀល ពីចុងចម្លើយ ផ្អែកតាមភស្តុតាងខាងលើ ឃើញថា ចុងចម្លើយក៏មានកំហុស ក្នុងការមិនបំពេញកាតព្វកិច្ចនៃកិច្ចសន្យារបស់ខ្លួន ហើយកំហុសនេះបានបង្កការខូចខាតដល់ភាគីដើមចោទ ឃើញថា ការទាមទារនេះមានមូលហេតុត្រឹមត្រូវ ហេតុនេះ គប្បីសម្រេចនូវការទាមទារ ចំណុចនេះទៅតាមព្យសនកម្មជាក់ស្តែង ។

-ដើមចោទបានទាមទារឱ្យចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី តាមកំណត់ហេតុខាងលើ ចុងចម្លើយមានកំហុស ហេតុនេះ គប្បីសម្រេចឱ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តីបាន (តាមមាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

## សេចក្តីសម្រេចបញ្ចប់

-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ច សងប្រាក់មកឱ្យដើមចោទឈ្មោះ ដ នូវ ៖

១-ប្រាក់ដើមចំនួន ១០ ០០០ **(មួយម៉ឺន)ដុល្លារអាមេរិក** ។

២-ឱ្យចុងចម្លើយសងជំងឺចិត្តចំនួន ៣ ០០០ ០០០ (បីលាន)រៀល ឱ្យទៅដើមចោទ (ការទាមទារលើសពីនេះ ត្រូវច្រានចោល) ។

៣-ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

៤-ច្រានចោលការទាមទារសុំរំលាយកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទីចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ និងសុំរំលាយកិច្ចសន្យាសងប្រាក់ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ របស់ចុងចម្លើយឈ្មោះ ច ។

សាលក្រមនេះបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៩ កំបាំងមុខដើមចោទ និងចុងចម្លើយ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៩ ។

ដើមចោទ និងចុងចម្លើយ មានសិទ្ធិប្តឹងទាស់ក្នុងរយៈពេល ២(ពីរ)សប្តាហ៍ និងប្តឹងឧទ្ធរណ៍ក្នុងរយៈពេល ០១(មួយ)ខែ គិតចាប់ពីថ្ងៃបានទទួលសាលក្រមនេះ ។

ចៅក្រម

**ហត្ថលេខា និងត្រា : លី សុខលេង**

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃច័ន្ទ ០៨កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

**លី សុខលេង**

**ក្រឡាបញ្ជី**

**សាគល ករុណា**